Inside front page

# កម្មវិធីសិក្សាអំពីសារសំខាន់នៃបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា (ICT) សម្រាប់ថ្នាក់ដឹកនាំ រដ្ឋាភិបាល

## (Academy of ICT Essentials for Government Leaders)

**ម៉ូឌុល ៣**

**កម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិក**

**Nag Yeon Lee**

**សៀវភៅម៉ូឌុលកម្មវិធីសិក្សាអំពីសារសំខាន់នៃបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា (ICT) សម្រាប់ថ្នាក់ដឹកនាំ រដ្ឋាភិបាល**

**ម៉ូឌុល 3 ៖ កម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិក**

រក្សាសិទ្ធិដោយ © UN-APCICT 2009

ISBN:

អត្ថបទបោះពុម្ពផ្សាយនេះ ត្រូវបានចេញផ្សាយក្រោមអាជ្ញាប័ណ្ណរក្សាកម្មសិទ្ធិបញ្ញាផ្នែកគំនិតច្នៃប្រឌិតលេខ ៣.០ (Creative Commons Attribution 3.0 License) ។ ដើម្បីមើលច្បាប់ចម្លងនៃអាជ្ញាប័ណ្ណនេះ សូមចូលទៅកាន់វ៉ែបសាយ http://creativecommons.org/licenses/by/3.0/ ។

ទស្សនៈ រូបភាព និងសេចក្តីប៉ាន់ស្មាននានាដែលបានរៀបរៀងនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ គឺជាទំនួលខុសត្រូវរបស់អ្នកនិពន្ធ និងមិនត្រូវបានចាត់ទុកថា ជាការឆ្លុះបញ្ចាំងអំពីទស្សនៈ ឬបង្ហាញអំពីការអនុម័តទទួលស្គាល់របស់អង្គការសហប្រជាជាតិឡើយ ។

នាមកត្តាដែលប្រើ និងការបង្ហាញឯកសារផ្សេងៗនៅក្នុងអត្ថបទបោះពុម្ពផ្សាយនេះ ក៏មិនមែនជា ការសម្តែងទស្សនៈណាមួយពីសំណាក់លេខាធិការដ្ឋានអង្គការសហប្រជាជាតិ អំពីស្ថានភាពស្រប ច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ ណាមួយ ឬអាជ្ញាធរនានារបស់ប្រទេស តំបន់ ឬដែនដីទាំងនេះ ឬអំពីការកំណត់ព្រំដែន ឬដែនកំណត់នៃប្រទេស តំបន់ ឬដែនដីទាំងនេះឡើយ ។

ការលើកឡើងអំពីឈ្មោះក្រុមហ៊ុន និងផលិតផលពាណិជ្ជកម្មផ្សេងៗ មិនមែនបង្កប់អត្ថន័យថាជាការអនុម័តទទួលស្គាល់របស់អង្គការសហប្រជាជាតិឡើយ ។

អាស័យដ្ឋានទំនាក់ទំនង ៖

មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា

សម្រាប់ការអភិវឌ្ឍតំបន់អាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ (UN-APCICT)

Bonbudong, 3rd Floor Songdo Techno Park
7-50 Songdo-dong, Yeonsu-gu, ទីក្រុង Incheon

សាធារណៈរដ្ឋកូរ៉េ

ទូរស័ព្ទលេខ ៖ +82 32 245 1700-02

ទូរសារលេខ ៖ +82 32 245 7712

អ៊ីមែល ៖ info@unapcict.org

http://www.unapcict.org

រចនា និងកាត់តរូបភាពដោយ ៖ ក្រុមហ៊ុនបោះពុម្ព Scandinavian Publishing Co., Ltd. និង studio triangle

បោះពុម្ពនៅ ៖ សាធារណរដ្ឋកូរ៉េ

## បុព្វកថា

សតវត្សទី ២១ គឺបានលេចចេញយ៉ាងច្បាស់តាមរយៈការរីកចម្រើននៃផ្នែកទំនាក់ទំនងគ្នាក្នុងចំណោមប្រជាជន នៅក្នុងសាកលលោកនេះ ជាពិភពលោកមួយដែល ឱកាសកំពុងបើកចំហរសំរាប់មនុស្ស រាប់លាននាក់ ធ្វើការទាក់ទងគ្នាតាមរយៈបច្ចេកវិទ្យាថ្មីជាច្រើន,ការរីកដុះដាលនៅការទទួលបានពត៌មាននិងចំណេះដឹងចាំបាច់ដទៃទៀតបានធ្វើឲ្យប្រសើរឡើងគួរឲ្យកត់សម្គាល់សំរាប់ជីវភាពរស់នៅរបស់ ប្រជាជន
និងជួយកាត់បន្ថយភាពក្រីក្រផងដែរ ។ ការរីកចម្រើននេះអាចសម្រេចទៅបាន លុះត្រាតែយើងទាំងអស់គ្នាចេះចែករំលែកតម្លៃ ការប្តេជ្ញាចិត្ត និង សាមគ្គីភាព ដើម្បីការអភិវឌ្ឍក្នុងគោលបំណងបម្រើផលប្រយោជន៍រួមសម្រាប់មនុស្ស គ្រប់ៗគ្នា ។

ថ្មីៗនេះតំបន់អាស៊ីនិងប៉ាស៊ីហ្វិច បានក្លាយជាតំបន់ដ៏វិសេសធំបំផុតមួយនៅពេលដែលតំបន់នេះបានប្រើប្រាស់នូវបច្ចេកវិទ្យា ព័ត៌មាននិង គមនាគមន៍ (ICTs) ។ យោងតាមសហភាព គមនាគមន៍អន្តរជាតិ តំបន់អាស៊ីនិងប៉ាស៊ីហ្វិច គឺមានផ្ទះ ដែលប្រើប្រាស់ទូរស័ព្ទលើតុច្រើនជាង ពីររយ កោដិ (២០០កោដិ) និង អ្នក ប្រើប្រាស់ទូរស័ព្ទដៃចំនួន ១.៤ រយកោដិ ។ បើគិតចំពោះតែប្រទេសចិននិងឥណ្ឌានោះ គឺស្មើនឹង១/៤ នៃចំនួនអ្នកប្រើប្រាស់ ទូរស័ព្ទនៅក្នុងពិភពលោក សម្រាប់ទិន្នន័យគិតត្រឹមឆ្នាំ ២០០៨។ តំបន់អាស៊ី–ប៉ាស៊ីហ្វិចផងដែរ គឺមានអត្រា៤០ភាគរយ នៃអ្នកប្រើប្រាស់ប្រព័ន្ធ អ៊ីនធឺណែត របស់ ពិភពលោក និងស្មើ៣៩ ភាគរយ នៃទីផ្សារអ្នកប្រើប្រាស់ រលកអាកាសផ្សព្វផ្សាយ (Broadband) ដ៏ធំបំផុត នៅក្នុង ពិភពលោក។

បើគិតអំពីប្រវត្តិនៃការរីកចម្រើនជឿនលឿនយ៉ាងរហ័សនៃបច្ចេកវិទ្យានេះ មានមតិភាគច្រើនបានចោទសួរថា តើការបែកចែករលកសញ្ញា(Digital) អាចនឹងត្រូវវិនាសបាត់បង់ឬទៅជាយ៉ាងណា នៅពេលខាងមុខ។ ជាអកុសល សំនួរនេះនៅមិនទាន់មានចម្លើយនៅឡើយ។សូម្បីតែរយៈពេល៥ឆ្នាំបន្ទាប់ពីជំនួបកំពូលពិភពលោកស្តីអំពីលើ វិស័យពត៍មានវិទ្យា-The World Summit on The Information Society(WSIS) ត្រូវបានធ្វើឡើងនៅក្នុង Geneva នៅក្នុងឆ្នាំ ២០០៣ និង ការរកឃើញ នៃបច្ចេកវិទ្យាដ៏ច្រើនសម្បើមព្រមទាំងការប្តេជ្ញាចិត្តនៃអ្នកបំពីការងារដ៏សំខាន់ៗក្នុងតំបន់ក៏ដោយ ក៏ដំណើរការ គមនាគម ជាមូលដ្ឋាន នៅតែបន្តគម្លាតនៅតែឆ្ងាយរវាងមនុស្សភាគច្រើន ជាពិសេ

សសំរាប់ជនក្រីក្រ ។

ជាង ២៥ ប្រទេសក្នុងតំបន់ ភាគច្រើនជាប្រទេសកំពុងអភិវឌ្ឍន៍នៃដែនកោះតូចៗ និង ប្រទេស កំពុងអភិវឌ្ឍន៍ដែលមិនមានព្រំដែនជាប់នឹងឆ្នេរសមុទ្រ មានចំនួនអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធើរណេត តិចជាង ១០ នាក់ក្នុងចំណោម១០០នាក់(១០%) ដែលចំនួន ១០%នេះ ជាអ្នករស់នៅក្នុងទីក្រុងធំៗ នៃប្រទេសទាំងនោះ ផ្ទុយទៅវិញប្រទេសជឿនលឿនដែលស្ថិតនៅក្នុងតំបន់នោះដែរ មានអត្រានៃ អ្នកប្រើប្រាស់ប្រព័ន្ធ អ៊ីនធើរណេត ៨០ នាក់ ក្នុងចំណោមមនុស្ស ១០០ នាក់(៨០%) ។ ការប្រើប្រាស់រលកនៃការផ្សាយ(Broadband)របស់ប្រទេសរីកចំរើន និង ប្រទេសកំពុងអភិវឌ្ឍន៍ គឺមានភាពខុសគ្នាយ៉ាងសម្បើម ។

ដើម្បី កាត់បន្ថយគម្លាតសមត្ថភាពយល់ដឹងលើផ្នែកបច្ចេកវិទ្យានៃ Ditigal និង ICT ក្នុងការអភិវឌ្ឍ សង្គម–សេដ្ឋកិច្ចវិទ្យានៅក្នុងតំបន់ អ្នកបង្កើតច្បាប់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នោះ បានបង្កើតនូវអទិភាព

ឲ្យបានច្រើន, អនុម័តនៅគោល នយោបាយមួយចំនួន រៀបចំយ៉ាងជាក់លាក់នូវ ច្បាប់ និង និយតកម្មគម្រោង ផ្តល់ប្រាក់មូលនិធិ និងជួយសម្រួលក្នុងភាពជាដៃគូផ្សេងៗជាច្រើនទៀត ដើម្បីជំរុញ វិស័យ ឧស្សាហកម្ម ICT ព្រមទាំងធ្វើការអភិវឌ្ឍនូវជំនាញ ICT ឲ្យដល់ប្រជាជនរបស់ពួកគេ ។

គម្រោងសកម្មភាពមួយ (The Plan of Action) នៃ WSIS បានថ្លែងថា “…មនុស្សម្នាក់ៗគួរតែទទួលបាន ឱកាសក្នុងការទទួលយកនៅជំនាញចាំបាច់ណាមួយ រួមទាំង ចំណេះដឹង ដើម្បីយល់ដឹង ដើម្បីចូលរួម និងដើម្បីទទួលបានប្រយោជន៍ពីសង្គមពត៌មានវិទ្យា រួមទាំង ចំណេះដឹង ផ្នែកសេដ្ឋកិច្ច។ នៅទីបញ្ចប់ គម្រោងសកម្មភាពនេះ បានអំពាវនាវឲ្យមានការសហការនៅក្នុងតំបន់និងពីអន្តរជាតិ សំរាប់វិស័យ នៃការកសាង សមត្ថភាព ដោយធ្វើការសង្កត់ធ្ងន់ ទៅលើ ការបង្កើតការប្រមូលផ្តុំយ៉ាងធំមួយសំរាប់អ្នកមាន វិជ្ជាជីវៈនិងជំនាញការ ខាង ICT អោយបានច្រើន ។

ជាការឆ្លើយតបនឹងការអំពាវនាវនេះ PCICT បានធ្វើការអភិវឌ្ឍ នូវ ICT ដ៏ធំទូលាយមួយនេះសំរាប់ ការអភិវឌ្ឍន៍នូវកម្មវិធីហ្វឹកហ្វឺនដែលមានឈ្មោះថា *កម្មវិធីសិក្សាជាន់ខ្ពស់នៃ អាយស៊ីធី ពិសេស សំរាប់ថ្នាក់ដឹកនាំក្នុងជួររដ្ឋាភិបាល* ដែលក្នុងពេលឥឡូវនេះ មានប្រាំបីវគ្គ ផ្សេងៗគ្នា ប៉ុន្តែវគ្គនីមួយៗមានទំនាក់ទំនងគ្នា ដោយមានគោលបំណងចែករំលែក ចំណេះដឹងរួមទាំងជំនាញពិសេស ដែលនឹងជួយអ្នកបង្កើតច្បាប់ ឲ្យចេះធ្វើផែនការនិងអនុវត្តដោយប្រើនូវចំណេះដឹង ដែលទទួលបានពី ICT ប្រកប ដោយប្រសិទ្ធិភាព ។

APCICT គឺជាវិទ្យាស្ថានមួយក្នុងចំណោមវិទ្យាស្ថាន ៥ របស់គណកម្មាធិការសង្គមនិង សេដ្ឋកិច្ច នៃ អង្គការសហប្រជាជាតិដែលប្រចាំនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិច (the United Nations Economic and Social Commission of Asia and the Pacific(ESCAP) ។ ESCAP ជំរុញឲ្យមានការគាំពារនិង ការដាក់បញ្ចូលការអភិវឌ្ឍផ្នែក សេដ្ឋកិច្ចសង្គម ទៅក្នុង អាស៊ីនិងប៉ាស៊ីហ្វិច តាមរយៈការវិភាគ, ការងារសាមញ្ញៗ ការកសាងសមត្ថភាព កិច្ចសហការក្នុងតំបន់ រួមទាំងការចែករំលែកនូវចំណេះដឹង ក្នុងភាពជាដៃគូក្នុងស្រុក និង បណ្តាភាគហ៊ុនផ្សេងៗទៀត។ ESCAPតាមរយៈAPCICT គឺបាន ទទួលយកការផ្តត់ផ្តង់ចំពោះ ការប្រើប្រាស់ សេចក្តីត្រូវការ និង ការបកប្រែនៃមេរៀនរបស់ Academic នេះនៅក្នុងប្រទេសផ្សេងៗពីគ្នាជាច្រើនព្រមទាំងចែករំលែកចំណេះយ៉ាងទៀងទាត់របស់ពួកគេដែលធ្វើឡើងជា បន្តបន្ទាប់ តាមរយៈ សិក្ខាសាលាថ្នាក់ជាតិនិងតំបន់ សំរាប់មន្ត្រីជាន់ខ្ពស់ និង មន្ត្រីថ្នាក់កណ្តាល រួមទាំងទិសដៅផ្សេងទៀត ដែលទាក់ទងនឹង ការកសាងសមត្ថភាពរួម ព្រមទាំងទទួលបានមកវិញនូវចំណេះដឹង ហើយត្រូវបានគេ បកប្រែដាក់ បញ្ចូលបន្ថែម ដើម្បីបង្កើនការយល់ដឹងនៃសារៈប្រយោជន៍ ICT និង ពង្រឹងការអនុវត្ត ឆ្ពោះទៅរកការ អភិវឌ្ឍទិសដៅជាច្រើន ។

Noeleen Heyzer

អនុរដ្ឋលេខាធិការនៃអង្គការសហប្រជាជាតិ

និង លេខាធិការប្រតិបត្តិនៃ ESCAP

## អារម្ភកថា

ដំណើរការនៅក្នុងការវិវត្តនៃ *កម្មវិធីសិក្សាជាន់ខ្ពស់នៃ អាយស៊ីធី ពិសេសសំរាប់ថ្នាក់ដឹកនាំក្នុងជួរ រដ្ឋាភិបាលសម្រាប់វគ្គបន្ត* នេះ ពិតជាបានបង្ហាញនូវការផុសឡើងនៃបទពិសោធន៍ថ្មីៗ ។ The Academy មិនត្រឹមតែជួយបំពេញបន្ថែមនូវចន្លោះនៃការកសាងសមត្ថភាពយល់ដឹងអំពីICT ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានត្រួសត្រាផ្លូវថ្មីមួយសំរាប់ការអភិវឌ្ឍន៍នូវកម្មវិធីសិក្សា (តាមយៈការចូលរួមរបស់ អ្នកសិក្សា និងភាពជាម្ចាស់នៃការអនុវត្ត) ។

The Academy គឺជាកម្មវិធីដល់ល្អបំផុតរបស់ APCICT ដែលបានធ្វើការអភិវឌ្ឍន៍ ដោយពឹងផ្អែកលើ:
លទ្ធផលនៃការស្ទង់មតិដែលធ្វើឡើងជាមួយប្រទេសជាង ២០ នៅក្នុងតំបន់ រួមទាំងទទួលការប្រឹក្សាយោបល់ពីមន្ត្រីរដ្ឋាភិបាលជាច្រើនរូប សមាជិកជាច្រើននៃសហគមន៍អភិវឌ្ឍន៍អន្តរជាតិ កម្មវិធីសិក្សានិងអ្នកអប់រំជាច្រើនរូប ធ្វើការស្រាវជ្រាវ និងវិភាគយ៉ាងស៊ីជំរៅអំពីភាពខ្លាំង និង ភាពខ្សោយ ចំពោះឧបករណ៍សម្រាប់ការហ្វឹកហ្វឺនដែលមានស្រាប់។ ព័ត៌មានត្រឡប់របស់អ្នកចូលរួមសិក្ខាសាលារបស់ APCICTបានរៀបចំឡើងជាបន្តបន្ទាប់សម្រាប់ថ្នាក់តំបន់និងអនុតំបន់ទៅលើអត្ថប្រយោជន៍និងភាពជាប់ទាក់ទងគ្នាពីវគ្គមួយទៅវគ្គមួយរួមទាំងយុទ្ធសាស្ត្រហ្វឹកហ្វឺនយ៉ាងសមរម្យមួយនិងមានភាពប្រាកដនិយមនៅ
ក្នុងការរំលឹកឡើងវិញ អំពីវគ្គទាំងនោះ ដោយមានការដឹកនាំពីអ្នកជំនាញជាច្រើនរូបនៅក្នុងវគ្គសិក្សា សម្រាប់ការអភិវឌ្ឍវិស័យ ICT ។ សិក្ខាសាលារបស់ The Academy ត្រូវបានធ្វើឡើង តាមតំបន់ដែលបានផ្តល់ ឱកាសដែលមិនអាចកាត់ថ្លៃបាន ក្នុងការផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងក្នុងចំណោមអ្នកចូលរួមពី ប្រទេសផ្សេងៗ សិក្ខាសាលានេះដែលបានបង្កើតនូវ Academy Alumni នឹងដើរតួយ៉ាងសំខាន់ ក្នុងការធ្វើឲ្យលេចចេញជារូបរាងនៅមេរៀនជាបន្តបន្ទាប់នេះ ។

ការដាក់បង្ហាញចេញដំបូងនៅវគ្គសិក្សាទាំងប្រាំបី សម្គាល់ឃើញថាជាការចាប់ផ្តើមសម្រាប់ដំណើរការ ដ៏ជោគជ័យ ដែលជាភាពខ្លាំងនៃដៃគូដែលមានស្រាប់ និងការកសាងភាពថ្មីផ្សេងមួយទៀតដើម្បីអភិវឌ្ឍ នៅក្នុងការធ្វើឲ្យសម្រេច នៅគោលនយោបាយរបស់ ICTD កាត់តាមតំបន់ ។ APCICT បានប្តេជ្ញាចិត្ត ក្នុងការផ្តត់ផ្គង់ផ្នែកបច្ចេកទេសនៅក្នុងការផ្សព្វផ្សាយអំពី National Academies ពីព្រោះថាការឆ្ពោះទៅមុខយ៉ាង សំខាន់របស់វា គឺការធានាថា The Academy នឹងជួយក្នុងការសម្រេចគោលនយោបាយ ។ APCICT ផងដែរបាននឹងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយវិទ្យាស្ថានហ្វឹកហ្វឺនរបស់ជាតិនិងតំបន់មួយចំនួន ដែលមាន ទំនាក់ទំនងជាមួយការគ្រប់គ្រង ថ្នាក់កណ្តាល, ការគ្រប់គ្រងរបស់រដ្ឋ និងការគ្រប់គ្រង់តាមលំដាប់ថ្នាក់ ប្រចាំតំបន់ ដើម្បីធ្វើឲ្យប្រសើរ ឡើងនូវសមត្ថភាពរបស់ពួកគេក្នុងការឆ្លើយតបនៅតំរូវការ ការបកប្រែ និង ចែករំលែកនូវមេរៀននីមួយៗរបស់ Academy ព្រមទាំងធ្វើវាទៅជាសេចក្តីត្រូវការ និងជាអទិភាពដំបូងសម្រាប់រដ្ឋ ។

លើសពីនេះទៅទៀត APCICT កំពុងតែជួលនូវពហុប៉ុស្តិ៍ជាច្រើន ដើម្បីធានាថា ខ្លឹមសារមេរៀនរបស់ Academy បានទៅដល់អ្នកមើល(អ្នកសិក្សា)ក្នុងលក្ខណៈយ៉ាងទូលំទូលាយនៅក្នុងតំបន់មួយ។ ក្រៅពីការផ្តល់នូវកម្មវិធីសិក្សាដោយផ្ទាល់របស់ Academy នៅក្នុងតំបន់និងតាមស្រុក Academy ក៏មាន the APCICT Virtual Academy (AVA) ដែលជាទម្រង់នៃការសិក្សាពីចម្ងាយ តាមប្រព័ន្ធ Onlineដែលត្រូវបង្កើតឡើងដើម្បីឲ្យអ្នកសិក្សាទទួលបានចំណេះដឹងពីកន្លែងរបស់ខ្លួន (ដោយមិនចាំបាច់ ទៅសិក្សាផ្ទាល់នៅវិទ្យាស្ថាន)។ AVA ធានាថាវគ្គនីមួយៗរបស់ Academy ជាមួយឧបករណ៍សិក្សាដទៃទៀត ដូចជាផ្ទាំងបញ្ចាំងបទបង្ហាញនៃមេរៀន និងករណីសិក្សាដទៃទៀត គឺមានភាពងាយស្រួលក្នុងការទាញយក (Download) មកពីប្រព័ន្ធអ៊ីនធឺណេត ដែលមានលក្ខណៈជាក់ស្តែងដូចបានទៅរៀនជាមួយសាស្ត្រាចារ្យដោយផ្ទាល់រួមមានឯកសារមេរៀនទាំងស្រុង,ការសិក្សាស្វែងយល់ទៅលើការគ្រប់គ្រង ខ្លឹមសារមេរៀនស្តីអំពី ការអភិវឌ្ឍន៍ទៅលើ ឧបករណ៍មួយចំនួន ព្រមទាំងមានការទទួលស្គាល់ (ឧ.វិញ្ញាបណ្ណប័ត្រ)។

វគ្គទាំងប្រាំបីរបស់ Academy និងការផ្តល់សិក្ខាសាលាស្តីពី Academy ថ្នាក់ជាតិ, ថ្នាក់តំបន់និងអនុតំបន់ នឹងមិនអាចសម្រេចទៅបានទេ ប្រសិនបើគ្មានការប្តេជ្ញាចិត្ត ការចង្អុលបង្ហាញនិង ការចូលរួមយ៉ាងសកម្មអំពី បុគ្គលម្នាក់ៗ ឬអង្គភាពនានា ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះកិច្ចប្រឹងប្រែងនិងសមិទ្ធផលនានា នៃAcademy Alumni ដែលសម្រេចដោយមានការចូលរួមពីសហការពីក្រសួង រដ្ឋាភិបាល វិទ្យាស្ថានហ្វឹកហ្វឺន ព្រមទាំងអង្គភាពជាតិ និងអង្គភាពប្រចាំតំបន់ជាច្រើនដែលបានចូលរួម ក្នុងសិក្ខាសាលាAcademy។ ពួកគេមិនត្រឹមតែផ្តល់នូវទស្សនៈដ៏មានតំលៃជាច្រើនដើម្បីដាក់បញ្ចូលទៅក្នុង
វគ្គនីមួយៗប៉ុណ្ណោះទេ ថែមទាំងដើរតួយ៉ាងសំខាន់ជាច្រើនទៀត ដោយពួកគេបានជួយគាំទ្រ Academy នៅក្នុងប្រទេសរបស់ពួកគេ ដែលឲ្យជាលទ្ធផលសម្រាប់ការយោគយល់គ្នាជាលក្ខណៈផ្លូវការ រវាង APCICT ជាមួយ វិទ្យាស្ថានរបស់ជាតិ និងតំបន់មួយចំនួន ក្នុងការផ្តល់នូវការឆ្លើយតបតាមតំរូវការ និងការផ្តល់នូវមុខវិជ្ជា របស់ Academy សម្រាប់ប្រទេសទាំងនោះ យ៉ាងទៀងទាត់ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតសម្រាប់ការខិតខំប្រឹងប្រែងក្នុងការចូលរួមពីបុគ្គលដែល
ប្រកបដោយគតិបណ្ឌិត ក្នុងការបង្កើតនៅដំណើរប្រតិបត្តិការ ដ៏អស្ចារ្យមួយនេះឲ្យប្រព្រឹត្តទៅបាន ដែលមានដូចជា លោក Shahid Akhtar ជាទីប្រឹក្សាគម្រោងនៃ *The Academy*, Patricia Arinto ជាអ្នកពិនិត្យ Christine Apikul, ជាអ្នកគ្រប់គ្រងផ្នែកបោះពុម្ព និងរាល់អ្នកនិពន្ធ *Academy,* និងក្រុមការងារ APCICT ។

ខ្ញុំសង្ឃឹមយ៉ាងស្មោះស្ម័គ្រថា *Academy* មួយនេះនឹងជួយប្រទេសជាច្រើនឲ្យរួចផុតពីចន្លោះប្រហោងក្នុង ការ បណ្តុះបណ្តាលធនធានមនុស្សផ្នែកICTលុបបំបាត់ភាពរាំងស្ទះក្នុងការទទួលយកICT មកប្រើប្រាស់ដោយផ្ទាល់

ខ្លួនព្រមទាំងជួយជំរុញឲ្យមានការអនុវត្តនៃវិស័យICT ដើម្បីពន្លឿនការអភិវឌ្ឍវិស័យសេដ្ឋកិច្ចសង្គម រួមទាំង ការសម្រេចបានស្នាដៃក្នុងគោលដៅ រាប់លានផ្សេងទៀត។

Hyeun-Suk Rhee
ប្រធាន
UN-APCICT

**អំពីស៊េរីម៉ូឌុលនេះ**

នៅក្នុង “សម័យព័ត៌មានវិទ្យា” បច្ចុប្បន្ននេះ ភាពងាយស្រួលក្នុងការទទួលបានព័ត៌មាន កំពុងធ្វើការ ផ្លាស់ប្តូររបៀបនៃការរស់នៅ ជីវិតការងារ ក៏ដូចជាការកំសាន្តរបស់យើងគ្រប់ៗគ្នា ។ “សេដ្ឋកិច្ចឌីជីថល” ដែលត្រូវបានស្គាល់ថាជា “សេដ្ឋកិច្ចនៃចំណេះដឹង” “សេដ្ឋកិច្ចជាបណ្តាញ” ឬ “សេដ្ឋកិច្ចថ្មី” នោះ ត្រូវបានកំណត់លក្ខណៈតាមរយៈការផ្លាស់ប្តូរ ពីផលិតកម្មទំនិញទៅរកការបង្កើតជាគំនិតថ្មីៗ ។ នេះចង្អុលបង្ហាញអំពីភាពរីកចម្រើន ដែលត្រូវបានដើរតួយ៉ាងសំខាន់ ដោយបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា (ICTs) នៅក្នុងប្រព័ន្ធសេដ្ឋកិច្ច និងសង្គមទាំងមូលថែមទៀតផង ។

ជាលទ្ធផល រដ្ឋាភិបាលទូទាំងសកលលោកបានផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើការអភិវឌ្ឍ ផ្នែកបច្ចេកវិទ្យា គមនាគន៍ព័ត៌មានវិទ្យា (ICTD) ។ សម្រាប់រដ្ឋាភិបាលទាំងនេះ ICTD មិនមែនមានន័យត្រឹមតែជាការអភិវឌ្ឍឧស្សាហកម្ម បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ឬវិស័យសេដ្ឋកិច្ចប៉ុណ្ណោះទេ ការអភិវឌ្ឍនេះថែមទាំងមានវិសាលភាពទៅលើការ ប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាដើម្បីជំរុញអោយមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច ក៏ដូចជាការរីកចម្រើន ផ្នែកសង្គម និងនយោបាយផងដែរ ។

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងចំណោមផលលំបាកនានាដែលរដ្ឋាភិបាលកំពុងជួបប្រទះក្នុងការបង្កើត គោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យានោះ គឺអ្នកបង្កើតគោលនយោបាយទាំងនោះជាញឹកញាប់មិនទាន់ទម្លាប់នឹងបច្ចេកវិទ្យា ដែលខ្លួនកំពុងប្រើប្រាស់សម្រាប់ការអភិវឌ្ឍជាតិតែម្តង ។ ដោយហេតុថាបុគ្គលម្នាក់មិនអាចគោរពតាមបញ្ញត្តិដែលខ្លួនមិនយល់នោះ អ្នកបង្កើតគោលនយោបាយបានគេចចេញពីការបង្កើតគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ។ ប៉ុន្តែការទំលាក់បញ្ហា រៀបចំគោលនយោបាយបច្ចេកវិទ្យាទូរគមនាគមន៍ព័ត៌មានវិទ្យានេះទៅអោយជំនាញការផ្នែកបច្ចេកវិទ្យាទទួលខុសត្រូវនោះ ក៏ជារឿងមួយមិនត្រឹមត្រូវដែរ ពីព្រោះជាធម្មតាជំនាញការបច្ចេកវិទ្យាទាំងនេះ មិនបានដឹងអំពីទំនាក់ទំនងនៃគោលនយោបាយនេះចំពោះបច្ចេកវិទ្យាដែលខ្លួនកំពុងបង្កើត និងប្រើប្រាស់ នោះទេ ។

**ស៊េរីម៉ូឌុលកម្មវិធីសិក្សាអំពីសារសំខាន់នៃបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាសម្រាប់ថ្នាក់ដឹកនាំរដ្ឋាភិបាល នេះ ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាសម្រាប់ការអភិវឌ្ឍតំបន់អាស៊ី និងប៉ាស៊ីហ្វិក របស់អង្គការសហប្រជាជាតិ** (UN-APCICT) សម្រាប់ ៖

១. អ្នកបង្កើតគោលនយោបាយថ្នាក់ជាតិ និងរដ្ឋាភិបាលមូលដ្ឋានដែលទទួលខុសត្រូវក្នុងការបង្កើត គោលនយោបាយ ICT

២. មន្ត្រីរដ្ឋបាលដែលទទួលខុសត្រូវការងារអភិវឌ្ឍន៍ និងកម្មវិធីផ្អែកតាម ICT និង

៣. អ្នកគ្រប់គ្រងនានានៅក្នុងវិស័យសាធារណៈ ដែលកំពុងស្វែងរកការប្រើប្រាស់ឧបករណ៍ ICT សម្រាប់ការងារគ្រប់គ្រងគម្រោងរបស់ខ្លួន ។

ស៊េរីម៉ូឌុលនេះមានគោលបំណងអភិវឌ្ឍភាពទម្លាប់ឬបន្ទាំ ជាមួយនឹងបញ្ហាសំខាន់ៗដែលជាប់ពាក់ព័ន្ធ នឹង ICTD ដែលកើតចេញពីទស្សនវិស័យផ្នែកគោលនយោបាយ និងបច្ចេកវិទ្យា ។ គោលបំណងនៃម៉ូឌុលនេះមិនមែនត្រឹមតែសម្រាប់ការអភិវឌ្ឍសៀវភៅណែនាំបច្ចេកទេស ICT តែប៉ុណ្ណោះនោះទេ ប៉ុន្តែជាងនេះទៅ ទៀតគឺដើម្បីផ្តល់នូវការយល់ដឹងដ៏ល្អអំពីអ្វីដែលបច្ចេកវិទ្យា ឌីជីថលសព្វថ្ងៃអាចមាន ឬកន្លែងដែលបច្ចេកវិទ្យានេះ ត្រូវបានដឹកនាំទៅរក និងអ្វីដែលបច្ចេកវិទ្យានេះ ការបង្កើតគោលនយោបាយនានា ។ ប្រធានបទផ្សេងៗដែលមាននៅក្នុងម៉ូឌុលនេះ ត្រូវបានធ្វើការកំណត់ ឡើងតាមរយៈការវិភាគទៅលើតម្រូវការនៃការបណ្តុះបណ្តាល ព្រមទាំងការស្ទាបស្ទង់ទៅលើ សម្ភារៈដែលចាំបាច់សម្រាប់វគ្គបណ្តុះ បណ្តាលដទៃទៀតនៅលើសកលលោក ។

ម៉ូឌុលនេះ ត្រូវបានរចនាឡើងនៅក្នុងរបៀបមួយដែលអាចអោយអ្នកអានគ្រប់រូបអាចធ្វើការស្វ័យសិក្សា បាន ឬដើម្បីប្រើប្រាស់ជាធនធានសិក្សាសម្រាប់វគ្គបណ្តុះបណ្តាល ឬកម្មវិធីបណ្តុះបណ្តាលនានា ។ ម៉ូឌុលនេះអាចប្រើប្រាស់ជាឯកសារឯករាជ្យ និងឯកសារយោងជាមួយឯកសារផ្សេងៗទៀត ហើយកិច្ច ប្រឹងប្រែងផ្សេងៗត្រូវបានធ្វើឡើងនៅក្នុងម៉ូឌុលនីមួយៗដើម្បី ផ្សារភ្ជាប់ម៉ូឌុលនេះទៅនឹងនិក្ខេបបទ និងកិច្ចពិភាក្សានានានៅក្នុងម៉ូឌុលដទៃទៀតដែលស្ថិតនៅក្នុងស៊េរីជាមួយគ្នានោះ ។ គោលបំណងរយៈពេល វែងគឺធ្វើយ៉ាងណាអោយម៉ូឌុលនេះត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាដែលមានការទទួលស្គាល់ ។

ម៉ូឌុលនីមួយៗចាប់ផ្តើមជាមួយនឹងសេចក្តីថ្លែងអំពីកម្មវត្ថុសិក្សា និងលទ្ធផលគោលដៅដែលនឹងទទួល បានក្រោយពេលសិក្សា ដែលអ្នកអានគ្រប់រូបអាចធ្វើការវាយតម្លៃអំពីភាពរីកចម្រើនរបស់ខ្លួនធៀបនឹងលទ្ធផលគោលដៅដែលផ្តល់អោយបាន ។ ខ្លឹមសារនៃម៉ូឌុលនេះ ចែកចេញជាផ្នែកៗដែលក្នុងនោះ រួមមានករណីសិក្សា និងលំហាត់អនុវត្តផ្សេងៗដើម្បីជួយអោយអ្នកអានយល់ កាន់តែស៊ីជម្រៅអំពី ទស្សនទានជាគន្លឹះនានា ។ លំហាត់ទាំងនេះអាចនឹងអនុវត្តដោយបុគ្គលអ្នកអានម្នាក់ៗ ឬក្រុមសិក្ខាកាមដែល ចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល ។ ម៉ូឌុលនេះផ្តល់នូវរូបភាព និងតារាងផ្សេងៗ ដើម្បីធ្វើការចង្អុលបង្ហាញអំពីតថភាពជាក់លាក់នានានៅក្នុងការពិភាក្សា ។ ឯកសារយោង និងធនធានឯកសារនៅលើបណ្តាញ អ៊ីនធឺណិតទាំងឡាយ មានរាយនៅក្នុងសៀវភៅណែនាំនេះ សម្រាប់អ្នកអានក្នុងការការសិក្សាស្រាវជ្រាវដើម្បីបង្កើនទស្សនវិស័យអំពីបច្ចេកវិទ្យានេះបន្ថែមទៀត ។

ការប្រើប្រាស់ ICTD មានលក្ខណៈទូលំទូលាយណាស់រហូតដល់ពេលខ្លះករណីសិក្សា និងឧទាហរណ៍ នៅក្នុង និងទូទាំងម៉ូឌុលទាំងមូលអាចមានលក្ខណៈផ្ទុយគ្នា ។ យើងរំពឹងថាករណីនេះ នឹងអាចកើតមានឡើង ។ នេះគឺជារឿងមួយដែលគួរអោយភ្ញាក់ផ្អើល ព្រមទាំងបញ្ហាប្រឈមនៃមុខវិជ្ជាសិក្សាដែលទើបនឹង លេចឡើងថ្មីៗ និងសញ្ញានៃមុខវិជ្ជាទាំងនោះខណៈពេលដែល ប្រទេសនីមួយៗចាប់ផ្តើមរុករកសក្តានុពល នៃ ICTs ដើម្បីប្រើប្រាស់ធ្វើជាឧបករណ៍សម្រាប់ការអភិវឌ្ឍរបស់ខ្លួន ។

ការគាំទ្រកម្មវិធីសិក្សាសម្រាប់ស៊េរីម៉ូឌុលកម្មវិធីសិក្សានៅក្នុងទម្រង់ជាឯកសារបោះពុម្ពនេះ គឺជាបែបផែន នៃការសិក្សាពីចម្ងាយតាមបណ្តាញអ៊ីនធឺណិត ពោលគឺកម្មវិធីសិក្សាជាក់ស្តែង APCICT (AVA – http://www.unapcict.org/academy) ដោយមានថ្នាក់រៀនដែលផ្តល់នូវបទបង្ហាញពីគ្រូបណ្តុះបណ្តាល ក្នុងទម្រង់ជាវីដេអូ និងបទបង្ហាញក្នុងទម្រង់ជាកម្មវិធី PowerPoint នៃម៉ូឌុលនានា ។

លើសពីនេះទៀត APCICT បានបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណិតមួយសម្រាប់ ICTD (e-Co Hub - http://www.unapcict.org/ecohub) ដែលជាផទិការបម្រើដល់គោលបំណង ជាក់លាក់មួយតាមបណ្តាញអ៊ីនធឺណិតសម្រាប់អ្នកអនុវត្ត និងអ្នកបង្កើតគោលនយោបាយ ICTD ដើម្បី លើកកម្ពស់បទពិសោធន៍នៃការសិក្សា និងការបណ្តុះបណ្តាលរបស់ខ្លួន ។ មជ្ឈមណ្ឌលសហប្រតិបត្តិការ តាមប្រព័ន្ធអ៊ីនធឺណិត ផ្តល់អោយអ្នកនូវការទទួលបានធនធាន ចំណេះដឹងនៅក្នុងតថភាពផ្សេងៗពីគ្នានៃ ICTD ព្រមទាំងផ្តល់នូវលំហអន្តរកម្មមួយសម្រាប់ចែករំលែកចំណេះដឹង និងបទពិសោធន៍ ព្រមទាំង សហប្រតិបត្តិការក្នុងគោលបំណងជួយអោយ ICTD កាន់តែមានលក្ខណៈទំនើប ។

ម៉ូឌុល ៣

ម៉ូឌុលនេះ ផ្តល់នូវទិដ្ឋភាពទូទៅអំពីរដ្ឋាភិបាលអេឡិចត្រូនិក ដែលរួមមានសមាសធាតុ និងទស្សនាទាន គន្លឹះៗ គោលការណ៍ និងប្រភេទនៃកម្មវិធីផ្សេងៗទៀត ។ ម៉ូឌុលនេះ ពិភាក្សាអំពីរបៀបបង្កើតប្រព័ន្ធ រដ្ឋាភិបាលអេឡិចត្រូនិកតាមរយៈ វិភាគលម្អិតនៃប្រព័ន្ធគំរូ និងការកំណត់ ការពិចារណាទៅលើ ការរចនា ។

**កម្មវត្ថុនៃម៉ូឌុល**

ម៉ូឌុលនេះ មានគោលបំណង ៖

១. ផ្តល់នូវទិដ្ឋភាពទូទៅអំពីសមាសធាតុសំខាន់ៗរបស់រដ្ឋាភិបាលអេឡិចត្រូនិក

២. រៀបរាប់ និងផ្តល់ជាឧទាហរណ៍អំពីប្រភេទសេវាកម្មរដ្ឋាភិបាលអេឡិចត្រូនិក និង

៣. ពិភាក្សាអំពីកត្តាជោគជ័យសំខាន់ៗ ក៏ដូចជាឧបសគ្គក្នុងការទទួលបានជោគជ័យនៅក្នុងសេវា រដ្ឋាភិបាលអេឡិចត្រូនិក

**លទ្ធផលដែលទទួលបានពីការសិក្សា**

បន្ទាប់ពីបានសិក្សាទៅលើម៉ូឌុលនេះរួច អ្នកអានអាចមានលទ្ធភាព ៖

១. ពិភាក្សាអំពីរបៀបដែលកម្មវិធី ICT អាចកែលម្អរបៀបធ្វើការងាររបស់រដ្ឋាភិបាល

២. រៀបរាប់អំពីកម្មវិធី ICT ផ្សេងៗគ្នានៅក្នុងវិស័យខុសៗគ្នារបស់រដ្ឋាភិបាល និង

៣. វិភាគលើកត្តាដែលនាំអោយ ជោគជ័យ ឬបរាជ័យនៃកម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិកជាក់លាក់

## មាតិកា


Noeleen Heyzer ........................................ 3

Hyeun-Suk Rhee ........................................ 5

UN-APCICT ........................................ 5

អំពីស៊េរីម៉ូឌុលនេះ ........................................ 6

ម៉ូឌុល ៣ ........................................ 8

កម្មវត្ថុនៃម៉ូឌុល ........................................ 8

លទ្ធផលដែលទទួលបានពីការសិក្សា ........................................ 8

បញ្ជីប្រអប់ ........................................ 11

បញ្ជីរូបភាព ........................................ 11

បញ្ជីតារាង ........................................ 11

តារាងទី ៩ ឧទាហរណ៍នៃសុខាភិបាលអេឡិចត្រូនិកពាក្យកាត់ ........................................ 11

ពាក្យកាត់ ........................................ 12

១.១ និយមន័យរដ្ឋាភិបាលអេឡិចត្រូនិក ........................................ 14

១.២ នវានុវត្តន៍សេវាប្រជាពលរដ្ឋ និងសេវាអាជីវកម្ម (ការចែកចាយការិយាល័យមុខ) ........................................ 15

១.៣ នវានុវត្តន៍របៀបធ្វើការងាររបស់រដ្ឋាភិបាល (G2G) (ការចែកចាយនៅការិយាល័យក្រោយ) ........................................ 16

១.៤ អត្ថប្រយោជន៍នៃការអនុវត្ត ICT ប្រកបដោយជោគជ័យក្នុងរដ្ឋាភិបាល ........................................ 16

ចក្ខុវិស័យ កម្មវត្ថុ និងយុទ្ធសាស្ត្រ ........................................ 18

ច្បាប់ និងបទបញ្ញត្តិ ........................................ 19

រចនាសម្ព័ន្ធអង្គភាព ........................................ 19

ដំណើរការអាជីវកម្ម ........................................ 19

១.៦ កត្តាហានិភ័យក្នុងការដាក់ពង្រាយរដ្ឋាភិបាលអេឡិចត្រូនិក ........................................ 20

១.៧ រដ្ឋាភិបាលអេឡិចត្រូនិកថ្ងៃអនាគត ........................................ 20

៣.៤ ហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិក ........................................ 58

មជ្ឈមណ្ឌលរដ្ឋបាលធនធានកុំព្យូទ័រ និងព័ត៌មានជាតិ ........................................ 59

បមាណីយកម្មរដ្ឋាភិបាលអេឡិចត្រូនិក ........................................ 61

សេវារួមរបស់រដ្ឋាភិបាលអេឡិចត្រូនិក ........................................ 61

មជ្ឈមណ្ឌលសហគមន៍អេឡិចត្រូនិក ........................................ 62

៣.៦ កម្មវិធីសុខាភិបាល និងទូរវេជ្ជសាស្ត្រ ៖ បង្កើនការទទួលបានសេវាសុខាភិបាល ........................................ 66

៣.៧ កម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយ ៖ សេវាគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិរួមបញ្ចូលគ្នា ........................................ 69

សទ្ទានុក្រម ........................................ 74

កំណត់សម្គាល់សម្រាប់គ្រូបង្គោល ........................................ 76

អំពីអ្នកនិពន្ធ ........ 77
UN-APCICT ........ 78
ESCAP ........ 79
មេរៀនទី ២-ICT សម្រាប់ការអភិវឌ្ឍន៍ ប្រតិបត្តិការ និង ការគ្រប់គ្រង ........ 80
មេរៀនទី ៤–និន្នាការនានារបស់ ICT សម្រាប់ថ្នាក់ដឹកនាំរដ្ឋាភិបាល ........ 80
មេរៀនទី ៨– ជម្រើសលើការផ្តល់មូលនិធិនៃ ICT សម្រាប់ការអភិវឌ្ឍន៍........ 80
**APCICT Virtual Academy (AVA –** http://ava.unapcict.org**)** ........ 80

បញ្ជីករណីសិក្សា

១. PFnet

២. មជ្ឈមណ្ឌលសហគមន៍ឌីជីថលក្នុងប្រទេសបង់ក្លាដែស

៣. ផែនទីបង្ហាញផ្លូវរដ្ឋាភិបាលអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ

៤. ផែនទីបង្ហាញផ្លូវរដ្ឋាភិបាលអេឡិចត្រូនិករបស់ប្រទេសម៉ុងហ្គោលី

៥. គម្រោងប្រព័ន្ធព័ត៌មានរដ្ឋបាលរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា (GAIS)

៦. លទ្ធកម្មអេឡិចត្រូនិកក្នុងទីក្រុង Andhra Pradesh ប្រទេសឥណ្ឌា

៧. កំណែទម្រង់ទំនៀមទម្លាប់ប្រទេសហ្វីលីពីន

៨. ពាណិជ្ជកម្មអេឡិចត្រូនិកក្នុងសាធារណរដ្ឋកូរ៉េ

៩. ពាណិជ្ជកម្មអេឡិចត្រូនិកក្នុងប្រទេសថៃ

១០. គម្រោង LGU អេឡិចត្រូនិកក្នុងប្រទេសហ្វីលីពីន

១១. ប្រព័ន្ធគ្រប់គ្រងចំណេះដឹងអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ

១២. ការគ្រប់គ្រងចំណេះដឹងសម្រាប់ការកាត់បន្ថយហានិភ័យ–គ្រោះមហន្តរាយក្នុងប្រទេសឥណ្ឌា

១៣. ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ Sahana

**បញ្ជីប្រអប់**


ប្រអប់ទី ១ លិបិក្រម (Index)វិធានការលើបណ្តាញវែបសាយត៍របស់អង្គការសហប្រជាជាតិ

ប្រអប់ទី ២ ដំណោះស្រាយបញ្ហាផ្លូវច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្មអេឡិចត្រូនិក

ប្រអប់ទី ៣ អង្គការសុខភាពពិភពលោកអំពីសុខភាពអេឡិចត្រូនិក


**បញ្ជីរូបភាព**


រូបភាពទី ១ កត្តាជោគជ័យសំខាន់ៗនៅក្នុងការអនុវត្តរដ្ឋាភិបាលអេឡិចត្រូនិក

រូបភាពទី ២ ប្រព័ន្ធភាពជាដៃគូរដ្ឋាភិបាលអេឡិចត្រូនិក

រូបភាពទី ៣ ការដាក់ពង្រាយប្រព័ន្ធអេឡិចត្រូនិកជាតិរបស់ប្រទេសម៉ិកស៊ិក

រូបភាពទី ៤ ផែនការប្រចាំឆ្នាំសម្រាប់ការអនុវត្តផែនទីបង្ហាញផ្លូវរដ្ឋាភិបាលអេឡិចត្រូនិករបស់ សាធារណរដ្ឋកូរ៉េ

រូបភាពទី ៥ ផែនការថវិកាធម្មតា និងការវិនិយោគលើ ICT

រូបភាពទី ៦ ក្របខ័ណ្ឌទស្សនាទាននៃរដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ

រូបភាពទី ៧ រដ្ឋាភិបាលអេឡិចត្រូនិក window រួម (Single-window e-government)

រូបភាពទី ៨ ការប្រើប្រាស់សេវា G2C នៅសាធារណរដ្ឋកូរ៉េ

រូបភាពទី ៩ Window ដំណើរការរួមរដ្ឋាភិបាលអេឡិចត្រូនិកសម្រាប់សាធារណរដ្ឋកូរ៉េ

រូបភាពទី ១០ សេវាច្រកចូលបណ្តាញវែបសាយត៍ព័ត៌មានធានារ៉ាប់រងសង្គមរបស់សាធារណរដ្ឋកូរ៉េ ផ្អែកតាមមូលដ្ឋានទិន្នន័យរួមបញ្ចូលគ្នា

រូបភាពទី ១១ ប្រព័ន្ធចុះបញ្ជីប្រជាពលរដ្ឋរបស់សាធារណរដ្ឋកូរ៉េ

រូបភាពទី ១២ ផែនទីទស្សនាទានសម្រាប់ប្រព័ន្ធគ្រប់គ្រងអចលនវត្ថុរបស់សាធារណរដ្ឋកូរ៉េ

រូបភាពទី ១៣ ទស្សនាទានសម្រាប់សេវាចុះបញ្ជីយានយន្តរបស់សាធារណរដ្ឋកូរ៉េ

រូបភាពទី ១៤ ប្រព័ន្ធលទ្ធកម្មរដ្ឋាភិបាល window រួម

រូបភាពទី ១៥ ប្រព័ន្ធពន្ធគយអេឡិចត្រូនិកនៃសាធារណរដ្ឋកូរ៉េ

រូបភាពទី ១៦ ម៉ាស៊ីនកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលកូរ៉េ

រូបភាពទី ១៧ ទស្សនាទានសម្រាប់ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានឌីជីថលនៅក្នុងសាធារណរដ្ឋកូរ៉េ

រូបភាពទី ១៨ ទស្សនាទានរដ្ឋបាលអប់រំទូទាំងប្រទេសឌីជីថលរបស់សាធារណរដ្ឋកូរ៉េ

រូបភាពទី ១៩ ដំណើរឆ្ពោះទៅកាន់ប្រព័ន្ធរដ្ឋាភិបាលសមាហរណកម្ម

រូបភាពទី ២០ ស្ថាបត្យកម្មមជ្ឈមណ្ឌលកុំព្យូទ័រដែលបានធ្វើសមារណកម្មក្នុងរដ្ឋាភិបាល

រូបភាពទី ២១ ឋានវិទ្យាទូរពិគ្រោះយោបល់នៅក្នុងប្រជុំកោះប៉ាស៊ីហ្វិក


**បញ្ជីតារាង**


តារាងទី ១ ការផ្លាស់ប្តូរនៅក្នុងដំណើរការការងាររបស់រដ្ឋាភិបាលចេញពីរដ្ឋាភិបាលអេឡិចត្រូនិក

តារាងទី ២ ដំណាក់កាលអភិវឌ្ឍរដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ

តារាងទី ៣ គំរូរដ្ឋាភិបាលអេឡិចត្រូនិកតាមប្រភេទអន្តរកម្មរវាងភាគីពាក់ព័ន្ធ

តារាងទី ៤ ភារកិច្ចស្នូលទាំងបួនសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុរដ្ឋាភិបាលមូលដ្ឋាន

តារាងទី ៥ ការផ្តោះប្តូរឯកសារអេឡិចត្រូនិក និងអត្រាអនុម័តអេឡិចត្រូនិកក្នុងចំណោមទីភ្នាក់ងាររដ្ឋបាល

តារាងទី ៦ តម្លៃទីផ្សារនៃការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ

តារាងទី ៧ ការកំណត់អាទិភាពសេវារួមរដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ

តារាងទី ៨ ការប្រៀបធៀបគ្នារវាងទិន្នន័យ ព័ត៌មាន និងចំណេះដឹង

តារាងទី ៩ ឧទាហរណ៍នៃសុខាភិបាលអេឡិចត្រូនិក

ពាក្យកាត់

| | |
|---|---|
| APCICT | មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាសម្រាប់ការ អភិវឌ្ឍ តំបន់អាស៊ី និងប៉ាស៊ីហ្វិក (Asian and Pacific Training Centre for Information and Communication Technology for Development) |
| APDIP | កម្មវិធីព័ត៌មានវិទ្យាសម្រាប់ការអភិវឌ្ឍតំបន់អាស៊ី-ប៉ាស៊ីហ្វិក (Asia-Pacific Development Information Programme) |
| ASYCUDA | ប្រព័ន្ធស្វ័យប្រវត្តិសម្រាប់ទិន្នន័យពន្ធគយ (Automated System for Customs Data) |
| AusAID | ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍអន្តរជាតិអូស្ត្រាលី Australian Agency for International Development |
| B2B | អាជីវកម្ម-ទៅ-អាជីវកម្ម Business-to-Business |
| B2C | អាជីវកម្ម-ទៅ-ប្រជាពលរដ្ឋ Business-to-Citizen |
| B2G | អាជីវកម្ម-ទៅ-រដ្ឋាភិបាល Business-to-Government |
| BOC | ការិយាល័យពន្ធគយ ប្រទេសហ្វីលីពីន Bureau of Customs, Philippines |
| BPR | វិស្វកម្មដំណើរការអាជីវកម្មឡើងវិញ Business Process Reengineering |
| CIC | មជ្ឈមណ្ឌលព័ត៌មានសហគមន៍ ប្រទេសបង់ក្លាដែស Community Information Centre, Bangladesh |
| EDI | ការផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកទៅវិញទៅមក Electronic Data Interchange |
| eRPTS | ប្រព័ន្ធសារពើពន្ធចលនទ្រព្យអេឡិចត្រូនិកប្រទេសហ្វីលីពីន Electronic Real Property Tax System, Philippines |
| ESCAP | គណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក Economic and Social Commission for Asia and the Pacific |
| FOSS | កម្មវិធីសម្រាប់មើលកូដទិន្នន័យចំហ Free and Open Source Software |
| G2B | រដ្ឋាភិបាល-ទៅ-អាជីវកម្ម Government-to-Business |
| G2C | រដ្ឋាភិបាល-ទៅ-ប្រជាពលរដ្ឋ Government-to-Citizen |
| G2G | រដ្ឋាភិបាល-ទៅ- រដ្ឋាភិបាល Government-to-Government |
| GAIS | ប្រព័ន្ធព័ត៌មានរដ្ឋបាលរដ្ឋាភិបាល ប្រទេសកម្ពុជា Government Administration Information System, Cambodia |
| GoAP | រដ្ឋាភិបាល Andhra Pradesh ប្រទេសឥណ្ឌា |
| ICT | បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា |
| ICTD | ការអភិវឌ្ឍផ្នែកបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាសម្រាប់ការអភិវឌ្ឍ Information and Communication Technology for Development |
| IDRC | មជ្ឈមណ្ឌលស្រាវជ្រាវសម្រាប់ការអភិវឌ្ឍអន្តរជាតិ ប្រទេសកាណាដា International Development Research Centre, Canada |
| ILC | មជ្ឈមណ្ឌលសិក្សាអ៊ីនធឺណិត ប្រទេសបង់ក្លាដែស Internet Learning Centre, Bangladesh |
| INV | តំបន់បណ្តាញព័ត៌មាន Information Network Village, Republic of Korea |
| ISP | ការរៀបចំផែនការយុទ្ធសាស្ត្រព័ត៌មាន Information Strategy Planning |
| IT | បច្ចេកវិទ្យាព័ត៌មានវិទ្យា Information Technology |
| KADO | ទីភ្នាក់ងារកូរ៉េសម្រាប់ឱកាស និងការជំរុញអោយប្រើប្រាស់ប្រព័ន្ធឌីជីថល Korea Agency for Digital Opportunity and Promotion |

| | |
|---|---|
| KMS | ប្រព័ន្ធគ្រប់គ្រងចំណេះដឹង Knowledge Management System |
| LAN | បណ្តាញក្នុងតំបន់ Local Area Network |
| LGU | អង្គភាពរដ្ឋាភិបាលមូលដ្ឋានប្រទេសហ្វីលីពីន<br>Local Government Unit, Philippines |
| MOGAHA | ក្រសួងរដ្ឋបាលរដ្ឋាភិបាល និងកិច្ចការផ្ទៃក្នុង សាធារណរដ្ឋកូរ៉េ Ministry of Government Administration and Home Affairs, Republic of Korea |
| MOPAS | ក្រសួងរដ្ឋបាលសាធារណៈ និងសន្តិសុខ សាធារណរដ្ឋកូរ៉េ Ministry of Public Administration and Security, Republic of Korea |
| NCA | ទីភ្នាក់ងារកុំព្យូទ័រភាវូបណីយកម្មជាតិ សាធារណរដ្ឋកូរ៉េ<br>National Computerization Agency, Republic of Korea |
| NCC | មជ្ឈមណ្ឌលកុំព្យូទ័រជាតិ ប្រទេសហ្វីលីពីន<br>National Computer Center, Philippines |
| NDMS | ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយជាតិ<br>National Disaster Management System |
| NGO | អង្គការមិនមែនរដ្ឋាភិបាល Non-Governmental Organization |
| NIA | ទីភ្នាក់ងារសង្គមព័ត៌មានជាតិ សាធារណរដ្ឋកូរ៉េ<br>National Information Society Agency, Republic of Korea |
| NRI | ស្ថាប័នធនធានជាតិ ប្រទេសឥណ្ឌា National Resource Institution, India |
| NTS | សេវាសារពើពន្ធជាតិ National Tax Service |
| OECD | អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច<br>Organisation for Economic Co-operation and Development |
| PC | កុំព្យូទ័រផ្ទាល់ខ្លួន Personal Computer |
| PFnet | បណ្តាញអ៊ីនធឺណិតដំបូងបង្អស់សម្រាប់ប្រជាពលរដ្ឋ People First Network |
| RIC | មជ្ឈមណ្ឌល ICT ជនបទ ប្រទេសបង់ក្លាដែស |
| RTC | មជ្ឈមណ្ឌលបច្ចេកវិទ្យាជនបទប្រទេសបង់ក្លាដែស<br>Rural ICT Centre, Bangladesh |
| SME | សហគ្រាសខ្នាតតូច និងមធ្យម Small and Medium Enterprise |
| TV | ទូរទស្សន៍ Television |
| UN | អង្គការសហប្រជាជាតិ United Nations |
| UNCTAD | សន្និសិទស្តីពីពាណិជ្ជកម្ម និងអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ<br>United Nations Conference on Trade and Development |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ United Nations Development Programme |
| UNOPS | ការិយាល័យសេវាគ្រប់គ្រងគម្រោងរបស់អង្គការសហប្រជាជាតិ<br>United Nations Office for Project Services |
| WHO | អង្គការសុខភាពពិភពលោក World Health Organization |

## បញ្ជីនៃសញ្ញាសំគាល់នានា


សញ្ញាសម្រាប់ផ្នែកសិក្សា


អ្វីដែលត្រូវអនុវត្ត/ការងារដែលត្រូវធ្វើ


សំនួរគិតរិះ


សាកល្បងខ្លួនអ្នក

## ១.០ ទិដ្ឋភាពទូទៅនៃកម្មវិធី ICT

### ១.១ និយមន័យរដ្ឋាភិបាលអេឡិចត្រូនិក

រដ្ឋាភិបាលអេឡិចត្រូនិក អាចមាននិយមន័យយ៉ាងទូលាយថា ជាកម្មវិធីបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ (ICTs) សម្រាប់កែលម្អសមិទ្ធកម្មដំណើរការ និងសេវាកម្មរបស់រដ្ឋាភិបាលបុរាណ ។ ជាងនេះទៅទៀត រដ្ឋាភិបាលអេឡិចត្រូនិក គឺជា "ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីប្រែក្លាយប្រតិបត្តិការរដ្ឋាភិបាល ដើម្បីបង្កើនប្រសិទ្ធិភាព ផលសម្រេចបាន និងការចែកចាយ សេវាកម្ម " ។[1]

រដ្ឋាភិបាលអេឡិចត្រូនិកមិនមែនជាព្រឹត្តិការណ៍ទោលក្នុងអំឡុងពេលដ៏ខ្លីឡើយ ប៉ុន្តែគឺជាដំណើរវិវត្តន៍ រយៈពេលវែងនៃការប្រែក្លាយរដ្ឋាភិបាលដើម្បីផ្តោតលើសេវាប្រជាពលរដ្ឋ ។ ដូច្នេះ ជាការចាំបាច់ក្នុងការបង្កើតផែនទីបង្ហាញផ្លូវរដ្ឋាភិបាលអេឡិចត្រូនិកកម្រិតខ្ពស់ (ការរចនាពីថ្នាក់លើទៅថ្នាក់ក្រោម) ដោយ មានផែនការអនុវត្តលម្អិតពីថ្នាក់ក្រោមទៅថ្នាក់លើវិញ ។ ម៉ូឌុល ២ នៅក្នុងស៊េរីម៉ូឌុលកម្មវិធីសិក្សាអំពីសារសំខាន់នៃបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា *ICT សម្រាប់ថ្នាក់ដឹកនាំ រដ្ឋាភិបាល ពិភាក្សាអំពីចក្ខុ វិស័យ និងយុទ្ធសាស្ត្រសម្រាប់ការបង្កើតផែនទីបង្ហាញផ្លូវរដ្ឋាភិបាលអេឡិចត្រូនិក ។ ម៉ូឌុលនេះពិភាក្សាអំពីការអនុវត្តពីថ្នាក់ក្រោមទៅថ្នាក់លើ ។*

គោលដៅរបស់រដ្ឋាភិបាលអេឡិចត្រូនិក គឺការចែកចាយសេវារដ្ឋាភិបាលអោយកាន់តែប្រកបដោយ ប្រសិទ្ធភាពដល់ប្រជាពលរដ្ឋ។ ជាទូទៅ មានសេវាកាន់តែច្រើននៅលើអ៊ីនធឺណិត និង ការរីកដុលដាលឡើងនៃការប្រើប្រាស់សេវាទាំងនោះកាន់តែច្រើនឡើងៗ ហើយក៏មានផលប៉ះពាល់នៃរដ្ឋាភិបាលអេឡិច- ត្រូនិកកាន់តែច្រើនផងដែរ។ ដូច្នេះរដ្ឋាភិបាលអេឡិចត្រូនិកតម្រូវអោយមានចំនួនប្រជាពលរដ្ឋអេឡិច- ត្រូនិកនិងអាជីវកម្មអេឡិចត្រូនិកសំខាន់ៗដ៏ច្រើន ដើម្បីបង្កើតអោយមានឥទ្ធិពលប្រកបដោយ និរន្តភាព ហួសពី ប្រសិទ្ធផល និងតម្លាភាពរបស់រដ្ឋាភិបាល ។ ទោះបីជាយ៉ាងណាក៏ដោយ ការសម្រេចអោយបាននូវចំនួនប្រជាពលរដ្ឋអេឡិចត្រូនិកនិង អាជីវកម្មអេឡិចត្រូនិកសំខាន់ៗដ៏ច្រើននេះមិនមែនជាការងាយស្រួល ឡើយ ។ ជាឧទាហរណ៍ ការសិក្សារបស់ធនាគារពិភពលោកអំពីសារសំខាន់នៃការបង្កើត សេវាអ៊ីនធឺណិត បន្ថែមដល់ប្រជាពលរដ្ឋអេឡិចត្រូនិក និង អាជីវកម្មអេឡិចត្រូនិកបានអោយដឹងថា ៖

> ប្រទេសជាច្រើនដែលផ្តួចផ្តើមកម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិករយៈពេល ៥ ដល់១០ ឆ្នាំ មុនទើបតែដឹងថា កម្រិតនៃការចូលរួមជាសាធារណៈ និងការប្រើប្រាស់សេវារដ្ឋាភិបាលអេឡិចត្រូនិកនៅតែមានកម្រិតទាបនៅឡើយ ទោះបីជាមានការវិនិយោគសាធារណៈ ប្រកបដោយនិរន្តភាពទៅលើផ្នែកផ្គត់ផ្គង់ដែលមាន ជោគជ័យក្នុងការបង្កើតអោយមានសេវារដ្ឋាភិបាលតាមប្រព័ន្ធអ៊ីនធឺណិតក៏ដោយ ។[2]

រដ្ឋាភិបាលអេឡិចត្រូនិកនឹងទទួលជោគជ័យតែក្នុងករណីដែលមានតម្រូវការ និងការផ្គត់ផ្គង់ច្រើន រដ្ឋាភិបាលអេឡិចត្រូនិក ពីប្រជាជនភាគច្រើនប៉ុណ្ណោះ ។ តម្រូវការទាំងនេះមួយចំនួន នឹងចេញមកពីការយល់ដឹងប្រសើរជាងមុននៃឱកាសដែលផ្តល់ ដោយការចែកចាយសេវារដ្ឋាភិបាលកាន់តែប្រសើរ និង រហ័សជាងមុន ។ ប្រជាពលរដ្ឋ និងអាជីវកម្មក៏ចាំបាច់ត្រូវមានការ ជំរុញទឹកចិត្ត អោយប្រើប្រាស់សេវារដ្ឋាភិបាលអេឡិចត្រូនិកតាមរយៈការផ្តល់ខ្លឹមសារដែលមានការចាប់អារម្មណ៍ពាក់ព័ន្ធនឹងឌីជីថលងាយស្រួលប្រើប្រាស់ ។ ជាពិសេស ចាំបាច់ត្រូវអនុវត្តកត្តាខាងក្រោមដើម្បីបង្កើនតម្រូវការ និងការផ្គត់ផ្គង់សេវារដ្ឋាភិបាលអេឡិចត្រូនិក ។

- បង្កើតហេដ្ឋារចនាសម្ព័ន្ធចែកចាយសេវាទូទៅតាម window រួម ដែលមានបណ្តាញច្រើនដែលរួមមាន ដូចជាមជ្ឈមណ្ឌលសេវាប្រជាពលរដ្ឋ "រូបវន្ត" និងចំណុចលទ្ធភាពទទួលបានជាសាធារណៈ ដូចជាទូរមណ្ឌល មជ្ឈមណ្ឌល ទូរស័ព្ទ ច្រកបណ្តាញវែបសាយត៍ និងច្រកបណ្តាញទូរស័ព្ទចល័ត ។
- អនុវត្តវិធានការដែលនឹងបង្កើនទំនុកចិត្តសាធារណៈនៅក្នុងប្រតិបត្តិការដែលគាំទ្រដោយ ICT និងអន្តរកម្មដទៃទៀត ក្នុងបរិយាកាសឌីជីថល ។
- លើកទឹកចិត្តអោយមានការអភិវឌ្ឍខ្លឹមសារពាក់ព័ន្ធ ទាក់ទាញការចាប់អារម្មណ៍ អោយមានភាព ងាយស្រួលសម្រាប់អ្នកប្រើប្រាស់ និងខ្លឹមសារទូរស័ព្ទចល័តរួមទាំង "កម្មវិធីអ្នកសម្លាប់" និង
- អនុវត្តកម្មវិធីផ្តោតលើការប្រើប្រាស់ និងលទ្ធភាពចំណាយដែលបានកែលម្អនៃខ្លឹមសារអ៊ីនធឺណិត ព្រមទាំងខ្លឹមសារ ទូរស័ព្ទចល័ត និង ICT ។

**កិច្ចការដែលត្រូវអនុវត្ត**

១. កំណត់សេវារដ្ឋាភិបាលអេឡិចត្រូនិកមួយដែលនឹងបង្កើតអោយមានតម្រូវការ និងការផ្គត់ផ្គង់ច្រើនពីប្រជាពលរដ្ឋ និងអាជីវកម្មនៅក្នុងប្រទេសរបស់អ្នក ។ សូមរាយមូលហេតុដែលអ្នកគិតថាសេវានេះនឹងមានការប្រើប្រាស់ច្រើន ។

២. កំណត់សេវារដ្ឋាភិបាលអេឡិចត្រូនិកមួយ ដែលមិនមានការប្រើប្រាស់ច្រើនដូចឧទាហរណ៍ដែលអ្នកលើកឡើងនៅក្នុងចំណុចទី១ ខាងលើ ហើយរាយមធ្យោបាយជាក់លាក់ក្នុងការជំរុញដល់ប្រជាពលរដ្ឋ និងអាជីវកម្មក្នុងប្រទេសរបស់អ្នក ដើម្បីប្រើប្រាស់ ឬចូលរួមក្នុងសេវាកម្មប្រភេទនេះ ។

កម្មវត្ថុទាំងបួនខាងក្រោមនេះ អាចសម្រេចបាន នៅពេលដែលគម្រោងរដ្ឋាភិបាលអេឡិចត្រូនិកត្រូវបាន អនុវត្តប្រកបដោយជោគជ័យ ។

- សេវារដ្ឋាភិបាលតាមអ៊ីនធឺណិត
- រដ្ឋាភិបាលមិនប្រើក្រដាស
- រដ្ឋាភិបាលផ្អែកលើចំណេះដឹង
- រដ្ឋាភិបាលតម្លាភាព

---

[1] Mark Forman, *រដ្ឋាភិបាលអេឡិចត្រូនិក ៖ ការប្រើប្រាស់បច្ចេកវិទ្យាដើម្បីប្រែក្លាយប្រសិទ្ធភាព និងប្រសិទ្ធផលរបស់រដ្ឋាភិបាល (២០០៥) រដ្ឋាភិបាលអេឡិចត្រូនិក ៖ ការប្រើប្រាស់បច្ចេកវិទ្យាដើម្បីប្រែក្លាយប្រសិទ្ធភាព និងប្រសិទ្ធផលរបស់រដ្ឋាភិបាល (២០០៥) ៤* http://siteresources.worldbank.org/INTEDEVELOPMENT/Resources/FormanEgov(6_05).ppt.

[2] ធនាគារពិភពលោក, រដ្ឋាភិបាលអេឡិចត្រូនិកសម្រាប់ទាំងអស់គ្នា - ការពិនិត្យមើលឡើងវិញទៅលើបទពិសោធន៍អន្តរជាតិដោយមានការកែលម្អ ដំណើរការ សាធារណៈ តម្រូវការ និងការចូលរួមក្នុងសេវារដ្ឋាភិបាលអេឡិចត្រូនិក ៖ ដំណើរឆ្ពោះទៅកាន់យុទ្ធសាស្ត្របញ្ចូលឌីជីថលសម្រាប់ប្រទេសកាសាស្ថាន សេចក្តី ជូនដំណឹងអំពីការប្រឹក្សាបច្ចេកទេសអនុវត្តរបស់រដ្ឋាភិបាលអេឡិចត្រូនិក ISG (សេចក្តីព្រាងកែសម្រួល ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦) ១១ ។

ដើម្បីសម្រេចគោលបំណងទាំងបួននេះ ចាំបាច់ត្រូវបង្កើតរដ្ឋាភិបាលអេឡិចត្រូនិកនៅកម្រិតសហព័ន្ធ រដ្ឋ និងមូលដ្ឋាន ។ មានភារកិច្ចបីសំខាន់នៅកម្រិតរដ្ឋាភិបាលទាំងនេះ ពោលគឺ ក) នវានុវត្តន៍សេវា ប្រជាពលរដ្ឋ (G2C) ខ) នវានុវត្តន៍សេវាអាជីវកម្ម (G2B) និង គ) នវានុវត្តន៍របៀបធ្វើការងាររបស់ រដ្ឋាភិបាល (G2G) ។

ការពិភាក្សាកម្មវិធី ICT ខាងក្រោមសម្រាប់នវានុវត្តន៍សេវាប្រជាពលរដ្ឋ (G2C) សេវាអាជីវកម្ម (G2B) និងរបៀបធ្វើការងាររបស់រដ្ឋាភិបាល (G2G) ប្រើប្រាស់ផែនការរដ្ឋាភិបាលអេឡិចត្រូនិករបស់ សាធារណរដ្ឋកូរ៉េ ជាករណីបង្ហាញចម្បង ។ សាធារណរដ្ឋកូរ៉េជាប់ចំណាត់លេខ ៦ ក្នុងលិបិក្រមត្រៀមលក្ខណៈរបស់រដ្ឋាភិបាលអេឡិចត្រូនិកនៃអង្គការសហប្រជាជាតិឆ្នាំ២០០៨ ដែលជាធាតុផ្សំនៃ លិបិក្រម វិធានការលើបណ្តាញវ៉េបសាយត៍ លិបិក្រមហេដ្ឋារចនាសម្ព័ន្ធ ទូរគមនាគមន៍ និងលិបិក្រមធនធាន មនុស្ស ។ សាធារណរដ្ឋកូរ៉េ ក៏វាស់វែងទិដ្ឋភាព "រដ្ឋាភិបាល–ទៅ–ប្រជាពលរដ្ឋ" (G2C) និង "រដ្ឋាភិបាល–ទៅ–រដ្ឋាភិបាល" (G2G) របស់រដ្ឋាភិបាលអេឡិចត្រូនិក ។ ការវាស់ស្ទង់ឆ្នាំ ២០០៨ ក៏មានធាតុផ្សំមួយចំនួននៃ "រដ្ឋាភិបាល–ទៅ–អាជីវកម្ម" ។

### ១.២ នវានុវត្តន៍សេវាប្រជាពលរដ្ឋ និងសេវាអាជីវកម្ម (ការចែកចាយការិយាល័យមុខ)

សេវា G2C រួមមានការផ្សព្វផ្សាយព័ត៌មានដល់សាធារណជន និងសេវាប្រជាពលរដ្ឋមូលដ្ឋាន ចំណែកឯ ប្រតិបត្តិការ G2B មានសេវាផ្សេងៗគ្នាដែលផ្លោះប្តូរគ្នារវាងរដ្ឋាភិបាល និងសហគមន៍អាជីកម្ម ។

សេវាគាំទ្រដោយ ICT ឬ G2C អេឡិចត្រូនិកត្រូវបានកំណត់ដោយប្រព័ន្ធចែករំលែកព័ត៌មានទូទាំង រដ្ឋាភិបាល និងកម្មវិធីផ្អែកតាមប្រព័ន្ធអ៊ីនធឺណិតថ្មីដែលអនុញ្ញាតអោយប្រជាពលរដ្ឋទទួលបានព័ត៌មាន និងសេវាផ្សេងដែលប្រើប្រាស់ ច្រកបណ្តាញ អ៊ីនធឺណិត window តែមួយ ។ ច្រកបណ្តាញទាំងនេះ អាចផ្តល់សេវាប្រជាពលរដ្ឋដូចខាងក្រោម ៖

- ដំណើការ និងការចេញការអនុញ្ញាត/ច្បាប់អនុញ្ញាត និងលិខិតបញ្ជាក់ផ្សេងៗ
- ព័ត៌មានស្តីពីសេចក្តីជូនដំណឹងអំពីច្បាប់/រដ្ឋបាល និងច្បាប់ពាក់ព័ន្ធ
- សេវាបង់ថ្លៃប្រើប្រាស់ ដែលរួមមានការសងថ្លៃពន្ធដារ និងការបង់ថ្លៃសុខុមាលភាពសង្គម
- ឱកាសក្នុងការចូលរួមក្នុងរដ្ឋបាលរដ្ឋាភិបាលដោយស្មើអោយមានការយកចិត្តទុកដាក់ជាសាធារណៈ និងការបោះឆ្នោត អេឡិចត្រូនិក

ដើម្បីបង្កើតច្រកបណ្តាញប្រជាពលរដ្ឋ និងប្រព័ន្ធចែករំលែកព័ត៌មានជាសាធារណៈ មូលដ្ឋានទិន្នន័យក្នុងការចុះបញ្ជីស្នាក់នៅ អចលនវត្ថុ យានយន្ត សារពើពន្ធ និងការធានារ៉ាប់រង នឹងត្រូវបានធ្វើសមាហរណកម្ម ។

ការចែកចាយសេវា G2B អេឡិចត្រូនិក ប្រើប្រាស់ទម្រង់សេវា window ច្រកចេញចូលតែមួយសម្រាប់អាជីវកម្ម ។ សេវានេះរួមមានកិច្ចការរដ្ឋបាលស៊ីវិលសាជីវកម្ម ព័ត៌មានឧស្សាហកម្ម និងសេវាប្រតិបត្តិការអេឡិចត្រូនិក ដូចជាលទ្ធកម្ម ការដេញថ្លៃ និងការផ្តល់រង្វាន់ ព្រមទាំងសេវាចំណាយលើសារពើពន្ធ និងថ្លៃសេវាសាធារណៈផ្សេងៗ ។ ការចែកចាយ G2B អេឡិចត្រូនិកប្រកបដោយប្រសិទ្ធភាពតម្រូវអោយមានកម្មវិធី ICT ដូចខាងក្រោម ៖

- ប្រព័ន្ធសមាហរណកម្មលទ្ធកម្ម – ឧទាហរណ៍ប្រព័ន្ធលទ្ធកម្មរដ្ឋាភិបាលច្រកតែមួយដែលដំណើរការពាក់ព័ន្ធនឹងលទ្ធកម្មទាំងឡាយដូចជាការចុះបញ្ជី ការផ្គត់ផ្គង់ កិច្ចសន្យា និងការបង់ថ្លៃធ្វើឡើងតាមរយៈអ៊ីនធឺណិត ។
- ប្រព័ន្ធគយអេឡិចត្រូនិកដែលនឹងធ្វើអោយរដ្ឋបាលគយកាន់មានប្រសិទ្ធិភាពក្នុងឧស្សាហកម្មនាំចេញនាំចូល និងបង្កើត អោយមានការទប់ស្កាត់ការរត់ពន្ធខុសច្បាប់ប្រកបដោយប្រសិទ្ធភាព
- ពាណិជ្ជកម្មអេឡិចត្រូនិចគាំទ្រដល់ការទិញ និងលក់ទំនិញ និងសេវាកម្មតាមអ៊ីនធឺណិត

កម្មវិធីទាំងនេះ នឹងមានពិភាក្សាលម្អិតបន្ថែមក្នុងផ្នែកទី២ ។

**ធ្វើតេស្តខ្លួនឯង**

ដោយប្រើនិយមន័យដែលត្រូវបានផ្តល់អោយខាងលើ ព្រមជាមួយនឹងចំណេះដឹងផ្ទាល់ខ្លួនអំពីសេវារដ្ឋាភិបាល ចូរសម្រេចចិត្តថាតើចំណុចខាងក្រោមណាមួយគឺជាឧទាហរណ៍នៃសេវាG2C និងសេវា G2B ។

១. សេវាសារពើពន្ធ ដូចជាការដាក់ឯកសារ និងការចំណាយលើការប្រកាសពន្ធ

២. សេវាលទ្ធកម្ម រួមមានការដាក់សំណើ ការដេញថ្លៃ និងការផ្តល់រង្វាន់

៣. សេវាធានារ៉ាប់រងសង្គម ៖ វេជ្ជសាស្ត្រ ប្រាក់សោធននិវត្តន៍ជាតិ ធានារ៉ាប់រងសំណងការងារ និងឧបទ្ទវហេតុ

៤. ការចុះបញ្ជី និងការតាមដានប្រជាពលរដ្ឋតាំងទីលំនៅ

៥. ការចុះបញ្ជីអាជីវកម្ម

៦. ការគ្រប់គ្រងព័ត៌មានអចលនវត្ថុ

៧. ប្រព័ន្ធរដ្ឋបាលយានយន្ត

### ១.៣ នវានុវត្តន៍របៀបធ្វើការងាររបស់រដ្ឋាភិបាល (G2G) (ការចែកចាយនៅការិយាល័យក្រោយ)

ការចែកចាយ G2G អេឡិចត្រូនិកមានគោលបំណងកែទម្រង់ដំណើរការការងារផ្ទៃក្នុងរបស់រដ្ឋាភិបាល ដើម្បីបង្កើនប្រសិទ្ធផល ។ ជាងនេះទៅទៀត ការកែទម្រង់ដំណើរការការងាររដ្ឋាភិបាលដែលប្រើប្រាស់ ICT នេះ រំពឹងថាមានលទ្ធផលដូចខាងក្រោម ៖

- ប្រព័ន្ធរាយការណ៍របស់រដ្ឋាភិបាលកណ្តាល និងមូលដ្ឋាន គឺមានលក្ខណៈពាក់ព័ន្ធគ្នាដែលជាលទ្ធផល នៃសុក្រឹត្យភាពដែលមានការកើនឡើង ។
- មានការចែករំលែកព័ត៌មានក្នុងចំណោមទីភ្នាក់ងារក្នុងទម្រង់ជាការចែករំលែកមូលដ្ឋានទិន្នន័យ ។ ការអនុវត្តបែបនេះ អាចបង្កើននូវប្រសិទ្ធផលការងារ ។
- ទីភ្នាក់ងាររដ្ឋាភិបាល ផ្លោះប្តូរគំនិត និងធនធាន ។
- ការធ្វើសេចក្តីសម្រេចចិត្តលើកិច្ចសហប្រតិបត្តិការ ត្រូវបានធ្វើឡើងតាមរយៈការធ្វើសន្និសីទតាម វីដេអូ ។

ការប្រែក្លាយឯកសារជាទម្រង់ឌីជីថលដែលដំណើរការក្នុងទីភ្នាក់ងាររដ្ឋាភិបាល និងដំណើរការផ្លោះទៅរក ប្រតិបត្តិការរដ្ឋាភិបាលមិនប្រើក្រដាស ជាគំនិតផ្តួចផ្តើមគន្លឹះ G2C ។ ការផ្លោះប្តូរឯកសារអេឡិចត្រូនិក ត្រូវបានរំពឹងថានឹងធានាប្រសិទ្ធផល សន្តិសុខ និងទំនុកចិត្តក្នុងផ្នែករដ្ឋបាល ។

ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួននៃសេវា G2G នៅសាធារណរដ្ឋកូរ៉េ ។

**ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុថ្នាក់ជាតិដែលបានដាក់បញ្ចូល** ៖ ការគ្រប់គ្រងទាន់ពេលវេលានៃសកម្មភាព សារពើពន្ធថ្នាក់ជាតិតាមរយៈការធ្វើអន្តរកម្មប្រព័ន្ធហិរញ្ញវត្ថុ ២៣ ដែលកំពុងប្រតិបត្តិការឯករាជ្យក្នុង ទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗ ។

**ប្រព័ន្ធព័ត៌មានរដ្ឋាភិបាលអេឡិចត្រូនិកមូលដ្ឋាន** ៖ ព័ត៌មានីយកម្មនៃកិច្ចការរដ្ឋបាលរដ្ឋាភិបាលមូលដ្ឋាន ២៣២ ដូចជា ការចុះបញ្ជីស្នាក់នៅ និងអចលនវត្ថុ ហិរញ្ញវត្ថុ និងពន្ធនៅកម្រិតក្រុង ជនបទ និងស្រុក ។

**ប្រព័ន្ធព័ត៌មានអប់រំ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក** ៖ បណ្តាញព័ត៌មានទូទាំងប្រទេសក្នុងចំណោមសាលារៀន ការិយាល័យអប់រំខេត្ត និងអនុទីភ្នាក់ងាររបស់ខ្លួន និងក្រសួងអប់រំ និងអភិវឌ្ឍន៍ធនធានមនុស្ស ។

**អន្តរផ្លាស់ប្តូរឯកសារអេឡិចត្រូនិករបស់រដ្ឋាភិបាល** ៖ ដំណើរការអេឡិចត្រូនិក រួមមានការរៀបចំការអនុម័ត ការចែកចាយ និងការរក្សាទុកឯកសាររដ្ឋាភិបាលទាំងអស់ ។

ប្រព័ន្ធ G2C តម្រូវអោយមានចំណុចដូចខាងក្រោម ៖

- ការបង្កើតអោយមានដំណើរការការងារអេឡិចត្រូនិក
- ដំណើការឯកសារអេឡិចត្រូនិក
- ប្រព័ន្ធគ្រប់គ្រងចំណេះដឹង

ចំណុចទាំងនេះនឹងត្រូវពិភាក្សាលម្អិតបន្ថែមនៅក្នុងផ្នែកទី២ និងទី៣ ។

**កិច្ចការដែលត្រូវអនុវត្ត**

កំណត់ទិដ្ឋភាពនៃដំណើរការការងាររបស់ទីភ្នាក់ងារដែលត្រូវធ្វើការកែលម្អ ។ បង្ហាញអំពីរបៀបដែល ICTs អាចត្រូវបាន ប្រើប្រាស់ដើម្បីកែលម្អដំណើរការការងាររបស់ភ្នាក់ងាររបស់អ្នក ។

### ១.៤ អត្ថប្រយោជន៍នៃការអនុវត្ត ICT ប្រកបដោយជោគជ័យក្នុងរដ្ឋាភិបាល

តារាងទី ១ បង្ហាញអំពីចំណុចដែលត្រូវពិចារណាដើម្បីក្លាយជាការផ្លាស់ប្តូរដ៏មានអត្ថប្រយោជន៍ចំពោះដំណើរការការងាររបស់ រដ្ឋាភិបាលដែលបានមកពីកំណែទម្រង់គាំទ្រ ICT ដ៏មានប្រសិទ្ធភាព ។

*តារាងទី ១ ៖ ការផ្លាស់ប្តូរនៅក្នុងដំណើរការការងាររបស់រដ្ឋាភិបាលចេញពីរដ្ឋាភិបាលអេឡិចត្រូនិក*

| **ចេញពី** | **មកជា** |
|---|---|
| ដំណើរការការងាររបស់រដ្ឋាភិបាលដែលប្រើក្រដាស | ដំណើរការឯកសារតាមប្រព័ន្ធអេឡិចត្រូនិក |

| នីតិវិធីដឹកនាំដោយនាយកដ្ឋាន | នីតិវិធីដឹកនាំដោយសេវាកម្ម |
|---|---|
| មានចំណុចទំនាក់ទំនងរដ្ឋាភិបាលច្រើន និងការធ្វើដំណើរ ផ្ទាល់ខ្លួន (មុខទល់នឹងមុខ) មកកាន់មន្ត្រីរដ្ឋាភិបាល | មានចំណុចទំនាក់ទំនងតែមួយ និងដំណើការតាមប្រព័ន្ធ អ៊ីនធឺណិតដែលធ្វើដំណើរផ្ទាល់ខ្លួនទៅកាន់ការិយាល័យ រដ្ឋាភិបាលដែលមិនចាំបាច់ |
| ការគ្រប់គ្រងធនធានព័ត៌មានកម្រិតនាយកដ្ឋាន ដែលមាន ការចម្លងច្រើន និងមានភាពខ្វះខ្លាយក្នុងការប្រើបុគ្គលិកក្នុងចំណោម នាយកដ្ឋានផ្សេងៗ ។ | ធនធានព័ត៌មានទូទាំងរដ្ឋាភិបាលដោយប្រើប្រាស់បទដ្ឋានទូទៅ និងកំណត់ប្រភេទដោយការរួមបញ្ចូលតែមួយ |

ការផ្លាស់ប្តូរទាំងនេះ បង្កើនប្រសិទ្ធផល តម្លាភាព និងទំនួលខុសត្រូវក្នុងរដ្ឋាភិបាលតាមរយៈការកាត់ បន្ថយរយៈពេលប្រតិបត្តិការ និងការដកចេញនូវស្រទាប់ការិយាធិបតេយ្យដែលជាន់គ្នា ។ លើសពីនេះ ទៀត រដ្ឋាភិបាលអេឡិចត្រូនិក ជួយកសាងនូវទំនុកចិត្តរវាងរដ្ឋាភិបាល និងពលរដ្ឋ ពីព្រោះរដ្ឋាភិបាល អេឡិចត្រូនិកនេះ បង្កើនអន្តរកម្មដោយផ្ទាល់រវាង ការិយាល័យរដ្ឋាភិបាល និងប្រជាពលរដ្ឋ ព្រមទាំង បង្កើតជាព័ត៌មានដូចគ្នាជាសកល និងអាចរកបានដោយសេរី ។

ជាចុងក្រោយ ការណែនាំ ICT ធ្វើអោយកំណែទម្រង់អភិបាលកិច្ចមានលក្ខណៈកាន់តែងាយស្រួល ។ នៅពេលដែលការប្រើប្រាស់ ICT បានរាលដាលយ៉ាងឆាប់រហ័សទូទាំងសង្គមអាស៊ី អង្គការរដ្ឋាភិបាល មជ្ឈការ និងការិយាធិបតេយ្យ ប្រឈមនឹងតម្រូវការថ្មីៗ និងសម្ពាធប្រកួតប្រជែងពីប្រជាពលរដ្ឋ និងសហគមន៍អាជីវកម្ម ។ ជាទូទៅ គម្រោងរដ្ឋាភិបាល អេឡិចត្រូនិកបង្កើនទស្សនាទានក្នុងចំណោម ប្រជាពលរដ្ឋ និងអាជីវកម្មដែលរដ្ឋាភិបាលកំពុងធ្វើទំនើបកម្ម និងបន្តឆ្ពោះទៅមុខ ។

| **សំណួរត្រិះរិះ** |
|---|
| ក្នុងបរិបទរបស់អ្នក តើការផ្លាស់ប្តូរទាំងអស់ដែលបានមកដោយសារ កម្មវិធី ICT ក្នុងរដ្ឋាភិបាល មានអត្ថប្រយោជន៍ដែរឬទេ?តើមានឱកាសដែរឬទេនៅពេលដែលគំនិតផ្តួចផ្តើមរដ្ឋាភិបាល អេឡិចត្រូនិក ត្រូវបាន ប្រជាពលរដ្ឋ មិនទទួលស្គាល់ក្នុងរបៀប វិជ្ជមាន? សូមរៀបរាប់អំពីឱកាសទាំងនេះ ។ |

**១.៥ កត្តាជោគជ័យសំខាន់ៗ**

ក្នុងការអនុវត្តរដ្ឋាភិបាលអេឡិចត្រូនិក កត្តាសំខាន់ៗដើម្បីទទួលបានជោគជ័យ អាចត្រូវបានបែងចែកជា ប្រាំក្រុមចម្បងៗ ៖

***រូបភាពទី ១. កត្តាជោគជ័យសំខាន់ៗក្នុងការអនុវត្តរដ្ឋាភិបាលអេឡិចត្រូនិក***

(ប្រភព ៖ Soh Bong Yu "រដ្ឋាភិបាលអេឡិចត្រូនិករបស់ប្រទេសកូរ៉េ ៖ របៀបដែលយើងកំពុងធ្វើការជាមួយរដ្ឋាភិបាលអេឡិចត្រូនិក" (បទបង្ហាញ KADO), ២៥, https://www.kado.or.kr/koil/bbs/board_view.asp?config_code=362&offset=0&board_code=3246)




**ចក្ខុវិស័យ កម្មវត្ថុ និងយុទ្ធសាស្ត្រ**

ផែនការដែលមានរយៈពេលវែងហៅថា ″ចក្ខុវិស័យ″ ហើយយុទ្ធសាស្ត្រ មានសារសំខាន់ណាស់ក្នុងការ អនុវត្តរដ្ឋាភិបាលអេឡិចត្រូនិក ។ ការងារដ៏ធំរួមមួយមិនអាចដោះស្រាយក្នុងពេលតែមួយបានឡើយ ។ វិធីសាស្ត្រដែលកាន់តែមានប្រសិទ្ធភាពគឺត្រូវគិតអោយបានវែងឆ្ងាយ(ជាការរៀបចំពីថ្នាក់លើទៅ
ថ្នាក់ក្រោម) ប៉ុន្តែ ការអនុវត្តវិញគឺគេត្រូវចាប់ផ្តើមពី កិច្ចការតូចៗ និងកំណត់អាទិភាពការងារជាមុនសិន (ពីថ្នាក់ក្រោមទៅថ្នាក់លើ) ។

សរុបសេចក្តីមក រដ្ឋាភិបាលអេឡិចត្រូនិកដែលប្រកបដោយជោគជ័យ ចាំបាច់ត្រូវមាន ៖

- ចក្ខុវិស័យច្បាស់លាស់របស់អ្នកដឹកនាំ
- ការគាំទ្រយ៉ាងពេញទំហឹងពីប្រជាពលរដ្ឋ
- ការរៀបចំរបៀបវារៈ

### ច្បាប់ និងបទបញ្ញត្តិ

ជាប្រការមួយដ៏សំខាន់ដែលត្រូវមានផែនការពេលវេលា និងកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រាន់សម្រាប់ការ ផ្លាស់ប្តូរប្រព័ន្ធច្បាប់ដែលទាមទារអោយមានការគាំទ្រដល់ការអនុវត្តដំណើរការថ្មីៗ ។ ច្បាប់ខាងក្រោមនេះចាំបាច់ត្រូវបង្កើតឡើងសម្រាប់ រដ្ឋាភិបាលអេឡិចត្រូនិក ដើម្បីទទួលបានជោគជ័យចំពោះ ៖

- ច្បាប់ស្តីពីសិទ្ធិឯកជន និងបញ្ហាដែលពាក់ព័ន្ធ
- ច្បាប់ពាក់ព័ន្ធនឹងការផ្លាស់ប្តូរដំណើរការអាជីវកម្ម និងប្រព័ន្ធព័ត៌មាន
- ច្បាប់ពាក់ព័ន្ធនឹងស្ថាប័ត្យកម្មបច្ចេកវិទ្យាព័ត៌មានរបស់រដ្ឋាភិបាល និងការបង្កើតមជ្ឈមណ្ឌលកុំព្យូទ័រដែលត្រូវបានធ្វើ សមាហរណកម្ម

### រចនាសម្ព័ន្ធអង្គភាព

កិច្ចខិតខំប្រឹងប្រែងដែលចាំបាច់ត្រូវមាននៅក្នុងចំណុចនេះ មិនគួរត្រូវបានមើលរំលងឡើយ ។ ការរៀបចំ រចនាសម្ព័ន្ធអង្គភាពឡើងវិញជាធម្មតាត្រូវមានកិច្ចខិតខំប្រឹងប្រែងសរុបរហូតដល់ ៣០ទៅ ៥០ភាគរយ ។ ការផ្លាស់ប្តូររចនាសម្ព័ន្ធអង្គភាព ចាំបាច់ត្រូវមានផែនការ និងការអនុវត្តអោយបានល្អប្រសើរក្នុងលក្ខណៈ ជាប្រព័ន្ធ ។

ខាងក្រោមនេះ គឺជាចំណុចសំខាន់ៗដែលមានឥទ្ធិពលទៅលើការផ្លាស់ប្តូរអង្គភាព ៖

- ភាពជាអ្នកដឹកនាំដ៏ខ្លាំងដែលមានការប្តេជ្ញាចិត្ត
- ការធ្វើផែនការ – ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន និងការគ្រប់គ្រងការផ្លាស់ប្តូរ
- ការរៀបចំផែនការថវិកា និងការអនុវត្តផែនការថវិកា
- ការសម្របសម្រួល និងសហប្រតិបត្តិការ
- ការពិនិត្យតាមដាន និងការវាស់វែងសមិទ្ធកម្ម
- ភាពជាដៃគូរដ្ឋាភិបាល–វិស័យឯកជន–ប្រជាពលរដ្ឋ

### ដំណើរការអាជីវកម្ម

របៀបនៃការធ្វើអាជីវកម្មដែលកំពុងអនុវត្ត អាចនឹងមិនមែនជារបៀបសមស្រប ឬមានប្រសិទ្ធភាពបំផុត ដែលមិនអាចខ្វះបានឡើយ ។ មធ្យោបាយមួយក្នុងចំណោមមធ្យោបាយនវានុវត្តន៍ដំណើរការអាជីវកម្ម គឺវិស្វកម្មដំណើរការអាជីវកម្មឡើងវិញ (BPR) ។ BPR ពាក់ព័ន្ធនឹងការរៀបចំលំហូរការងារឡើងវិញ នៅក្នុង ឬរវាងកម្រិតនាយកដ្ឋាន ដើម្បី បង្កើនប្រសិទ្ធផលដំណើរការ (ឧទាហរណ៍ ៖ ដើម្បីលុបបំបាត់អប្រសិទ្ធផលក្នុងដំណើរការការងារ)

### បច្ចេកវិទ្យាព័ត៌មាន

បច្ចេកវិទ្យាព័ត៌មានមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ។ កត្តាដែលត្រូវពិចារណានៅពេលជ្រើសរើស បច្ចេកវិទ្យា និង ពាណិជ្ជករគឺ ៖

- កម្រិតនៃបច្ចេកវិទ្យាកម្មវិធីដែលត្រូវការជាចាំបាច់
- ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ
- សមត្ថភាពក្នុងការសហការ
- បមាណីយកម្ម (Standardization)
- សមត្ថភាពបច្ចេកទេស និងធនធានមនុស្ស

**កិច្ចការដែលត្រូវអនុវត្ត**

ប្រសិនបើប្រទេសរបស់អ្នកមានផែនការរដ្ឋាភិបាលអេឡិចត្រូនិក សូមពិនិត្យឡើងវិញនូវផែនការដែល ប្រើប្រាស់បញ្ជី ត្រួតពិនិត្យនៃកត្តាជោគជ័យសំខាន់ៗដែលត្រូវពិភាក្សាក្នុងផ្នែកនេះ ។

### ១.៦ កត្តាហានិភ័យក្នុងការដាក់ពង្រាយរដ្ឋាភិបាលអេឡិចត្រូនិក

គេជឿជាក់ថាជឿថាការអនុវត្តរដ្ឋាភិបាលអេឡិចត្រូនិកក្នុងប្រទេសជាច្រើន មិនបានបំពេញតាមការ រំពឹងទុកខ្ពស់ឡើយ ។ ករណីសិក្សាមួយបានបង្ហាញថា ៣៥ ភាគរយនៃកម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិក ជុំវិញពិភពលោកទទួលបានបរាជ័យ ហើយ ៥០ ភាគរយទទួលបរាជ័យដោយផ្នែក និង ១៥ ភាគរយទៀត ត្រូវបានចាត់ទុកថាទទួលបានជោគជ័យ ។[3]

កត្តានាំទៅរកបរាជ័យនៃការដាក់ពង្រាយរដ្ឋាភិបាលអេឡិចត្រូនិកក្នុងប្រទេសកំពុងអភិវឌ្ឍ រួមមានដូច ខាងក្រោម ៖

- ការខ្វះកិច្ចព្រមព្រៀងនៅក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈ – ការប្រឆាំងផ្ទៃក្នុងដោយរដ្ឋាភិបាល
- ការធ្វើផែនការ និងយុទ្ធសាស្ត្រមិនគ្រប់គ្រាន់ – រដ្ឋាភិបាលអេឡិចត្រូនិកត្រូវណែនាំក្នុងទម្រង់មិន ច្បាស់លាស់ និងគ្មាន លក្ខណៈជាប្រព័ន្ធ
- ធនធានមនុស្សមិនគ្រប់គ្រាន់ – ការកសាងសមត្ថភាពស្ថាប័ន និងមនុស្សមិនគ្រប់គ្រាន់
- អវត្តមានផែនការវិនិយោគ
- ការខ្វះខាតបច្ចេកវិទ្យា និងការផ្គត់ផ្គង់ប្រព័ន្ធ
- បច្ចេកវិទ្យាក្មេងខ្ចី – ការយកចិត្តទុកដាក់ហួសហេតុទៅលើបច្ចេកវិទ្យា ឬការដាក់ពង្រាយបច្ចេកវិទ្យា តម្រង់ទិស
- ការអនុវត្តឆាប់រហ័សដោយគ្មានការសាកល្បង និងរៀបចំបានគ្រប់គ្រាន់

បញ្ហាប្រឈមសំខាន់បំផុត ទទួលស្គាល់ថាគ្មានដំណោះស្រាយណាមួយដែលត្រូវនឹងគ្រប់ស្ថានភាព ទាំងអស់នោះឡើយ ។ អាស៊ី និងប៉ាស៊ីហ្វិកត្រូវបានកំណត់ដោយបរិបទនយោបាយ សេដ្ឋកិច្ច សង្គម និងអភិបាលកិច្ចខុសៗគ្នាជាច្រើនដែលតម្រូវអោយ មានវិធីសាស្ត្រខុសៗគ្នាផងដែរ ។

**កិច្ចការដែលត្រូវអនុវត្ត**

ពិចារណាអំពីគំនិតផ្តួចផ្តើមរដ្ឋាភិបាលអេឡិចត្រូនិក ឬគម្រោងរបស់រដ្ឋាភិបាលរបស់អ្នក ដែលទទួល បានបរាជ័យ ឬសម្រេចបានជោគជ័យតែផ្នែកមួយចំនួន ។ សូមរៀបរាប់អំពីគម្រោង និងពន្យល់អំពី មូលហេតុដែលនាំអោយបរាជ័យ ។

### ១.៧ រដ្ឋាភិបាលអេឡិចត្រូនិកថ្ងៃអនាគត

ការរីកចម្រើនដ៏ឆាប់រហ័សនៅក្នុងផ្នែកបច្ចេកវិទ្យា បានផ្តល់អោយនូវជម្រើសជាច្រើនសម្រាប់ការដាក់ ពង្រាយរដ្ឋាភិបាលអេឡិចត្រូនិក ។ បច្ចេកវិទ្យាថ្មីៗមានសក្តានុពលក្នុងការផ្តល់នូវសេវាកម្មប្រសើរជាមុន ដល់ប្រជាពលរដ្ឋ និងអាជីវកម្មនានា ។ ដូច្នេះ ដំណាក់កាលនៃរដ្ឋាភិបាលអេឡិចត្រូនិក អាចកំណត់ដូច បានបង្ហាញក្នុងតារាងទី ២ ។

*តារាងទី២. ដំណាក់កាលអភិវឌ្ឍរដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ*

| **កុំព្យូទ័រភាវូនីយកម្ម (ជំហានទី ១)** | **អ៊ីនធឺណិត (ជំហានទី ២)** | **សមាហរណកម្ម (ជំហានទី ៣)** | **មានគ្រប់ទីកន្លែង/រលូន (ជំហានទី ៤)** |
|---|---|---|---|
| *ឆ្នាំ១៩៨០ ដល់ដើមឆ្នាំ១៩៩០* | *ពាក់កណ្តាលឆ្នាំ១៩៩០ ដល់ឆ្នាំ២០០០* | *ឆ្នាំ២០០០ ដល់ឆ្នាំ២០០៧* | *អំឡុងឆ្នាំ២០១០* |
| ស្វ័យប្រវត្តិកម្ម | បណ្តាញ | សម្រេចគោលដៅរួម | បង្កប់ |
| មូលដ្ឋានទិន្នន័យទៅមូលដ្ឋានទិន្នន័យ | កុំព្យូទ័រទៅកាន់កុំព្យូទ័រ | មនុស្សទៅមនុស្ស | វត្ថុទៅវត្ថុ |
| បែងចែកសេវាកម្ម | សេវាលើបណ្តាញអ៊ីនធឺណិត | សេវាច្រកចេញចូលតែមួយ | សេវារលូន/មិនអាចមើលឃើញ |

ប្រភព ៖ នាយកដ្ឋានយុទ្ធសាស្ត្របច្ចេកវិទ្យា *យុទ្ធសាស្ត្របច្ចេកវិទ្យា និងរដ្ឋាភិបាលអេឡិចត្រូនិករបស់ ប្រទេសកូរ៉េ (ទីក្រុងសេអ៊ូល ៖ ទីភ្នាក់ងារកុំព្យូទ័រភាវូបនីយកម្មជាតិឆ្នាំ២០០៦)*[4]

ក្នុងករណីសាធារណរដ្ឋកូរ៉េ ដំណាក់កាលទី ១ ដល់ទី ៣ ត្រូវបានបញ្ចប់ក្នុងឆ្នាំ២០០៧ ។ បច្ចេកវិទ្យាថ្មីៗ ដូចជាបណ្តាញបំលែង Broadband និងបច្ចេកវិទ្យាមានគ្រប់ទីកន្លែងកំពុងដឹកនាំទៅរកការអភិវឌ្ឍបន្ថែម ទៀត (ដំណាក់កាលទី ៤) ។ ការអភិវឌ្ឍថ្មីៗក្នុងវិស័យ ICT ទាំងនេះ នឹងត្រូវពិភាក្សានៅក្នុងម៉ូឌុល ៤ (និន្នាការ ICT សម្រាប់ថ្នាក់ដឹកនាំរដ្ឋាភិបាល) ។ ក្នុងករណីភាគច្រើន រដ្ឋាភិបាលនីមួយៗគួរតែបំពេញ អោយបានដល់ដំណាក់កាលទី៣ ដើម្បីផ្តល់សេវាច្រកចេញចូលតែមួយ ដល់ប្រជាពលរដ្ឋ ។ បន្ទាប់ពី ពេលនោះមក បច្ចេកវិទ្យាថ្មីអាចត្រូវបានអនុម័ត ដើម្បីអោយមានសេវាប្រសើរជាងមុនដល់ ប្រជាពលរដ្ឋ នៅពេលដែលតម្រូវការមានការកើនឡើង ។

---

[3] ទីភ្នាក់ងារសង្គមព័ត៌មានជាតិ "ការតភ្ជាប់អាស៊ីតាមរយៈរដ្ឋាភិបាលអេឡិចត្រូនិក" (វេទិការដ្ឋាភិបាលអេឡិចត្រូនិកអាស៊ីឆ្នាំ ២០០៧ ទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៧) ។

[4] ទីភ្នាក់ងារកុំព្យូទ័រភាវូបនីយកម្មជាតិ (NCA) ត្រូវបានដាក់ឈ្មោះថ្មីជាភ្នាក់ងារសង្គមព័ត៌មានថ្នាក់ជាតិ (NIA) ក្នុងខែតុលា ឆ្នាំ២០០៦ ។

## ២.០. គំរូ យុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវរបស់រដ្ឋាភិបាលអេឡិចត្រូនិក

### ២.១. គំរូរដ្ឋាភិបាលអេឡិចត្រូនិក

អង្គភាពរដ្ឋាភិបាលជាច្រើនបានប្រកាន់យកនូវការធ្វើបដិវត្តន៍ឌីជីថល និងកំពុងដាក់ព័ត៌មាន សាធារណៈ និងសេវារដ្ឋាភិបាលជាច្រើនបែបយ៉ាងនៅលើប្រព័ន្ធអ៊ីនធឺណិតសម្រាប់ភាគីពាក់ព័ន្ធនៃរដ្ឋាភិបាលអេឡិចត្រូនិក ។ ភាគីពាក់ព័ន្ធទាំងនេះ រួមមាន ៖

- ប្រជាពលរដ្ឋ
- អាជីវកម្ម
- បុគ្គលិករដ្ឋាភិបាល
- ក្រសួង មន្ទីរ និងទីភ្នាក់ងាររដ្ឋាភិបាល
- មេដឹកនាំសហជីព
- មេដឹកនាំសហគមន៍ អង្គការមិនរកកម្រៃ
- អ្នកនយោបាយ
- វិនិយោគិនបរទេស
- ផ្សេងៗ

**សំណួរត្រិះរិះ**

1. តើអាចទៅរួចទេ ដែលថាបុគ្គលម្នាក់អាចស្ថិតនៅក្នុងប្រភេទខុសៗគ្នានៃភាគីពាក់ព័ន្ធរបស់រដ្ឋាភិបាល អេឡិចត្រូនិក ?

2. តើអ្នកណាខ្លះ ឬតើក្រុមមនុស្សណាខ្លះ ដែលនឹងស្ថិតនៅក្រោមប្រភេទ “ផ្សេងៗ” ?

Fang[5] កំណត់នូវគំរូចំនួន ៨ នៃរដ្ឋាភិបាលអេឡិចត្រូនិក ស្របទៅតាមប្រភេទនៃអន្តរកម្មរវាងភាគី ពាក់ព័ន្ធ (សូមមើល តារាងទី ៣) ។

***តារាងទី ៣ ៖ គំរូនៃរដ្ឋាភិបាលអេឡិចត្រូនិកផ្អែកតាមប្រភេទអន្តរកម្មរវាងភាគីពាក់ព័ន្ធ***

| **គំរូរដ្ឋាភិបាលអេឡិចត្រូនិក** | **អន្តរកម្មរវាងភាគីពាក់ព័ន្ធ** |
|---|---|
| រដ្ឋាភិបាល–ទៅ–ប្រជាពលរដ្ឋ (G2C) | ការផ្ដល់សេវាសាធារណៈ និងព័ត៌មានតែពីរដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ ។ |
| ប្រជាពលរដ្ឋ–ទៅ–រដ្ឋាភិបាល (C2G) | អនុញ្ញាតអោយមានការផ្លាស់ប្តូរព័ត៌មាន និងការប្រាស្រ័យទាក់ទង រវាង ប្រជាពលរដ្ឋ និងរដ្ឋាភិបាល ។ |
| រដ្ឋាភិបាល–ទៅ–អាជីវកម្ម (G2B) | រួមមានប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក ដែលរដ្ឋាភិបាលផ្ដល់ដល់ អាជីវកម្មនូវប្រភេទព័ត៌មានដែលអាជីវកម្មទាំងនេះត្រូវការដើម្បីធ្វើអាជីវកម្មជាមួយរដ្ឋាភិបាល ។ ឧទាហរណ៍គឺប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិក ។ |
| អាជីវកម្ម–ទៅ–រដ្ឋាភិបាល (B2G) | សំដៅទៅលើការផ្សព្វផ្សាយទីផ្សារផលិតផល និងសេវាដល់រដ្ឋាភិបាល ដើម្បីជួយ រដ្ឋាភិបាលកាន់តែមានប្រសិទ្ធផលតាមរយៈការកែលម្អដំណើរការ អាជីវកម្ម និងការគ្រប់គ្រងកំណត់ត្រាអេឡិចត្រូនិកជាដើម ។ ប្រព័ន្ធលទ្ធកម្ម អេឡិចត្រូនិក គឺជាកម្មវិធីមួយដែលជួយសម្រួលដល់ទាំងអន្តរកម្ម G2B និងទាំង B2G ។ |
| រដ្ឋាភិបាល–ទៅ–បុគ្គលិក (G2E) | រួមមានគំនិតផ្តួចផ្តើម ដែលនឹងជួយសម្រួលដល់ការគ្រប់គ្រងសេវាសាធារណៈ និងការប្រាស្រ័យទាក់ទងផ្ទៃក្នុងជាមួយបុគ្គលិកមន្ត្រីរដ្ឋាភិបាល ។ ឧទាហរណ៍គឺប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធអ៊ីនធឺណិត ។ |
| រដ្ឋាភិបាល–ទៅ–រដ្ឋាភិបាល (G2G) | ផ្ដល់លទ្ធភាពដល់ការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មានតាម ប្រព័ន្ធអេឡិចត្រូនិកនៅក្នុងចំណោមនាយកដ្ឋាន ឬទីភ្នាក់ងាររដ្ឋាភិបាលតាមរយៈមូលដ្ឋានទិន្នន័យរួមបញ្ចូលគ្នា ។ |
| រដ្ឋាភិបាល–ទៅ–អង្គការមិនរកកម្រៃ (G2N) | រដ្ឋាភិបាលផ្ដល់ព័ត៌មានដល់អង្គការមិនរកកម្រៃ គណបក្សនយោបាយ និង អង្គការសង្គម ។ |
| អង្គការមិនរកកម្រៃ–ទៅ–រដ្ឋាភិបាល (N2G) | ផ្ដល់លទ្ធភាពដល់ការផ្លាស់ប្តូរព័ត៌មាន និងការប្រាស្រ័យទាក់ទងរវាងរដ្ឋាភិបាល និងអង្គការមិនរកកម្រៃ គណបក្សនយោបាយ និងអង្គការសង្គម ។ |

ដូច្នេះ គេអាចនិយាយបានថា រដ្ឋាភិបាលអេឡិចត្រូនិកពាក់ព័ន្ធនឹងភាពជាដៃគូពីរប្រភេទ ៖ ភាពជាដៃគូផ្ទៃក្នុងនិង ភាពជាដៃគូខាងក្រៅ (សូមមើលរូបភាពទី ២) ។ ភាពជាដៃគូផ្ទៃក្នុង គឺជាភាពជាដៃគូរវាង និងក្នុងចំណោមមែកធាងនានារបស់រដ្ឋាភិបាល (អង្គនីតិប្រតិបត្តិ អង្គនីតិប្បញ្ញត្តិ និង តុលាការ) ។ ភាពជាដៃគូខាងក្រៅសំដៅទៅលើទំនាក់ទំនងរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ និង អាជីវកម្ម ។

[5] Zhiyuan Fang “រដ្ឋាភិបាលអេឡិចត្រូនិកនៅក្នុងសម័យឌីជីថល ៖ ទស្សនាទាន ការអនុវត្ត និងការអភិវឌ្ឍ” ទិន្នានុប្បវត្តិអន្តរជាតិសម្រាប់ កុំព្យូទ័រ អ៊ីនធឺណិត និងការគ្រប់គ្រងឆ្នាំទី១០ ច្បាប់ចេញផ្សាយលេខ២ (ឆ្នាំ២០០២) ៖ ១–២២
http://www.journal.au.edu/ijcim/2002/may02/article1.pdf

*រូបភាពទី ២ ៖ ប្រព័ន្ធភាពជាដៃគូរដ្ឋាភិបាលអេឡិចត្រូនិក*

(ប្រភព ៖ Zhiyuan Fang "រដ្ឋាភិបាលអេឡិចត្រូនិកនៅក្នុងសម័យឌីជីថល ៖ ទស្សនាទាន ការអនុវត្ត និងការអភិវឌ្ឍ" ទិន្នានុប្បវត្តិអន្តរជាតិសម្រាប់កុំព្យូទ័រ អ៊ីនធឺណិត និងការគ្រប់គ្រង ឆ្នាំទី១០ ច្បាប់ចេញផ្សាយលេខ២ (២០០២) ៖ ១-២២ http://www.journal.au.edu/ijcim/2002/may02/article1.pdf)




### ២.២. វិស័យអាទិភាពសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិកនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍

ការស្រាវជ្រាវ និងការអនុវត្តល្អៗបំផុតដែលត្រូវបានកត់ត្រាជាឯកសាររបស់បណ្តាប្រទេសនានា បង្ហាញថា ជំហាន ជាមូលដ្ឋានគ្រឹះនៅក្នុងការបង្កើតរដ្ឋាភិបាលអេឡិចត្រូនិកមាន ៣ ៖ ជំហានទី១ គឺកសាងការតភ្ជាប់បណ្តាញ ឬហេដ្ឋារចនាសម្ព័ន្ធ ជំហានទី២ គឺរៀបចំបង្កើតខ្លឹមសារ ឬកម្មវិធី និងជំហានទី៣ គឺប្រព័ន្ធ ឬសមាហរណកម្ម ។

វិធីសាស្ត្រដែលមានបីជំហាននេះ ត្រូវបានអនុវត្តដោយបណ្តាប្រទេសជាច្រើន ក្នុងនោះរួមទាំង ប្រទេសបង់ក្លាដែស ចិន ជប៉ុន ម៉ិចស៊ិក និងសាធារណរដ្ឋកូរ៉េ ។ ក្នុងករណីនៃប្រទេសម៉ិចស៊ិក (សូមមើលរូបភាពទី ៣) ការតភ្ជាប់បណ្តាញ មានន័យថាដោះស្រាយគម្លាតឌីជីថល ដោយផ្តល់លទ្ធភាព ជាសាធារណៈក្នុងការទទួលបានឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និង ការបណ្តុះបណ្តាលតាមរយៈមជ្ឈមណ្ឌលសហគមន៍ឌីជីថល ។ អាទិភាពរបស់ប្រទេសម៉ិចស៊ិកសម្រាប់ការរៀបចំបង្កើតខ្លឹមសារ និងកម្មវិធី (ជំហានទី២) គឺការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (e-learning) សុខាភិបាលអេឡិចត្រូនិក (e-health) សេដ្ឋកិច្ច អេឡិចត្រូនិក (e-economy) និងរដ្ឋាភិបាលអេឡិចត្រូនិក (e-government) ។ នៅក្នុងជំហាននេះដែរ វ៉ែបសាយត៍ របស់រដ្ឋាភិបាលនៅកម្រិតនាយកដ្ឋាន ឬកម្រិតក្រសួង ក៏ត្រូវបានរៀបចំបង្កើតឡើងផងដែរ ។ ជំហានទី៣ សម្រាប់ម៉ិចស៊ិក អេឡិចត្រូនិក (e-Mexico) ពាក់ព័ន្ធនឹងការដាក់បញ្ចូលគ្នា ឬការតភ្ជាប់ប្រព័ន្ធ ឬវ៉ែបសាយត៍អ៊ីនធឺណិតទាំងអស់ ដើម្បីផ្តល់ សេវាច្រកចេញចូលតែមួយដល់ប្រជាពលរដ្ឋ និងអាជីវកម្ម ។

*រូបភាពទី ៣ ៖ ការដាក់ពង្រាយប្រព័ន្ធអេឡិចត្រូនិកជាតិរបស់ប្រទេសម៉ិចស៊ិក*

(ប្រភព ៖ វ៉ែបសាយត៍ម៉ិចស៊ិកអេឡិចត្រូនិក http://www.e-mexico.gob.mx)




នៅក្នុងប្រទេសហ្វីជី និងប្រជុំកោះសូឡូម៉ុង សមាសភាគទាំង ៥ នៃផែនការរដ្ឋាភិបាលអេឡិចត្រូនិក រួមមាន ៖ ផែនការរដ្ឋាភិបាលអេឡិចត្រូនិក កម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិក មជ្ឈមណ្ឌលទិន្នន័យ រដ្ឋាភិបាល ហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន–គមនាគមន៍រដ្ឋាភិបាល ព្រមទាំងការអភិវឌ្ឍនិងការបណ្តុះបណ្តាល សមត្ថភាព ICT ។ កម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិកទាំង ៨ ត្រូវបានកំណត់ដូចតទៅ ៖ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់គ្រូ និងសិស្សនៅតាមតំបន់ជនបទ ប្រព័ន្ធអាហារូបករណ៍ អេឡិចត្រូនិក ប្រព័ន្ធរដ្ឋបាលពន្ធនាគារ មូលដ្ឋានទិន្នន័យបទឧក្រិដ្ឋ ប្រព័ន្ធសុខុមាលភាពសង្គមអេឡិចត្រូនិក ប្រព័ន្ធគ្រប់គ្រង ឯកសារ ការធ្វើព័ត៌មានីយកម្មអាជ្ញាធរគយ និងប្រព័ន្ធធនធានមនុស្ស[6] ។

ការភ្ជាប់បណ្តាញ គឺបញ្ហាប្រឈមមួយសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសនៅរដ្ឋដែលនៅ លើកោះ ។ ប្រជុំកោះសូឡូម៉ុង បានដោះស្រាយបញ្ហាប្រឈមទាំងនេះ តាមរយៈគំនិតផ្តួចផ្តើមមួយ ដែលហៅថាបណ្តាញអ៊ីនធឺណិតដំបូង បង្អស់សម្រាប់ប្រជាពលរដ្ឋ (PFnet) ។

**PFnet**

នៅក្នុងភូមិដាច់ស្រយាលមួយឈ្មោះ Sasamunga នៅលើកោះ Choiseul ស្ថិតនៅចម្ងាយប្រហែល ១.០០០ ម៉ែល៍ពីរដ្ឋធានី Honiara នៃប្រជុំកោះសូឡូម៉ុង ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងជាមួយនឹង សាច់ញាតិ មិត្តភក្តិ និងនាយកដ្ឋាន រដ្ឋាភិបាលតាមអ៊ីមែលចាប់តាំងពីឆ្នាំ២០០១ មកម្ល៉េះ ។ នេះជារឿងមួយដែលគួរអោយកត់សម្គាល់ ពីព្រោះ ភូមិនេះពុំមាន អគ្គិសនី ឬខ្សែបណ្តាញទូរស័ព្ទឡើយ ។ ប្រាំឆ្នាំមុន មធ្យោបាយតែមួយគត់របស់ភូមិនេះដើម្បីប្រាស្រ័យទាក់ទង ជាមួយនឹង ពិភពលោកខាងក្រៅ គឺតាមរយៈសំបុត្រដែលចំណាយពេលប្រហែល ៣–៤ សប្តាហ៍ដើម្បីមកដល់រដ្ឋធានី Honiara (តាមនាវាដឹកជញ្ជូនក្នុងស្រុក) ។ វិទ្យុផ្សាយតាមរលកធាតុអាកាសខ្លី ត្រូវបានប្រើប្រាស់នៅក្នុង ស្ថានភាពអាសន្ន ។

ការប្រើប្រាស់អ៊ីមែលដោយគ្មានចរន្តអគ្គិសនីអាចធ្វើទៅបានសម្រាប់ប្រជាពលរដ្ឋនៅ Sasamunga តាមរយៈប្រព័ន្ធ PFnet ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០១ ជាគម្រោងរបស់ UNDP-UNOPS ។ ប្រព័ន្ធនេះរួមមានកុំព្យូទ័រយួរដៃតម្លៃ ២.០០០ដុល្លារមួយគ្រឿង ដែលដំណើរការដោយថាមពល ព្រះអាទិត្យ ។ សារអ៊ីមែលដែលវាយជាអត្ថបទនៅក្នុងកុំព្យូទ័រ ត្រូវបានបញ្ជូនតាមរយៈវិទ្យុដែលមាន ហ្វ្រេកង់ខ្ពស់ និងរលកធាតុអាកាសទាបទៅកាន់ឧបករណ៍ទទួលសញ្ញាវិទ្យុធំមួយនៅឯ ហាងកាហ្វេ អ៊ីនធឺណិតនៅរដ្ឋធានី Honiara ដែលនៅទីនោះ ប្រតិបត្តិករមួយរូបទទួលសារអ៊ីមែល រួចហើយបញ្ជូនសារ ទាំងនោះបន្តទៅកាន់អាសយដ្ឋានដែលពាក់ព័ន្ធ ។ ការធ្វើដូច្នេះកើតឡើងជាច្រើនដងក្នុងមួយថ្ងៃ ដែលមានន័យថាមានការ

---

[6] Anand Chand "រដ្ឋាភិបាលអេឡិចត្រូនិកនៅក្នុងតំបន់ប៉ាស៊ីហ្វិកខាងត្បូង ៖ ករណីសិក្សាពីប្រទេសហ្វីជី និងប្រជុំកោះសូឡូម៉ុង" (ឯកសារ បង្ហាញនៅឯសិក្ខាសាលាថ្នាក់តំបន់ស្តីពីគំនិតផ្តួចផ្តើមរដ្ឋាភិបាលអេឡិចត្រូនិកអាស៊ី–ប៉ាស៊ីហ្វិក ក្រុងបាងកក ព្រះរាជាណាចក្រថៃ ថ្ងៃទី២៤–២៥ ខែ មេសា ឆ្នាំ២០០៦) http://www.apdip.net/projects/e-government/capblg/casestudies/Fiji-Chand.pdf

ប្រាស្រ័យទាក់ទងគ្នាជាប់មិនដាច់រវាងប្រតិបត្តិករស្ថានីយអ៊ីមែលនៅតំបន់ ជនបទ និងប្រតិបត្តិករនៅឯហាងកាហ្វេអ៊ីនធឺណិត នៅរដ្ឋធានី Honiara ។

នៅឯស្ថានីយអ៊ីមែលនីមួយៗសារអ៊ីមែលត្រូវបាន "ចាត់ចែង" ដូចតទៅ ៖ អតិថិជនយកសារដែលសរសេរ ដោយដៃនៅលើក្រដាសមួយសន្លឹកមកកាន់ស្ថានីយ (ជាធម្មតា សរសេរជាភាសាមិនសូវត្រឹមត្រូវ) ឬអាន សារដោយផ្ទាល់មាត់អោយប្រតិបត្តិករស្ថានីយ ដែលជាអ្នកវាយអត្ថបទសារនេះ រួចហើយផ្ញើទៅហាង កាហ្វេអ៊ីនធឺណិតនៅក្នុងទីក្រុង Honiara ។ ដោយសារតែ ប្រតិបត្តិករនៅឯស្ថានីយនីមួយៗបំពេញ មុខងារជាអ្នកវាយអត្ថបទ និងផ្ញើសារអ៊ីមែលជំនួសមុខអោយអតិថិជន បញ្ហាអនក្ខរកម្មមិនមែនជា ឧបសគ្គចំពោះការប្រើប្រាស់សេវា PFnet ឡើយ ។

PFnet ត្រូវបានផ្តល់មូលនិធិជាបឋមដោយ UNDP ហើយនៅក្នុងបណ្តាឆ្នាំក្រោយៗមកទៀត គម្រោងនេះ បានទទួលមូលនិធិពី AusAID ប្រទេសជប៉ុន សហភាពអឺរ៉ុប ចក្រភពអង់គ្លេស ជំនួយអភិវឌ្ឍន៍ផ្លូវការ របស់ប្រទេសញូវហ្ស៊ីលែន និងសាធារណរដ្ឋប្រជាមានិតចិន ។ បច្ចុប្បន្ន PFnet ទ្រទ្រង់មូលនិធិដោយ ខ្លួនឯង និងគ្រប់គ្រងដោយសមាគមអ្នកស្ម័គ្រចិត្ត អភិវឌ្ឍន៍ជនបទ ដែលជាអង្គការមិនមែនរដ្ឋាភិបាល មានមូលដ្ឋាននៅក្នុងទីក្រុង Honiara ។ បណ្តាញនេះមានស្ថានីយ អ៊ីមែលចំនួន ១៤ នៅក្នុងប្រទេស ប្រជុំកោះសូឡូម៉ុង ឬស្ថានីយអ៊ីមែលមួយនៅក្នុងកោះនីមួយៗក្នុងចំណោមកោះសំខាន់ៗ ។ ស្ថានីយ អ៊ីមែលនីមួយៗដាក់នៅក្នុងបន្ទប់តូចមួយជាធម្មតានៅក្នុងគ្លីនិកសុខភាពខេត្ត សាលារៀនសហគមន៍ ឬមណ្ឌលសាធារណៈដែលអាចប្រើប្រាស់បាន និងមានសុវត្ថិភាពមួយចំនួនផ្សេងទៀត ។

ប្រភព ៖

ដកស្រង់ចេញពី Anand Chand "រដ្ឋាភិបាលអេឡិចត្រូនិកនៅក្នុងតំបន់ប៉ាស៊ីហ្វិកខាងត្បូង ៖ ករណីសិក្សាពីប្រទេសហ្វីជី និងប្រជុំកោះសូឡូម៉ុង" (ឯកសារបង្ហាញនៅឯសិក្ខាសាលាថ្នាក់តំបន់ស្តីពីគំនិតផ្តួចផ្តើមរដ្ឋាភិបាលអេឡិចត្រូនិកអាស៊ី–ប៉ាស៊ីហ្វិក ក្រុងបាងកក ព្រះរាជាណាចក្រថៃ ថ្ងៃទី២៤ –២៥ ខែមេសា ឆ្នាំ២០០៦) http://www.apdip.net/projects/e-government/capblg/casestudies/Fiji-Chand.pdf "

នៅប្រទេសបង់ក្លាដែស យុទ្ធសាស្ត្រសម្រាប់បង្កើតការតភ្ជាប់បណ្តាញ គឺមណ្ឌលសហគមន៍ឌីជីថល ដែលមាន ៤ ប្រភេទ ៖ មណ្ឌលព័ត៌មានសហគមន៍ (CICs) មណ្ឌល ICT ជនបទ (RICs) មណ្ឌល បច្ចេកវិទ្យាជនបទ (RTCs) និង មណ្ឌលសិក្សាអ៊ីនធឺណិត (ILCs) ។[7]

**មណ្ឌលសហគមន៍ឌីជីថលនៅប្រទេសបង់ក្លាដែស**

មណ្ឌលព័ត៌មានសហគមន៍ (CICs) នៅក្នុងប្រទេសបង់ក្លាដែសត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៦ ដោយ Grameen Phone ដែលជាក្រុមហ៊ុនទូរគមនាគមន៍ដ៏ធំជាងគេបំផុតនៅក្នុងប្រទេសបង់ក្លាដែស ។ សព្វថ្ងៃ មាន CICs ២៦កន្លែង នៅក្នុងតំបន់ផ្សេងៗនៃប្រទេសបង់ក្លាដែស ។ CIC នីមួយៗ ត្រូវបានបំពាក់ដោយម៉ាស៊ីនកុំព្យូទ័រយ៉ាងហោចណាស់ ១គ្រឿង ម៉ាស៊ីនបោះពុម្ព ម៉ាស៊ីនស្កេន ម៉ាស៊ីនថត ភ្ជាប់ទៅនឹងអ៊ីនធឺណិតមួយ និងម៉ូដឹម (ឧបករណ៍តភ្ជាប់បណ្តាញ កុំព្យូទ័រតាមរយៈខ្សែទូរស័ព្ទ) សម្រាប់ ការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតដោយប្រើប្រាស់កម្មវិធី EDGE ។ CICs ផ្តល់សេវា ដូចតទៅដោយឥតគិតថ្លៃ ៖ អ៊ីមែល ទូរសារ ការផ្ញើសារបន្ទាន់ និងការប្រើអ៊ីនធឺណិត ។ ប្រជាពលរដ្ឋ ប្រើប្រាស់សេវាអ៊ីមែល ទូរសារ និងការផ្ញើសារបន្ទាន់ ដើម្បីប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិ និងសាច់ញាតិដែលរស់នៅក្រៅប្រទេស ។ ពួកគេប្រើប្រាស់អ៊ីនធឺណិតដើម្បីប្រើប្រាស់ សេវាអេឡិចត្រូនិករបស់រដ្ឋាភិបាល ធ្វើការស្រាវជ្រាវនៅលើ ប្រព័ន្ធអ៊ីនធឺណិត និងអានព័ត៌មាននៅលើអ៊ីនធឺណិត ។ CICs ត្រូវបានគ្រប់គ្រងជាសាខាមួយរបស់ ក្រុមហ៊ុន Grameen Phone ។ ជាមួយនឹងទុន វិនិយោគអប្បបរមា ៨០.០០០ BDT (រូបិយប័ណ្ណរបស់ បង់ក្លាដែស) សហគ្រិនក្នុងស្រុកអាចកាន់កាប់ និងដំណើរការ CIC មួយបាន ។ មានផែនការដើម្បីបើក CICs ចំនួន ៦០.០០០ នៅទូទាំងប្រទេសបង់ក្លាដែស ។

RICs ត្រូវបានសម្ពោធបើកអោយដំណើរការនៅក្នុងឆ្នាំ២០០៦ ដោយបណ្តាញសមធម៌ឌីជីថល (Digital Equity Network) ដោយមានការគាំទ្រពី KATALYST ដែលជាសម្ព័ន្ធអង្គការមួយធ្វើការនៅក្នុងប្រទេស បង់ក្លាដែស ដោយមានការគាំទ្រពីម្ចាស់ជំនួយចម្រុះ ។ RIC នីមួយៗ បំពាក់ដោយទូរស័ព្ទមួយគ្រឿង ម៉ាស៊ីនកុំព្យូទ័រច្រើនគ្រឿង ម៉ាស៊ីនបោះពុម្ព មួយគ្រឿង និងម៉ាស៊ីនស្កេនមួយគ្រឿង កម្មវិធីភ្ជាប់អ៊ីនធឺណិត និងម៉ាស៊ីនថតឌីជីថល ។ ទស្សនវិស័យរបស់ RICs គឺដើម្បីផ្តល់ សេវាព័ត៌មានដល់សហគ្រាសខ្នាតតូច បំផុត តូច និងមធ្យម នៅតាមតំបន់ជនបទនៃប្រទេសបង់ក្លាដែស ។ ជាពិសេស RICs ផ្សព្វផ្សាយព័ត៌មាន អាជីវកម្មដល់ក្រុមហ៊ុនក្នុងស្រុកក្នុងវិស័យជម្រើសមួយចំនួនដូចជា ការចិញ្ចឹមសត្វស្លាប ជលផល និង ដំណាំដំឡូងជាដើម ។ RICs ក៏ផ្តល់ព័ត៌មានសង្គម សុខភាព អប់រំ និងព័ត៌មានអំពីរដ្ឋាភិបាលផងដែរ ។

RTCs ត្រូវបានបង្កើតឡើងនៅក្នុង Rajoir, Madaripur និង Sarishabari, Jamalpur នៅក្នុងឆ្នាំ២០០៦ ដោយ Practical Action Bangladesh ដើម្បីលើកកម្ពស់បច្ចេកវិទ្យានៅតាមតំបន់ជនបទសមស្រប សម្រាប់ការអភិវឌ្ឍជនបទ ។ ជាពិសេស នៅតាម RTCs នានា បច្ចេកវិទ្យាជាប្រពៃណីត្រូវបានកែលម្អ ហើយបច្ចេកវិទ្យាថ្មីៗត្រូវបានដាក់អោយ ប្រើប្រាស់ដើម្បីបំពេញតម្រូវការជនបទ ។ ឧបករណ៍វាស់កម្ពស់ និងឧបករណ៍ថ្លឹងទម្ងន់ និងឧបករណ៍កែច្នៃកសិកម្មសំខាន់ៗ ផ្សេងទៀតអាចរកបានសម្រាប់ការប្រើប្រាស់ បង្ហាញ និងជួលទៅអោយប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។ ក្នុងចំណោមឧបករណ៍កែច្នៃ កសិកម្មទាំងនេះ រួមមានឧបករណ៍វាស់សំណើមគ្រាប់ធញ្ញជាតិ ប្រដាប់វាស់ស្ទង់កាំរស្មីដែលវៀច (refract meter)

[7] Ananya Raihan *ចំណុចតភ្ជាប់បណ្តាញសហគមន៍ ឬចលនាទូរមណ្ឌល នៅបង់ក្លាដែស (រដ្ឋាភិបាលអេឡិចត្រូនិក* UNPAN នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ឆ្នាំ២០០៧) http://ipai.pbwiki.com/f/Annex+_A.pdf .

ឧបករណ៍វាស់ pH ឧបករណ៍វាស់កំហាប់សូលុយស្យុងអំបិល ឧបករណ៍វាស់កម្រិតអាស៊ីដ ឧបករណ៍កិន គ្រាប់ម្រេច ចង្រ្កាន microwave ប្រដាប់ញែកកាម៉ែមទឹកដោះគោ ទែម៉ូម៉ែត្រឌីជីថល ម៉ាស៊ីនក្រឡុក ធុងលាយ និងម៉ាស៊ីនបិទភ្ជិតកញ្ចប់ ។ នៅតាម RTCs ក៏មានម៉ាស៊ីនកុំព្យូទ័រមួយគ្រឿង និងខ្សែទូរស័ព្ទ ភ្ជាប់ជាមួយបណ្តាញអ៊ីនធឺណិតដែលកសិករ អាជីវករ សហគ្រិន និងអតិថិជនផ្សេងទៀត អាចប្រើប្រាស់ ដើម្បីទទួលបានព័ត៌មានផងដែរ ។ RTCs ក៏ផ្តល់ព័ត៌មានអំពីការងារ សម្រាប់យុវជន កម្មករ ចំណាកស្រុក និងប្រជាពលរដ្ឋដែលមានការងារធ្វើមិនគ្រប់គ្រាន់នៅក្នុងមូលដ្ឋានផងដែរ ។

ILCs ដែលត្រូវបានសម្ពោធអោយដំណើរការនៅក្នុងឆ្នាំ២០០៥ គឺជាកម្មវិធីមួយរបស់សាលារៀននៅលើ អ៊ីនធឺណិតនៃ Relief International ។ បច្ចុប្បន្ន មាន ILC ចំនួន ២៧ ដែលដំណើរការនៅតាមសាលារៀន នៅទូទាំងប្រទេសបង់ក្លាដែស ។ ILC នីមួយៗ ត្រូវបានបំពាក់ម៉ាស៊ីនកុំព្យូទ័រពី ៥-១០គ្រឿង ម៉ាស៊ីនស្កែន មួយ ម៉ាស៊ីនថតឌីជីថលមួយ និងការភ្ជាប់អ៊ីនធឺណិត ។ ILCs ផ្តល់ការបណ្តុះបណ្តាលជំនាញកុំព្យូទ័រដល់ សិស្សសាលា និងគ្រូ ព្រមទាំងការបណ្តុះបណ្តាល អំពីការសិក្សាដែលផ្អែកលើគម្រោង និងការសិក្សា សហការជាក្រុម ។ ថ្លៃសមាជិកត្រូវបានតម្រូវអោយបង់ដើម្បីប្រមូល មូលនិធិសម្រាប់ការចំណាយ ។

ប្រភព ៖

ដកស្រង់ចេញពី Ananya Raihan *ចំណុចតភ្ជាប់បណ្តាញសហគមន៍ ឬចលនាទូរមណ្ឌលនៅប្រទេសបង់ក្លាដែស* (*រដ្ឋាភិបាលអេឡិចត្រូនិក* UNPAN នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ឆ្នាំ២០០៧) http://ipai.pbwiki.com/f/Annex+_A.pdf ។

**សំណួរត្រិះរិះ**

តើយុទ្ធសាស្រ្តអ្វីខ្លះដែលផែនការរដ្ឋាភិបាលអេឡិចត្រូនិកនៃប្រទេសរបស់អ្នកមាន សម្រាប់ការតភ្ជាប់ បណ្តាញអ៊ីនធឺណិតនៅក្នុងតំបន់ជនបទ និងតំបន់ដាច់ស្រយាល ? ប្រសិនបើគ្មានយុទ្ធសាស្រ្តបែបនេះទេ តើយុទ្ធសាស្រ្តអ្វីខ្លះដែលអ្នកនឹងផ្តល់ជា អនុសាសន៍ និងមូលហេតុអ្វី ?

## ២.៣. ការរៀបចំផែនការយុទ្ធសាស្រ្តរដ្ឋាភិបាលអេឡិចត្រូនិក

យុទ្ធសាស្រ្តត្រឹមត្រូវមួយ គឺជាកត្តាសំខាន់ចាំបាច់សម្រាប់ការអនុវត្តគម្រោងរដ្ឋាភិបាលអេឡិចត្រូនិក ប្រកបដោយប្រសិទ្ធភាព ។ ផែនការយុទ្ធសាស្រ្ត គឺជាផែនទីបង្ហាញផ្លូវសម្រាប់អង្គការមួយដើម្បីធ្វើដំណើរ ចេញពីស្ថានភាពបច្ចុប្បន្នរបស់ខ្លួនឆ្ពោះទៅកាន់ស្ថានភាពអនាគតរយៈពេលមធ្យម ឬរយៈពេលវែងដែល ខ្លួនចង់បាន ។

ដំណើរការធ្វើផែនការយុទ្ធសាស្រ្តរួមមាន ៥ជំហាន[8] ដែលត្រូវបានពិភាក្សានៅខាងក្រោមនេះ ។ ឧទាហរណ៍ដែល ប្រើប្រាស់នៅក្នុងផ្នែកនេះ គឺផែនទីបង្ហាញផ្លូវរដ្ឋាភិបាលអេឡិចត្រូនិករបស់ សាធារណរដ្ឋកូរ៉េ ។

<u>ជំហានទី១ ៖ វិភាគបរិយាកាសបច្ចុប្បន្ន</u>

គេអាចប្រើប្រាស់ការវិភាគ SWOT ដើម្បីកំណត់កត្តាខាងក្នុង និងកត្តាខាងក្រៅដែលអនុគ្រោះ និងមិន អនុគ្រោះ ចំពោះការសម្រេចគោលបំណង ឬគោលដៅរដ្ឋាភិបាលអេឡិចត្រូនិកជាក់លាក់ណាមួយ ។ SWOT មានន័យថា ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង ។

<u>ជំហានទី២ ៖ ថ្លែងអំពីទស្សនវិស័យ</u>

សេចក្តីថ្លែងអំពីទស្សនវិស័យ គឺជាសេចក្តីថ្លែងមួយដែលបញ្ជាក់អំពីថាតើអង្គការមួយចង់ក្លាយខ្លួនទៅជា បែបណា ។ ទស្សនវិស័យផ្តោតទៅលើអនាគត និងដើម្បីជំរុញទឹកចិត្តសមាជិករបស់អង្គការឆ្ពោះទៅរក ការសម្រេចបាននូវអនាគតដែល អង្គការចង់បាន ។

ឧទាហរណ៍ សេចក្តីថ្លែងអំពីទស្សនវិស័យរដ្ឋាភិបាលអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ គឺដើម្បីក្លាយជា "រដ្ឋាភិបាល អេឡិចត្រូនិកបើកចំហដែលល្អប្រសើរបំផុតនៅលើពិភពលោក" ដោយ ៖

- បង្កើនសេវាសាធារណៈនៅលើអ៊ីនធឺណិតអោយដល់ ៨៥ភាគរយ ។
- ធ្វើការដើម្បីស្ថិតនៅក្នុងចំណោមរដ្ឋាភិបាលកំពូលទាំង១០ នៅលើពិភពលោក សម្រាប់ភាព ប្រកួតប្រជែងផ្អែកគាំទ្រអាជីវកម្ម ។
- កាត់បន្ថយការធ្វើដំណើរសម្រាប់បេក្ខជនដាក់ពាក្យចូលបម្រើការក្នុងមុខងារសាធារណៈមកត្រឹម ៣ដង ក្នុងមួយឆ្នាំ និង
- បង្កើនអត្រានៃការប្រើប្រាស់កម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិកអោយដល់ ៦០ភាគរយ ។

សេចក្តីថ្លែងអំពីទស្សនវិស័យត្រូវតែមានភាពច្បាស់លាស់ ។ ហើយទោះជាទស្សនវិស័យថ្លែងអំពីគំនិត ដ៏ល្អមួយដែលជំរុញទឹកចិត្តក្តី ក៏ទស្សនវិស័យនេះត្រូវតែថ្លែងអំពីបំណងប្រាថ្នាដែលមានភាពប្រាកដនិយម

[8] Adegboyega Ojo, Elsa Estevez, Bernd Friedrich និង Tomasz Janowski, "ការធ្វើផែនការយុទ្ធសាស្រ្តសម្រាប់អភិបាលកិច្ច អេឡិចត្រូនិក" (បង្ហាញនៅឯសាលារៀន UNeGov.net ទី៧ ស្តីពីមូលដ្ឋានគ្រឹះនៃអភិបាលកិច្ចអេឡិចត្រូនិក នៅ Cheonan សាធារណរដ្ឋកូរ៉េ ថ្ងៃទី៨-១១ ខែតុលា ឆ្នាំ២០០៧) http://www.unegov.net/03-Events/26-S-Cheonan/public/module-2.pdf .

និងអាចសម្រេចបានផងដែរ ។ លើសពីនេះទៅទៀត ទស្សនវិស័យត្រូវតែស្របជាមួយនឹងវប្បធម៌ និងគុណតម្លៃរបស់អង្គការ ។

<u>ជំហានទី៣ ៖ ប្រែក្លាយទស្សនវិស័យទៅជាគោលដៅ</u>

គោលដៅគឺជាទិស ឬចំណុចដៅរយៈពេលវែង (៣ ដល់ ៥ឆ្នាំ) ដែលផ្អែកលើទស្សនវិស័យ ។ ឧទាហរណ៍ គោលដៅ ជាតិរបស់សាធារណរដ្ឋកូរ៉េ រួមមានដូចខាងក្រោម ៖

- កសាងលទ្ធិប្រជាធិបតេយ្យជាមួយប្រជាពលរដ្ឋ
- កសាងសង្គមមួយ ដែលមានកំណើនសង្គមប្រកបដោយតុល្យភាព
- រួមវិភាគទានដល់សម័យកាលសន្តិភាព និងវិបុលភាពនៅក្នុងតំបន់អាស៊ីភាគឦសាន
- សម្រេចអោយបានផលិតផលជាតិសរុបក្នុងមនុស្សម្នាក់ ២០.០០០ ដុល្លារអាមេរិក (គោលដៅនេះ សម្រេចបាននៅក្នុងឆ្នាំ២០០៧) ។

គោលដៅរដ្ឋាភិបាលអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ រួមមាន ៖

- បង្កើតគំនិតថ្មីៗសម្រាប់វិធីធ្វើការរបស់រដ្ឋាភិបាល
- បង្កើតគំនិតថ្មីៗសម្រាប់សេវាប្រជាពលរដ្ឋ
- បង្កើតគំនិតថ្មីៗសម្រាប់ការគ្រប់គ្រងធនធានព័ត៌មាន
- កែទម្រង់ប្រព័ន្ធច្បាប់

<u>ជំហានទី៤ ៖ កំណត់យុទ្ធសាស្ត្រដើម្បីដោះស្រាយការរកឃើញនៃការវិភាគ SWOT និងសម្រេចគោលដៅ ដែលបានបញ្ជាក់</u>

យុទ្ធសាស្ត្រអាចរួមបញ្ចូលទាំងកិច្ចការគ្រប់គ្រងជាក់លាក់ និងវិធានការដើម្បីសម្រេចគោលដៅជាក់លាក់ មួយដែលកំណត់នៅក្នុងផែនទីបង្ហាញផ្លូវសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក ។ ឧទាហរណ៍ យុទ្ធសាស្ត្រគឺជាការកសាងផែនការមេដ៏ទូលំទូលាយមួយ ដែលថ្លែងអំពីរបៀបដែលរដ្ឋាភិបាលនឹងសម្រេចគោលបំណងរបស់ខ្លួន ។ ការអនុវត្តយុទ្ធសាស្ត្រ គឺជាដំណើរការ នៃការប្រែក្លាយយុទ្ធសាស្ត្រ និងគោលនយោបាយនានាទៅជាសកម្មភាព តាមរយៈការបង្កើតកម្មវិធី ថវិកា និងនីតិវិធី ។

<u>ជំហានទី៥ ៖ បង្កើតគោលបំណងជាក់ស្តែងនិងអាចវាស់វែងបានចេញពីយុទ្ធសាស្ត្រ</u>

គោលបំណង គឺជាលទ្ធផលចុងក្រោយនៃសកម្មភាពដែលបានគ្រោងទុកមួយ ។ គោលបំណងគួរតែជា សេចក្តីថ្លែងដែលជាក់លាក់ និងអាចវាស់វែងបាន អំពីអ្វីដែលត្រូវសម្រេចអោយបាននៅពេលជាក់លាក់ ណាមួយ ។ ផ្ទុយពីគោលបំណង គោលដៅគឺជាសេចក្តីថ្លែងដោយចំហអំពីអ្វីដែលគេចង់សម្រេចបាន ដោយគ្មានការកំណត់បរិមាណនូវអ្វីដែលត្រូវសម្រេចបាន និងគ្មានលក្ខណវិនិច្ឆ័យពេលវេលាសម្រាប់ការ បញ្ចប់ជាស្ថាពរឡើយ ។ ឧទាហរណ៍នៃគោលបំណងគឺ ៖ យ៉ាងហោចណាស់ ៩៥% នៃអាជីវកម្ម ទាំងអស់នឹងប្រើប្រាស់ប្រព័ន្ធ G2B នៅត្រឹមឆ្នាំ២០០៩ ។

នៅពេលបញ្ចប់ជាស្ថាពរ លទ្ធផលនៃដំណើរការធ្វើផែនការយុទ្ធសាស្ត្រ នឹងជាផែនការ ឬផែនទីបង្ហាញ ផ្លូវលម្អិតមួយ ដែលត្រូវផ្សព្វផ្សាយប្រាប់ដល់អ្នករាល់គ្នា និងពិនិត្យឡើងវិញជាទៀងទាត់ ដើម្បីធានាថា ផែនការ ឬផែនទីបង្ហាញផ្លូវនេះ នៅតែមានភាពពាក់ព័ន្ធដដែល ។ ផែនទីបង្ហាញផ្លូវសម្រាប់ រដ្ឋាភិបាលអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ គឺជាឧទាហរណ៍មួយ។

**ផែនទីបង្ហាញផ្លូវសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ**

រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េបានបង្កើតផែនទីបង្ហាញផ្លូវលម្អិតមួយសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក នៅបន្ទាប់ពី ដំណើរការធ្វើផែនការយុទ្ធសាស្ត្រដ៏ហ្មត់ចត់មួយ ដែលរួមបញ្ចូលទាំងការវិភាគ SWOT ការធ្វើផែនការយុទ្ធសាស្ត្រព័ត៌មាន (ISP) និង BPR ។ ដំណើរការនេះត្រូវបានដឹកនាំដោយអនុគណៈ កម្មាធិការមួយ ដែលស្ថិតនៅក្រោមឱវាទគណៈកម្មាធិការ ប្រធានាធិបតីសម្រាប់ការច្នៃប្រឌិតថ្មី និងវិមជ្ឈការរដ្ឋាភិបាល (ឬ គណៈកម្មាធិការកំណែទម្រង់រដ្ឋាភិបាល) ។

ផែនទីបង្ហាញផ្លូវនេះ គឺជាផែនការ៥ឆ្នាំមួយ ដែលគ្របដណ្តប់រយៈពេលពីឆ្នាំ២០០៣-២០០៧ ។ ផែនទីបង្ហាញផ្លូវ នេះបញ្ជាក់អំពីវិស័យច្នៃប្រឌិតថ្មីចំនួន ៤ របៀបវារៈចំនួន ១០ចំណុច និងកិច្ចការ ឬគម្រោងចំនួន ៣១ ដូចបង្ហាញខាង ក្រោមនេះ ។

***របៀបវារៈ និងផែនទីបង្ហាញផ្លូវសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ***

| វិស័យច្នៃប្រឌិតថ្មីទាំង៤ | របៀបវារៈ ១០ចំណុច | គម្រោងសំខាន់ៗទាំង ៣១ |
|---|---|---|
| ១. នវានុវត្តន៍វិធីធ្វើការងារ សម្រាប់រដ្ឋាភិបាល | ១. បង្កើតដំណើរការការងារ អេឡិចត្រូនិក | ១. ដំណើរការឯកសារអេឡិចត្រូនិក |
| | | ២. ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុប្រមូលផ្តុំសម្រាប់រដ្ឋាភិបាល ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន |

| | | |
|---|---|---|
| | | ៣. រដ្ឋាភិបាលអេឡិចត្រូនិកថ្នាក់មូលដ្ឋាន |
| | | ៤. ប្រព័ន្ធសវនកម្មអេឡិចត្រូនិក |
| | | ៥. រដ្ឋសភាអេឡិចត្រូនិក |
| | | ៦. សេវាយុត្តិធម៌ព្រហ្មទណ្ឌរួមបញ្ចូលគ្នា |
| | | ៧. ប្រព័ន្ធរដ្ឋបាលបុគ្គលិកប្រមូលផ្តុំគ្នា |
| | | ៨. ប្រព័ន្ធការទូតអេឡិចត្រូនិក |
| | | ៩. ប្រព័ន្ធបច្ចុប្បន្នភាពសម្រាប់ការគ្រប់គ្រង គោលនយោបាយជាតិ |
| | ២. ពង្រីកប្រព័ន្ធចែករំលែក ព័ត៌មានរដ្ឋបាល | ១០. ការពង្រីកប្រព័ន្ធចែករំលែកព័ត៌មានរដ្ឋបាល |
| | ៣. រៀបចំដំណើរការអាជីវកម្ម ដែលផ្តោតទៅលើសេវា | ១១. ការអភិវឌ្ឍ គំរូយោងអាជីវកម្មរដ្ឋាភិបាល |
| ២. នវានុវត្តន៍សេវាប្រជាពលរដ្ឋ | ៤. កែលម្អសេវាប្រជាពលរដ្ឋ | ១២. កែលម្អសេវាប្រជាពលរដ្ឋនៅលើអ៊ីនធឺណិត |
| | | ១៣. សេវាគ្រប់គ្រងគ្រោះមហន្តរាយជាតិដែលរួម បញ្ចូលគ្នា |
| | | ១៤. ប្រព័ន្ធព័ត៌មានរដ្ឋបាលស្ថាបត្យកម្មប្រមូលផ្តុំ |
| | | ១៥. ប្រព័ន្ធសេវាពន្ធនៅលើអ៊ីនធឺណិតដែលប្រមូលផ្តុំ |
| | | ១៦. សេវាសុខុមាលភាពជាតិដែលរួមបញ្ចូលគ្នា |
| | | ១៧. ប្រព័ន្ធព័ត៌មានស្បៀងអាហារ និងឱសថដែល ប្រមូលផ្តុំ |
| | | ១៨. សេវាព័ត៌មានការងារដែលប្រមូលផ្តុំ |
| | | ១៩. ប្រព័ន្ធសាលាក្តីរដ្ឋបាលនៅលើអ៊ីនធឺណិត |
| | ៥. កែលម្អសេវាគាំទ្រអាជីវកម្ម | ២០. សេវាគាំទ្រអាជីវកម្មច្រកចេញចូលតែមួយ (G4B) |
| | | ២១. សេវាព័ត៌មានភស្តុភារជាតិដែលប្រមូលផ្តុំ |
| | | ២២. សេវាអាជីវកម្មអេឡិចត្រូនិក |
| | | ២៣. សេវាគាំទ្រជនបរទេសទូលំទូលាយ |
| | | ២៤. ការគាំទ្រសម្រាប់ការនាំចេញដំណោះស្រាយ រដ្ឋាភិបាលអេឡិចត្រូនិក |
| | ៦. កែលម្អការចូលរួមរបស់ ប្រជាពលរដ្ឋនៅលើអ៊ីនធឺណិត | ២៥. ការពង្រីកការចូលរួមរបស់ប្រជាពលរដ្ឋនៅលើ អ៊ីនធឺណិត |
| | ៧. ប្រមូលផ្តុំ និងធ្វើបទដ្ឋានកម្ម ធនធានព័ត៌មាន | ២៦. ប្រព័ន្ធរដ្ឋបាលធនធានព័ត៌មានប្រមូលផ្តុំទូទាំង រដ្ឋាភិបាល |
| ៣. នវានុវត្តន៍សម្រាប់ ការគ្រប់គ្រងធនធានព័ត៌មាន | | ២៧. ការកែលម្អបណ្តាញសារគមនាគមន៍រដ្ឋាភិបាល អេឡិចត្រូនិក |
| | | ២៨. ការបង្កើតស្ថាបត្យកម្មបច្ចេកវិទ្យាព័ត៌មានទូទាំង រដ្ឋាភិបាល |
| | ៨.ពង្រឹងប្រព័ន្ធសន្តិសុខព័ត៌មាន | ២៩. ការបង្កើតប្រព័ន្ធសន្តិសុខព័ត៌មាន |
| | ៩. ពង្រឹងសមត្ថភាពបុគ្គលិក និងអង្គការ IT | ៣០. ការកែរចនាសម្ព័ន្ធបុគ្គលិក និងអង្គការ IT |

៤. កែទម្រង់ប្រព័ន្ធច្បាប់ ១០. កែទម្រង់ប្រព័ន្ធច្បាប់ រដ្ឋាភិបាលអេឡិចត្រូនិក ៣១. កំណែទម្រង់ច្បាប់ និងបទប្បញ្ញត្តិរដ្ឋាភិបាល អេឡិចត្រូនិក

ប្រភព ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម *2004 Broadban IT Korea ៖ សៀវភៅសស្តីពីព័ត៌មានីយកម្ម (សេអ៊ូល ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០៤) ២០* http://www.nia.or.kr/special_content/eng/ ។

ខាងក្រោមនេះ គឺជាផែនទីបង្ហាញផ្លូវរបស់ប្រទេសម៉ុងហ្គោលី សម្រាប់ការអនុវត្តគម្រោងរដ្ឋាភិបាល អេឡិចត្រូនិក ។

**ផែនទីបង្ហាញផ្លូវរបស់ប្រទេសម៉ុងហ្គោលីសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក**

នៅឆ្នាំ២០០៥ អាជ្ញាធរបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICTA) របស់ប្រទេសម៉ុងហ្គោលី បានចាប់ផ្តើម អនុវត្តកម្មវិធីជាតិម៉ុងហ្គោលីអេឡិចត្រូនិក និងផែនការមេសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិករបស់ប្រទេសម៉ុងហ្គោលី ។

កម្មវិធីជាតិម៉ុងហ្គោលីអេឡិចត្រូនិក មានគោលបំណងកែលម្អគុណភាពជីវិតរបស់ប្រជាពលរដ្ឋតាមរយៈ ការកសាង បរិយាកាសសេដ្ឋកិច្ចថ្មីមួយ កែលម្អភាពប្រកួតប្រជែងរបស់ប្រទេស និងលើកស្ទួយកិច្ចអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។ កម្មវិធីនេះ មានគោលបំណងចំនួន ១៦ និងផែនការសកម្មភាពមួយ ដែលកំពុងអនុវត្តតាមរយៈគម្រោងនានា ដូចជា "កុំព្យូទ័រ ផ្ទាល់ខ្លួនសម្រាប់អ្នកទាំងអស់គ្នា" និង "អក្ខរកម្មបច្ចេកវិទ្យាព័ត៌មានសម្រាប់ប្រជាពលរដ្ឋគ្រប់រូប" ។

ជាផ្នែកនៃគម្រោង"កុំព្យូទ័រផ្ទាល់ខ្លួនសម្រាប់ទាំងអស់គ្នា" អង្គការរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និង ក្រុមហ៊ុនឯកជន បានរួមសហការគ្នាដើម្បីបង្កើតសមាគមសេវាក្រុមហ៊ុនផ្គត់ផ្គង់អ៊ីនធឺណិតម៉ុងហ្គោលី និងសមាគមផ្គត់ផ្គង់ កុំព្យូទ័រម៉ុងហ្គោលី ។ សមាគមទាំងនេះបានកាត់បន្ថយការចំណាយទៅលើការ ប្រើប្រាស់កុំព្យូទ័រនៅលើអ៊ីនធឺណិត ។

ជាងនេះទៅទៀត ច្បាប់ត្រូវបាន ឬកំពុងត្រូវបានធ្វើវិសោធនកម្ម តាមការគូសបញ្ជាក់នៅក្នុងកម្មវិធីជាតិ ម៉ុងហ្គោលីអេឡិចត្រូនិក ដើម្បីផ្តល់បរិយាកាសច្បាប់ដែលអនុគ្រោះដល់ ICTD ។ មិនត្រឹមតែច្បាប់ដែលទាក់ទងនឹង ICT ប៉ុណ្ណោះទេ ដែលត្រូវបានធ្វើវិសោធនកម្មនោះ សូម្បីតែច្បាប់ផ្សេងទៀតដែល ប៉ះពាល់ដល់ ICTD ក៏ត្រូវបានធ្វើវិសោធនកម្មផងដែរ ។ ឧទាហរណ៍ ច្បាប់ស្តីពីការអប់រំមាន វាក្យខណ្ឌមួយដែលចែងអំពីការបង្កើតកម្មវិធីសិក្សា ICT សម្រាប់សាលាអនុវិទ្យាល័យ និងអ្នកឯកទេស ផ្នែក ICT ។

ផែនការមេសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិករបស់ប្រទេសម៉ុងហ្គោលី ត្រូវបានបង្កើតឡើងនៅក្រោយការ ស្ទង់មតិដ៏ហ្មត់ចត់មួយ ដើម្បីប៉ាន់ប្រមាណស្ថានភាពនិងតម្រូវការផ្នែក ICT របស់ម៉ុងហ្គោលី ជាពិសេសនៅក្នុងចំណោមអង្គការរបស់រដ្ឋាភិបាល ។ ផែនការមេនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយមាន ទស្សនវិស័យ យុទ្ធសាស្ត្រ និងផែនការសម្រាប់ការអនុវត្ត ក្នុងនោះរួមទាំងសកម្មភាពនៅក្នុងគម្រោងពេលវេលាជាក់លាក់ផងដែរ ។ ទស្សនវិស័យនៃផែនការមេនេះ គឺដើម្បី កសាងប្រទេសមួយដែលរឹងមាំ និងមានភាពប្រកួតប្រជែង ដោយបង្កើតនូវរដ្ឋាភិបាលដែលផ្តោតសំខាន់លើប្រជាពលរដ្ឋមាន តម្លាភាព និងឈរលើមូលដ្ឋានចំណេះដឹង តាមរយៈការប្រើប្រាស់ ICT ទំនើប ។

គម្រោង ២២ ដែលបញ្ជាក់នៅក្នុងផែនការមេនេះ ផ្តោតសំខាន់ភាគច្រើនបំផុតទៅលើការធ្វើឌីជីថល ភាវូបនីយកម្ម ព័ត៌មាន និងនីតិវិធីរបស់រដ្ឋាភិបាល ការផ្តល់លទ្ធភាពទទួលបានធនធានព័ត៌មានជម្រើស និងការកែលម្អសេវាសាធារណៈតាមអ៊ីនធឺណិត ។ គម្រោងមួយ គឺវែបសាយត៍រដ្ឋាភិបាលបើកចំហដែល ផ្តល់ជាកន្លែងសម្រាប់អាជីវកម្ម និងប្រជាពលរដ្ឋដើម្បីធ្វើ អត្ថាធិប្បាយទៅលើគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានា និងលើកឡើងនូវក្តីកង្វល់ទាំងឡាយអោយអង្គការរដ្ឋាភិបាល បានដឹង ។ គម្រោងមួយទៀត គឺវែបសាយត៍របស់ទីភ្នាក់ងារពន្ធដារនៃប្រទេសម៉ុងហ្គោលី ដែលនៅលើវែបសាយត៍ នេះ គេអាចថតចម្លងយកទម្រង់បែបបទ និងឯកសារពន្ធដារនានាបាន ។

ប្រភព ៖


ICTA *ការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យានៅប្រទេសម៉ុងហ្គោលី - ឆ្នាំ២០០៦ ៖ សៀវភៅស* (Ulaanbaatar: ICTA, 2006) http://www.itconsulting.mn/publications/WB%20of%20Mongolia%20final.pdf ។

Lkhagvasuren Ariunaa, *ម៉ុងហ្គោលី ៖ ប្រមូលផ្តុំសហគមន៍សម្រាប់ការចូលរួមនៅក្នុងគំនិតផ្តួចផ្តើមរដ្ឋាភិបាលអេឡិចត្រូនិកសម្រាប់ ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលត្រូវសង្គមផាត់ចេញ (ទីក្រុងបាងកក ៖* UNDP-APDIP ឆ្នាំ២០០៥)
http://www.apdip.net/projects/e-government/capblg/casestudies/Mongolia-Ariunaa.pdf ។

Lkhagvasuren Ariunaa និង Batchuluun Batpurev, ".mn Mongolia" នៅក្នុងការត្រួតពិនិត្យឡើងវិញឌីជីថលនៃតំបន់អាស៊ី–ប៉ាស៊ីហ្វិក ឆ្នាំ២០០៧/២០០៨ (New Delhi: Sage, IDRC, Orbicom, ២០០៧)
http://www.idrc.ca/en/ev-127135-201-1-DO_TOPIC.html ។

Odgerel Ulziikhutag, *ម៉ុងហ្គោលី ៖ ភាពប្រឈមសំខាន់ៗសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ (ទីក្រុង បាងកក ៖* UNDP-APDIP, ២០០៥)

http://www.apdip.net/projects/e-government/capblg/casestudies/Mongolia-Ulziikhutag.pdf ។

**កិច្ចការដែលត្រូវអនុវត្ត**

1. តើរដ្ឋាភិបាលរបស់អ្នកមានផែនទីបង្ហាញផ្លូវសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក ឬផែនការ ICT ដែរឬទេ? ចូររក ចម្លើយនៃសំណួរនេះ ហើយពណ៌នាអំពីដំណើរការ ដែលផែនទីបង្ហាញផ្លូវ ឬផែនការ ICT ត្រូវបានបង្កើតឡើង ។ តើដំណើរការនេះដូចគ្នា ឬក៏ខុសគ្នាយ៉ាងដូចម្តេចខ្លះ ពីការធ្វើផែនការយុទ្ធសាស្ត្រ ដែលបានរៀបរាប់ខាងលើ ?
2. ប្រសិនបើរដ្ឋាភិបាលរបស់អ្នកមិនទាន់មានផែនទីបង្ហាញផ្លូវសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក ឬផែនការ ICT នៅឡើយទេ ចូរសរសេរការវិភាគសង្ខេបមួយ ដោយបង្ហាញអំពីជំហាននានា នៅក្នុងដំណើរការធ្វើផែនការយុទ្ធសាស្ត្រ ដែលនឹងមានភាពប្រឈមជាពិសេសចំពោះរដ្ឋាភិបាល របស់អ្នក និងបញ្ជាក់អំពីមូលហេតុ ។ ចូរបញ្ជាក់ផងដែរថា តើអ្នកណាខ្លះដែលអ្នកគិតថា គួរតែចូលរួមនៅក្នុងដំណើរការធ្វើផែនការយុទ្ធសាស្ត្រ ដើម្បីបង្កើតផែនទីបង្ហាញផ្លូវសម្រាប់ រដ្ឋាភិបាលអេឡិចត្រូនិកនៃប្រទេសរបស់អ្នក ។

### ២.៤. ការអនុវត្ត និងការវាយតម្លៃរដ្ឋាភិបាលអេឡិចត្រូនិក

ការអនុវត្តរដ្ឋាភិបាលអេឡិចត្រូនិកប្រកបដោយជោគជ័យ ពឹងផ្អែកលើការបំពេញកិច្ចការ ឬគម្រោង នីមួយៗនៅក្នុង ផែនទីបង្ហាញផ្លូវសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក ។

នៅក្នុងករណីសាធារណរដ្ឋកូរ៉េ ក្រសួងរដ្ឋបាលនិងកិច្ចការក្នុងប្រទេសរបស់រដ្ឋាភិបាល (MOGAHA)[9] បានបង្កើតនូវ គោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងគម្រោង និងបានប្រកាសគោលការណ៍ណែនាំ នេះជាដីកាផ្សព្វផ្សាយ (លេខ ១៤២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៤) ។ MOGAHA ក៏បានចាត់តាំង ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម (NCA)[10] ដើម្បី គ្រប់គ្រងគម្រោង ។ សសរសំខាន់ពីរ គឺជំរុញការ អនុវត្តរដ្ឋាភិបាលអេឡិចត្រូនិក ៖ គម្រោងគាំទ្ររដ្ឋាភិបាលអេឡិចត្រូនិក និង គម្រោងកសាងមូលដ្ឋាន ទិន្នន័យរដ្ឋបាល ។ គម្រោងគាំទ្ររដ្ឋាភិបាលអេឡិចត្រូនិក ដែលផ្តោតអាទិភាពទៅលើការគាំទ្រដល់ កិច្ចការផែនទីបង្ហាញផ្លូវ ជួយដល់គម្រោងនានាដែលពាក់ព័ន្ធនឹងក្រសួងជាច្រើន គម្រោងគោល នយោបាយថ្មីៗ ឬគម្រោងព័ត៌មានីយកម្មមូលដ្ឋាន នៅក្នុងផែនការថវិកាដែលបានធ្វើវិភាជន៍ និង គោលការណ៍ណែនាំសម្រាប់ឆ្នាំនីមួយៗ ។

គម្រោងផែនទីបង្ហាញផ្លូវសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិករបស់ប្រទេសកូរ៉េ ត្រូវបានអនុវត្តជា ដំណាក់កាលៗ ដូច មានបង្ហាញនៅក្នុងរូបភាពទី ៤ ។

***រូបភាពទី ៤ ៖ ផែនការប្រចាំឆ្នាំសម្រាប់ការអនុវត្តផែនទីបង្ហាញផ្លូវរដ្ឋាភិបាលអេឡិចត្រូនិករបស់ សាធារណរដ្ឋកូរ៉េ***

(ប្រភព ៖ NIA, ed., *របាយការណ៍រដ្ឋាភិបាលអេឡិចត្រូនិកប្រចាំឆ្នាំ២០០៦ (សេអ៊ូល ៖* MOGAHA ឆ្នាំ ២០០៦) ១១

http://www.nia.or.kr/open_content/common/fileList/fileList.jsp?tn=PU_0000100&id=54651)




---

[9] នៅក្នុងអំឡុងពេលរៀបចំរដ្ឋាភិបាលឡើងវិញ ដែលអនុវត្តនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៨ MOGAHA ត្រូវបានប្តូរឈ្មោះទៅជាក្រសួងរដ្ឋបាល និង សន្តិសុខសាធារណៈ (MOPAS) វិញ

[10] NCA ត្រូវបានប្តូរឈ្មោះទៅជាទីភ្នាក់ងារសង្គមព័ត៌មានជាតិ (NIA) នៅក្នុងខែតុលាឆ្នាំ2006

ចាប់ពីឆ្នាំ២០០៤ រហូតដល់ខែមិថុនា ឆ្នាំ២០០៦ ថវិកាប្រមាណ៥១៦លានដុល្លារអាមេរិកត្រូវបានវិនិយោគ ទៅលើកិច្ចការផ្សព្វផ្សាយរដ្ឋាភិបាលអេឡិចត្រូនិកចំនួន ១៣៧ ក្នុងនោះរួមបញ្ចូលទាំងអនុគម្រោងនៃផែនទីបង្ហាញផ្លូវសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក ចំនួន ១០៥ ផងដែរ[11] ។

សាធារណរដ្ឋកូរ៉េជាប់ចំណាត់ថ្នាក់លេខ ៦ នៅក្នុងចំណោមបណ្តាប្រទេសទូទាំងពិភពលោកនៅក្នុង ការស្ទង់មតិស្តីពីរដ្ឋាភិបាលអេឡិចត្រូនិករបស់អង្គការសហប្រជាជាតិនាឆ្នាំ២០០៨[12] ដែលមានពិន្ទុបូករួមចូលគ្នាសរុប ០,៨៣១៧ ។ ការស្ទង់ មតិរបស់អង្គការសហប្រជាជាតិ គ្របដណ្តប់លើវិស័យចំនួន ៣ ៖ ក) លិបិក្រមវិធានការលើបណ្តាញវ៉ែបសាយត៍ ខ) លិបិក្រមហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និង គ) សូចនាករមូលធនមនុស្ស ។ លិបិក្រមវិធានការលើបណ្តាញវ៉ែបសាយត៍ ដែលវាស់វែងវត្តមាននៅលើ អ៊ីនធឺណិតរបស់ទីភ្នាក់ងាររដ្ឋាភិបាល ផ្តល់ដល់រដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិនូវចំណាត់ថ្នាក់ប្រៀបធៀបមួយសម្រាប់លទ្ធភាព របស់រដ្ឋជាសមាជិកក្នុងការផ្តល់សេវាលើអ៊ីនធឺណិតដល់ប្រជាពលរដ្ឋ របស់ខ្លួន ។ ពិន្ទុលិបិក្រមវិធានការលើបណ្តាញ វ៉ែបសាយត៍របស់សាធារណរដ្ឋកូរ៉េនៅក្នុងការស្ទង់មតិរបស់អង្គការសហប្រជាជាតិគឺ ០,៨២២៧ ។

***ប្រអប់ ១ ៖ លិបិក្រមវិធានការលើបណ្តាញវ៉ែបសាយត៍របស់អង្គការសហប្រជាជាតិ***

ដំណាក់កាលទី១ – ការលេចឡើង

វត្តមាននៅលើអ៊ីនធឺណិតរបស់រដ្ឋាភិបាលមួយ រួមមានទំព័រនៅលើអ៊ីនធឺណិតមួយ និង/ឬ វ៉ែបសាយត៍ ផ្លូវការមួយ ។ អាសយដ្ឋានភ្ជាប់ទៅក្រសួង ឬមន្ទីរអប់រំ សុខាភិបាល សុខុមាលភាពសង្គម ការងារ និងហិរញ្ញវត្ថុអាចនឹងមាន ឬគ្មាន ។ ភាគច្រើននៃព័ត៌មានមានលក្ខណៈជាព័ត៌មានដែល មិនប្រែប្រួល ឬគ្មានបច្ចុប្បន្នភាព ហើយមានអន្តរកម្មតិចតួចជាមួយនឹង ប្រជាពលរដ្ឋ ។

ដំណាក់កាលទី២ – ការកែលម្អ

រដ្ឋាភិបាលផ្តល់ព័ត៌មានកាន់តែច្រើនថែមទៀត អំពីគោលនយោបាយសាធារណៈ និងអភិបាលកិច្ច ។ មានអាសយដ្ឋានតភ្ជាប់ទៅនឹងព័ត៌មានកាលប្បវត្តិ (ឧ. ឯកសារ ទម្រង់បែបបទ របាយការណ៍ ច្បាប់ និងបទប្បញ្ញត្តិ ព្រឹត្តិបត្រព័ត៌មាន) ដែលប្រជាពលរដ្ឋងាយស្រួលនឹងទទួលបាន ។

ដំណាក់កាលទី៣ – ភាពមានអន្តរកម្ម

រដ្ឋាភិបាលផ្តល់សេវានៅលើអ៊ីនធឺណិត ដូចជា ទម្រង់បែបបទដែលថតចម្លងយកបានសម្រាប់ការបង់ពន្ធ និងបែបបទស្នើសុំការបន្តអាជ្ញាប័ណ្ណ ។ លើសពីនេះទៅទៀត ច្រកបណ្តាញ ឬវ៉ែបសាយត៍ដែលមានភាពអន្តរកម្មជាមួយនឹងសេវា ដែលរៀបចំឡើងដើម្បីធ្វើអោយការទំនាក់ទំនងការងារជាមួយរដ្ឋាភិបាលមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋ កំពុងចាប់ផ្តើមមាន ឡើង ។

ដំណាក់កាលទី៤ – ភាពមានអន្តរកម្មទៅវិញទៅមក

រដ្ឋាភិបាលចាប់ផ្តើមបំលែងខ្លួនដោយបង្កើតអោយមានអន្តរកម្មទៅមករវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល ។ នេះរួមបញ្ចូល ទាំងជម្រើសសម្រាប់ការបង់ពន្ធ ការដាក់ពាក្យស្នើសុំអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត និងលិខិតឆ្លងដែន ការសុំអាជ្ញាប័ណ្ណបន្ត និងអន្តរកម្ម G2C ផ្សេងៗទៀត ព្រមទាំងអនុញ្ញាតអោយ ប្រជាពលរដ្ឋចូលប្រើប្រាស់សេវាទាំងនេះ នៅលើប្រព័ន្ធអ៊ីនធឺណិត ២៤ ម៉ោងលើ២៤ម៉ោងផងដែរ ។ រាល់កិច្ចការទំនាក់ទំនងទាំងអស់ ត្រូវបានធ្វើឡើងនៅលើ អ៊ីនធឺណិត ។

ដំណាក់កាលទី៥ – ការតភ្ជាប់

រដ្ឋាភិបាលប្រែក្លាយខ្លួនទៅជាអង្គភាពតភ្ជាប់បណ្តាញមួយ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ ប្រជាពលរដ្ឋតាមរយៈការបង្កើតហេដ្ឋារចនាសម្ព័ន្ធការិយាល័យគាំទ្ររួមបញ្ចូលគ្នា ។ នេះគឺជាកម្រិតជឿនលឿនបំផុតនៃរដ្ឋាភិបាលអេឡិចត្រូនិកនៅលើប្រព័ន្ធអ៊ីនធឺណិត ។ កម្រិតជឿនលឿនបំផុតនេះ ត្រូវបានសម្គាល់ដោយ ៖

1. ទំនាក់ទំនងខ្សែទទឹង (ក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាល)
2. ទំនាក់ទំនងខ្សែបណ្តោយ (ទីភ្នាក់ងាររដ្ឋាភិបាលថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន)
3. ទំនាក់ទំនងហេដ្ឋារចនាសម្ព័ន្ធ (លទ្ធភាពអន្តរប្រតិបត្តិការ)
4. ទំនាក់ទំនងរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ
5. ទំនាក់ទំនងក្នុងចំណោមភាគីពាក់ព័ន្ធ (រដ្ឋាភិបាល វិស័យឯកជន ស្ថាប័នសិក្សា អង្គការមិនមែន រដ្ឋាភិបាល និងសង្គមស៊ីវិល) ។

ជាងនេះទៅទៀត ការចូលរួមតាមប្រព័ន្ធអេឡិចត្រូនិក និងការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបាន គាំទ្រ និងលើកទឹកចិត្ត ដោយរដ្ឋាភិបាល នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ។

ប្រភព ៖ ដកស្រង់ចេញពីអង្គការសហប្រជាជាតិ ការស្ទង់មតិរបស់អង្គការសហប្រជាជាតិ ស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ២០០៨ ៖ ពីរដ្ឋាភិបាលអេឡិច ត្រូនិកឆ្ពោះទៅកាន់អភិបាលកិច្ចដែលតភ្ជាប់គ្នា (ទីក្រុងញូវយ៉ក ៖ អង្គការសហប្រជាជាតិ ឆ្នាំ២០០៨) http://unpan1.un.org/intradoc/groups/public/documents/UN/UNPAN028607.pdf ។

[11] NIA, ed., *របាយការណ៍រដ្ឋាភិបាលអេឡិចត្រូនិកប្រចាំឆ្នាំ២០០៦ (សេអ៊ូល ៖* MOGAHA ឆ្នាំ២០០៦) ១១ http://www.nia.or.kr/open_content/common/fileList/fileList.jsp?tn=PU_0000100&id=54651 .

[12] អង្គការសហប្រជាជាតិ ឆ្នាំ២០០៨ ការស្ទង់មតិរបស់អង្គការសហប្រជាជាតិ ស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ២០០៨ ៖ ពីរដ្ឋាភិបាល អេឡិចត្រូនិកទៅអភិបាលកិច្ចដែលមានការភ្ជាប់បណ្តាញ (ទីក្រុងញូវយ៉ក ៖ អង្គការសហប្រជាជាតិ ឆ្នាំ២០០៨) http://unpan1.un.org/intradoc/groups/public/documents/UN/UNPAN028607.pdf .

លិបិក្រមហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ វាស់វែងសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធដើម្បីផ្តល់សេវា រដ្ឋាភិបាលអេឡិចត្រូនិក ក្នុងនោះរាប់បញ្ចូលទាំងទូរដង់ស៊ីតេសម្រាប់ទាំងទូរស័ព្ទអចល័ត និងទូរស័ព្ទចល័តចំនួនកុំព្យូទ័រផ្ទាល់ខ្លួន ចំនួនអ្នកប្រើ ប្រាស់អ៊ីនធឺណិត និងការភ្ជាប់បណ្តាញដោយគ្មានខ្សែ ។ ពិន្ទុសូចនាករហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍របស់សាធារណរដ្ឋកូរ៉េ នៅក្នុងឆ្នាំ២០០៨ គឺ ០,៦៨៨៦ ។

លិបិក្រមមូលធនមនុស្ស បូកបញ្ចូលគ្នានូវអត្រាអក្ខរកម្មមនុស្សពេញវ័យ និងអនុបាតនៃការចុះឈ្មោះ ចូលរៀនសរុបសម្រាប់ការអប់រំនៅថ្នាក់បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ។ សូចនាករមូលធនមនុស្សរបស់សាធារណរដ្ឋកូរ៉េ មាន ពិន្ទុខ្ពស់ណាស់ គឺ ០,៩៨៤១ ។

## ២.៥. ផែនការថវិការដ្ឋាភិបាលអេឡិចត្រូនិក

ដូចដែលបង្ហាញនៅក្នុងរូបភាពទី ៥ ថវិកា ICT គួរតែចាត់ចែងខុសពីថវិកាធម្មតា ។ ជាធម្មតា ថវិកា ICT ត្រូវបានចាត់ទុកជាការវិនិយោគដើមទុនរយៈពេលវែង ជាជាងការចំណាយរយៈពេលខ្លី ។ ការផ្តល់មូលនិធិសម្រាប់ការអនុវត្តគម្រោង ICT អាចនឹងទទួលបានដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ។ វិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រទាំងនេះ គឺភាពជាដៃគូ រវាងវិស័យសាធារណៈ–វិស័យឯកជន ដែលត្រូវបានពិភាក្សានៅក្នុងម៉ូឌុលទី៨ នៃកម្រងម៉ូឌុលបណ្ឌិតសភានៃមូលដ្ឋានគ្រឹះ ICT សម្រាប់មេ ដឹកនាំរដ្ឋាភិបាល ។

**រូបភាពទី ៥ ៖ ផែនការថវិកាធម្មតា និងការវិនិយោគលើ ICT**



*នៅក្នុងសាធារណរដ្ឋកូរ៉េ ថវិកាសម្រាប់ការធ្វើព័ត៌មានីយកម្មនៅក្នុងឆ្នាំ២០០៦ គឺ ៣,៤ពាន់លាន ដុល្លារអាមេរិក ក្នុងនោះប្រហែល ៩១៧លានដុល្លារអាមេរិក* (២៦,៧%) *ត្រូវបានលៃលកសម្រាប់ការអនុវត្តគម្រោងរដ្ឋាភិបាលអេឡិចត្រូនិក និង ៩,៥លានដុល្លារអាមេរិក* (២,៨%) *សម្រាប់ការកាត់ បន្ថយគម្លាតវិស័យឌីជីថល ។ ថវិកានេះ ត្រូវបានធ្វើ វិភាជន៍ទៅតាមវិស័យអាទិភាព ឬវិស័យនានាដែលនឹងសម្រេចបានលទ្ធផលប្រកបដោយនិរន្តរភាពដូចជាការកាត់បន្ថយ ឯកសារនៅលើក្រដាស និងការសន្សំសំចៃថ្លៃចំណាយរដ្ឋបាល និងសង្គមកិច្ច*[13] ។

*ចាប់តាំងពីឆ្នាំ២០០៥មក ថវិកាសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េត្រូវបានផ្ទេរពី មូលនិធិជំរុញ* ICT *ទៅគណនីទូទៅ ហើយថវិកាសម្រាប់គម្រោងផែនទីបង្ហាញផ្លូវនីមួយៗត្រូវបានអនុវត្ត ដោយ* NCA (*ក្រោយមកត្រូវបាន ប្តូរឈ្មោះទៅជា* NIA) *ក្រោយពីមានការសម្របសម្រួលដោយ* MOGAHA (*ក្រោយមកត្រូវបានប្តូរឈ្មោះទៅជា* MOPAS) *និងការពិចារណាហ្មត់ចត់ដោយគណៈកម្មាធិការមួយ ។*

***កិច្ចការដែលត្រូវអនុវត្ត***

*ប្រសិនបើរដ្ឋាភិបាលរបស់អ្នកមានផែនទីបង្ហាញផ្លូវ ឬផែនការសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក ៖*

1. *ចូរស្វែងរកព័ត៌មានថាតើមានផែនការអនុវត្ត ឬអត់ ហើយវិភាគភាពខ្លាំង និងភាពខ្សោយនៃ ផែនការនេះ ។*
2. *ចូរស្វែងរកព័ត៌មានថាតើថវិកាអ្វីសម្រាប់ការអនុវត្តផែនទីបង្ហាញផ្លូវ ឬផែនការរដ្ឋាភិបាលអេឡិច ត្រូនិកថាតើថវិកានេះត្រូវបានធ្វើវិភាជន៍យ៉ាងដូចម្តេច និងថាតើប្រភពមូលនិធិបានមកពីណា ។ ចូរបញ្ជាក់ថាតើអ្នកគិតថាផែនការ ថវិកានេះគ្រប់គ្រាន់ដែរឬទេ និងមូលហេតុនៃការវាយតម្លៃ របស់អ្នក ។*

### ***៣.០. ប្រភេទនៃកម្មវិធី ICT និងការអនុវត្ត***

*ដូចដែលបានលើកឡើងនៅក្នុងផ្នែកមុនដែរ វិស័យបីនៃកម្មវិធី* ICT *ពោលគឺនវានុវត្តន៍សេវាប្រជា ពលរដ្ឋថ្មីៗ* (G2C) *នវានុវត្តន៍សេវាអាជីវកម្ម* (G2B) *និងនវានុវត្តន៍របៀបធ្វើការងាររបស់រដ្ឋាភិបាល* (G2G) *នឹងត្រូវលើកយកមក ពិភាក្សាលម្អិត ។ ឧទាហរណ៍ភាគច្រើនបំផុតត្រូវបានដកស្រង់ចេញពីបទពិសោធន៍ រដ្ឋាភិបាលអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ ។ រូបភាពទី ៦ បង្ហាញអំពីក្របខ័ណ្ឌទស្សនាទានសម្រាប់ រដ្ឋាភិបាលអេឡិចត្រូនិកនៅកូរ៉េ ។ រូបភាពនេះបង្ហាញអំពី លទ្ធភាពច្រើនច្រកក្នុងការចូលទៅដល់* window *តែមួយ ប្រភេទនៃសេវារួមបញ្ចូលគ្នាដែលបានផ្តល់ និងកម្មវិធីគ្រប់គ្រង ការភ្ជាប់បណ្តាញ នៅកម្រិតនាយកដ្ឋាន និងការធ្វើសមាហរណកម្មទិន្នន័យនីមួយៗ ។*

***រូបភាពទី ៦ ៖ ក្របខ័ណ្ឌទស្សនាទាននៃរដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ***[14]

(*ប្រភព ៖* Soh Bong Yu “*រដ្ឋាភិបាលអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ ៖ របៀបដែលយើងកំពុងធ្វើការងារជាមួយរដ្ឋាភិបាលអេឡិចត្រូចនិច*” (*បទបង្ហាញ* KADO) ៥ https://www.kado.or.kr/koil/bbs/board_view.asp?config_code=362&offset=0&board_code=3246)

---

[13] NIA, ed., *របាយការណ៍រដ្ឋាភិបាលអេឡិចត្រូនិកប្រចាំឆ្នាំ២០០៦ (សេអ៊ូល ៖* MOGAHA ឆ្នាំ២០០៦) ១០ http://www.nia.or.kr/open_content/common/fileList/fileList.jsp?tn=PU_0000100&id=54651 .

[14] ចាប់តាំងពីពេលដែលរដ្ឋាភិបាលកូរ៉េថ្មីចូលកាន់តំណែងនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨មកការរៀបចំរដ្ឋាភិបាលត្រូវបានផ្លាស់ប្តូររចនាសម្ព័ន្ធ ។ ក្រសួងព័ត៌មាន និងទូរគមនាគមន៍ត្រូវបានច្របាច់បញ្ចូលគ្នាជាមួយក្រសួងរដ្ឋបាល និងសន្តិសុខសាធារណៈ (MOPAS) ហើយក្រសួងរដ្ឋបាលរដ្ឋាភិបាល និងកិច្ចការផ្ទៃក្នុង (MOGAHA) ត្រូវបានប្តូរឈ្មោះទៅជាក្រសួងរដ្ឋបាល និងសន្តិសុខសាធារណៈ (MOPAS, http://www.mopas.go.kr) ។ ទីភ្នាក់ងារកុំព្យូទ័រភាវូនីយកម្មជាតិ (NCA) ត្រូវបានប្តូរឈ្មោះទៅជាទីភ្នាក់ងារសង្គមព័ត៌មានជាតិ (NIA, http://www.nia.or.kh) នៅខែតុលា ឆ្នាំ២០០៦ ។ ទាំង KADO និង NIA ស្ថិតនៅក្រោមឱវាទរបស់ MOPAS .




### ៣.១. កម្មវិធីរដ្ឋាភិបាល–ទៅ–ប្រជាពលរដ្ឋ (G2C)

#### សេវាប្រជាពលរដ្ឋនៅលើអ៊ីនធឺណិត (ច្រកបណ្តាញ G2C)

ភាពគ្មានប្រសិទ្ធផលនៅក្នុងកិច្ចការរដ្ឋបាលនៃរដ្ឋាភិបាល ត្រូវបានរកឃើញសគល់ទៅដល់ការមានមូលដ្ឋាន ទិន្នន័យជាតិ ដាច់ដោយឡែកពីគ្នា ដូចជា មូលដ្ឋានទិន្នន័យសម្រាប់ប្រជាពលរដ្ឋ កម្មសិទ្ធិដីធ្លី យានយន្ត និងពន្ធដារ ។ ការមានមូលដ្ឋានទិន្នន័យដាច់ដោយឡែកពីគ្នាមានន័យថា ប្រជាពលរដ្ឋត្រូវតែធ្វើ ការចុះបញ្ជីជាច្រើនដង ឆ្លងកាត់បែបបទ ឯកសារជាច្រើនសម្រាប់ការបញ្ជាក់ និងធ្វើដំណើរជាច្រើនលើក ច្រើនសាទៅកាន់ទីភ្នាក់ងាររដ្ឋាភិបាល ។ ដើម្បីកែលម្អ ប្រសិទ្ធផល និងផលិតភាពរដ្ឋបាល ប្រព័ន្ធមួយ សម្រាប់តភ្ជាប់មូលដ្ឋានទិន្នន័យជាតិធំៗ និងច្រកបណ្តាញផ្លូវការរបស់រដ្ឋាភិបាល សម្រាប់សេវាស៊ីវិល ត្រូវបានបង្កើតឡើងនៅក្នុងសាធារណរដ្ឋកូរ៉េ ។ ច្រកបណ្តាញ G2C គឺជាច្រកចេញចូល (Window) រួមមួយដែលប្រជាពលរដ្ឋ និងអាជីវកម្មអាចទទួលបានសេវារដ្ឋាភិបាលផ្សេងៗ ដោយប្រើប្រាស់ច្រកជាច្រើន (សូមមើលរូបភាពទី ៧) ។

**រូបភាពទី ៧ ៖ រដ្ឋាភិបាលអេឡិចត្រូនិក Window រួម**

(ប្រភព ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្មរដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារជាតិ កុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០២) ៣៩
http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023903.pdf)




នៅក្នុងប្រព័ន្ធនេះ រដ្ឋាភិបាលផ្តល់សេវាផ្សេងៗ ក្នុងនោះរាប់បញ្ចូលទាំងការចេញវិញ្ញាបនបត្រ ផ្សេងៗ ការពិគ្រោះយោបល់ ចំណាត់ការចំពោះញត្តិស៊ីវិល ការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និងការផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋាភិបាល ។ វិធីសាស្ត្រពហុមធ្យោបាយ (multi-channel) គឺជាការចាំបាច់ដើម្បីធានានូវការចូលរួមជាអតិបរមារបស់ប្រជាពលរដ្ឋ និង អាជីវកម្ម នៅក្នុងសេវារដ្ឋាភិបាលអេឡិចត្រូនិក ពីព្រោះក្រុមផ្សេងៗគ្នានឹងមានកម្រិតនៃលទ្ធភាពខុសៗគ្នា ដើម្បី ប្រើប្រាស់មធ្យោបាយទាំងនេះ ។ ឧទាហរណ៍ ប្រជាពលរដ្ឋជនបទមានលទ្ធភាពប្រើប្រាស់មធ្យោបាយ អេឡិចត្រូនិក (ដូចជាអ៊ីនធឺណិត អ៊ីមែល ទូរស័ព្ទ ទូរទស្សន៍ឌីជីថល) តិចជាងប្រជាពលរដ្ឋនៅទីក្រុង[15] ។

មធ្យោបាយផ្តល់សេវាច្រកចេញចូលតែមួយខុសៗគ្នា ដែលអាចប្រើប្រាស់ ដើម្បីបង្កើនលទ្ធភាព ទទួលបានសេវារដ្ឋាភិបាលអេឡិចត្រូនិក រួមមានដូចខាងក្រោម ៖

- មណ្ឌលសេវាប្រជាពលរដ្ឋច្រកចេញចូលតែមួយ ដែលនៅកន្លែងនេះ ការផ្តល់សេវាច្រកចេញ ចូលតែមួយ ត្រូវបានអនុវត្តដោយទីភ្នាក់ងារជាច្រើន ដែលរួមកម្លាំងគ្នាដើម្បីបម្រើអតិថិជនដែលចូលចិត្ត ឬអាចមាន លទ្ធភាពសម្រាប់ការទំនាក់ទំនងជួបមុខគ្នាផ្ទាល់ ។ ឧទាហរណ៍នៃ មណ្ឌលសេវាប្រជាពលរដ្ឋបែបនេះ អាចឃើញមាននៅក្នុងប្រទេសអូស្ត្រាលី ប្រេស៊ីល កាណាដា អាល្លឺម៉ង់ ឥណ្ឌា កាហ្សាក់ស្ថាន ព័រទុយហ្គាល់ អាហ្វ្រិកខាងត្បូង និងចក្រភព អង់គ្លេស ។
- ទូរមណ្ឌល - ចំណុចចេញចូលជាសាធារណៈដែលផ្តល់លទ្ធភាពក្នុងការទទួលបានសេវា រដ្ឋាភិបាលអេឡិចត្រូនិក ដោយឥតគិតថ្លៃ ឬដោយមានឧបត្ថម្ភកធន (តាមរយៈបណ្តាញប៉ុស្តិ៍ប្រៃសណីយ៍ បណ្ណាល័យ សាលារៀន មណ្ឌលសហគមន៍ ។ល។) ។
- មណ្ឌលសេវាតាមទូរស័ព្ទ — ការផ្តល់សេវាតាមរយៈទូរស័ព្ទដែលផ្តល់ដោយមណ្ឌលសេវា តាមទូរស័ព្ទរបស់រដ្ឋ ដែលជាធម្មតាត្រូវបានម៉ៅការបន្តទៅអោយអ្នកម៉ៅការឯកជន ។ ឧទាហរណ៍នៃមណ្ឌលបែបនេះ អាចឃើញ មាននៅក្នុងប្រទេសកាណាដា អ៊ីតាលី និង សហរដ្ឋអាមេរិក ។
- ច្រកបណ្តាញវែបសាយត៍ - ការផ្តល់សេវាតាមរយៈវែបសាយត៍រដ្ឋាភិបាលដែលងាយស្រួល ប្រើដោយផ្អែកលើ បច្ចេកវិទ្យាដែលអាចប្រតិបត្តិការរួមគ្នាបាន ។ ឧទាហរណ៍អាចឃើញមាននៅក្នុងប្រទេសកាណាដា សាធារណរដ្ឋកូរ៉េ សិង្ហបុរី ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ។
- រដ្ឋាភិបាលទូរស័ព្ទចល័ត (M-Government) — ការផ្តល់សេវាតាមរយៈសារទូរស័ព្ទខ្លីៗ និង វែបសាយត៍ដែលបង្កើតឡើងជាក់លាក់សម្រាប់សេវា m-government ។ ឧទាហរណ៍អាច ឃើញមាននៅក្នុងប្រទេសឥណ្ឌា ហ្វីលីពីន និងចក្រភពអង់គ្លេស ។
- សេវារដ្ឋាភិបាលតាមទូរទស្សន៍ (T-Government) — ការផ្តល់សេវាអេឡិចត្រូនិកដែលផ្អែក លើទូរទស្សន៍ឌីជីថលដែលមានភាពអន្តរកម្មតាមរយៈប៉ុស្តិ៍ទូរទស្សន៍/ វែបសាយត៍រដ្ឋាភិបាល ដែលបង្កើតឡើងជាក់លាក់ ជាមួយនឹងការផ្តល់ខ្លឹមសារព័ត៌មានផ្សព្វផ្សាយ និងតាមតម្រូវការ ។

[15] សម្រាប់ព័ត៌មានបន្ថែមទៀតអំពីប្រភេទផ្សេងៗនៃច្រកចេញចូលតែមួយដែលមានពហុមធ្យោបាយសម្រាប់ការប្រើប្រាស់សេវារដ្ឋាភិបាល សូម មើលឯកសារយោង ៖ ធនាគារពិភពលោក រដ្ឋាភិបាលអេឡិចត្រូនិកសម្រាប់ទាំងអស់គ្នា — *ការពិនិត្យអំពីបទពិសោធន៍អន្តរជាតិស្តីពីការកែលម្អ លទ្ធភាព តម្រូវការ និងការចូលរួមរបស់សាធារណៈ នៅក្នុងសេវារដ្ឋាភិបាលអេឡិចត្រូនិក ៖ ផ្តោះទៅរកយុទ្ធសាស្ត្រសមាហរណកម្មឌីជីថល សម្រាប់ប្រទេសកាហ្សាក់ស្ថាន កំណត់ត្រាប្រឹក្សាបច្ចេកទេសសម្រាប់ការអនុវត្តរដ្ឋាភិបាលអេឡិចត្រូនិករបស់* ISG (សេចក្តីព្រាង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦) ។

ឧទាហរណ៍មាននៅក្នុងប្រទេសចិន អ៊ីតាលី សាធារណរដ្ឋកូរ៉េ ចក្រភពអង់គ្លេស និង សហរដ្ឋអាមេរិក[16] ។

ក្នុងករណីសាធារណរដ្ឋកូរ៉េ ចលនាឆ្ពោះទៅរករដ្ឋាភិបាលច្រកចេញចូលតែមួយពហុមធ្យោបាយ និងផ្តោតសំខាន់លើប្រជាពលរដ្ឋបានចាប់ផ្តើមជាមួយនឹងការបង្កើតវេបសាយត៍ផ្លូវការរបស់រដ្ឋាភិបាលកូរ៉េ និងមណ្ឌលសេវាប្រជាពលរដ្ឋតាមផ្ទះ នៅក្នុងឆ្នាំ១៩៩៧ ដើម្បីផ្តល់បែបបទស្នើសុំព័ត៌មាន និងសេវារដ្ឋបាលជាលក្ខណៈប្រព័ន្ធដល់សាធារណជន ។ នៅក្នុងឆ្នាំ១៩៩៩ សេវាប្រជាពលរដ្ឋ ២០ប្រភេទ អាចរកបានតាមរយៈមណ្ឌលសេវាប្រជាពលរដ្ឋតាមផ្ទះ ។ នៅក្នុងឆ្នាំ២០០០ មណ្ឌលនេះ ត្រូវបានច្របាច់បញ្ចូលគ្នាជាមួយប្រព័ន្ធរដ្ឋបាលនៅក្នុងក្រសួង ដើម្បីអោយប្រជាពលរដ្ឋអាចបញ្ជូនសំណើពីកុំព្យូទ័រផ្ទាល់ខ្លួន របស់ពួកគេ ហើយបន្ទាប់មក ទទួលឯកសារដែលបានស្នើសុំនៅផ្ទះរបស់ពួកគេតាមរយៈការផ្ញើតាមប៉ុស្តិ៍ ប្រៃសណីយ៍ ។

គម្រោង G2C ត្រូវបានចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ២០០០ ដើម្បីជួយអោយប្រជាពលរដ្ឋអាចមាន លទ្ធភាព ងាយស្រួលក្នុងការទទួលបានព័ត៌មាន និងដើម្បីប្រើប្រាស់សេវាស៊ីវិលនៅលើអ៊ីនធឺណិតតាមច្រកចេញចូលតែមួយ នៅពេលណា និងនៅកន្លែងណាក៏បាន ។ នៅខែមេសា ឆ្នាំ២០០២ ជំហានទី១ និង ជំហានទី២នៃ G2C ត្រូវបានអនុវត្តចប់ ជាស្ថាពរ ។ ISP សម្រាប់កែលម្អសេវាប្រជាពលរដ្ឋនៅលើអ៊ីនធឺណិតត្រូវបានអនុវត្តនៅក្នុងឆ្នាំ២០០៣ ដើម្បីចាក់គ្រឹះសម្រាប់ប្រព័ន្ធ G2C ដែល មានស្តង់ដារ ។ បច្ចុប្បន្នប្រជាពលរដ្ឋកូរ៉េអាចដាក់ពាក្យស្នើសុំចូលប្រើប្រាស់ និងទទួលបានឯកសារបញ្ជាក់នានាតាមរយៈសេវារដ្ឋបាលស៊ីវិលនៅលើអ៊ីនធឺណិត G2C នៅពេលណាមួយ និងនៅកន្លែងណាមួយក៏បាន ដោយមិនចាំបាច់ធ្វើដំណើរទៅកាន់ ការិយាល័យរដ្ឋាភិបាល ។ គិតត្រឹមខែមិថុនា ឆ្នាំ២០០៦ ចំនួននៃសេវាដែលបានផ្តល់បានរីកធំគួរអោយកត់សម្គាល់រហូតដល់ទៅប្រហែល ៥.០០០ប្រភេទនៃ គោលការណ៍ណែនាំ សម្រាប់មុខងារសាធារណៈ ៦៣០ប្រភេទនៃពាក្យស្នើសុំស៊ីវិល និង ៣០ ប្រភេទនៃការធានារ៉ាប់រងតាមប្រព័ន្ធអ៊ីនធឺណិត ។ លើសពីនេះទៅទៀត កិច្ចប្រឹងប្រែងដ៏ខ្លាំងក្លាដើម្បីជំរុញ ការប្រើប្រាស់ សេវាសម្រាប់សាធារណៈ និងការតភ្ជាប់ទៅកាន់វេបសាយត៍ឯកជននានា ដូចជា NAVER[17] និងវេបសាយត៍ផ្សេងៗទៀត បាននាំអោយមានការកើនឡើងគួរអោយកត់សម្គាល់នូវការប្រើប្រាស់ សេវានេះ ៖ ពីតិចជាង ១.០០០នាក់ក្នុងមួយថ្ងៃនៅក្នុងឆ្នាំ ២០០២ នៅពេលដែលសេវានេះត្រូវបានចាប់ផ្តើមសម្ពោធដាក់អោយដំណើរការ រហូតដល់ ៤៥.០០០នាក់ ក្នុងមួយថ្ងៃ គិត ត្រឹមខែមិថុនា ឆ្នាំ២០០៦ (សូមមើលរូបភាពទី ៨) ។

គ្រឹះដ៏រឹងមាំសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិកទំនើប នៅក្នុងសាធារណរដ្ឋកូរ៉េត្រូវបានបង្កើតឡើងជាមួយ នឹងការកសាងប្រព័ន្ធសេវាប្រជាពលរដ្ឋនៅលើអ៊ីនធឺណិត និងការតភ្ជាប់មូលដ្ឋានទិន្នន័យជាតិធំៗចំនួន ៥ ក្នុងនោះរាប់បញ្ចូលទាំងមូលដ្ឋាន ទិន្នន័យប្រជាពលរដ្ឋ ដីធ្លី យានយន្ត ពន្ធដារ និងធានារ៉ាប់រង ។ ប្រព័ន្ធសេវាប្រជាពលរដ្ឋថ្មីនេះបានកែលម្អគុណភាពជីវិតរបស់ប្រជាពលរដ្ឋ និងប្រសិទ្ធផលនៃកិច្ចការរដ្ឋបាលដោយផ្តល់សេវាដែលមានតម្រូវការឯកសារតិចតួច និងការធ្វើដំណើរទៅកាន់ការិយាល័យ រដ្ឋាភិបាលដោយផ្ទាល់កាន់តែតិចតួច ។ ប្រសិនបើគិតជាមធ្យម ៣០%នៃសេវាប្រជាពលរដ្ឋសរុបត្រូវបានចាត់ការនៅលើអ៊ីនធឺណិតក្នុងរយៈពេល ៥ឆ្នាំ ការសន្សំប្រាក់បានប្រហែល ១,៨ពាន់លានដុល្លារ ត្រូវបានគេរំពឹងទុក នៅពេលដែលការអនុវត្ត ប្រព័ន្ធត្រូវបានបញ្ចប់ជាស្ថាពរ ។




(ឯកតា ៖ ១.០០ករណី)

**រូបភាពទី ៨ ៖ ការប្រើប្រាស់សេវា G2C នៅសាធារណរដ្ឋកូរ៉េ**

(ប្រភព ៖ NIA, ed., របាយការណ៍រដ្ឋាភិបាលអេឡិចត្រូនិកប្រចាំឆ្នាំ២០០៦ (សេអ៊ូល ៖ MOGAHA ឆ្នាំ២០០៦) ២២ http://www.nia.or.kr/open_content/common/fileList/fileList.jsp?tn=PU_0000100&id=54651)

រូបភាពទី ៩ បង្ហាញអំពីរបៀបដែលប្រព័ន្ធ G2C ដំណើរការ ។ ប្រព័ន្ធនេះអាចបែងចែកជា ៣ផ្នែក ៖ ១) ចំណុចទាក់ទង តែមួយ ដែលប្រជាពលរដ្ឋអាចទទួលបានព័ត៌មាន និងសេវារដ្ឋាភិបាលនៅកន្លែងណា និងនៅពេលណាក៏បានតាមរយៈអ៊ីនធឺណិត ២) ប្រព័ន្ធសម្រាប់ការចែករំលែកព័ត៌មានដែលត្រូវបាន រចនាឡើងដើម្បីផ្តល់លទ្ធភាពដល់នាយកដ្ឋានីមួយៗដើម្បីចែករំលែកព័ត៌មាន និង ៣) ហេដ្ឋារចនាសម្ព័ន្ធ ដូចជាសេវាវិញ្ញាបនបត្រអេឡិចត្រូនិក ច្រកចូលសម្រាប់ការទូទាត់ប្រាក់ និងសេវាទូរស័ព្ទចល័ត ។

[16] Ibid.
[17] NAVER គឺជាវេបសាយត៍អ៊ីនធឺណិតមួយក្នុងចំណោមវេបសាយត៍អ៊ីនធឺណិតដែលពេញនិយមនៅក្នុងសធារណរដ្ឋកូរ៉េ ដែលប្រតិបត្តិការដោយ សាជីវកម្ម NHN, http://www.naver.com.

***រូបភាពទី ៩ ៖ Window ដំណើរការរួមរដ្ឋាភិបាលអេឡិចត្រូនិកសម្រាប់សាធារណរដ្ឋកូរ៉េ***

(*ប្រភព ៖* Soh Bong Yu “*រដ្ឋាភិបាលអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ ៖ របៀបដែលយើងកំពុងធ្វើការងារជាមួយរដ្ឋាភិបាលអេឡិចត្រូចនិច*” (*បទបង្ហាញ* KADO) *១៩* https://www.kado.or.kr/koil/bbs/board_view.asp?config_code=362&offset=0&board_code=3246)




*នៅក្នុងប្រទេសកម្ពុជាប្រព័ន្ធព័ត៌មានរួមបញ្ចូលគ្នាសម្រាប់សេវារដ្ឋាភិបាលក៏ត្រូវបានបង្កើតឡើងផងដែរ ។*

**គម្រោងប្រព័ន្ធព័ត៌មានរដ្ឋបាលរដ្ឋាភិបាល (GAIS) នៅកម្ពុជា**

*គម្រោងប្រព័ន្ធព័ត៌មានរដ្ឋបាលរដ្ឋាភិបាល* (GAIS) *ត្រូវបានផ្តួចផ្តើមគំនិតឡើងដោយរាជ រដ្ឋាភិបាលកម្ពុជា ជាគម្រោងដ៏សំខាន់បំផុតមួយដើម្បីណែនាំការប្រើប្រាស់* ICT *ដល់សង្គមកម្ពុជា និងដើម្បីពន្លឿនកំណែទម្រង់រដ្ឋបាល ។ នៅក្នុងខែសីហា ឆ្នាំ២០០០ អាជ្ញាធរជាតិទទួលបន្ទុក កិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា ត្រូវបានបង្កើតឡើង និងចាត់តាំងអោយអនុវត្ត គម្រោង* GAIS *ភ្លាមៗ ។*

*គម្រោង* GAIS *មានកម្មវិធីស្នូលចំនួន ៣ ៖*

1. *ប្រព័ន្ធផ្តល់ការយល់ព្រមអេឡិចត្រូនិក* — *ដើម្បីអនុញ្ញាតអោយក្រសួងអាចផ្លាស់ប្តូរឯកសារ និងអ៊ីម៉ែល គ្រប់គ្រង ឯកសារ និងចុះផ្សាយសេចក្តីប្រកាសនានាដោយងាយស្រួល ។*

2. *ការចុះបញ្ជីអចលនវត្ថុ* — *ដើម្បីគ្រប់គ្រង និងតាមដានទិន្នន័យជាមូលដ្ឋានស្តីពីអចលទ្រព្យ ការផ្ទេរកម្មសិទ្ធិ ពន្ធ និងស្ថិតិផ្សេងៗទៀត ។*

3. *ការចុះបញ្ជីអត្រានុកូលដ្ឋាន* — *ដើម្បីគ្រប់គ្រង និងតាមដានទិន្នន័យជាមូលដ្ឋានអំពីប្រជាពលរដ្ឋ ការផ្លាស់ប្តូរនៅក្នុង គ្រួសារ កម្រិតវប្បធម៌ និងស្ថានភាពការងារ ពន្ធដែលជំពាក់ ឬបង់រួច និងស្ថិតិផ្សេងៗទៀត ។*

4. *ការចុះបញ្ជីយានយន្ត* — *ដើម្បីគ្រប់គ្រង និងតាមដានទិន្នន័យជាមូលដ្ឋានស្តីពីយានយន្ត និងម្ចាស់យានយន្ត ដំណើរការនៃការចុះបញ្ជី ការផ្ទេរកម្មសិទ្ធិ ព័ត៌មានអធិការកិច្ច ពន្ធដែលជំពាក់ ឬបង់រួច និងស្ថិតិផ្សេងៗទៀត ។*

*ហេដ្ឋារចនាសម្ព័ន្ធសម្រាប់កម្មវិធីទាំង៤នេះ ផ្អែកលើបណ្តាញកុំព្យូទ័រនៅនឹងកន្លែងមួយ និងបណ្តាញ ទូលំទូលាយសម្រាប់ក្រសួង និងរដ្ឋលេខាធិការដ្ឋានទាំង ២៧ និងសាលារាជធានីភ្នំពេញ ។*

*គម្រោងនេះមានបំណងដើម្បីបង្កើនប្រសិទ្ធផលនៃដំណើរការចុះបញ្ជី និងប្រព័ន្ធផ្តល់ការយល់ព្រមលើ ឯកសារដោយបំលែងព័ត៌មានទៅជាទម្រង់ឌីជីថល និងតភ្ជាប់ក្រសួងមន្ទីររដ្ឋាភិបាលតាមប្រព័ន្ធ អេឡិចត្រូនិក ។ ប្រព័ន្ធទាំងមូលត្រូវបាន រៀបចំឡើងដើម្បីបង្កើតចំណូលសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ។*

GAIS បានដើរតួនាទីដើម្បីទប់ស្កាត់បទល្មើសនានាដែលទាក់ទងនឹងយានយន្ត និងអចលនវត្ថុផ្សេងទៀត ។ អំពើប្លន់យានយន្តត្រូវបានកាត់បន្ថយគួរអោយកត់សម្គាល់ ពីព្រោះយានយន្តមិនអាចចុះបញ្ជីម្តងទៀតបានឡើយ ។ ប្រព័ន្ធនេះ ក៏បានកាត់បន្ថយថ្លៃចំណាយទៅលើការចុះបញ្ជី ព្រមទាំងពេលវេលា ដែលត្រូវការចាំបាច់ដើម្បីធ្វើការចុះបញ្ជីផងដែរ ។ នៅមុន ការដាក់ពង្រាយ GAIS ការចុះបញ្ជីត្រូវចំណាយប្រាក់ចន្លោះពី ២០.០០០រៀល ទៅ ៥០.០០០រៀល (៥ ទៅ ១២,៥០ដុល្លារ សហរដ្ឋអាមេរិក) ។ នេះគឺជាថ្លៃចំណាយបន្ថែមពីលើតម្លៃផ្លូវការ ។ ជាមួយនឹង GAIS ថ្លៃចំណាយបន្ថែមក្រៅទាំងនេះ លែងមានទៀតហើយ ។

គម្រោង GAIS ដែលចាប់ផ្តើមអនុវត្តនៅក្នុងខែតុលា ឆ្នាំ២០០៤ ត្រូវបានរៀបចំឡើងជាគម្រោងសាកល្បង ។ គម្រោងក្រោយមកទៀត គឺប្រព័ន្ធព័ត៌មានរដ្ឋបាលរាជធានី–ខេត្ត បច្ចុប្បន្ន កំពុងដំណើរការដើម្បីអនុវត្តគំរូនេះនៅក្នុងបណ្តា ខេត្ត–ក្រុងផ្សេងទៀត ។

ប្រភព ៖ Leewood Phu កម្ពុជា ៖ វិថីឆ្ពោះទៅរកអភិបាលកិច្ចអេឡិចត្រូនិក (ទីក្រុងបាងកក ៖ UNDP-APDIP ឆ្នាំ២០០៥)
http://www.apdip.net/projects/e-government/capblg/casestudies/Cambodia.pdf ។

Nobert Klein “.kh កម្ពុជា” នៅក្នុងរបាយការណ៍ស្ថានភាពឌីជីថលនៃតំបន់អាស៊ី–ប៉ាស៊ីហ្វិក ឆ្នាំ២០០៥/២០០៦ (ORBICOM, IDRC, UNDP-APDIP : 2005)
http://www.digital-review.org/2005-6PDFs/2005%20C12%20kh%20Cambodia%20124-127.pdf ។

### ប្រព័ន្ធពន្ធដាររួមបញ្ចូលគ្នា[18]

ប្រព័ន្ធពន្ធដារដែលរួមបញ្ចូលគ្នានៅលើអ៊ីនធឺណិតនៅក្នុងសាធារណរដ្ឋកូរ៉េ មានគោលបំណងដើម្បីជួយ សម្រួលដល់ការប្រើប្រាស់សេវាពន្ធដារតាមផ្ទះ (Home Tax Service) ដែលផ្តល់លទ្ធភាពដល់អ្នកបង់ពន្ធ ដើម្បីធ្វើកិច្ចការទាំងឡាយដែលទាក់ទងនឹងពន្ធដារ ដោយមិនចាំបាច់ធ្វើដំណើរទៅកាន់ការិយាល័យ ពន្ធដារ ។ កន្លងមក ការិយាល័យពន្ធដារជាតិ (NTS) ផ្ញើលិខិតជូនដំណឹងអំពីការបង់ពន្ធតាមរយៈ ប៉ុស្តិ៍ប្រៃសណីយ៍ ហើយអ្នកបង់ពន្ធធ្វើដំណើរដោយផ្ទាល់ខ្លួនទៅកាន់ការិយាល័យ NTS ដើម្បីបំពេញ បែបបទបង់ពន្ធ ។ អ្នកបង់ពន្ធធ្វើដំណើរទៅកាន់ធនាគារដោយផ្ទាល់ខ្លួន ដើម្បីបង់ពន្ធ ឬប្រើប្រាស់ ជម្រើសទូទាត់ការបង់ពន្ធជាតិតាមរយៈសេវាធនាគារតាមអ៊ីនធឺណិតដែលមាន ។

គោលបំណងនៃប្រព័ន្ធពន្ធដាររួមបញ្ចូលគ្នានេះ គឺដើម្បីបង្កើនចំណូលពន្ធ ទប់ស្កាត់អំពើពុករលួយ បង្កើនការបង់ពន្ធ ដោយស្ម័គ្រចិត្តដោយអ្នកបង់ពន្ធ បង្កើតរដ្ឋបាលពន្ធដារដែលទំនើប និងធានានូវសេវាសាធារណៈដែលរហ័សទាន់ចិត្ត និងមាន ភាពត្រឹមត្រូវ ។

ប្រព័ន្ធពន្ធដារនៅលើអ៊ីនធឺណិតគ្របដណ្តប់លើពន្ធលើប្រាក់ចំណូល ពន្ធសាជីវកម្ម ពន្ធលើតម្លៃបន្ថែម ពន្ធលើអចលនវត្ថុ និងពន្ធផ្សេងៗទៀត ។ ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០០ ប្រព័ន្ធបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានរៀបចំបង្កើតឡើង ជាគម្រោងសាកល្បង ជាមួយនឹងភ្នាក់ងារពន្ធដារនៃសាខា NTS ក្រុងសេអ៊ូល និងពាក់ព័ន្ធជាមួយតែពន្ធកាត់ទុក និងពន្ធលើ តម្លៃបន្ថែមប៉ុណ្ណោះ ។ វិសាលភាពនៃប្រព័ន្ធនេះត្រូវបានពង្រីកដើម្បីរួមបញ្ចូលទាំងពន្ធលើភេសជ្ជៈស្រវឹង និងពន្ធរដ្ឋាករ ពិសេស នៅក្នុងឆ្នាំ២០០១ ។ ៣០ភាគរយនៃបែបបទបង់ពន្ធកាត់ទុកចំនួន ២,៥៣លានច្បាប់ និង ១០ភាគរយនៃបែបបទបង់ ពន្ធលើតម្លៃបន្ថែមចំនួន ២,១២លានច្បាប់ ត្រូវបានបំពេញជាទម្រង់ អេឡិចត្រូនិកនៅក្នុងឆ្នាំ២០០១ ។ វិសាលភាពនៃប្រព័ន្ធ បែបបទបង់ពន្ធអេឡិចត្រូនិកត្រូវបាន ពង្រីកបន្ថែមទៀត ដើម្បីរួមបញ្ចូលទាំងពន្ធលើជំនួញមូលបត្រ និងពន្ធតែមប្រ៍ ។ លើស ពីនេះទៅទៀត ប្រព័ន្ធបង់ពន្ធអេឡិចត្រូនិកត្រូវបានបង្កើតឡើងដើម្បីផ្តល់លទ្ធភាពដល់ការបង់ភ្លាមៗនូវពន្ធដែលត្រូវបានជូន ដំណឹង ឬរបាយការណ៍តាមប្រព័ន្ធអេឡិចត្រូនិក ។ ជាងនេះទៅទៀត បុគ្គល និងអាជីវកម្មអាចដាក់ពាក្យស្នើសុំ និងពិនិត្យ មើលវិញ្ញាបនបត្រអេឡិចត្រូនិកនៃការចុះបញ្ជីក្រុមហ៊ុន ការបង់ពន្ធ ការផ្អាកក្រុមហ៊ុនបណ្តោះអាសន្ន និងការបិទក្រុមហ៊ុន ។

ដោយលុបបំបាត់ការបញ្ចូលទិន្នន័យច្រំដែលច្រើនសា និងពន្លឿនកិច្ចការដែលទាក់ទងនឹងពន្ធ ប្រព័ន្ធ ពន្ធដាររួមបញ្ចូល គ្នានេះ កែលម្អប្រសិទ្ធផលប្រតិបត្តិការ និងកាត់បន្ថយការចំណាយ ។ ឧទាហរណ៍ ប្រាក់សន្សំដល់ទៅ ១៤៦ពាន់លាន KRW (ប្រហែល ១៤៦លានដុល្លារអាមេរិក) ក្នុងមួយឆ្នាំៗ ត្រូវបានរំពឹងទុកថានឹងទទួលបានពីការលុបបំបាត់ការជូនដំណឹង ជាលាយលក្ខណ៍អក្សរដែលផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ និងការយឺតយ៉ាវដែលមធ្យោបាយនៃការបញ្ជូននេះអាចបង្កឡើង ។ អ្នក បង់ពន្ធអាចសន្សំប្រាក់បានដល់ទៅ ៣០០ពាន់លាន KRW (ប្រហែល ៣០០លានដុល្លារអាមេរិក) ក្នុងមួយឆ្នាំៗពីការចំណាយលើបុគ្គលិក និងការចំណាយលើការធ្វើដំណើរ ដែលទាក់ទងនឹង ការធ្វើដំណើរទៅកាន់ការិយាល័យពន្ធដារ ចំណែក ឯ NTS ត្រូវបានរំពឹងថា នឹងសន្សំប្រាក់បាន ១២០ពាន់លាន KRW (ប្រហែល ១២០លានដុល្លារអាមេរិក) ក្នុងមួយ ឆ្នាំៗ ពីរដ្ឋបាលពន្ធដារ ដែលមិនប្រើក្រដាស ។

---

[18] ផ្នែកនេះត្រូវបានដកស្រង់ចេញពីទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម រដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារជាតិ កុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០២) ។ http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023903.pdf

***ប្រព័ន្ធធានារ៉ាប់រងរួមបញ្ចូលគ្នា***[19]

*នៅក្នុងឆ្នាំ២០០១ ISP សម្រាប់ការស្ថាបនាប្រព័ន្ធព័ត៌មានភ្ជាប់គ្នាទៅវិញទៅមក ត្រូវបានចាត់ទុកជា សសរមួយក្នុងចំណោមសសរសំខាន់ៗនៃរដ្ឋាភិបាលអេឡិចត្រូនិក ។ នៅមុនពេលនេះ ទីភ្នាក់ងារនានាដែលក្តាប់ទីផ្សារធានារ៉ាប់រងធំៗ ទាំង៤ ដំណើរការប្រព័ន្ធព័ត៌មានដាច់ដោយឡែកពីគ្នា សូម្បីតែពួកគេមានភាពដូចគ្នាដ៏ច្រើនក្នុងន័យជាដំណើរការរដ្ឋបាល គោលដៅ និងប្រភេទនៃសេវា ។ ជាមួយនឹងប្រព័ន្ធព័ត៌មានរួមបញ្ចូលគ្នា ធនធានព័ត៌មាននៅលើទីផ្សារធានារ៉ាប់រងធំៗទាំង៤ គឺ សោធននិវត្តន៍ជាតិ ធានារ៉ាប់រងសុខភាព ធានារ៉ាប់រងសំណងគ្រោះថ្នាក់ការងារ និងធានារ៉ាប់រងការងារ បច្ចុប្បន្ននេះ ត្រូវបានចែករំលែកដោយងាយស្រួល ហើយប្រតិបត្តិការទូទៅនានា ដូចជា របាយការណ៍ និងការផ្លាស់ប្តូរលក្ខខណ្ឌនានា ត្រូវបាន ចាត់ចែងដោយងាយស្រួល ។*

***រូបភាពទី ១០ ៖ សេវាវ៉េបសាយត៍ព័ត៌មានធានារ៉ាប់រងសង្គមរបស់សាធារណរដ្ឋកូរ៉េ*** *ដែលផ្អែកលើមូលដ្ឋានទិន្នន័យរួមបញ្ចូលគ្នា*

*(ប្រភព ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម រដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារជាតិ កុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០២) ៤៣)*

http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023903.pdf




*ទោះបីជាទីភ្នាក់ងារនីមួយៗប្រតិបត្តិការវ៉េបសាយត៍របស់ខ្លួនផ្ទាល់ក្តី ព័ត៌មានដែលប្រមូលបានពីបុគ្គល និងសាជីវកម្ម ដែលត្រូវបានធានារ៉ាប់រង ព្រមទាំងពីការិយាល័យ NTS និង MOGAHA ត្រូវបានគ្រប់គ្រង និងចែករំលែកដោយទីភ្នាក់ងារទាំងអស់ ។ ទីភ្នាក់ងារជាង ២០ (លើកលែងតែអាជីវកម្ម មន្ទីរពេទ្យ និងការិយាល័យក្រុង និងខេត្ត) ត្រូវបានតភ្ជាប់គ្នា ទៅវិញទៅមកតាមរយៈប្រព័ន្ធនេះ ។ វ៉េបសាយត៍នៃទីភ្នាក់ងារនីមួយៗ ដើរតួជាមណ្ឌលព័ត៌មាននៅលើអ៊ីនធឺណិត ដែលតាមរយៈមណ្ឌលនេះ ញត្តិស៊ីវិល លិខិតជូនដំណឹង និងការបង់សេវាធានារ៉ាប់រង ត្រូវបានចាត់ចែង ។*

*ជាមួយនឹងការចែករំលែកព័ត៌មានក្នុងចំណោមទីភ្នាក់ងារធានារ៉ាប់រងពាក់ព័ន្ធតាមរយៈប្រព័ន្ធរួមបញ្ចូលគ្នានេះ ចំនួន នៃឯកសារដែលត្រូវការពេលវេលាចាត់ចែង និងថ្លៃចំណាយទៅលើចំណាត់ការ ត្រូវបានកាត់បន្ថយគួរអោយកត់សម្គាល់ ដែលនាំអោយគេសន្សំប្រាក់ប្រចាំឆ្នាំបាន ៥៤២,៣ពាន់លាន KRW (ប្រហែល ៥៤២,៣លានដុល្លារអាមេរិក) ។ ប្រព័ន្ធនេះក៏ត្រូវបានគេរំពឹងថា នឹងជួយសម្រួលដល់ការកំណត់អត្តសញ្ញាណប្រជាពលរដ្ឋដែលមិនត្រូវបានគ្របដណ្តប់ ដោយសេវាធានារ៉ាប់រងដែលមាន ស្រាប់ផងដែរ ។*

***កម្មវិធីចុះបញ្ជីប្រជាពលរដ្ឋ (អត្តសញ្ញាណប័ណ្ណជាតិ)***[20]

*ការធ្វើព័ត៌មានីយកម្មការចុះបញ្ជីប្រជាពលរដ្ឋ គឺជាកិច្ចការរដ្ឋាភិបាលអេឡិចត្រូនិកដ៏ចម្បងមួយផងដែរ ។ នៅក្នុងសាធារណរដ្ឋកូរ៉េ ដំណើរការនេះបានចាប់ផ្តើមកាលពី ២ទសវត្សរ៍កន្លងទៅ ជាមួយនឹងការច្របាច់បញ្ចូលគ្នាទៅជាកំណត់ត្រា តែមួយនូវកំណត់ត្រាដែលទាក់ទងនឹងការចុះបញ្ជីប្រជាពលរដ្ឋទាំងអស់នៃ បុគ្គលម្នាក់ៗ និងការស្ថាបនាមូលដ្ឋានទិន្នន័យចុះបញ្ជី ថ្នាក់ជាតិមួយ ។ ក្នុងរយៈពេលពីរឆ្នាំ (១៩៨៩-១៩៩០) មន្ត្រីរាជការដែលមានមូលដ្ឋាននៅតាមការិយាល័យស្រុកចំនួន ៣.៦៧៨ នៅទូទាំងប្រទេស កត់ត្រាទិន្នន័យពីបញ្ជីប្រមាណ ៥,៧លានក្បាលដោយដៃ ។ នៅក្នុងឆ្នាំ១៩៩៨ មណ្ឌលផ្តល់ប័ណ្ណ ចុះបញ្ជីប្រជាពលរដ្ឋត្រូវបានបង្កើតឡើងដើម្បីកែលម្អប្រសិទ្ធផលនៃសេវាទាំងនេះ ដោយប្រើប្រាស់ប្រព័ន្ធ ចុះបញ្ជីប្រជាពលរដ្ឋនៅក្នុងបណ្តាញរបស់ទីភ្នាក់ងាររដ្ឋាភិបាលធំៗ ។ នៅក្នុងឆ្នាំ២០០១ ប្រព័ន្ធចុះបញ្ជីប្រជាពលរដ្ឋត្រូវបានរៀបចំបង្កើតឡើង និងចែកចាយ សម្រាប់ការប្រើប្រាស់ទូទៅ ។*

---

[19] Ibid.

[20] ផ្នែកនេះត្រូវបានដកស្រង់ចេញពីទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម រដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារជាតិ កុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០២) ។ http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023905.pdf

ប្រព័ន្ធចុះបញ្ជីប្រជាពលរដ្ឋ មាននៅលើអ៊ីនធឺណិតសម្រាប់ទីភ្នាក់ងាររដ្ឋបាលទាំងអស់ ដែលត្រូវការ ព័ត៌មានសម្រាប់ ប្រតិបត្តិការផ្សេងៗ ។ ប្រព័ន្ធបណ្តាញរដ្ឋបាលអាចផ្តល់សេវាសំខាន់ៗដូចតទៅ ៖ ការគ្រប់គ្រងការចុះបញ្ជីប្រជាពលរដ្ឋ ការប្រមូលពន្ធលំនៅដ្ឋាន ការចេញសេចក្តីជូនដំណឹងអំពីការ ចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សាដោយស្វ័យប្រវត្តិ និងការចេញ បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបាន ចុះឈ្មោះ ។ សម្រាប់ប្រជាពលរដ្ឋ អត្ថប្រយោជន៍នៃការមានប្រព័ន្ធតភ្ជាប់គ្នាទៅវិញ ទៅមកនេះ គឺថាប្រព័ន្ធនេះអនុញ្ញាតអោយមនុស្សគ្រប់គ្នាដែលរស់នៅក្នុងស្រុកមួយ អាចដាក់ពាក្យសុំលិខិតបញ្ជាក់ការចុះបញ្ជីប្រជាពលរដ្ឋនៅក្នុងការិយាល័យស្រុកផ្សេងទៀត ហើយការផ្លាស់ប្តូរអាសយដ្ឋានត្រូវបាន អនុវត្តដោយស្វ័យប្រវត្តិចំពោះ កំណត់ត្រាសោធននិវត្តន៍ថ្នាក់ជាតិ កំណត់ត្រាធានារ៉ាប់រងសុខភាព កំណត់ត្រាចុះបញ្ជីយានយន្ត និងប័ណ្ណបើកបរ ។

**រូបភាពទី ១១ ៖ ប្រព័ន្ធចុះបញ្ជីប្រជាពលរដ្ឋរបស់សាធារណរដ្ឋកូរ៉េ**

(ប្រភព ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្មរដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារជាតិ កុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០២) ១៥ http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023905.pdf)




### ប្រព័ន្ធគ្រប់គ្រងព័ត៌មានអចលនវត្ថុ[21]

សកម្មភាពរដ្ឋាភិបាលដែលទាក់ទងនឹងអចលនវត្ថុ រួមបញ្ចូលនូវដីអភិវឌ្ឍន៍លំនៅដ្ឋាន ផែនការធ្វើ លំនៅដ្ឋាន និងផែនការប្រើប្រាស់ដី ការប្រមូលពន្ធលើអចលនវត្ថុ និងការទប់ស្កាត់វិនិយោគទុន បំប៉ោងតម្លៃអចលនវត្ថុ ។ សកម្មភាព ទាំងនេះ ទាមទារនូវការគ្រប់គ្រងទូលំទូលាយ និងប្រកបដោយ ប្រសិទ្ធផលនូវព័ត៌មានអចលនវត្ថុ ដែលអាចធ្វើទៅកើត ដោយសារការធ្វើព័ត៌មានីយកម្ម ។

នៅដើមឆ្នាំ១៩៨២ បញ្ជីដីលំនៅដ្ឋាន និងដីព្រៃ ត្រូវបានរក្សាទុកនៅក្នុងប្រព័ន្ធកុំព្យូទ័រ ដែលបង្កើតបានជា មូលដ្ឋានទិន្នន័យអចលនវត្ថុនៃដី ៣២លានក្បាលនៅទូទាំងប្រទេស ។ ក្រោយមក ការិយាល័យស្រុកក្នុងមូលដ្ឋានត្រូវបានតភ្ជាប់ ទៅនឹងបណ្តាញនៅការិយាល័យកណ្តាលដើម្បីដំណើរការនូវការផ្លាស់ប្តូរ នៅក្នុងព័ត៌មានអចលនវត្ថុ ។ ដំណើរការនេះ ដែល ចំណាយរយៈពេល ៦ឆ្នាំ (១៩៨៥–១៩៩០) បានកែលម្អភាពត្រឹមត្រូវ និងល្បឿននៃសេវាសាធារណៈ ដូចជា ការចេញវិញ្ញា–បនបត្រសម្រាប់ការចុះបញ្ជី និងការផ្សព្វផ្សាយបញ្ជីនៅលើអ៊ីនធឺណិត ។ ក្រោយមកទៀត នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៩១ សេវាត្រូវបានផ្តល់នៅលើអ៊ីនធឺណិត ក្នុងនោះរួមបញ្ចូលទាំងការចេញវិញ្ញាបនបត្រចុះបញ្ជី ។

ប្រព័ន្ធចុះបញ្ជីឈ្មោះអចលនវត្ថុ ត្រូវបានបង្កើតឡើងនៅបន្ទាប់ពីការបង្កើតមណ្ឌលព័ត៌មានដែនដីជាតិ នៅក្នុងឆ្នាំ ១៩៩៧ ។ ចាប់តាំងពីឆ្នាំ១៩៩៨មក ប្រព័ន្ធអចលនវត្ថុត្រូវបានរួមបញ្ចូលគ្នាទៅក្នុងប្រព័ន្ធរដ្ឋបាលទូលំទូលាយមួយសម្រាប់ស្រុកធំៗចំនួន ២១ ។ ដូច្នេះ ប្រព័ន្ធរដ្ឋបាលទូលំទូលាយនេះកែសម្រួល ប្រព័ន្ធអចលនវត្ថុអោយស្របទៅនឹងប្រព័ន្ធគ្រប់គ្រង ដីធ្លី និងអគារ ព្រមទាំងប្រព័ន្ធពាក់ព័ន្ធផ្សេងៗទៀត ។

ការកសាងចប់ជាស្ថាពរនូវមូលដ្ឋានទិន្នន័យដីធ្លី និងអន្តរកម្មនៅលើអ៊ីនធឺណិតរវាងទីភ្នាក់ងារពាក់ព័ន្ធ បាននាំឆ្ពោះទៅរកកំណែទម្រង់សេវារដ្ឋបាលដែលទាក់ទងនឹងដីធ្លី ដែលបានផ្តល់ជាលទ្ធផលដូចខាង ក្រោម ៖

- ការកែសម្រួលដំណើរការដែលមាន១០ដំណាក់កាល ទៅជាដំណាក់កាល ៣ ។
- ការទប់ស្កាត់កំណើន ១៥% នៅក្នុងធនធានមនុស្សសម្រាប់សេវារដ្ឋបាលនានាដែលទាក់ទង នឹងដីធ្លី ។
- ការកែលម្អគុណភាពសេវា ។
- ការផ្តល់លទ្ធភាពប្រើប្រាស់បញ្ជីដីធ្លីលំនៅដ្ឋាន និងដីព្រៃដល់ប្រជាពលរដ្ឋដែលអាចមើលតាមរយៈ ម៉ាស៊ីនកុំព្យូទ័រនៅក្នុងផ្ទះរបស់ខ្លួន ។
- ការកាត់បន្ថយពេលវេលាចាត់ការលើសំណើនីមួយៗពី ៣០នាទី មកនៅត្រឹម ៥នាទី ។
- តម្លាភាពកាន់តែប្រសើរឡើងនៅក្នុងកិច្ចការដែលទាក់ទងនឹងដីធ្លី និងអចលនវត្ថុ ។

[21] lbid.

***រូបភាពទី ១២ ៖ ផែនទីទស្សនាទានសម្រាប់ប្រព័ន្ធគ្រប់គ្រងអចលនវត្ថុរបស់សាធារណរដ្ឋកូរ៉េ***

(*ប្រភព ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្មរដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ* (*សេអ៊ូល ៖ ទីភ្នាក់ងារជាតិ កុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០២*) *១៧*
http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023905.pdf)




***ការគ្រប់គ្រងយានយន្ត***[22]

*នៅពេលដែលចំនួនរថយន្តនៅក្នុងសាធារណរដ្ឋកូរ៉េឡើងលើស ១០គ្រឿង គេបានគិតគូរថាប្រព័ន្ធ ព័ត៌មានមួយ ដើម្បីចាត់ការលើឯកសារស្នើសុំផ្នែករដ្ឋបាលទាក់ទងនឹងយានយន្តដែលកើនឡើងយ៉ាងគំហុកអោយមានប្រសិទ្ធភាព គឺជាការ ចាំបាច់ ។*

*ប៉ុន្តែទោះជាយ៉ាងណា ប្រព័ន្ធរដ្ឋបាលយានយន្តរួមបញ្ចូលគ្នាបច្ចុប្បន្ននេះចំណាយពេលវេលាមួយទសវត្សរ៍ ដើម្បីវិវឌ្ឍទៅមុខ ។ នៅឆ្នាំ១៩៩១ ការយកចិត្តទុកដាក់ត្រូវបានផ្តោតទៅលើការចុះបញ្ជី និងការត្រួតពិនិត្យយានយន្តដែលមិនបានជួយ ច្រើនដល់ការកែលម្អប្រសិទ្ធផលនៃសេវាយានយន្តទូទៅឡើយ ដោយសារតែកង្វះការយកចិត្តទុកដាក់ទៅលើសេវាគាំទ្រនានា ដូចជា ការបញ្ជាក់ភិនភាគយានយន្ត ការគ្រប់គ្រងនិងការផ្តល់លិខិតបើកបរបណ្តោះអាសន្ន និងប័ណ្ណបើកបរ ។ នៅក្នុងឆ្នាំ ១៩៩៨ ប្រព័ន្ធរដ្ឋបាលយានយន្តដែលកាន់តែទូលំទូលាយមួយត្រូវបានបង្កើតឡើង ។ ប្រព័ន្ធនេះរួមបញ្ចូលនូវ កិច្ចការរដ្ឋបាលយានយន្តគ្រប់បែបយ៉ាង ចាប់តាំងពីការចុះបញ្ចូល ការត្រួតពិនិត្យ រហូតដល់ការ ប្រតិបត្តិការ ។ ប្រព័ន្ធមួយដែលគ្របដណ្តប់ លើយានយន្តដែលមានកង់ពីរ និងគ្រឿងម៉ាស៊ីនសំណង់ ត្រូវបានបន្ថែមនៅក្នុងឆ្នាំ១៩៩៩ ហើយពីរឆ្នាំក្រោយមកទៀត យន្តការរួមមួយដែលអនុញ្ញាតអោយ ទីភ្នាក់ងារផ្សេងៗអាចប្រមូលនិងចែករំលែកព័ត៌មានដែលទាក់ទងនឹងយានយន្ត ត្រូវបាន បង្កើតឡើង ។*

*ប្រព័ន្ធរួមបញ្ចូលគ្នានេះ បានជួយសន្សំថវិកាប្រមាណ ៨,២ពាន់លាន* KRW (*ប្រហែល ៨,២លាន ដុល្លារអាមេរិក*)*។ ប្រព័ន្ធនេះក៏ជួយសន្សំពេលវេលារបស់រដ្ឋាភិបាល និងប្រជាពលរដ្ឋបាន យ៉ាងច្រើនផងដែរ ដោយការចុះបញ្ជីយានយន្តមួយ បច្ចុប្បន្នចំណាយពេលតែ ២០នាទីប៉ុណ្ណោះ មិនមែនមួយម៉ោងដូចពេលមុនឡើយ ។*

[22] Ibid

***រូបភាពទី ១៣ ៖ ទស្សនាទានសម្រាប់សេវាចុះបញ្ជីយានយន្តរបស់សាធារណរដ្ឋកូរ៉េ***

(*ប្រភព ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម រដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ* (*សេអ៊ូល ៖ ទីភ្នាក់ងារជាតិ កុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០២*) *១៩*
http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023905.pdf)




***សំណួរត្រិះរិះ***

1. *ក្នុងចំណោមសេវា* G2C *ដែលបានរៀបរាប់នៅក្នុងផ្នែកនេះ តើសេវាណាខ្លះដែលអ្នកគិតថា ជាសេវាអាទិភាព តាម ទស្សនៈរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសរបស់អ្នក* ? *តើមូលហេតុអ្វី* ?

2. *តើប្រព័ន្ធពន្ធដាររួមបញ្ចូលគ្នាមួយអាចជួយបង្កើនចំណូលពន្ធ យ៉ាងដូចម្តេច* ? *តើត្រូវការអ្វីខ្លះ ដើម្បីរៀបចំបង្កើត ប្រព័ន្ធបែបនេះនៅក្នុងប្រទេសរបស់អ្នក* ?

3. *នៅក្នុងផ្នែកនេះ យើងបានពិភាក្សាអំពីសេវាប្រជាពលរដ្ឋជាមូលដ្ឋានចំនួន ៥ នៅក្នុង* G2C ។ *តើអ្នកអាចកំណត់នូវសេវា ផ្សេងទៀតណាមួយក្រៅពីសេវាប្រជាពលរដ្ឋ ដែលអាចជាផ្នែកមួយនៃប្រព័ន្ធ* G2C *បានឬទេ* ?

***ធ្វើតេស្តខ្លួនឯង***

*ចូរពន្យល់អំពីដំណើរការការងារសម្រាប់ប្រព័ន្ធនីមួយៗ ក្នុងចំណោមប្រព័ន្ធដូចតទៅ ៖ ក*) *ប្រព័ន្ធពន្ធដារ រួមបញ្ចូលគ្នា ខ*) *ប្រព័ន្ធធានារ៉ាប់រងរួមបញ្ចូលគ្នា គ*) *ការចុះបញ្ជីប្រជាពលរដ្ឋ ឃ*) *ការចុះបញ្ជីយានយន្ត និង ង*) *ប្រព័ន្ធគ្រប់គ្រងអចលនវត្ថុ ។*

### ***៣.២. រដ្ឋាភិបាលទៅអាជីវកម្ម* (G2B) *៖ នវានុវត្តន៍សេវាអាជីវកម្ម***

***ប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិករួមបញ្ចូលគ្នា***

*សាធារណរដ្ឋកូរ៉េបានចូលរួមក្នុងកិច្ចព្រមព្រៀងលទ្ធកម្មរដ្ឋាភិបាលរបស់អង្គការពាណិជ្ជកម្មពិភពលោក នៅក្នុងឆ្នាំ ១៩៩៤ ។ កិច្ចព្រមព្រៀងនេះបានផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាផ្សេងៗ ដែលពាក់ព័ន្ធនឹងប្រព័ន្ធលទ្ធកម្មដោយមនុស្ស ដូចជាភាពគ្មានប្រសិទ្ធផលដែលបណ្តាលមកពីវិធីដំណើរការច្រំដែលៗ ដោយមនុស្ស និងអំពើពុករលួយដោយសារទំនាក់ទំនងបុគ្គល*[23] ។ *ដូច្នេះហើយសេចក្តីសម្រេចត្រូវបានធ្វើឡើងដើម្បីបង្កើតប្រព័ន្ធលទ្ធកម្មឌីជីថលទំនើបមួយ ដែលនឹងធានានូវការ ផ្តល់ទាន់ពេលវេលា ផលិតផលមានគុណភាព និងតម្លៃសមរម្យ ផ្អែកតាមព័ត៌មានលទ្ធកម្មត្រឹមត្រូវ និងកសាងបរិយាកាស*

---

[23] "រដ្ឋាភិបាលអេឡិចត្រូនិក ៖ ការសន្សំពេលវេលា និងការចំណាយតិចជាមួយនឹងសេវាអេឡិចត្រូនិក" *Korea Herald* ថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០០៧ http://www.britain.or.kr/information/print.php?lang=e&umode=graphic&dno=13525 .

លទ្ធកម្មប្រកបដោយតម្លាភាព និងប្រសិទ្ធផលសម្រាប់អ្នកចូលរួមទាំងអស់[24] ។

**រូបភាពទី ១៤ ៖ ប្រព័ន្ធលទ្ធកម្មរដ្ឋាភិបាល Window រួម**

(ប្រភព ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម រដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារជាតិ កុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០២) ៤១

http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023903.pdf




ប្រព័ន្ធឌីជីថលដែលត្រូវបានអនុវត្ត ត្រូវបានអោយឈ្មោះថា ប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិកនៃការិយាល័យ លទ្ធកម្មសាធារណៈរបស់សាធារណរដ្ឋកូរ៉េ (KONEPS) ។ នេះគឺជាប្រព័ន្ធនៅលើអ៊ីនធឺណិតដែលផ្តល់លទ្ធភាពដល់ចំណាត់ការលឿន រហ័ស និងងាយស្រួលនូវនីតិវិធីរដ្ឋបាល ដែលទាក់ទងនឹងលទ្ធកម្ម សាធារណៈទាំងអស់ ក្នុងនោះរួមបញ្ចូលទាំងការដេញថ្លៃ កិច្ចសន្យា ការទូទាត់ប្រាក់ និងការប្រគល់ ផលិតផល ។ ព័ត៌មានលទ្ធកម្ម ក្នុងនោះរួមទាំងការទទួលសំណើទិញ និងសេចក្តី ប្រកាសជូនដំណឹងអំពី ការដេញថ្លៃជាសាធារណៈ ការផ្តល់កិច្ចសន្យា និងស្ថានភាពនៃកិច្ចសន្យា ត្រូវបានផ្តល់នៅលើអ៊ីនធឺណិត ដែលធានាបាននូវភាពត្រឹមត្រូវ និងតម្លាភាពសម្រាប់កិច្ចការទាំងអស់ ។ ប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិកនេះ គឺជាប្រព័ន្ធដេញថ្លៃ នៅលើអ៊ីនធឺណិតដំបូងបង្អស់នៅក្នុងសាធារណរដ្ឋកូរ៉េ ។ ប្រព័ន្ធនេះ កំពុងត្រូវបានប្រើប្រាស់ដោយស្ថាប័ន និងទីភ្នាក់ងារ ប្រមាណ ៧៧០ អង្គការសាធារណៈចំនួន ៣៥.០០០ និងក្រុមហ៊ុនចំនួន ១៦០.០០០[25] ។

ចូរធ្វើការប្រៀបធៀបប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ ជាមួយនឹងប្រព័ន្ធលទ្ធកម្មអេឡិច ត្រូនិកនៃ រដ្ឋ Andhra Pradesh នៅប្រទេសឥណ្ឌា ។

**លទ្ធកម្មអេឡិចត្រូនិកនៅក្នុងរដ្ឋ Andhra Pradesh ប្រទេសឥណ្ឌា**

ជាមួយនឹងការអនុម័តច្បាប់ស្តីពី IT នៅឆ្នាំ២០០០ ដើម្បីផ្តល់ការទទួលស្គាល់ផ្នែកច្បាប់ដល់ កិច្ចការតាមប្រព័ន្ធ អេឡិចត្រូនិក រដ្ឋាភិបាលនៃរដ្ឋ Andhra Pradesh (GoAP) បានមើលឃើញសារ សំខាន់នៃប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិក ក្នុងការសម្រេចគោលដៅអភិបាលកិច្ចអេឡិចត្រូនិក និងអភិបាល កិច្ចល្អ ។ នៅឆ្នាំ២០០២ GoAP បានបង្កើតភាពជាដៃគូជាមួយក្រុមហ៊ុនឯកជននៅក្នុងប្រទេសឥណ្ឌា ដើម្បីអភិវឌ្ឍដំណើរការ និងកម្មវិធីលទ្ធកម្មអេឡិចត្រូនិក ។ ភាពជាដៃគូនេះ មានគោលដៅដើម្បី ៖

- បង្កើត Window រួមសម្រាប់កិច្ចការលទ្ធកម្ម
- សន្សំពេលវេលា និងលុយកាក់ដែលចំណាយទៅលើកិច្ចការលទ្ធកម្ម
- ធ្វើបទដ្ឋានីយកម្មដំណើរការលទ្ធកម្មរបស់រដ្ឋាភិបាល
- អនុញ្ញាអោយមានឱកាសស្មើភាពគ្នាដល់អាជីវកម្ម
- លើកកម្ពស់តម្លាភាព

[24] ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម រដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម ២០០២) http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023903.pdf .

[25] lbid

- *កាត់បន្ថយឱកាសសម្រាប់អំពើពុករលួយ*

*ចាប់តាំងពីការអនុវត្តសាកល្បងនៅក្នុងឆ្នាំ២០០៣ មក វ៉ែបសាយត៍* e-procurement.gov.in *បានក្លាយជា វេទិកាលទ្ធកម្មអេឡិចត្រូនិកសម្រាប់នាយកដ្ឋានទាំងអស់របស់* GoAP *ក្នុងនោះរាប់បញ្ចូលទាំងស្ថាប័ន មូលដ្ឋាន និងសាជីវកម្មក្រុងផងដែរ ។ សេវានេះក៏ផ្តល់ដល់រដ្ឋាភិបាលនៃបណ្តារដ្ឋផ្សេងទៀតផងដែរ ។*

*វ៉ែបសាយត៍លទ្ធកម្មអេឡិចត្រូនិកតភ្ជាប់អ្នកទិញ និងអ្នកផ្គត់ផ្គង់តាមរយៈការផ្លាស់ប្តូរតាមប្រព័ន្ធអេឡិច ត្រូនិកនូវសំណើដេញថ្លៃ កាតាឡុក កិច្ចសន្យា ការបញ្ជាទិញ និងវិក្កយបត្រ ។ វ៉ែបសាយត៍នេះក៏មានកម្មវិធីគ្រប់គ្រងសំណើដេញថ្លៃ ផងដែរ ដើម្បីជួយអ្នកទិញនៅក្នុងដំណើរការដេញថ្លៃ ។ អ្នកផ្គត់ផ្គង់អាចថតចម្លងយកឯកសារដេញថ្លៃ និងតាមដានស្ថានភាព នៃការដេញថ្លៃ ។*

*នៅក្នុងខែមករា ឆ្នាំ២០០៣ អភិបាលរដ្ឋ* Adhra Pradesh *បានចេញបទបញ្ជាមួយ ដែលថ្លែងថា ៖ “សំណើដេញ ថ្លៃណាមួយសម្រាប់ការងារវិស្វកម្ម ឬលទ្ធកម្មទំនិញ និងសេវាដែលមានតម្លៃចាប់ពី ១០.០០០.០០០* INR *(ប្រហែល ២៣៦.៥០០ ដុល្លារអាមេរិក) ឡើងទៅ ដោយស្នងការដ្ឋានដេញថ្លៃ នឹងត្រូវធ្វើឡើងតែតាមរយៈវ៉ែបសាយត៍លទ្ធកម្ម អេឡិចត្រូនិកប៉ុណ្ណោះ" ។*

*លទ្ធកម្មដែលបានផ្តើមមានសម្ភារៈផ្គត់ផ្គង់ ឱសថសាស្ត្រ យានយន្ត និងកិច្ចសន្យាសោក្នុងដៃ* (turnkey contract) *។ ចាប់ពីជំហានដំបូងដែលមានតែនាយកដ្ឋាន ៨ ដែលបានប្រើប្រាស់ប្រព័ន្ធនេះ និងបានអនុវត្តកិច្ចការ ដេញថ្លៃចំនួន ៥៦៤លើក នៅក្នុងឆ្នាំ២០០៣មក ប្រព័ន្ធនេះបានរីកកាន់តែធំ ដោយរួមបញ្ចូលនូវទីភ្នាក់ងារ ចំនួន ៧៧ ដែលធ្វើកិច្ចការដេញថ្លៃចំនួន ៩.៩៨១លើក នៅក្នុងឆ្នាំ២០០៦ ។ ពេលវេលាវដ្តនៃ ការដេញថ្លៃត្រូវបានកាត់បន្ថយគួរអោយកត់សម្គាល់ពី ៩០–១៣៥ថ្ងៃ មកនៅត្រឹម ៣៥–៤២ថ្ងៃ ។*

*ភាពប្រឈមនៅក្នុងការបង្កើតប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិកនេះ រួមមាន ៖ រចនាគំរូអាជីវកម្មប្រកបដោយ និរន្តរភាព ជំរុញកិច្ចសហប្រតិបត្តិការអន្តរនាយកដ្ឋាន ការទទួលបានការប្តេជ្ញាចិត្តរបស់ភាគីពាក់ព័ន្ធ ក្នុងការអនុម័ត និងប្រើប្រាស់ប្រព័ន្ធ និងការធានាសន្តិសុខរបស់ប្រព័ន្ធ ។*

*ប្រភព ៖*

*ក្រសួងព័ត៌មានវិទ្យា គមនាគមន៍ និងបច្ចេកវិទ្យា* “ eprocurement.gov.in” *រដ្ឋាភិបាលនៃរដ្ឋ* Andhra Pradesh *ប្រទេសឥណ្ឌា* http://www.eprocurement.gov.in *។*

*ក្រសួងព័ត៌មានវិទ្យា គមនាគមន៍ និងបច្ចេកវិទ្យា “បទបញ្ជារដ្ឋាភិបាល ៖ ការផ្តល់សុពលភាព និងលទ្ធភាពដល់ដំណើរការ លទ្ធកម្ម តាមរយៈទីផ្សារលទ្ធកម្មអេឡិចត្រូនិកដោយក្រសួងដែលចូលរួម"* (GO.MS.2.2003)

http://www.aponline.gov.in/Quick%20Links/Departments/Information%20Technology%20and%20Communications/Govt-Gos-Acts/2003/GO.Ms.2.2003.html *។*

K. Bikshapathi “*ករណីសិក្សាស្តីពីលទ្ធកម្មអេឡិចត្រូនិកនៅរដ្ឋ* A.P.” (*បទបង្ហាញ ឆ្នាំ២០០៧*)
http://himachaldit.nic.in/Casestudy-APeProcurement.pdf *។*

K. Bikshapathi, P. RamaRaju *និង* Subhash Bhatnagar *លទ្ធកម្មអេឡិចត្រូនិកនៅក្នុងរដ្ឋាភិបាលនៃរដ្ឋ* *Andhra Pradesh* *ប្រទេសឥណ្ឌា* (*វ៉ាស៊ិនតោន ឌី.ស៊ី. ៖ ធនាគារពិភពលោក ឆ្នាំ២០០៦*)
http://go.worldbank.org/XJS8XWB030 *។*

***ប្រព័ន្ធកម្មវិធីពន្ធគយ***

*នៅមុនការបង្កើតប្រព័ន្ធគយអេឡិចត្រូនិកនៅក្នុងសាធារណរដ្ឋកូរ៉េ អ្នកនាំចូល និងអ្នកនាំចេញ ចាំបាច់ត្រូវតែបង្ហាញ ខ្លួននៅឯការិយាល័យគយ និងស្ថាប័នហិរញ្ញវត្ថុដើម្បីបំពេញបែបបទគយ បង់ពន្ធគយ និងស្នើសុំប្រាក់ពន្ធមកវិញ ។ ការបំពេញ បែបបទគយ ការឃ្លាំមើល និងការត្រួតពិនិត្យនៅតាមព្រលានយន្តហោះ និងកំពង់ផែសមុទ្រ មិនមានលក្ខណៈជាប្រព័ន្ធឡើយ ហើយទោះបីជាមានភាពល្អគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការជាមូលដ្ឋានរបស់អតិថិជនក្តី ក៏កិច្ចការទាំងនេះបង្កនូវការលំបាក ជាច្រើន ។*

*គោលបំណងនៃការកសាងប្រព័ន្ធគយអេឡិចត្រូនិក គឺដើម្បី ៖ ក) បង្កើតប្រព័ន្ធព័ត៌មានដែលសម្រួល ដល់រដ្ឋបាលគយ ខ) បញ្ឈប់ការរត់ពន្ធ គ) កាត់បន្ថយការចំណាយផ្នែកភស្តុភារនៅក្នុងវិស័យនាំចូល និងនាំចេញ និង ឃ) កែលម្អ គុណភាពសេវាគយដែលផ្តល់អោយ ។*

*ដូច្នេះ ប្រព័ន្ធគយអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ គឺជាច្រកចេញចូលតែមួយសម្រាប់កិច្ចការជំនួញ អន្តរជាតិ ។ នីតិវិធីបំពេញបែបបទគយ ដូចជា របាយការណ៍នាំចូល/នាំចេញ ការចូលចតនៅកំពង់ផែ*

និងទិន្នន័យគ្រប់គ្រងទំនិញ ត្រូវបាន ប្រែក្លាយទៅជាប្រព័ន្ធកុំព្យូទ័រ ដែលរួមចំណែកយ៉ាងច្រើនដល់ ការកែលម្អភាពប្រកួតប្រជែង របស់ក្រុមហ៊ុននាំចូល/ នាំចេញ ក្នុងស្រុក ។ តាមរយៈប្រព័ន្ធគយ អេឡិចត្រូនិក បច្ចុប្បន្ន ការបំពេញប៉ែបបទគយនាំចេញអាចដំណើរការក្នុងរយៈពេលតែ ២ នាទី ហើយការបំពេញប៉ែបបទគយនាំចូលអាចដំណើរការក្នុងរយៈពេល ១,៥ម៉ោង ។ នេះគឺជាប្រព័ន្ធបំពេញ ប៉ែបបទគយមួយ ក្នុងចំណោមប្រព័ន្ធបំពេញប៉ែបបទគយដែលលឿនជាងគេបំផុត ក្នុងចំណោមរដ្ឋជា សមាជិកចំនួន ១៦៩ នៃអង្គការពាណិជ្ជកម្ម ពិភពលោក ។ ការបំពេញប៉ែបបទគយនាំចូលដ៏ស្មុគស្មាញ ដែលធ្លាប់តែចំណាយពេល ២ថ្ងៃ បច្ចុប្បន្ន ត្រូវបានបំពេញនៅក្នុង ពេលតែ ២,៥ម៉ោង ដែលលឿន ជាងអនុសាសន៍របស់ UNCTAD ដល់ទៅ៤ម៉ោង[26] ។

ប្រព័ន្ធនេះ ជួយអោយសន្សំប្រាក់ប្រចាំឆ្នាំបានប្រហែល ២,៥ពាន់លានដុល្លារអាមេរិក ។ ជាងនេះទៅទៀត ប្រព័ន្ធនេះត្រូវបានទទួលស្គាល់ចំពោះការកាត់បន្ថយថ្លៃចំណាយទូទៅក្នុងវិស័យនេះបានប្រមាណ ៣.៨៧៨ពាន់លាន KRW ជារៀងរាល់ឆ្នាំ ដោយសារផលប៉ះពាល់ផ្ទាល់ ដូចជា ការកាត់បន្ថយពេលវេលា/ ថ្លៃចំណាយចំនួន ៧០៩ពាន់លាន KRW ផលប៉ះពាល់ដែលទាក់ទងក្នុងវិស័យនេះ ដូចជា ការកែលម្អ ផលិតភាពនៃឧស្សាហកម្មដែលទាក់ទង និងប្រសិទ្ធផលនៃការប្រើ ប្រាស់ឥណទានសរុប ២.៣៧០ពាន់ លាន KRW និងផលប៉ះពាល់បន្ទាប់បន្សំនៃទឹកប្រាក់ ៧៩៨ពាន់លាន KRW ទៅលើវិស័យឧស្សាហកម្ម ផ្សេងទៀត[27] ។

**រូបភាពទី ១៥ ៖ ប្រព័ន្ធពន្ធគយអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ**

(ប្រភព ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម រដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារជាតិ កុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០២) ២៩)

http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023904.pdf




**កំណែទម្រង់គយនៅប្រទេសហ្វីលីពីន**

នៅក្នុងឆ្នាំ១៩៩៥ ការិយាល័យពន្ធគយហ្វីលីពីន (BOC) សហការជាមួយធនាគារពិភពលោក និង UNCTAD បានអនុវត្តប្រព័ន្ធនៅលើអ៊ីនធឺណិត ដើម្បីចាត់ការសំណុំប៉ែបបទនាំចូល ការបង់ពន្ធ និងការផ្តល់បញ្ជាអនុញ្ញាតដល់កិច្ចការពន្ធគយ របស់ខ្លួន ។

ការិយាល័យបានជ្រើសរើសយក ASYCUDA[28] ជាកម្មវិធីដែលអាចរកបាន និងប្រើប្រាស់យ៉ាងទូលំ ទូលាយដែលបង្កើតឡើងដោយ UNCTAD ។ ប្រព័ន្ធដែលស្ទើរតែគ្មានក្រដាសទាល់តែសោះនេះផ្តល់ លទ្ធភាពដល់ការបង់ពន្ធ និងអាករ ផ្សេងៗដោយផ្ទាល់ទៅកាន់ធនាគារទីភ្នាក់ងារមួយដែលមានការ អនុញ្ញាត ។ ពន្ធនិងអាករដែលត្រូវបង់ ត្រូវបានផ្ទៀងផ្ទាត់

[26] *Korea Herald,* op. cit.
[27] Ibid
[28] ប្រព័ន្ធស្វ័យប្រវត្តិសម្រាប់ទិន្នន័យពន្ធគយ

ជាមួយនឹងចំនួនប្រាក់ដែលត្រូវបង់ ដែលកំណត់ នៅក្នុងមូលដ្ឋានទិន្នន័យរបស់ BOC ហើយបទបញ្ជាអនុញ្ញាតមួយត្រូវបាន ចេញអោយ នៅពេលដែល ចំនួនទាំងពីរនេះត្រូវគ្នា ។ ការធ្វើដូច្នេះជួយពន្លឿនដល់ដំណើរការបំពេញបែបបទគយ និងឆ្លើយតប ទៅតាមគោលបំណងទូទៅរបស់ BOC សម្រាប់ការជួយសម្រួលពាណិជ្ជកម្ម ។

ប្រព័ន្ធនេះក៏ផ្ដល់ការប៉ាន់ប្រមាណហានិភ័យនៃការដឹកជញ្ជូនទំនិញផងដែរ ។ រូបភាព ការប្រើប្រាស់លេខ កូដទំនិញ និងការយោងទៅរកមូលដ្ឋានទិន្នន័យខាងក្រៅនៅលើអ៊ីនធឺណិត ត្រូវបានប្រើប្រាស់ដើម្បីចាត់ថ្នាក់រាល់អង្គភាពប្រើប្រាស់ និង ឃ្លាំងជាការដឹកជញ្ជូនដែលមានហានិភ័យទាប មធ្យម ឬខ្ពស់ ដែលកំណត់អំពីកម្រិតនៃការត្រួតពិនិត្យឯកសារ និងការត្រួត ពិនិត្យទំនិញដោយផ្ទាល់ដែលចាំបាច់ ។ ការបញ្ចេញជាស្ថាពរនូវទំនិញនៅក្នុងកំពង់ផែ ត្រូវបានចាត់ការដោយប្រព័ន្ធបញ្ចេញនៅលើអ៊ីនធឺណិត (On-Line Release System) ដែលប្រើប្រាស់ប្រព័ន្ធទូរស័ព្ទសាធារណៈសម្រាប់សម្របសម្រួលកិច្ចការ នានាទៅកាន់ស្ថានីយកុងតឺន័រ ផែស្ងួត ដែលស្ថិតនៅចម្ងាយជាច្រើនគីឡូម៉ែត្រពីកំពង់ផែ ។

ចាប់តាំងពីពេលនោះមក ប្រព័ន្ធនេះត្រូវបានកែលម្អទៅជាផ្នែកមួយនៃគម្រោង ASYCUDAWorld (គយ អេឡិចត្រូនិក) ដែលរួមមានការកែលម្អប្រព័ន្ធស្នូល និងប្រព័ន្ធគាំទ្រ ក្នុងនោះរួមបញ្ចូលទាំងផ្នែករឹង និងហេដ្ឋារចនាសម្ព័ន្ធ បណ្ដាញ ។ ជាពិសេស ASYCUDAWorld ផ្ដល់នូវការកែលម្អដូចខាងក្រោម ៖

- ការបញ្ជូនបែបបទប្រតិវេទន៍តាមអ៊ីនធឺណិត
- ដំបូន្មានដោយស្វ័យប្រវត្តិស្ដីពីស្ថានភាពនៃប្រតិវេទន៍
- ប្រើប្រាស់ដៃគូសេវាដែលមានតម្លៃបន្ថែម
- ការបញ្ជូនបញ្ជីទំនិញដោយក្រុមហ៊ុនអាកាសចរណ៍ និងក្រុមហ៊ុនដឹកជញ្ជូនតាមប្រព័ន្ធអ៊ីនធឺណិត ក្នុងនោះរាប់បញ្ចូល ទាំងឧបករណ៍ deconsolidators ។
- ដំណើរការដោយស្វ័យប្រវត្តិសម្រាប់ប្រភេទផ្សេងៗទៀតនៃកិច្ចការនាំចូល ដូចជា កិច្ចការក្រៅផ្លូវការ (ក្នុងនោះរាប់ បញ្ចូលទាំងប្រព័ន្ធអីវ៉ាន់អ្នកដំណើរ) ទិន្នន័យឃ្លាំង និងទិន្នន័យដឹកជញ្ជូនឆ្លងកាត់ ។
- ដំណើរការដោយស្វ័យប្រវត្តិសម្រាប់ការជម្រះបញ្ជីសម្ភារៈវត្ថុធាតុដើម ។
- ការគ្រប់គ្រងបែបមជ្ឈការនូវកិច្ចការសញ្ញាប័ណ្ណ ។
- ការតភ្ជាប់ជាមួយទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ ។
- ការប្រើប្រាស់ធនធាននៅលើអ៊ីនធឺណិត តាមរយៈវ៉ែបសាយត៍ BOC ស្ដីពីការផ្ដល់ការអនុញ្ញាត ដំណើរការ គោល-នយោបាយ គោលការណ៍ណែនាំ និងព័ត៌មានដែលទាក់ទងផ្សេងទៀត ។

នៅក្នុងខែតុលា ឆ្នាំ២០០៤ ការធ្វើតេស្តសាកល្បងប្រព័ន្ធបំពេញបែបបទពន្ធគយថ្មីមួយ ដែលប្រើប្រាស់កម្មវិធីគយ អេឡិចត្រូនិក GXS RosettaNet eCustoms Solution ត្រូវបានអនុវត្តដោយជោគជ័យដោយ BOC ។ ប្រព័ន្ធស្វ័យប្រវត្តិថ្មីសម្រាប់ឯកសារដឹកជញ្ជូននេះ ផ្ដល់លទ្ធភាពដល់រោងចក្រឧស្សាហកម្មបច្ចេកវិទ្យា ទំនើបៗដើម្បីបញ្ជូនប្រតិវេទន៍ពន្ធគយ អេឡិចត្រូនិក ។ ប្រព័ន្ធថ្មីនេះ មានបំណងដើម្បីលើកកម្ពស់ផលិតភាពនៃវិស័យ អេឡិចត្រូនិក របស់ប្រទេសហ្វីលីពីន ដោយផ្ដល់លទ្ធភាពដល់កិច្ចការស្វ័យប្រវត្តិ និងមានសន្តិសុខកាន់តែ ច្រើនថែមទៀតជាមួយនឹងអ្នកផ្គត់ផ្គង់បរទេសរបស់ខ្លួន ។


ប្រភព ៖

ក្រុមប្រឹក្សាអាស៊ី-ប៉ាស៊ីហ្វិកសម្រាប់ការសម្រួលពាណិជ្ជកម្ម និងអាជីវកម្មអេឡិចត្រូនិក "របាយការណ៍ ជឿនលឿនរបស់ប្រទេសហ្វីលីពីន" នៅក្នុងសៀវភៅ *AFACT* ឆ្នាំ២០០៦ (តៃប៉ិ ៖ ការិយាល័យស្ដង់ដារ វាស់វែង និងអធិការកិច្ច ក្រសួងកិច្ចការ សេដ្ឋកិច្ច ឆ្នាំ២០០៦) ១១៣-១៣៤

http://www.afact.org/group/application/afact/2006AFACT/pdf/(4)%20Country%20Reports/7-p113_p134-2006%20Report-Philippines.pdf ។

Businesswire "ការិយាល័យគយហ្វីលីពីនដាក់ពង្រាយកម្មវិធីគយអេឡិចត្រូនិក GXS RosettaNet eCustoms Solution ការបំពេញបែបបទគយឆាប់រហ័ស និងផលប្រយោជន៍នៃការកាត់បន្ថយចំណាយ ត្រូវបានដៅទៅរកឧស្សាហកម្ម សម្ភារៈអគ្គិសនី និងអេឡិចត្រូនិក" (២០០៥)

http://findarticles.com/p/articles/mi_m0EIN/is_2005_August_25/ai_n14930696 ។

អនុគណៈកម្មាធិការទទួលបន្ទុកនីតិវិធីគយ "ឯកសារស្ដីពីការអនុវត្តល្អបំផុតរបស់ APEC សម្រាប់ បច្ចេកទេសថ្មៃប្រឌិតថ្មី សម្រាប់ការអនុវត្តច្បាប់តាមព្រំដែន IRP" (កិច្ចប្រជុំ APEC ថ្ងៃទី២៣-២៥ មិថុនា ២០០៧ Cairns អូស្ត្រាលី

http://aimp.apec.org/Documents/2007/SCCP/SCCP2/07_sccp2_016.doc ។

Subhash Bhatnagar កំណែទម្រង់គយហ្វីលីពីន (ធនាគារពិភពលោក ៖ ឆ្នាំ២០០១)

http://go.worldbank.org/J8J2YV6KG0 ។

***សំណួរត្រិះរិះ***

*តើអ្វីខ្លះដែលអ្នកគិតថាជាបញ្ហា និងភាពប្រឈម នៅក្នុងការអនុវត្ត និងថែទាំប្រព័ន្ធគយអេឡិចត្រូនិក ? តើបញ្ហា និងភាព ប្រឈមទាំងនេះ អាចដោះស្រាយបានយ៉ាងដូចម្តេច ?*

### ***កម្មវិធីពាណិជ្ជកម្មអេឡិចត្រូនិក***[29]

*ពាណិជ្ជកម្មអេឡិចត្រូនិកសំដៅជាចម្បងទៅលើការទិញ លក់ ផ្សព្វផ្សាយទីផ្សារ និងធ្វើសេវាផលិតផល ឬសេវានៅលើអ៊ីនធឺណិត និងបណ្តាញកុំព្យូទ័រផ្សេងទៀត ។ ប៉ុន្តែ ពាណិជ្ជកម្មអេឡិចត្រូនិកមាន ទិដ្ឋភាពជាច្រើន ។ តួនាទីរបស់ រដ្ឋាភិបាលនៅក្នុងពាណិជ្ជកម្មអេឡិចត្រូនិក គឺត្រូវផ្តល់លទ្ធភាពដល់ សហគមន៍អាជីវកម្មដើម្បីទទួលបានព័ត៌មានដែលមាន តម្លៃបំផុត និងប្រើប្រាស់ព័ត៌មាននេះអោយបាន ទាន់ពេលវេលាសម្រាប់ការផលិត និងលក់ទំនិញ និងសេវា ។ ពាណិជ្ជកម្មអេឡិច–ត្រូនិក ប្រើប្រាស់មូលដ្ឋាននៃអត្ថប្រយោជន៍ និងរចនាសម្ព័ន្ធនៃពាណិជ្ជកម្មជាប្រពៃណី ដោយបន្ថែមភាពអាច បត់បែនបានដែលផ្តល់ដោយបណ្តាញអេឡិចត្រូនិក ។*

#### ***ប្រអប់ ២ ៖ ការដោះស្រាយបញ្ហាច្បាប់ដែលទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិក***

*ការអនុម័តច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក គឺជាជំហានដ៏ចាំបាច់មួយដើម្បីបង្កើនទំនុកចិត្តទៅលើ មធ្យោបាយ តាមប្រព័ន្ធអេឡិចត្រូនិក ។ បញ្ហាផ្នែកច្បាប់មួយចំនួនទាមទារអោយមានការយកចិត្តទុក ដាក់ ។ ឧទាហរណ៍ អង្គការសម្រាប់ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍* (OECD) *បានកំណត់ បញ្ហាដូចតទៅ ៖ ពន្ធដារ ឯកជនភាព បញ្ហាទាក់ទងនឹងអ្នក ប្រើប្រាស់ ការបំលែងកូដ និងការបញ្ជាក់ លទ្ធភាពក្នុងការទទួលបាន និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន និង ផលប៉ះពាល់ទៅលើ សង្គមទាំងមូល ។*

*បញ្ហាទាក់ទងទៅនឹងការយកពន្ធទំនិញ និងសេវាដែលឆ្លងកាត់បណ្តាញអេឡិចត្រូនិក ចាំបាច់ត្រូវតែដោះ ស្រាយជាបន្ទាន់ ។ បញ្ហាសន្តិសុខទិន្នន័យ ក៏សំខាន់ចាំបាច់ផងដែរនៅក្នុងពាណិជ្ជកម្មអេឡិចត្រូនិក ទោះជាទាក់ទងនឹងការទិញសំបុត្រយន្តហោះតាមអ៊ីនធឺណិតក្តី ការប្រើប្រាស់ប័ណ្ណឥណទាន និងប័ណ្ណ ឥណពន្ធតាមរយៈអ៊ីនធឺណិត ឬពាណិជ្ជកម្មតាមអ៊ីនធឺណិត នៃក្រុមហ៊ុនវិនិយោគ សេវាធានារ៉ាប់រង និងសេវាដាក់ប្រាក់បញ្ញើក្តី ។*

*គណៈកម្មការសហប្រជាជាតិទទួលបន្ទុកច្បាប់ពាណិជ្ជកម្មអន្តរជាតិ* (UNCITRAL) *ស្ថាប័នច្បាប់ស្នូល នៃប្រព័ន្ធអង្គការសហប្រជាជាតិនៅក្នុងវិស័យច្បាប់ពាណិជ្ជកម្មអន្តរជាតិ បានរៀបចំច្បាប់ទូទៅមួយស្តីពី ពាណិជ្ជកម្មអេឡិចត្រូនិក ។ ជាពិសេស* UNCITRAL *បានរៀបចំច្បាប់គំរូរបស់* UNCITRAL *ស្តីពី ពាណិជ្ជកម្មអេឡិចត្រូនិក ឆ្នាំ១៩៩៦ ច្បាប់គំរូរបស់* UNCITRAL *ស្តីពីហត្ថលេខាអេឡិចត្រូនិក ឆ្នាំ២០០១ និងអនុសញ្ញាសហប្រជាជាតិស្តីពីការប្រើប្រាស់ប្រព័ន្ធគមនាគមន៍ អេឡិចត្រូនិកនៅក្នុងកិច្ចសន្យា អន្តរជាតិ ឆ្នាំ២០០៥ ។*

*លិខិតូបករណ៍ទាំងនេះ ដែលត្រូវបានអនុម័តដោយយុត្តាធិការមួយចំនួនរួចហើយនោះ និងដែលត្រូវបាន ចាត់ទុកជាបទដ្ឋានទូទៅ មានបំណងកែលម្អភាពអាចព្យាករណ៍បាននៅក្នុងកិច្ចការជំនួញឆ្លងព្រំដែន និង បង្កើនទំនុកចិត្តទៅលើប្រព័ន្ធ អេឡិចត្រូនិក ។ លិខិតូបករណ៍ទាំងនេះ ផ្អែកលើគោលការណ៍នានា ដូចជា ការមិនរើសអើងចំពោះប្រព័ន្ធគមនាគមន៍អេឡិច–ត្រូនិក ភាពមានមុខងារស្មើគ្នារវាងទម្រង់ជាក្រដាស និងទម្រង់អេឡិចត្រូនិក និងភាពអព្យាក្រឹតផ្នែកបច្ចេកវិទ្យា ។ ជាងនេះ ទៅទៀត លិខិតូបករណ៍* UNCITRAL *នៅក្នុងវិស័យផ្សេងៗនៃច្បាប់ពាណិជ្ជកម្មអន្តរជាតិ ដូចជា មជ្ឈត្តកម្ម លទ្ធកម្ម និងការ ដឹកជញ្ជូន ក៏មានចែងអំពីបញ្ញត្តិដែលពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកនៅក្នុងវិស័យទាំងនោះ ផងដែរ ។*

*ទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពសំខាន់ៗនៃពាណិជ្ជកម្មអេឡិចត្រូនិក គឺការបង្កើតកិច្ចការទំនាក់ទំនង រវាងក្រុមហ៊ុន និងក្រុមហ៊ុន* (B2B) *ដើម្បីជំរុញសហគ្រាសខ្នាតតូច និងមធ្យម* (SMEs) *។ រដ្ឋាភិបាលត្រូវតែកសាងហេដ្ឋារចនាសម្ព័ន្ធ ជាមូលដ្ឋាន ដែលចាំបាច់ដើម្បីជំរុញពាណិជ្ជកម្មអេឡិចត្រូនិក សម្រាប់អាជីវកម្មខ្នាតតូច ដូចជា បណ្តាញទូរគមនាគមន៍គ្មានខ្សែ ដែលប្រើប្រាស់ហ្វ្រេកង់ខ្ពស់ខ្លាំង និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ដូចជា បណ្តាញទូរគមនាគមន៍ចល័ត ផ្កាយរណប និងបណ្តាញផ្សាយ ។ នៅក្នុងពាណិជ្ជកម្មអេឡិចត្រូនិក* B2B *រដ្ឋាភិបាលចាំបាច់ត្រូវតែបង្កើត និងផ្តល់សេវានៅក្នុងវិស័យ ទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ភស្តុភារ សន្តិសុខ បណ្តាញពាណិជ្ជកម្ម អេឡិចត្រូនិកសាកល និងបញ្ហាផ្នែកច្បាប់ ។*

***ការកែលម្អពាណិជ្ជកម្មអេឡិចត្រូនិក* B2B *៖ ពាណិជ្ជកម្មអេឡិចត្រូនិក*** B2B *អាចកែលម្អផលិតភាព និងតម្លាភាពតាមរយៈការធ្វើព័ត៌មានីយកម្មសកម្មភាពអាជីវកម្មទាំងអស់ និងជំរុញការចែករំលែកព័ត៌មាន និងកិច្ចសហប្រតិបត្តិការ ក្នុងចំណោមក្រុមហ៊ុនដែលស្ថិតក្នុងខ្សែសង្វាក់ផ្គត់ផ្គង់តែមួយ ដើម្បីជំរុញ ពាណិជ្ជកម្មសហប្រតិបត្តិការ* (c-commerce) *។ ពាណិជ្ជកម្មសហប្រតិបត្តិការ គឺជាគំរូអាជីវកម្មមួយបែប ដែលក្រុមហ៊ុនមួយដាក់បញ្ចូលប្រព័ន្ធរបស់ខ្លួនជាមួយនឹងប្រព័ន្ធរបស់អ្នកផ្គត់ផ្គង់ និងដៃគូរបស់ខ្លួន នៅលើអ៊ីនធឺណិត ។ គំរូអាជីវកម្មនេះត្រូវបានគាំទ្រដោយកម្មវិធី* B2B *ក្នុងចំនួនកាន់តែច្រើន ឡើងដែលធ្វើស្វ័យប្រវត្តិកម្មដំណើរការអាជីវកម្មសំខាន់ៗនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ដោយលាតសន្ធឹងទៅ ហួសព្រំដែនសហគ្រាស ពីសម្ភារៈវត្ថុធាតុដើមរហូតដល់ផលិតផលសម្រេច ។*

*រដ្ឋាភិបាលអាចអភិវឌ្ឍ និងដាក់ពង្រាយសម្រាប់ការប្រើប្រាស់នូវប្រព័ន្ធដែលគាំទ្រពាណិជ្ជកម្ម សហប្រតិបត្តិការ និង កម្មវិធីកុំព្យូទ័រល្អបំផុតសម្រាប់ការដោះស្រាយបញ្ហាសម្រាប់កិច្ចសហប្រតិបត្តិការ អន្តរក្រុមហ៊ុន ។ រដ្ឋាភិបាលអាចជំរុញការ អនុវត្តគម្រោងសាកល្បងសម្រាប់ពាណិជ្ជកម្មសហប្រតិបត្តិការ ដោយយក* SMEs *ដែលមានសក្តានុពលជាគោលដៅសម្រាប់ គម្រោងទាំងនេះ ។ វប្បធម៌សាជីវកម្ម*

---

[29] ផ្នែកនេះដកស្រង់ចេញពីទស្សនវិស័យកូរ៉េអេឡិចត្រូនិក ឆ្នាំ២០០៦ ៖ ផែនការមេលើកទី៣ សម្រាប់ការជំរុញព័ត៌មានីយកម្ម (២០០២–២០០៦) (សេអ៊ូល ៖ ក្រសួងព័ត៌មាន និងគមនាគមន៍ ឆ្នាំ២០០២) http://www.ipc.go.kr/ipceng/policy/vision_2006.jsp

បច្ចុប្បន្នច្រើនតែមានលក្ខណៈបិទបាំង និងគ្មានតម្លាភាព ដូច្នេះហើយ រដ្ឋាភិបាលចាំបាច់ ត្រូវតែជំរុញការ ចែករំលែកព័ត៌មាន ។ ដើម្បីធានាភាពរលូននៃពាណិជ្ជកម្មអេឡិចត្រូនិក B2B និងការចែករំលែកព័ត៌មានជាការចាំបាច់ គឺត្រូវបង្កើតកម្មវិធីតភ្ជាប់ដែលមានប្រសិទ្ធផល និងជំរុញការធ្វើបទដ្ឋានីយកម្មទិន្នន័យ និងពិធីសារ ដែលជួយ សម្រួលដល់ការបញ្ជាក់ភាពពិតប្រាកដនៃកិច្ចការ និងធានានូវសន្តិសុខព័ត៌មាន ។

ពង្រីកបណ្តាញ B2B ៖ រដ្ឋាភិបាលគួរជំរុញពាណិជ្ជកម្មអេឡិចត្រូនិកក្នុងវិស័យផលិតកម្ម និងសេវា ដើម្បីកែលម្អ ភាពប្រកួតប្រជែងនៃវិស័យទាំងនេះ ។ នៅក្នុងសាធារណរដ្ឋកូរ៉េ រដ្ឋាភិបាលបានដាក់ចេញនូវគោលដៅអនុបាត ៣០% នៃ ពាណិជ្ជកម្មអេឡិចត្រូនិក ធៀបនឹងកិច្ចការអាជីវកម្មសរុប នៅក្នុង វិស័យស្នូលចំនួន ៦ (វិស័យអេឡិចត្រូនិក យានយន្ត ការស្ថាបនានាវា ដែកថែប គ្រឿងចក្រ និង វាយនភណ្ឌ) និង ២៥% នៅក្នុងវិស័យដែលនៅសល់ ។ រដ្ឋាភិបាលបានគាំទ្រការ កសាងហេដ្ឋារចនា សម្ព័ន្ធពាណិជ្ជកម្មអេឡិចត្រូនិក B2B ដូចជា ការធ្វើបទដ្ឋានីយកម្ម និងកាតាឡុកអេឡិចត្រូនិកនៃវិស័យ នីមួយៗ ។ នៅត្រឹមឆ្នាំ២០០៥ វិស័យជាង ៥០ បានកសាងបណ្តាញ B2B របស់ខ្លួន ។

កែលម្អភស្តុការ និងប្រព័ន្ធទូទាត់ប្រាក់សម្រាប់ការជំរុញពាណិជ្ជកម្មអេឡិចត្រូនិក B2B ៖ ប្រព័ន្ធភស្តុភារ រួមមួយ ដែលតភ្ជាប់ទៅប្រព័ន្ធដែលពាក់ព័ន្ធ (ឧទាហរណ៍ ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ) គឺជាសមាសភាគសំខាន់មួយនៃការជំរុញវិស័យ ពាណិជ្ជកម្មអេឡិចត្រូនិក B2B ។ ប្រព័ន្ធភស្តុភារបែបនេះ អាចកសាងឡើងដោយផ្អែកលើប្រព័ន្ធដឹកជញ្ជូនដ៏ឈ្លាសវៃ និង ប្រព័ន្ធព័ត៌មាន ភូមិសាស្ត្រ និងតាមរយៈការតភ្ជាប់ជាមួយនឹងបណ្តាញទូរគមនាគមន៍គ្មានខ្សែ ។

ជាងនេះទៅទៀតច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងនឹងប្រព័ន្ធទូទាត់ប្រាក់អេឡិចត្រូនិក ចាំបាច់ត្រូវតែកែ លម្អដើម្បីធានាបាននូវបរិយាកាសអាចទុកចិត្តបាន និងមានសុវត្ថិភាពសម្រាប់ពាណិជ្ជកម្មអេឡិចត្រូនិក ។ ជាការចាំបាច់គឺត្រូវពង្រីក ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រព័ន្ធទូទាត់ប្រាក់អេឡិចត្រូនិក និងដាក់អោយ អនុវត្តនូវប្រព័ន្ធកំណត់អត្តសញ្ញាណបុគ្គល និងប្រព័ន្ធ គ្រប់គ្រងសន្តិសុខ ដើម្បីធានានូវសុវត្ថិភាព ប្រាក់អេឡិចត្រូនិក ។

បង្កើតហេដ្ឋារចនាសម្ព័ន្ធសម្រាប់ពាណិជ្ជកម្មអេឡិចត្រូនិកអន្តរជាតិ ៖ ព័ត៌មានអំពីទីផ្សារអេឡិចត្រូនិក មានសារប្រយោជន៍សម្រាប់ការជំរុញពាណិជ្ជកម្មអេឡិចត្រូនិកអន្តរជាតិ ។ ព័ត៌មានបែបនេះ គួររួមបញ្ចូល នូវឯកសារកាតាឡុក និងស្តង់ដារទំនិញ ។ លើសពីនេះទៅទៀត រដ្ឋាភិបាលចាំបាច់ត្រូវតែផ្តល់ សេវាជំនាញ ដែលអាចជួយដោះស្រាយជម្លោះដែល អាចកើតចេញពីពាណិជ្ជកម្មអន្តរជាតិ ។

ពាណិជ្ជកម្មអេឡិចត្រូនិកផ្តល់នូវបរិយាកាសសម្រាប់ពាណិជ្ជកម្មអន្តរជាតិដែលមិនប្រើក្រដាស តាមរយៈ ការបង្កើតប្រព័ន្ធរួមបញ្ចូលគ្នាមួយនៃការធ្វើស្វ័យប្រវត្តិកម្មពាណិជ្ជកម្មអន្តរជាតិ ដែលសមស្របសម្រាប់ អ៊ីនធឺណិត ។ នៅក្នុងប្រទេសកូរ៉េ ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិក (EDI) ត្រូវបានរដ្ឋាភិបាល ចែកចាយដល់អ្នកនាំចេញទាំងអស់ ហើយឧបសគ្គចំពោះ ការធ្វើស្វ័យប្រវត្តិកម្មពាណិជ្ជកម្មអន្តរជាតិ ត្រូវបានលុបបំបាត់ ។ គម្រោងបណ្តាញពាណិជ្ជកម្មអេឡិចត្រូនិកសាកល ដើម្បី ចាត់ចែងដំណើរការ ទាំងអស់ដែលពាក់ព័ន្ធជាមួយនឹងពាណិជ្ជកម្មអន្តរជាតិ ក្នុងនោះរាប់បញ្ចូលទាំងសេវាអន្តរការី កិច្ចសន្យា ការទូទាត់ប្រាក់ និងភស្តុភារ ត្រូវបានគ្រោងផែនការ ។ ដោយតភ្ជាប់បណ្តាញទៅនឹងប្រព័ន្ធស្វ័យ ប្រវត្តិកម្មពាណិជ្ជកម្មអន្តរជាតិនៃបណ្តាប្រទេសអាស៊ី និងអឺរ៉ុបផ្សេងទៀត រដ្ឋាភិបាលសាធារណរដ្ឋ កូរ៉េសង្ឃឹមថានឹងបង្កើតបាននូវបរិយាកាសពាណិជ្ជកម្មអេឡិចត្រូនិកសម្រាប់ពាណិជ្ជករអន្តរជាតិគ្រប់ រូបភាព ។

ជំរុញការធ្វើព័ត៌មានីយកម្ម SMEs ៖ រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េបានកំណត់យកអាទិភាពមួយ ក្នុងចំណោម អាទិភាពទាំងឡាយរបស់ខ្លួន ដើម្បីតភ្ជាប់ក្រុមហ៊ុនទាំងអស់នៅក្នុងសាធារណរដ្ឋកូរ៉េជាមួយនឹងប្រព័ន្ធអ៊ីនធឺណិត និងពង្រីកមូលដ្ឋាននៃពាណិជ្ជកម្មអេឡិចត្រូនិកនៅទូទាំងប្រទេស ។ ដើម្បីសម្រេចបានអាទិភាពនេះ រដ្ឋាភិបាលជួយដល់ SMEs នៅក្នុង សាធារណរដ្ឋកូរ៉េក្នុងការទទួលបានការតភ្ជាប់ជាមួយនឹងប្រព័ន្ធអ៊ីនធឺណិត និងប្រើប្រាស់ IT តាមរយៈសេវារួមបញ្ចូលគ្នានានា ដែលផ្តល់ដោយក្រុមហ៊ុនផ្គត់ផ្គង់សេវាកម្មវិធី ។ ប្រព័ន្ធគាំទ្រពាណិជ្ជកម្មអេឡិចត្រូនិកទូលំទូលាយមួយកំពុងត្រូវបានធ្វើផែនការ រួមជាមួយនឹងការផ្តល់សេវានៅក្នុងតំបន់ឧស្សាហកម្មប្រមូលផ្តុំ ។

ប្រព័ន្ធចែកចាយព័ត៌មានឧស្សាហកម្មដែលនឹងជួយដល់ SMEs ចំនួន ៣០.០០០ នៅក្នុងសាធារណរដ្ឋកូរ៉េ ដើម្បីកែលម្អភាពប្រកួតប្រជែងរបស់ខ្លួននិងកាត់បន្ថយថ្លៃចំណាយទៅលើការទទួលបានព័ត៌មាន កំពុងត្រូវបានរៀបចំបង្កើតឡើង ។ មូលដ្ឋានទិន្នន័យ និងប្រព័ន្ធរុករកដែលរួមបញ្ចូលគ្នានៃព័ត៌មានឧស្សាហកម្ម នឹងត្រូវរៀបចំបង្កើតឡើងនៅក្នុងឧស្សាហកម្មធំៗ ដូចជា គ្រឿងចក្រ និងអេឡិចត្រូនិក ។ SMEs ក៏កំពុងត្រូវបានលើកទឹកចិត្តអោយចងក្រងជាសមាគមសម្រាប់ពាណិជ្ជកម្មអេឡិចត្រូនិក B2B ប្រភេទ សហគមន៍ក្នុងទ្រង់ទ្រាយតូច ។

**ពាណិជ្ជកម្មអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ**

ទំហំនៃពាណិជ្ជកម្មអេឡិចត្រូនិកនៅក្នុងសាធារណរដ្ឋកូរ៉េបានឡើងដល់ ៤១៣,៥៨៤ពាន់ពាន់លានKRW នៅក្នុងឆ្នាំ២០០៦ គឺកើនឡើង ១៥,៤ភាគរយពីឆ្នាំ២០០៥ ។ សមាមាត្រនៃប្រភេទអាជីវកម្មនីមួយៗពុំមានការប្រែប្រួលច្រើននោះទេ ដោយសមាមាត្រនៃប្រភេទកិច្ចការ B2B បានថយចុះ ហើយសមាមាត្រ នៃប្រភេទកិច្ចការ B2G បានកើនឡើងបន្តិច បន្តួច ។

ការស្ទង់មតិស្តីពីស្ថានភាពពាណិជ្ជកម្មអេឡិចត្រូនិកក្នុងស្រុក ឆ្នាំ២០០៦ ដែលអនុវត្តដោយវិទ្យាស្ថាន ពាណិជ្ជកម្ម អេឡិចត្រូនិកកូរ៉េ ទៅលើក្រុមហ៊ុនចំនួន ៤.០០០ នៅក្នុងសាធារណរដ្ឋកូរ៉េ បង្ហាញអោយឃើញថាក្រុមហ៊ុនប្រហែល ៣៦,៧ ភាគរយ កំពុងអនុវត្តកិច្ចការអេឡិចត្រូនិក (ដែលជានិយមន័យទូលំ ទូលាយនៃពាណិជ្ជកម្មអេឡិចត្រូនិក) ឬដំណើរការមួយ ឬច្រើនសម្រាប់កិច្ចការអេឡិចត្រូនិក តាមរយៈ កុំព្យូទ័រ ឬបណ្តាញ ។

យោងតាមទិន្នន័យពីការិយាល័យស្ថិតិជាតិ ទំហំកិច្ចការ B2B នៅក្នុងឆ្នាំ២០០៦ ស្មើនឹង ៨៨,៥ភាគរយនៃកិច្ចការសរុបទាំងអស់ ។ ក្នុងចំណោមកិច្ចការ B2B កិច្ចការដែលដឹកនាំដោយអ្នក ទិញមានចំនួន

៧១,៩ភាគរយ ហើយកិច្ចការដែល ដឹកនាំដោយអ្នកលក់ មានចំនួន ២៣,៥ភាគរយ ដែលនេះបង្ហាញអោយឃើញថា ទីផ្សារភាគច្រើនបំផុតនៅតែដឹកនាំដោយ អ្នកទិញ ។ ទំហំកិច្ចការពាណិជ្ជកម្មអេឡិចត្រូនិកដែលដឹកនាំដោយឈ្មួញកណ្តាល មាន ៤,៥ភាគរយនៃកិច្ចការសរុប ដែលកើន ឡើងបន្តិចបន្តួចពីឆ្នាំកន្លងទៅ ។

នៅក្នុងទីផ្សារ B2G ក្នុងឆ្នាំ២០០៦ កិច្ចសន្យាសំណង់ ដែលដណ្តើមយកមួយភាគធំនៅចន្លោះឆ្នាំ២០០២ និងឆ្នាំ ២០០៥ បានថយចុះមកនៅត្រឹមជាភាគតូច បើធៀបទៅនឹងការទិញទំនិញ និងសេវាជាលើកដំបូងនៅក្នុងរយៈពេល ៥ឆ្នាំ ។ ទីផ្សារ B2G ដែលពាក់ព័ន្ធជាមួយនឹងស្ថាប័នរដ្ឋាភិបាលនានា ដូចជា អង្គការរដ្ឋបាលកណ្តាល អង្គការរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងការិយាល័យអប់រំ មានទំហំស្មើនឹង ៣៤,៤៣៦ពាន់ពាន់លាន KRW ។

ចំនួននៃផ្សារលក់ទំនិញតាមអ៊ីនធឺណិតនៅក្នុងឆ្នាំ២០០៦ បានកើនឡើង ៤,០ភាគរយពីឆ្នាំ២០០៥ ឡើងដល់ចំនួន ៤.៥៣១ ។ ក្នុងចំណោមចំនួនសរុបនេះ ផ្សារលក់ទំនិញតាមអ៊ីនធឺណិតចំនួន ៤,២៨៩ ឬ ៩៤,៧ភាគរយ គឺជាផ្សារឯកទេស និងតែ ៥,៣ភាគរយប៉ុណ្ណោះ គឺជាផ្សារទូទៅ ។ ប៉ុន្តែ គិតជាទំហំកិច្ចការពាណិជ្ជកម្ម ៧១,១ភាគរយ ឬ ៩,៥៧០៧ពាន់ពាន់ លាន KRW នៃតម្លៃកិច្ចការ ពាណិជ្ជកម្មត្រូវបានធ្វើឡើងដោយផ្សារទូទៅ គឺច្រើនជាងនៅក្នុងឆ្នាំ២០០៥ ហើយ ២៨,៩ភាគ រយ ត្រូវបានអនុវត្តដោយផ្សារឯកទេស ។ នៅពេលវិភាគតាមប្រភេទនៃប្រតិបត្តិការ ផ្សារលក់ទំនិញនៅលើ អ៊ីនធឺណិតមាន ចំនួន ៤៨,៧ភាគរយ (២.២០៨) ចំណែកឯផ្សារដែលប្រតិបត្តិការទាំងនៅលើអ៊ីនធឺណិត និងទាំងក្នុងលក្ខណៈធម្មតាដោយមិន ភ្ជាប់ទៅនឹងបណ្តាញអ៊ីនធឺណិត មានចំនួន ៥១,៣ភាគរយ (២,៣២៣) ។

ប្រភព ៖

ដកស្រង់ចេញពីសៀវភៅសស្តីពីព័ត៌មានូបនីយកម្ម ឆ្នាំ២០០៧ ៖ សាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារសមាគមព័ត៌មាន ជាតិ ឆ្នាំ២០០៧)
http://www.nia.or.kr/open_content/board/fileDownload.jsp?tn=PU_0000100&id=53922&seq=1&fl=7 ។

***ពាណិជ្ជកម្មអេឡិចត្រូនិកនៅក្នុងប្រទេសថៃ ត្រូវបានពណ៌នានៅខាងក្រោមនេះ ។***

***ពាណិជ្ជកម្មអេឡិចត្រូនិកនៅក្នុងប្រទេសថៃ***

ពាណិជ្ជកម្មអេឡិចត្រូនិក គឺជាគោលដៅមួយក្នុងចំណោមគោលដៅចម្បងៗជាច្រើន ដែលចែងនៅក្នុង ក្របខ័ណ្ឌ គោលនយោបាយបច្ចេកវិទ្យាព័ត៌មាន ឆ្នាំ២០០១–២០១០ (IT2010) របស់ប្រទេសថៃ ។ គោលបំណងនៃពាណិជ្ជកម្ម អេឡិចត្រូនិកនេះ គឺដើម្បីពង្រឹងភាពប្រកួតប្រជែងរបស់សហគ្រិនថៃ ជាពិសេស SMEs ។

IT2010 ដាក់ចេញនូវយុទ្ធសាស្ត្រចំនួន ៨ សម្រាប់ការកែលម្អពាណិជ្ជកម្មអេឡិចត្រូនិកនៅក្នុងប្រទេសថៃ ៖

- អនុវត្តយុទ្ធសាស្ត្របរទេសសកម្មមុន ក្នុងនោះរួមបញ្ចូលទាំងការប្រកាសពាណិជ្ជកម្ម អេឡិចត្រូនិកជាយុទ្ធសាស្ត្រ ពាណិជ្ជកម្មជាតិ ដែលត្រូវបានធ្វើសមាហរណកម្មជាមួយផែនការ អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចលើកទី៩ និងលើក ទី១០ ។
- បង្កើតការយល់ដឹងអំពីពាណិជ្ជកម្មអេឡិចត្រូនិក ជាពិសេសក្នុងចំណោមសហគ្រិន SME ។
- ផ្តល់បរិយាកាសអនុគ្រោះផ្នែកច្បាប់សម្រាប់ពាណិជ្ជកម្មអេឡិចត្រូនិក ។
- ជំរុញ និងគាំទ្រប្រព័ន្ធសុវត្ថិភាព និងសន្តិសុខ ។
- ផ្តោតសំខាន់ទៅលើមូលដ្ឋានទិន្នន័យ និងយុទ្ធសាស្ត្រគ្រប់គ្រងទិន្នន័យ ក្នុងនោះរាប់បញ្ចូលទាំង វិធានការសម្រាប់ការបង្កើតមូលដ្ឋានទិន្នន័យ និងបណ្តាញទិន្នន័យ ដើម្បីជួយសម្រួល ដល់ការធ្វើផែនការ និងសេវាសម្រាប់បណ្តាក្រុមហ៊ុន ឧស្សាហកម្ម និងអ្នកប្រើប្រាស់ ។
- គាំទ្រ SMEs នៅក្នុងការប្រើប្រាស់កម្មវិធីពាណិជ្ជកម្មអេឡិចត្រូនិក និងកែលម្អភាពប្រកួតប្រជែង របស់ SEMs នៅក្នុងសេដ្ឋកិច្ចសាកលលោក ។
- អភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យអប់រំ និងសម្រាប់ការអភិវឌ្ឍជំនាញនៅក្នុងកម្លាំងទីផ្សារ បច្ចុប្បន្ន ។
- ផ្តល់ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់និងមានតម្លៃសមរម្យ ព្រមទាំងសមាសភាគនៃប្រព័ន្ធនេះ ដើម្បីផ្តល់លទ្ធភាពដល់ ការប្រើប្រាស់ទូលំទូលាយនូវកម្មវិធីពាណិជ្ជកម្មអេឡិចត្រូនិក ដោយទាំង ក្រុមហ៊ុន និងអ្នកប្រើប្រាស់ ក្នុងនោះរាប់ បញ្ចូលទាំងការបង្កើតស្តង់ដារសម្រាប់ផលិតផល ទំនិញ និងសេវាសំខាន់ៗនៅក្នុងប្រទេស ។

រដ្ឋាភិបាលថៃបានអនុវត្តគំនិតផ្តួចផ្តើមមួយចំនួន ដើម្បីជំរុញនិងពន្លឿនកំណើននៃពាណិជ្ជកម្ម អេឡិចត្រូនិក ។ គំនិត ផ្តួចផ្តើមមួយក្នុងចំណោមគំនិតផ្តួចផ្តើមទាំងនេះ គឺច្បាប់ស្តីពីការចុះបញ្ជី ពាណិជ្ជកម្មដែលតម្រូវអោយប្រតិបត្តិករពាណិជ្ជកម្ម អេឡិចត្រូនិកធ្វើការចុះបញ្ជីពាណិជ្ជកម្ម ។ ក្រសួងពាណិជ្ជកម្មកំពុងប្រើប្រាស់ស្លាកសញ្ញាទំនុកចិត្ត (តែមប្រ៍អេឡិចត្រូនិកនៃ ការអនុញ្ញាត) ដើម្បីកំណត់ស្តង់ដារសម្រាប់វែបសាយត៍ពាណិជ្ជកម្មអេឡិចត្រូនិក និងកសាងទំនុកចិត្តរបស់អតិថិជន ។ មណ្ឌល ទទួលពាក្យបណ្តឹងពាណិជ្ជកម្មអេឡិចត្រូនិក ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៦ ។ ជាងនេះទៅទៀត ទីភ្នាក់ងាររដ្ឋាភិបាលជាច្រើន ព្រមទាំងក្រុមហ៊ុនឯកជន ក្នុងនោះរាប់បញ្ចូល ទាំងធនាគារ និងរោងចក្រផលិតកំពុងអនុវត្តកិច្ចការពាណិជ្ជកម្ម នៅ លើអ៊ីនធឺណិត ។

នៅក្នុងឆ្នាំ២០០៤ គេហទំព័រវែបសាយត៍ជាង ២.៥០០ ដែលប្រតិបត្តិការដោយសហគ្រិនពាណិជ្ជកម្ម អេឡិចត្រូនិកប្រហែល ១.៨៦០នាក់នៅក្នុងប្រទេសថៃ ត្រូវបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ។ កិច្ចការ

B2B អេឡិចត្រូនិក រួមមាន ភាគច្រើននៃកិច្ចការនៅក្នុងវិស័យពាណិជ្ជកម្មអេឡិចត្រូនិកនៅក្នុង ប្រទេសថៃ ។ ក្រុមហ៊ុនផ្គត់ផ្គង់សេវាផ្នែកលក់ ដេញថ្លៃ/លទ្ធកម្ម នៅលើអ៊ីនធឺណិតដ៏សំខាន់មួយ គឺ Pantavanij (https://www.pantavanij.com) ។ កិច្ចការពាណិជ្ជកម្មរបស់ Pantavanij នៅក្នុងឆ្នាំ ២០០៥ បានឡើងដល់ ៤៧,៩ពាន់លានបាត ក្នុងនោះ ៣៥,២ពាន់លានបាត បានមកពីការទិញនៅលើ អ៊ីនធឺណិត និង ១២,៧ពាន់លានបាត បានមកពីការដាក់លក់ដេញថ្លៃនៅលើអ៊ីនធឺណិត ។ កិច្ចការពាណិជ្ជកម្មនៅលើអ៊ីនធឺណិត ក្នុងឆ្នាំ២០០៥ បានឡើងដល់ប្រហែល ១០០ពាន់លានបាត កើនពី ៦៣ពាន់លានបាតនៅក្នុងឆ្នាំ២០០៣ ។

ដើម្បីបន្តពង្រឹងវិស័យពាណិជ្ជកម្មអេឡិចត្រូនិករបស់ប្រទេសថៃ ជាការចាំបាច់ គឺត្រូវជំរុញពាណិជ្ជកម្ម អេឡិចត្រូនិក នៅក្នុងចំណោម SMEs និងលើកទឹកចិត្តពលរដ្ឋអោយចូលរួមនៅក្នុងកិច្ចការ B2C ។

ប្រភព ៖

អង្គភាពចារកម្មសេដ្ឋកិច្ច "ប្រទេសថៃ ៖ ទិដ្ឋភាពទូទៅនៃពាណិជ្ជកម្មអេឡិចត្រូនិក" នៅក្នុងទស្សនាវដ្ដី *The Economist* (ថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧)

http://globaltechforum.eiu.com/index.asp?layout=rich_story&doc_id=9936&title=Thailand%3A+Overview+of+e-commerce&channelid=4&categoryid=30 ។

មជ្ឈមណ្ឌលជាតិអេឡិចត្រូនិក និងបច្ចេកវិទ្យាកុំព្យូទ័រ សូចនាករ *ICT* ឆ្នាំ២០០៥របស់ប្រទេសថៃ (បាងកក ៖ មជ្ឈមណ្ឌល ជាតិអេឡិចត្រូនិក និងបច្ចេកវិទ្យាកុំព្យូទ័រ ទីភ្នាក់ងារជាតិវិទ្យាសាស្ត្រ និង អភិវឌ្ឍន៍បច្ចេកវិទ្យា ក្រសួងវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ឆ្នាំ២០០៥) http://www.nectec.or.th/2008/pdf/ict_indicators2005.pdf ។

លេខាធិការដ្ឋានគណៈកម្មាធិការជាតិបច្ចេកវិទ្យាព័ត៌មាន ក្របខ័ណ្ឌគោលនយោបាយបច្ចេកវិទ្យាព័ត៌មាន ឆ្នាំ២០០១-២០១០ : ទស្សនវិស័យឆ្ពោះទៅរកសេដ្ឋកិច្ចផ្អែកលើចំណេះដឹងរបស់ប្រទេសថៃ (បាងកក ៖ មជ្ឈមណ្ឌលជាតិអេឡិចត្រូនិក និងបច្ចេក-វិទ្យាកុំព្យូទ័រ ទីភ្នាក់ងារជាតិវិទ្យាសាស្ត្រ និងអភិវឌ្ឍន៍ បច្ចេកវិទ្យា ក្រសួងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ឆ្នាំ២០០៣)
http://www.etcommission.go.th/documents/it2010_publish_version_en.pdf ។

Somnuk Keretho និង Paisan Limstit ពាណិជ្ជកម្មអេឡិចត្រូនិក ៖ ច្រកអាជីវកម្មនៅក្នុងប្រទេសថៃ (បាងកក ៖ មជ្ឈមណ្ឌលជាតិអេឡិចត្រូនិក និងបច្ចេកវិទ្យាព័ត៌មាន ឆ្នាំ២០០២)
http://www.ecommerce.or.th/APEC-Workshop2002/ppt/pdf/ec_way_business_in_Thailand.pdf ។

Thaweesak Koanantakool និង Kalaya Udomvitid ".th Thailand" នៅក្នុងរបាយការណ៍ឌីជីថលនៃតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្នាំ២០០៧/២០០៨ (New Delhi: Sage, IDRC, Orbicom: ២០០៧)
http://www.idrc.ca/en/ev-127181-201-1-DO_TOPIC.html ។

**កិច្ចការដែលត្រូវអនុវត្ត**

1. ពណ៌នាអំពីវិស័យ SME នៅក្នុងប្រទេសរបស់អ្នក និងពន្យល់អំពីរបៀបដែលពាណិជ្ជកម្មអេឡិច ត្រូនិកអាចជួយដល់ វិស័យនេះ ។
2. តើកម្មវិធីពាណិជ្ជកម្មអេឡិចត្រូនិកអ្វីខ្លះដែលល្អបំផុត នៅក្នុងប្រទេសរបស់អ្នក ? ចូរពណ៌នា អំពីកម្មវិធីមួយ ក្នុងចំណោមកម្មវិធីទាំងនេះ ក្នុងនោះរាប់បញ្ចូលទាំងរបៀបដែលកម្មវិធីនេះ បានកើតឡើង និងផលប៉ះពាល់របស់កម្មវិធី នេះទៅលើសេដ្ឋកិច្ចនៃប្រទេសរបស់អ្នក ។

**ធ្វើតេស្តខ្លួនឯង**

1. រាយឈ្មោះសេវា G2B ធម្មតា ។
2. មូលហេតុអ្វីបានជាការកសាងប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិក គឺជាការសំខាន់ ?
3. មានសមាសភាគ និងអនុប្រព័ន្ធជាច្រើន ដែលត្រូវការចាំបាច់ដើម្បីបង្កើតប្រព័ន្ធដូចតទៅ ៖ លទ្ធកម្មអេឡិចត្រូនិក គយអេឡិចត្រូនិក និងពាណិជ្ជកម្មអេឡិចត្រូនិក ។ ចូរកំណត់សមាសភាគទាំងនេះ ។

4. ចូរពន្យល់ត្រួសៗអំពីអត្ថន័យនៃ B2B, B2G, B2C និង C2C និងរាយឈ្មោះប្រភេទនៃកិច្ចការ ពាណិជ្ជកម្ម ដែល ស្ថិតនៅក្រោមអត្ថន័យនៃពាក្យនីមួយៗ ។

5. តើផលិតផល និងសេវាប្រភេទអ្វីខ្លះ ដែលអាចផ្តល់អោយតាមរយៈពាណិជ្ជកម្មអេឡិចត្រូនិក ?

### ៣.៣. រដ្ឋាភិបាលទៅកាន់រដ្ឋាភិបាល (G2G) ៖ ការច្នៃប្រឌិតរបៀបធ្វើការថ្មីៗសម្រាប់រដ្ឋាភិបាល

#### ប្រព័ន្ធហិរញ្ញវត្ថុរួមបញ្ចូលគ្នា[30]

នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ដោយសារតែកំណើននៃសេរីភាវូបនីយកម្ម និងសាកលភាវូបនីយកម្មនៃ ទីផ្សារហិរញ្ញវត្ថុ ការប្រកួតប្រជែងរវាងស្ថាប័នហិរញ្ញវត្ថុក្នុងស្រុកកាន់តែមានសភាពតឹងតែង ហើយលទ្ធភាពរកប្រាក់ចំណេញកាន់តែធ្លាក់ចុះជាលំដាប់ ។ ដើម្បីដោះស្រាយបញ្ហានេះ និងបង្កើនភាព ប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ តម្រូវការសម្រាប់បណ្តាញ ព័ត៌មានហិរញ្ញវត្ថុមួយ ដែលរៀបចំឡើងវិញនូវនីតិវិធីកិច្ចការពាណិជ្ជកម្ម និងផ្តល់សេវាដែលមានគុណភាពកាន់តែល្អដល់អតិថិជនត្រូវបាន លើកឡើង ។

ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៨៥ ធនាគារក្នុងស្រុកនៅក្នុងសាធារណរដ្ឋកូរ៉េ បានអនុវត្តប្រព័ន្ធកុំព្យូទ័រនៅក្នុងអង្គភាពអាជីវកម្ម និងបានបង្កើតបណ្តាញតភ្ជាប់គ្នាទៅវិញទៅមករវាង ទីស្នាក់ការកណ្តាល និងសាខា ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ជាផ្នែកមួយនៃគម្រោងប្រព័ន្ធព័ត៌មាន មូលដ្ឋានថ្នាក់ជាតិ ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុអន្តរធនាគារ ត្រូវបានដាក់ពង្រាយ ដោយអនុញ្ញាតអោយ អតិថិជនអាចធ្វើកិច្ចការហិរញ្ញវត្ថុអន្តរធនាគារបាន ។ ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ អន្តរធនាគារ ត្រូវបាន កែលម្អនៅក្នុងឆ្នាំ១៩៩២–១៩៩៦ ហើយស្ថាប័នហិរញ្ញវត្ថុក្រៅពីធនាគារ ដូចជា ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនធានារ៉ាប់រង និងធនាគារវិនិយោគ ក៏ត្រូវបានតភ្ជាប់បណ្តាញជាមួយគ្នាទៅវិញទៅមក ផងដែរ ។ សេវាធនាគារតាម ក្រុមហ៊ុន និងសេវាធនាគារតាមផ្ទះ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៤ ។ នៅដើមឆ្នាំ១៩៩៧ ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ នៃស្ថាប័នហិរញ្ញវត្ថុមិនមែនធនាគារ ក៏ត្រូវបានបង្កើត ឡើងផងដែរ ដោយចាក់គ្រឹះសម្រាប់ការតភ្ជាប់ស្ថាប័នហិរញ្ញវត្ថុទាំងអស់ ក្នុងនោះរាប់បញ្ចូលទាំងធនាគារ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនធានារ៉ាប់រង និងធនាគារវិនិយោគ ។

នៅក្នុងវិស័យគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋាភិបាល ជាការចាំបាច់ដែលត្រូវតភ្ជាប់ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុទាំងអស់ ដែល ប្រតិបត្តិការដោយឯករាជ្យ នៅក្នុងទីភ្នាក់ងាររដ្ឋាភិបាលនានា ។ ប្រព័ន្ធហិរញ្ញវត្ថុរួមបញ្ចូលគ្នានេះ ត្រូវបានអោយឈ្មោះថា NAFIS (រូបភាពទី ១៦) ។

**រូបភាពទី ១៦ ៖ ម៉ាស៊ីនកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលកូរ៉េ**

(ប្រភព ៖ Soh Bong Yu, "រដ្ឋាភិបាលអេឡិចត្រូនិកនៃសាធារណរដ្ឋកូរ៉េ ៖ របៀបដែលយើងកំពុងធ្វើការងារជាមួយរដ្ឋាភិបាលអេឡិចត្រូនិច"

(បទបង្ហាញរបស់ KADO) ១៦

https://www.kado.or.kr/koil/bbs/board_view.asp?config_code=362&offset=0&board_code=3246)

[30] ផ្នែកនេះដកស្រង់ចេញពីទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម រដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រ ភាវូបនីយកម្ម ឆ្នាំ២០០២) http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023905.pdf .




*ដូចដែលបង្ហាញនៅក្នុងរូបភាពទី ១៦* NAFIS *រួមមាន ១០ម៉ូឌុល ៖*

*ម៉ូឌុលស្តីពីការរៀបចំថវិកា និងធ្វើវិភាជន៍ថវិកា គ្របដណ្តប់លើរាល់ដំណើរការធ្វើផែនការថវិការបស់ រដ្ឋាភិបាល ។*

*ម៉ូឌុលស្តីពីការគ្រប់គ្រងបង្កាន់ដៃចំណាយ និងការទូទាត់ប្រាក់ គ្របដណ្តប់លើការប្រមូលចំណូលពន្ធ និងចំណូល មិនមែនពន្ធ និងចំណាយសាធារណៈ ។*

*ម៉ូឌុលស្តីពីបញ្ជីទូទៅ គ្របដណ្តប់លើការកត់ត្រានូវរាល់កិច្ចការគណនេយ្យទាំងអស់ ការបិទបញ្ជីចុងឆ្នាំ និងការធ្វើ របាយការណ៍សារពើពន្ធរបស់អង្គភាពរដ្ឋាភិបាលនីមួយៗ ។*

*ម៉ូឌុលស្តីពីការគ្រប់គ្រងសាច់ប្រាក់សុទ្ធ គ្របដណ្តប់លើការព្យាករណ៍សាច់ប្រាក់ ការធ្វើវិភាជន៍សាច់ប្រាក់ និង ប្រតិបត្តិការសាច់ប្រាក់ទុកចោល ដោយធនាគារកណ្តាល ។*

*ម៉ូឌុលស្តីពីការគ្រប់គ្រងទ្រព្យ និងការគ្រប់គ្រងបំណុល គ្របដណ្តប់លើការគ្រប់គ្រងទ្រព្យសម្បត្តិជាតិ ដូចជា ដីធ្លី អគារ យន្តហោះ និងនាវា និងការគ្រប់គ្រងហានិភ័យរបស់ប្រទេស ។*

*ម៉ូឌុលស្តីពីស្ថិតិហិរញ្ញវត្ថុរួមបញ្ចូលគ្នា រួមបញ្ចូលនូវការបង្កើតរបាយការណ៍សារពើពន្ធដោយផ្អែកលើ ព័ត៌មានហិរញ្ញវត្ថុរួមបញ្ចូលគ្នាពីគ្រប់អង្គការរដ្ឋាភិបាលទាំងអស់ ។*

*ម៉ូឌុលស្តីពីការវិភាគហិរញ្ញវត្ថុ គ្របដណ្តប់លើការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច និងលំហាត់ ការវិភាគសន្ទស្សន៍ហិរញ្ញវត្ថុ និងការវាស់វែងសមិទ្ធកម្ម ។*

NAFIS *តភ្ជាប់ជាមួយនឹងប្រព័ន្ធខាងក្នុង និងខាងក្រៅដទៃទៀត ដោយផ្តល់លទ្ធភាពដល់ការគ្រប់គ្រងទាន់ សភាពការណ៍នូវសកម្មភាពសារពើពន្ធជាតិ និងតភ្ជាប់ទៅវិញទៅមកជាមួយប្រព័ន្ធដែលទាក់ទងនឹង ហិរញ្ញវត្ថុចំនួន ២៣ ដែលកំពុង ប្រតិបត្តិការដោយឯករាជ្យនៅក្នុងទីភ្នាក់ងាររដ្ឋាភិបាលនានា ។*

*ទិន្នន័យ និងរបាយការណ៍គណនេយ្យថ្នាក់មូលដ្ឋាន និងពិសេស ត្រូវបានរួមបញ្ចូលគ្នានៅក្នុង ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុជាតិ ។ មានប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ ៤០ ដែលកំពុងដំណើរការនៅក្នុង សាធារណរដ្ឋកូរ៉េ ។* NAFIS *គ្របដណ្តប់លើការគ្រប់ គ្រងគណនេយ្យនិងហិរញ្ញវត្ថុទូទៅរបស់រដ្ឋាភិបាល ដែលគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តផ្អែកគោលនយោបាយ ។*

*បណ្ដាញព័ត៌មានហិរញ្ញវត្ថុលុបបំបាត់នូវឧបសគ្គពេលវេលា និងទីកន្លែង ដោយផ្ដល់លទ្ធភាពដល់កិច្ចការ ហិរញ្ញវត្ថុ ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្ដាហ៍ និង៣៦៥ថ្ងៃក្នុងមួយឆ្នាំ ពីបន្ទប់ទទួលភ្ញៀវទៅដល់កន្លែងធ្វើការ ។ បណ្ដាញនេះ ផ្ដល់នូវកម្លាំងរុញច្រានទីផ្សារហិរញ្ញវត្ថុក្នុងស្រុកអោយមានកំណើន ដោយបង្កើតជាវេទិកាប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុរួមមួយ ។ បណ្ដាញនេះត្រូវបានរំពឹងថា នឹងជួយពង្រឹងភាពប្រកួតប្រជែងជាអន្តរជាតិនៃវិស័យហិរញ្ញវត្ថុរបស់សាធារណរដ្ឋកូរ៉េ ពីព្រោះ ស្ថាប័នហិរញ្ញវត្ថុនានានឹងអាច បំពេញតាមស្តង់ដារនៃការអនុវត្តប្រសើរបំផុតរបស់បណ្ដាប្រទេសជឿនលឿន តាមរយៈហេដ្ឋារចនាសម្ព័ន្ធ នេះ ។*

*ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុរួមបញ្ចូលគ្នាសម្រាប់រដ្ឋាភិបាលថ្នាក់កណ្ដាល/ ថ្នាក់មូលដ្ឋាន ៖ ហិរញ្ញវត្ថុជាតិ ត្រូវបានដាក់បញ្ចូលគ្នា និងគ្រប់គ្រងនៅក្រោមប្រព័ន្ធថវិកា និងគណនេយ្យឌីជីថល ដែលត្រូវបានអនុម័តជារបៀបវារៈជាតិដាច់ដោយឡែកពីគម្រោងផែនទីបង្ហាញផ្លូវសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក ។ នៅក្នុងឆ្នាំ២០០៤ ការធ្វើព័ត៌មានូបនីយកម្មហិរញ្ញវត្ថុ ថ្នាក់មូលដ្ឋាន ត្រូវបានអនុវត្តនៅក្នុងដំណាក់កាល ចំនួន ៤ (សូមមើលតារាងទី ៤) ។*

*តារាងទី ៤ ៖ កិច្ចការស្នូលទាំងបួនសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុរដ្ឋាភិបាលមូលដ្ឋាន*

| ***ដំណាក់កាល*** | ***សមិទ្ធផលចម្បងៗ*** |
|---|---|
| *គណនេយ្យ* Accrual/Double Accounting | . *រចនាប្រធានបទគណនេយ្យ*<br>. *ការទូទាត់ប្តូកសរុបរួមគ្នា និងរបាយការណ៍ហិរញ្ញវត្ថុ*<br>. *ទិន្នន័យប្បវត្តិអេឡិចត្រូនិកសម្រាប់ដំណើរការស្តង់ដារ*<br>. *ពង្រឹងសវនកម្ម និងគណនេយ្យករដែលគាំទ្រដោយខ្លួនឯង* |
| *ដាក់អោយអនុវត្តប្រព័ន្ធថវិកាគម្រោង* | . *កំណត់ថវិកាគម្រោង*<br>. *រៀបចំរចនាសម្ព័ន្ធខ្ទង់ថវិកាឡើងវិញ*<br>. *ការគ្រប់គ្រងសមិទ្ធកម្មនៃប្រព័ន្ធថវិកាគម្រោង*<br>. *ការគ្រប់គ្រងថ្លៃចំណាយតាមមុខងារ* |
| *ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ* | . *កែលម្អការគ្រប់គ្រងមូលនិធិ និងការវិភាជន៍ប្រកបដោយ ប្រសិទ្ធផល ។*<br>. *ការបង្ហាញវិក្កយបត្រ និងការទូទាត់ប្រាក់តាមប្រព័ន្ធ អេឡិចត្រូនិក ។*<br>. *កែលម្អការគ្រប់គ្រងបំណុល*<br>. *ការធ្វើមូលនិធិតាមប្រព័ន្ធអេឡិចត្រូនិក* |
| *កែលម្អការធ្វើព័ត៌មានូបនីយកម្ម* | . *រៀបចំប្រព័ន្ធហិរញ្ញវត្ថុថ្នាក់មូលដ្ឋានដែលមានបទដ្ឋាន*<br>. *កសាងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុក្នុងមូលដ្ឋាន*<br>. *តភ្ជាប់/ បង្រួមប្រព័ន្ធបញ្ចូលគ្នា ។* |

*ប្រភព ៖* NIA, ed., *របាយការណ៍រដ្ឋាភិបាលអេឡិចត្រូនិកប្រចាំឆ្នាំ២០០៦ (សេអ៊ូល ៖* MOGAHA *ឆ្នាំ២០០៦) ១៤*
http://www.nia.or.kr/open_content/common/fileList/fileList.jsp?tn=PU_0000100&id=54651 ។

*គ្រប់ផ្នែកទាំងអស់នៃប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុថ្នាក់មូលដ្ឋាន ក្នុងនោះរាប់បញ្ចូលទាំងការគ្រប់គ្រងចំណូល ទ្រព្យ និងបំណុល ត្រូវតែរៀបចំបង្កើតឡើង និងចែកចាយដល់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន ។ គោលដៅគឺដើម្បីកែលម្អប្រសិទ្ធផលនៃការ គ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់មូលដ្ឋាន ទប់ស្កាត់ភាពត្រួតគ្នានៃវិនិយោគ ទុន និងផ្ដល់លទ្ធភាពដល់ការចែករំលែកព័ត៌មាននៅក្នុង ចំណោមរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ។ ការចែករំលែកព័ត៌មាននេះ នឹងនាំឆ្ពោះទៅរកការសន្សំសំចៃថ្លៃចំណាយទូទៅ ជាពិសេស ក្នុងផ្នែកពលកម្ម និងការគ្រប់គ្រង ។*

### ***ប្រព័ន្ធព័ត៌មានរដ្ឋាភិបាលអេឡិចត្រូនិកថ្នាក់មូលដ្ឋាន***[31]

*ម្យ៉ាងវិញទៀត មានតម្រូវការដើម្បីកែលម្អប្រសិទ្ធផលដែលបាននិងកំពុងធ្លាក់ចុះ ដោយសារតែដំណើរការ កិច្ចការរដ្ឋបាលដោយដៃ ដើម្បីសម្រួលដំណើរការញត្តិស៊ីវិលនៅលើក្រដាស និងដើម្បីកែទម្រង់សេវាញត្តិស៊ីវិលតាមរយៈការិយាល័យច្រកចេញចូលតែមួយ ។ ម្យ៉ាងទៀត ការវិនិយោគជាន់គ្នាទៅលើការធ្វើព័ត៌មានូបនីយកម្ម ត្រូវបានធ្វើឡើងដោយអង្គភាពដែល មានមុខងារខុសៗគ្នា ឬអង្គភាពថ្នាក់តំបន់បណ្ដាលអោយលទ្ធផលពីការវិនិយោគទុនមានកម្រិតទាប ។ ដូច្នេះ ប្រព័ន្ធព័ត៌មាន រដ្ឋបាល ចាំបាច់ត្រូវតែផ្ទេរទៅអោយអង្គភាពថ្នាក់តំបន់ដើម្បីបង្កើនប្រសិទ្ធផលប្រតិបត្តិការ និងការពេញចិត្តរបស់អតិថិជន ។*

*រដ្ឋាភិបាលឌីជីថលថ្នាក់មូលដ្ឋាន ផ្ដល់លទ្ធភាពដល់ការចែករំលែកព័ត៌មានទាន់សភាពការណ៍ តាមរយៈ ការតភ្ជាប់ ទំនាក់ទំនងខ្សែបណ្ដោយ និងខ្សែទទឹង រវាងអង្គការរដ្ឋបាលថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន ។ ជាពិសេសជាងនេះទៅទៀត គម្រោងធ្វើព័ត៌មានូបនីយកម្មសម្រាប់រដ្ឋាភិបាលថ្នាក់មូលដ្ឋាននៅក្នុង សាធារណរដ្ឋកូរ៉េ ត្រូវបានអនុវត្តដើម្បីធ្វើបទដ្ឋានីយកម្ម ដំណើរការព័ត៌មាន និងការបំពេញកិច្ចការ ។ គម្រោងនេះ ដែលត្រូវបានអនុវត្តក្នុងរយៈពេល ៣ឆ្នាំ ដោយចាប់ផ្ដើមនៅក្នុងឆ្នាំ ២០០៣ បានជួយកាត់ បន្ថយភាពត្រួតគ្នានៃការវិនិយោគ ព្រមទាំងគម្លាតឌីជីថលនៅក្នុងតំបន់ផ្សេងៗគ្នា នៅក្នុងសាធារណរដ្ឋ កូរ៉េ ។ ប្រសិទ្ធផលត្រូវបានកែលម្អ ហើយសេវាអតិថិជនត្រូវបានកែលម្អ ជាមួយនឹងការបង្កើតហេដ្ឋារចនា សម្ព័ន្ធអេឡិចត្រូនិក សម្រាប់កិច្ចការរដ្ឋបាល និងកិច្ចការញត្តិពលរដ្ឋ ។*

---

[31] Ibid

***រូបភាពទី ១៧ ៖ ទស្សនាទានសម្រាប់ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានឌីជីថលរបស់សាធារណរដ្ឋកូរ៉េ***

*(ប្រភព ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម រដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖*

*ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០២) ៤៧*

http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023903.pdf)




*ការធ្វើឌីជីថលភាវូបនីយកម្មរដ្ឋាភិបាលថ្នាក់មូលដ្ឋាន នៅក្នុងសាធារណរដ្ឋកូរ៉េ បានចាប់ផ្តើមនៅ ឆ្នាំ១៩៩៧ ជាមួយ នឹងការរៀបចំផែនការជាមូលដ្ឋានសម្រាប់ប្រព័ន្ធព័ត៌មានរដ្ឋបាលទូលំទូលាយសម្រាប់ បណ្តាក្រុង សង្កាត់ និងស្រុក ។ បន្ទាប់ពី ការសាកល្បងសមាសភាគផ្សេងៗនៃប្រព័ន្ធនេះប្រកបដោយ ជោគជ័យនៅក្នុងក្រុងចំនួន ៤ ក្នុងឆ្នាំ២០០០ ប្រព័ន្ធនេះត្រូវបាន ចាប់ផ្តើមអនុវត្តនៅទូទាំងប្រទេស ហើយបច្ចុប្បន្ន គ្របដណ្តប់លើក្រុង សង្កាត់ និងស្រុកចំនួន ២៣២ ។ កម្មវិធីញត្តិស៊ីវិល ការចុះបញ្ជី និងការដំណើរការ អាចរកបាននៅទូទាំងប្រទេស ហើយខ្សែរកំពុងត្រូវបានដំឡើងសម្រាប់ពលរដ្ឋ ដែលពួកគេ អាចប្រើប្រាស់សេវាផ្តល់វិញ្ញាបនបត្រផ្សេងៗគ្នាចំនួន ៣៧ ។*

*សម្រាប់ពលរដ្ឋ ផលប្រយោជន៍នៃប្រព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិកថ្នាក់មូលដ្ឋាន រួមមាន ការកាត់បន្ថយគួរ អោយកត់សម្គាល់នូវបរិមាណក្រដាសស្នាម និងចំនួននៃការធ្វើដំណើរទៅកាន់ទីភ្នាក់ងាររដ្ឋាភិបាល ដែលពាក់ព័ន្ធ ។ នេះឆ្លុះបញ្ចាំងអោយ ឃើញនូវការផ្លាស់ប្តូរនៅក្នុងទិសដៅនៃសេវារដ្ឋាភិបាលពីការ ផ្តោតសំខាន់ទៅលើអាជីវកម្ម ទៅជាផ្តោតសំខាន់ទៅលើអតិថិជន វិញ ។*

*ក្នុងទស្សនៈរបស់រដ្ឋាភិបាល ការធ្វើឌីជីថលភាវូបនីយកម្ម និងការរួមបញ្ចូលគ្នា មានន័យថាជាការ សម្របសម្រួលកាន់តែប្រសើរឡើងរវាងរដ្ឋាភិបាលថ្នាក់កណ្តាល និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ការកែលម្អ ប្រព័ន្ធរដ្ឋបាល និងកំណើននៃ ប្រសិទ្ធផល ។ ឧទាហរណ៍ នៅក្នុងសាធារណរដ្ឋកូរ៉េ ការធ្វើស្វ័យប្រវត្តិកម្ម ដំណើរការការងារចំនួន ៩០៤ នៅក្នុងវិស័យរដ្ឋបាល ទូទៅចំនួន ១៨ បានបង្កើនប្រសិទ្ធផល នៅក្នុងនីតិវិធីការងារ ខណៈដែលបន្ទុកការងារទៅលើមន្ត្រីរាជការត្រូវបានកាត់បន្ថយ ដោយសារការ ទប់ស្កាត់ភាពត្រួតគ្នានៃមុខងារ ។ រដ្ឋាភិបាលថ្នាក់កណ្តាល និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន មានប្រព័ន្ធរាយការណ៍ តភ្ជាប់គ្នាមួយ ដែលនាំអោយមានប្រសិទ្ធផល និងភាពត្រឹមត្រូវកើនឡើង ។*

ដើម្បីតភ្ជាប់ក្រសួងរដ្ឋាភិបាលថ្នាក់កណ្តាលទាំង ១៨ ជាមួយនឹងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន យន្តការ ផ្តល់ព័ត៌មានមួយ ត្រូវបានបង្កើតឡើង នៅក្រោយការធ្វើបទដ្ឋានីយកម្មខ្ទង់ព័ត៌មានចំនួន ១.២៣៧ ។ សេវាស៊ីវិលសរុបចំនួន ៧៥១ប្រភេទ ត្រូវបានធ្វើឌីជីថលភាវូបនីយកម្ម ហើយសេវា ៤៨ប្រភេទ ត្រូវបានតភ្ជាប់ជាមួយនឹងវែបសាយត៍ G2C ហើយបច្ចុប្បន្ន សេវាទាំងនេះអាចប្រើប្រាស់បានតាមរយៈ អ៊ីនធឺណិត ។

ដើម្បីកែលម្អរដ្ឋបាលក្រុង/ សង្កាត់/ ស្រុក ដំណើរការការងាររដ្ឋបាលចំនួន ២១ ត្រូវបានធ្វើឌីជីថលភាវូប នីយកម្ម នៅក្រោមគម្រោងព័ត៌មានូបនីយកម្មសម្រាប់រដ្ឋបាលក្រុង/ សង្កាត់/ ស្រុក នៅចន្លោះឆ្នាំ១៩៩៨ និងឆ្នាំ២០០៣ ។ ជាមួយគ្នានេះដែរ នៅក្នុងឆ្នាំ២០០៣ រដ្ឋាភិបាលថ្នាក់ក្រុងសង្កាត់ និងស្រុកបានទទួលយក ទំនួលខុសត្រូវទូទៅសម្រាប់ដំណើរការគ្រប់គ្រង ការចុះបញ្ជីប្រជាពលរដ្ឋ ដែលពីមុនត្រូវបានអនុវត្តដោយ អង្គភាពភូមិ ។

នៅក្នុងអំឡុងពេល BPR និង ISP សម្រាប់គម្រោងឌីជីថលភាវូបនីយកម្មក្នុងឆ្នាំ២០០៥ គោលដៅ និងគោលបំណងសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិកថ្នាក់មូលដ្ឋាននៅកម្រិតក្រុង/ សង្កាត់/ ស្រុក ត្រូវបាន កែលម្អ ហើយគម្រោងអាទិភាព ចំនួន ២០ ត្រូវបានកំណត់ ។ ឯកសារប្រមាណ ២.៨៩៧ ត្រូវបានធ្វើឌីជីថលភាវូបនីយកម្ម និងចែករំលែក ដោយផ្តល់លទ្ធភាព ដល់សេវាច្រកចេញចូលតែមួយ និងកាត់បន្ថយតម្រូវការដើម្បីធ្វើដំណើរទៅកាន់ទីភ្នាក់ងារជាច្រើនកន្លែង ។ បន្ថែមពីលើនេះ MOGAHA (ដែលត្រូវបានប្តូរឈ្មោះទៅជា MOPAS នៅក្នុងឆ្នាំ២០០៨) ត្រូវបានចាត់អោយរៀបចំបង្កើតប្រព័ន្ធ ព័ត៌មានជាដំណាក់កាលៗ និងដាក់ពង្រាយប្រព័ន្ធនេះទៅដល់រដ្ឋាភិបាលថ្នាក់មូលដ្ឋានចំនួន ២៣៤ នៅត្រឹមឆ្នាំ២០១២ ។

ដូចដែលកិច្ចប្រឹងប្រែងរបស់សាធារណរដ្ឋកូរ៉េដែលបានរៀបរាប់ខាងលើបង្ហាញអោយឃើញ ការរៀបចំ បង្កើត និងអនុវត្តរដ្ឋាភិបាលអេឡិចត្រូនិកថ្នាក់មូលដ្ឋាន គឺជាដំណើរការមួយដ៏ស្មុគស្មាញ ។ បញ្ហានានា ចាំបាច់ត្រូវតែដោះស្រាយនៅក្នុងអំឡុងវដ្តនៃគម្រោងទាំងមូល ។ បញ្ហានៅក្នុងករណីនៃប្រទេសហ្វីលីពីន ត្រូវបានពណ៌នានៅខាងក្រោមនេះ ។

***គម្រោង e-LGU នៅប្រទេសហ្វីលីពីន***

ជាកិច្ចឆ្លើយតបទៅនឹងការអនុម័តច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក ដែលបានណែនាំអោយទីភ្នាក់ងារ រដ្ឋាភិបាលទាំងអស់ ក្នុងនោះរាប់បញ្ចូលទាំងអង្គភាពរដ្ឋាភិបាលមូលដ្ឋាន (LGUs) ប្រើប្រាស់មធ្យោបាយ អេឡិចត្រូនិកនៅក្នុងកិច្ចការ រដ្ឋាភិបាល មជ្ឈមណ្ឌលកុំព្យូទ័រជាតិ (NCC) នៃប្រទេសហ្វីលីពីន បានអនុវត្តគម្រោងចាប់ផ្តើមអភិបាលកិច្ចអេឡិចត្រូនិក នៅក្នុងអង្គភាពរដ្ឋាភិបាលថ្នាក់មូលដ្ឋាន (e-LGU) នៅចន្លោះឆ្នាំ២០០២ និងឆ្នាំ២០០៥ ។ គោលបំណងនៃគម្រោងនេះ គឺ ដើម្បីជួយដល់ LGUs ទាំងអស់ នៅក្នុងកិច្ចប្រឹងប្រែងធ្វើកុំព្យូទ័រភាវូបនីយកម្មរបស់ខ្លួន ដើម្បីផ្តល់លទ្ធភាពដល់ការផ្តល់សេវា រដ្ឋាភិបាល អោយបានកាន់តែប្រសើរ និងរហ័សទាន់ចិត្ត ។ គម្រោងនេះ រួមបញ្ចូលទាំងការបង្កើតវែបសាយត៍សម្រាប់ LGUs ទាំងអស់ និងការផ្តល់កម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិក ដូចជា ប្រព័ន្ធពន្ធអចលនវត្ថុ (eRPTS) ប្រព័ន្ធផ្តល់លិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណពាណិជ្ជកម្ម (eBPLS) និងប្រព័ន្ធប្រតិបត្តិការ និងគ្រប់គ្រង រតនាគារ (eTOMS) ។

គម្រោងនេះទទួលបានជោគជ័យនៅក្នុងការជំរុញអោយ ៩៩,៥% នៃ LGUs បង្កើតវែបសាយត៍ ។ ប៉ុន្តែ វែបសាយត៍មួយចំនួនក្នុងចំណោមវែបសាយត៍ទាំងនេះមិនត្រូវបានធ្វើបច្ចុប្បន្នភាពឡើយ ចាប់តាំងពីពេល បង្កើតរួចនៅឆ្នាំ២០០២ ហើយ ភាគច្រើននៃវែបសាយត៍ទាំងនេះផ្តល់តែព័ត៌មានទូទៅអំពី LGU (ឧ. ប្រវត្តិ ស្ថានភាពភូមិសាស្ត្រ សមាសភាពរដ្ឋាភិបាល) និងមិនផ្តល់នូវសេវារដ្ឋាភិបាលអេឡិចត្រូនិក ណាមួយឡើយ ។

ជាងនេះទៅទៀត គ្មាន LGU ណាមួយបានប្រើប្រាស់ eRPTS ពេញលេញឡើយ នៅពេលដែលគម្រោង e-LGU បញ្ចប់នៅឆ្នាំ២០០៥ ។ ផែនការគឺដើម្បីអោយអ្នកដែលឈ្នះការដេញថ្លៃបង្កើត eRPTS និងដំឡើងកម្មវិធីនេះនៅក្នុងតំបន់ សាកល្បងមួយ ហើយ NCC នឹងទទួលបន្ទុកក្នុងការដំឡើងប្រព័ន្ធនេះ នៅក្នុង LGUs ផ្សេងទៀត ។ ប៉ុន្តែ ក្រៅពីបញ្ហានានា នៅក្នុងការបង្កើតប្រព័ន្ធនេះ ការចំណាយបន្ថែមដែល LGUs ចាំបាច់ត្រូវតែចំណាយដើម្បីកែសម្រួលកម្មវិធីអោយត្រូវតាម តម្រូវការ កសាងមូលដ្ឋានទិន្នន័យ និងផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិក បានបណ្តាលអោយមានការយឺតយ៉ាវក្នុងការដាក់ ពង្រាយ កម្មវិធីនេះ ។ ជាការពិត LGU នីមួយៗបានទទួលប្រព័ន្ធ eRPTS ដោយឥតគិតថ្លៃមែន ប៉ុន្តែ ការធ្វើអោយប្រព័ន្ធ នេះមានដំណើរការពេញលេញ មិនអាចគ្មានការចំណាយនោះទេ ។

ការអនុវត្តគម្រោង e-LGU មានលក្ខណៈមជ្ឈការ និងធ្វើពីថ្នាក់លើទៅថ្នាក់ក្រោម ។ ភស្តុតាងដែល បញ្ជាក់អំពីបញ្ហានេះ រួមមាន ៖ ក) ការផ្ទុកនិងគ្រប់គ្រងមាតិកាព័ត៌មាននៃវែបសាយត៍មិនស្ថិតនៅក្នុង LGUs ទេ ខ) ជម្រើសនៃកម្មវិធី ICT សម្រាប់ LGUs កម្រិតត្រឹមតែប្រព័ន្ធបង្កើតប្រាក់ចំណូលចំនួនបី ប៉ុណ្ណោះ និង គ) ប្រព័ន្ធដែលបានបង្កើតឡើង គឺជាការ ទទួលខុសត្រូវរបស់អ្នកបង្កើតតែម្នាក់ មិនមែនជាសហគមន៍នៃអ្នកបង្កើតឡើយ ។
លទ្ធផលនៃគម្រោងនេះ ទំនងជានឹងខុសពីនេះ ប្រសិនបើដំណើការនៃការអនុវត្តមានលក្ខណៈចូលរួម ច្រើនជាងនេះដោយផ្តល់អោយ LGUs នូវលទ្ធភាពគ្រប់គ្រងមាតិកាព័ត៌មានរបស់ខ្លួន ហើយធនធានច្រើន ថែមទៀតត្រូវបានផ្តោតទៅលើ ការបង្កើតការយល់ដឹងអំពីផលប្រយោជន៍នៃការប្រើប្រាស់អ៊ីនធឺណិត ។ ជាងនេះទៅទៀត LGUs និងអង្គការផ្សេងទៀត អាចចូលរួមនៅក្នុងការរចនា និងរៀបចំបង្កើតកម្មវិធី រដ្ឋាភិបាលអេឡិចត្រូនិកដែលពាក់ព័ន្ធ ចំណែកឯស្ថាប័នជាតិបង្កើតនូវ បទដ្ឋានរួមមួយសម្រាប់ ស្ថាបត្យកម្មមូលដ្ឋានទិន្នន័យដើម្បីអនុញ្ញាតអោយមានការចែករំលែកព័ត៌មានក្នុងចំណោម LGUs ។

ប្រភព ៖

ដកស្រង់ចេញពី Erwin A. Alampay ហ្វីលីពីន ៖ ការដាក់បញ្ចូលការចូលរួមនៅក្នុងគម្រោង *e-LGU* របស់ហ្វីលីពីន (បាងកក ៖ UNDP-APDIP ឆ្នាំ២០០៥)
http://www.apdip.net/projects/e-government/capblg/casestudies/Philippines-Alampay.pdf ។

**កិច្ចការដែលត្រូវអនុវត្ត**

1. កំណត់វិស័យអាទិភាពមួយសម្រាប់ការបង្កើតប្រព័ន្ធព័ត៌មានរដ្ឋាភិបាលរួមបញ្ចូលគ្នា នៅក្នុងប្រទេសរបស់អ្នក ។ ចូរ ពន្យល់អំពីមូលហេតុអ្វីបានជាជ្រើសរើសអាទិភាពនេះ ។ ចូរពណ៌នាអំពីកិច្ចប្រឹងប្រែងដើម្បីបង្កើតប្រព័ន្ធបែបនេះ ប្រសិនបើមាន ។
2. ចូរពណ៌នាអំពីគម្រោង ឬផែនការណាមួយ ដើម្បីបង្កើតប្រព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិកនៅកម្រិត រដ្ឋាភិបាលថ្នាក់មូលដ្ឋាននៅក្នុងប្រទេសរបស់អ្នក ។ តើគោលដៅ និងគោលបំណង សមាសភាគ និងកាលវិភាគនៃគម្រោងមានអ្វីខ្លះ ។ តើអ្វីខ្លះដែលអ្នកគិតថា ជាភាពខ្លាំង និងភាពខ្សោយរបស់គម្រោង ? តើបញ្ហាអ្វីខ្លះដែលត្រូវដោះស្រាយ ដើម្បីធានាបាននូវជោគជ័ ?

### ការកែលម្អការផ្លាស់ប្តូរឯកសារអេឡិចត្រូនិក[32]

ការផ្លាស់ប្តូរឯកសារអេឡិចត្រូនិក និងការយល់ព្រមអេឡិចត្រូនិក ត្រូវបានលើកកម្ពស់នៅក្នុង សាធារណរដ្ឋកូរ៉េ ចាប់តាំងពីឆ្នាំ១៩៩៨មកម្ល៉េះ ។ គោលដៅ គឺដើម្បីធ្វើឱ្យដំណើរការរូបនីយកម្មនីតិវិធី ទាំងស្រុងនៃការដំណើរការឯកសារនៅក្នុង ទីភ្នាក់ងាររដ្ឋាភិបាល ។

ស្ថិតិស្តីពីការផ្លាស់ប្តូរឯកសារអេឡិចត្រូនិក បង្ហាញថា ទីភ្នាក់ងារចំនួន ៦៥៤ បានធ្វើការផ្លាស់ប្តូរឯកសារ នៅលើអ៊ីនធឺណិតតាមរយៈមជ្ឈមណ្ឌលផ្លាស់ប្តូរឯកសារអេឡិចត្រូនិករដ្ឋាភិបាល ដែលរួមមានទីភ្នាក់ងារកណ្តាលចំនួន៥៨ រដ្ឋាភិបាល ថ្នាក់មូលដ្ឋាន ២៥០ ការិយាល័យអប់រំ និងសាកលវិទ្យាល័យរដ្ឋ ១៩៨ រដ្ឋសភា និងគណៈកម្មការជាតិរៀបចំការបោះឆ្នោត ។ ជាមួយនឹងការអនុម័តបទដ្ឋានស្តីពីឯកសារអេឡិចត្រូនិកការយល់ព្រមតាមប្រព័ន្ធអេឡិចត្រូនិក បច្ចុប្បន្នកំពុងត្រូវបានអនុវត្ត នៅក្នុងទីភ្នាក់ងារ កណ្តាលចំនួន ៥៨ និងរដ្ឋាភិបាលថ្នាក់មូលដ្ឋានចំនួន ២៥០ ។ គិតត្រឹមខែមិថុនា ឆ្នាំ២០០៦ អត្រានៃការផ្លាស់ប្តូរឯកសារអេឡិចត្រូនិកនៅក្នុងចំណោមទីភ្នាក់ងារកណ្តាល គឺ ៩៧,៣ភាគរយ ហើយអត្រាមធ្យម ភាគនៃការផ្តល់ការ យល់ព្រមតាមប្រព័ន្ធអេឡិចត្រូនិក គឺ ៩៨,២ភាគរយ ។

តារាងទី ៥ ៖ ការផ្លាស់ប្តូរឯកសារអេឡិចត្រូនិក និងអត្រាអនុម័តអេឡិចត្រូនិកក្នុងចំណោមទីភ្នាក់ងារ រដ្ឋបាល (គិតត្រឹមខែ មិថុនា ឆ្នាំ២០០៦)

| ទីភ្នាក់ងារ | អត្រានៃការផ្លាស់ប្តូរឯកសារអេឡិចត្រូនិក | | | អត្រានៃការយល់ព្រមតាមប្រព័ន្ធអេឡិចត្រូនិក | | |
|---|---|---|---|---|---|---|
| | ចំនួនសរុបនៃ ការផ្លាស់ប្តូរ | ចំនួននៃការផ្លាស់ប្តូរ ឯកសារអេឡិចត្រូនិក | អត្រា (%) | ចំនួនសរុបនៃ ការផលិតឯកសារ | ចំនួននៃការយល់ព្រម តាមប្រព័ន្ធអេឡិចត្រូនិក | អត្រា (%) |
| សរុប | 12,574,097 | 12,231,383 | 97.3% | 32,441,273 | 31,849,755 | 98.2% |
| អង្គការរដ្ឋបាលថ្នាក់កណ្តាល | 5,114,791 | 4,913,759 | 96.1% | 10,951,466 | 10,771,392 | 98.4% |
| រដ្ឋាភិបាលថ្នាក់មូលដ្ឋាន | 7,459,306 | 7,317,624 | 98.1% | 21,489,807 | 21,078,363 | 98.1% |
| ក្រុង/ ខេត្ត | 1,135,228 | 1,116,287 | 98.3% | 3,410,501 | 3,356,823 | 98.4% |
| សង្កាត់/ ស្រុក | 6,324,078 | 6,201,337 | 98.1% | 18,079,306 | 17,721,540 | 98.0% |

ប្រភព ៖ NIA, ed., របាយការណ៍រដ្ឋាភិបាលអេឡិចត្រូនិកប្រចាំឆ្នាំ២០០៦ (សេអ៊ូល ៖ MOGAHA ឆ្នាំ២០០៦) ១២
http://www.nia.or.kr/open_content/common/fileList/fileList.jsp?tn=PU_0000100&id=54651 ។

ភាគរយខ្ពស់នៃការផ្លាស់ប្តូរឯកសារអេឡិចត្រូនិក និងការយល់ព្រមតាមប្រព័ន្ធអេឡិចត្រូនិក បង្ហាញថា ដំណើរការ ឯកសារអេឡិចត្រូនិកបានឈានដល់ដំណាក់កាលដែលមានស្ថិរភាពពេញលេញនៅក្នុង ទីភ្នាក់ងាររដ្ឋាភិបាល ទីភ្នាក់ងារកណ្តាល ទាំងអស់ ផ្លាស់ប្តូរឯកសារអេឡិចត្រូនិកដោយសុវត្ថិភាព តាមរយៈមជ្ឈមណ្ឌលផ្លាស់ប្តូរឯកសារអេឡិចត្រូនិករដ្ឋាភិបាល ហើយទីភ្នាក់ងារទាំងនេះ កំពុងព្យាយាម ពង្រីកការផ្លាស់ប្តូរឯកសារអេឡិចត្រូនិកទៅដល់ទីភ្នាក់ងារសាធារណៈ ដែលមិនទាន់ អនុវត្តប្រព័ន្ធ ផ្លាស់ប្តូរឯកសារអេឡិចត្រូនិកនៅឡើយ ឬដែលកំពុងប្រើប្រាស់ប្រព័ន្ធផ្លាស់ប្តូរឯកសារអេឡិចត្រូនិក ដែលគ្មានបទដ្ឋាន ។

ប្រព័ន្ធគ្រប់គ្រងបណ្ណសារ ៖ ការិយាល័យបណ្ណសារ និងកំណត់ត្រាជាតិ បានអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង បណ្ណសារ នៅក្នុងឆ្នាំ១៩៩៩ ដើម្បីរៀបចំ និងគ្រប់គ្រងបណ្ណសារជាលក្ខណៈប្រព័ន្ធ ។ ប្រព័ន្ធគ្រប់គ្រងបណ្ណសារជាតិត្រូវបានបង្កើតឡើងជាមួយនឹងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យមួយ ។ ប្រព័ន្ធ គ្រប់គ្រងអាជីវកម្ម ដែលគ្រប់គ្រងដំណើរការនៃការធ្វើសេចក្តី សម្រេចចិត្ត និងដំណើរការអាជីវកម្ម ទាំងមូល ព្រមទាំងឯកសារផ្តោតលើលទ្ធផល ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៥ ។ នៅ ឆ្នាំដដែលនោះ គម្រោង "ISP ប្រព័ន្ធគ្រប់គ្រងកំណត់ត្រា និងបណ្ណសារ" ត្រូវបានចាប់ផ្តើមអនុវត្តជាការ ទទួលស្គាល់ចំពោះតម្រូវការដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដែលរួមបញ្ចូលទាំងការគ្រប់គ្រង អាជីវកម្ម ។

នៅពេលដែលប្រព័ន្ធគ្រប់គ្រងកំណត់ត្រា និងបណ្ណសារត្រូវបានបង្កើតឡើងរួចរាល់ជាស្ថាពរ បទដ្ឋាននឹង ត្រូវប្រកាសជាផ្លូវការ ដោយពិគ្រោះយោបល់ជាមួយទីភ្នាក់ងារដែលពាក់ព័ន្ធ។ ជាកិច្ចប្រឹងប្រែងស្របពេល

---

32 ផ្អែកនេះដកស្រង់ចេញពី "សេចក្តីលម្អិតគួរអោយចាប់អារម្មណ៍អំពីរដ្ឋាភិបាលអេឡិចត្រូនិកនៃសាធារណរដ្ឋកូរ៉េ" *Korea IT Times* ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ http://www.kdcstaffs.com/it/main_view.php?mode=view&nNum=4575&parts=In-depth .

ជាមួយគ្នានេះដែរ ការិយាល័យបណ្ណសារនិងកំណត់ត្រាជាតិ នឹងអនុវត្តគម្រោងមួយដើម្បីបង្កើត ប្រព័ន្ធគ្រប់គ្រងបណ្ណសារ និងកំណត់ត្រានៅថ្នាក់កណ្តាល ។

### ប្រព័ន្ធព័ត៌មានអប់រំ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក[33]

នៅក្នុងឆ្នាំ២០០២ ជាផ្នែកមួយនៃគោលនយោបាយព័ត៌មានូបនីយកម្មសាលារៀន នៅក្នុងសាធារណរដ្ឋ កូរ៉េ គ្រូគ្រប់រូបត្រូវបានផ្តល់ម៉ាស៊ីនកុំព្យូទ័រមួយគ្រឿងសម្រាប់ការប្រើប្រាស់នៅឯសាលារៀន និងកុំព្យូទ័រមួយគ្រឿងៗទៀត ត្រូវបានទុក សម្រាប់សិស្ស ៨នាក់ ។ ឧបករណ៍សម្រាប់កែលម្អបរិក្ខារសាលារៀន និងបណ្តាញ LANs របស់សាលានៅលើអ៊ីនធឺណិត ក៏ត្រូវបានផ្តល់ដល់សាលារៀនទាំង ១០.០៦៤ របស់ប្រទេស (ដែលមានថ្នាក់រៀន ២២២.១៤៦បន្ទប់) ។

ប៉ុន្តែ ប្រសិទ្ធភាពនៅក្នុងការចែករំលែកព័ត៌មាននៅក្នុងចំណោមទីភ្នាក់ងារដែលទាក់ទង មិនត្រូវបានកែ លម្អឡើយដោយសារតែការិយាល័យរដ្ឋបាលអប់រំអនុវត្តគម្រោងព័ត៌មានូបនីយកម្មដាច់ដោយឡែក ហើយគ្មានបទដ្ឋានរួម នៅក្នុងកិច្ច ប្រតិបត្តិការផ្នែករដ្ឋបាល ។

ក្រោយមក ការធ្វើកុំព្យូទ័រភាវូបនីយកម្មរដ្ឋបាលអប់រំ — ដើម្បីបង្រួបបង្រួម និងប្រមូលផ្តុំធនធានព័ត៌មាន នៅក្នុងស្ថាប័នអប់រំ និងអង្គភាពមុខងារផ្សេងៗ — ត្រូវបានកំណត់ថាជាសសរមួយក្នុងចំណោមសសរសំខាន់ៗនៃរដ្ឋាភិបាលអេឡិច–ត្រូនិកនៅក្នុងសាធារណរដ្ឋកូរ៉េ ។ គោលបំណងនៃការធ្វើ ព័ត៌មានូបនីយកម្មអប់រំ រួមមាន ៖ ក) កសាងគ្រឹះសម្រាប់កែលម្អ ប្រសិទ្ធផលរដ្ឋបាល ខ) ជួយសម្រួលដល់ការចែករំលែកព័ត៌មានតាមរយៈបណ្តាញព័ត៌មានដែលតភ្ជាប់សាលារៀន ការិយាល័យ អប់រំខេត្តនិងក្រុង និងក្រសួងអប់រំនិងធនធានមនុស្ស និង គ) កែលម្អសេវារដ្ឋបាលដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

**រូបភាពទី ១៨ ៖ ទស្សនាទាននៃរដ្ឋបាលអប់រំឌីជីថលទូទាំងប្រទេស នៅក្នុងសាធារណរដ្ឋកូរ៉េ**

(ប្រភព ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម រដ្ឋាភិបាលអេឡិចត្រូនិកនៅក្នុងសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម ឆ្នាំ២០០២) ៥១ http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023903.pdf) ។




ប្រព័ន្ធគ្រប់គ្រងព័ត៌មានសាលារៀនរួមបញ្ចូលគ្នា ៖ ប្រព័ន្ធគ្រប់គ្រងព័ត៌មានសាលារៀនរួមបញ្ចូលគ្នា ត្រូវបានបង្កើតឡើង និងអនុវត្តជាលើកដំបូងនៅក្នុងឆ្នាំ១៩៩៧ ដើម្បីកាត់បន្ថយការងាររដ្ឋបាលប្រចាំថ្ងៃរបស់គ្រូបង្រៀន និងបុគ្គលិករដ្ឋបាល ។ ប្រព័ន្ធ នេះរួមមានអនុប្រព័ន្ធចំនួន ៤ ៖ ប្រព័ន្ធគាំទ្រកិច្ចការសិក្សា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអប់រំ ប្រព័ន្ធគាំទ្រការគ្រប់គ្រងសាលា និងប្រព័ន្ធព័ត៌មានអប់រំរួមបញ្ចូលគ្នា ។

---

33 ផ្នែកនេះដកស្រង់ចេញពីទីភ្នាក់ងារជាតិកុំព្យូទ័រភាវូបនីយកម្ម រដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ (សេអ៊ូល ៖ ទីភ្នាក់ងារជាតិកុំព្យូទ័រ ភាវូបនីយកម្ម ឆ្នាំ២០០២) http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023903.pdf និង http://unpan1.un.org/intradoc/groups/public/documents/APCITY/UNPAN023904.pdf .

នៅក្នុងឆ្នាំដំបូង ប្រព័ន្ធនេះត្រូវបានអនុវត្តនៅក្នុងសាលាផៀនចំនួន ១៦៨ ។ នៅឆ្នាំ១៩៩៨ សាលាអនុវិទ្យាល័យ និង វិទ្យាល័យចំនួន ៤.២៥១ មានប្រព័ន្ធនេះ ។ នៅត្រឹមខែធ្នូ ឆ្នាំ២០០១ ប្រព័ន្ធនេះត្រូវបានអនុវត្តនៅក្នុងសាលាបឋមសិក្សា និង មធ្យមសិក្សាចំនួន ១.៣៦៤ (ក្នុងនោះរួមមាន សាលាវិទ្យាល័យរដ្ឋ ២៣) និងសាលាផៀនទូទៅ ៨.៥០០ ។

គណៈកម្មាធិការសាលានៅក្នុងការិយាល័យក្រុង និងខេត្ត ទទួលខុសត្រូវចំពោះការបង្កើត និងដំណើរការ EDI និង ប្រព័ន្ធថវិកា/ហិរញ្ញវត្ថុដោយផ្ទាល់ខ្លួន ។ គិតមកទល់បច្ចុប្បន្ន ប្រព័ន្ធ EDI កំពុងត្រូវបានប្រើប្រាស់នៅក្នុង ៩៩,៩ភាគរយនៃ ការិយាល័យអប់រំក្រុងនិងខេត្តទាំង ១.៦១៤ ។

នៅក្នុងឆ្នាំ២០០០ ISP ត្រូវបានអនុវត្តដើម្បីបង្កើតប្រព័ន្ធព័ត៍មានរដ្ឋបាលអប់រំទូទាំងប្រទេស ដើម្បី គ្រប់គ្រង ភារកិច្ចរដ្ឋបាលចម្បងៗ (ធនធានមនុស្ស និងការគ្រប់គ្រងសិស្ស) នៅក្នុងវិស័យអប់រំ ។ គោលបំណងគឺដើម្បីកាត់បន្ថយ ពេលវេលាដំណើរការសម្រាប់កិច្ចការអប់រំអោយបាន ពី២០–៥០ភាគរយ និងទំហំឯកសារជាក្រដាសអោយបាន ៣០% និង ដើម្បីបង្កើនផលិតភាពប្រតិបត្តិការរបស់គ្រូបង្រៀន អោយបានលើសពី ២៥ភាគរយ ។ សម្រាប់ឪពុកម្តាយសិស្ស ការចេញ ក្រដាសពិន្ទុ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះ ឬការបញ្ចប់ការសិក្សាពីសាលាផៀននៅក្នុងប្រទេស នឹងកាន់តែមាន ភាពងាយស្រួល ។ សាធារណជនទូទៅក៏នឹងអាចចូលមើលកំណត់ត្រាសាលារបស់ពួកគេតាមរយៈ ប្រព័ន្ធអ៊ីនធឺណិត ដែលនឹងដើរតួជា ចំណុចអន្តរកម្មរវាងសាលាផៀន និងផ្ទះ ។

ការប្រើប្រាស់បណ្តាញ LAN នៅក្នុងសាលាផៀន និងការប្រើប្រាស់អ៊ីនធឺណិត–ICT នៅក្នុងវិស័យអប់រំ ៖ ផែនការទូលំ ទូលាយសម្រាប់ការប្រើប្រាស់ ICT នៅក្នុងសាលាបឋមសិក្សា និងមធ្យមសិក្សា (ឆ្នាំ១៩៩៧–២០០២) ចាត់ទុកអក្ខរកម្ម ICT នៅក្នុងសាលាបឋមសិក្សា និងមធ្យមសិក្សាជាការចាំបាច់ ចំពោះការអភិវឌ្ឍធនធានមនុស្សនៅក្នុងសង្គមព័ត៍មានដែល ផ្អែកលើចំណេះដឹងនៃសតវត្សរ៍ទី២១ ។ ដូច្នេះហើយការកសាងបណ្តាញ LANs តាមសាលាផៀន និងការផ្តល់ការតភ្ជាប់ អ៊ីនធឺណិតដល់ សាលាផៀន ១០.០០០ នៅទូទាំងប្រទេស នៅបន្ទាប់ពីមានប្រព័ន្ធព័ត៍មានអប់រំទូទាំងប្រទេសត្រូវបាន អនុវត្ត។

ការកសាងបណ្តាញ LAN ត្រូវបានធ្វើរួចរាល់ជាស្ថាពរនៅក្នុងសាលាផៀនចំនួន ៣៤៦ នៅត្រឹមឆ្នាំ១៩៩៧ (៣,៣% នៃសាលាផៀនសរុប) នៅក្នុងសាលាផៀនចំនួន ៤.៩០២ នៅត្រឹមឆ្នាំ១៩៩៩ (៤២,៨%) និងនៅក្នុងសាលាផៀនចំនួន ១០.០៦៤ (១០០%) នៅត្រឹមឆ្នាំ២០០០ ឬ ២ឆ្នាំលឿនជាងគោលដៅ កំណត់ ។ ការផ្តល់សេវាអ៊ីនធឺណិតក៏ត្រូវបានបញ្ចប់ជា ស្ថាពរនៅមុនកាលវិភាគគ្រោងទុកផងដែរ ។ នៅក្នុងខែកក្កដា ឆ្នាំ២០០០ ក្រសួងអប់រំ និងអភិវឌ្ឍន៍ធនធានមនុស្ស ក្រសួង ព័ត៍មាន និងគមនាគមន៍ និង Korea Telecom បានផ្តល់ការគាំទ្រហិរញ្ញវត្ថុសម្រាប់ការតភ្ជាប់អ៊ីនធឺណិត ។ សព្វថ្ងៃនេះ សាលាផៀនទាំងអស់នៅក្នុងសាធារណរដ្ឋកូរ៉េ ត្រូវបានតភ្ជាប់ទៅនឹងបណ្តាញព័ត៍មានទូទាំងប្រទេស (Pubnet) ឬបណ្តាញ អប់រំកូរ៉េ ។

ដំណាក់កាលទី២ នៃផែនការទូលំទូលាយសម្រាប់ការប្រើប្រាស់ ICT នៅក្នុងសាលាបឋមសិក្សា និងមធ្យមសិក្សា ដែលបានចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០២ មានគោលបំណងដើម្បីកែលម្អហេដ្ឋារចនា សម្ព័ន្ធ ICT នៅតាមសាលាផៀន ដោយ បង្កើនសមត្ថភាពបណ្តាញអោយដល់យ៉ាងហោចណាស់ ២ Mbps ។ ផែនការនេះ ក៏នឹងកាត់បន្ថយអនុបាតសិស្ស–ម៉ាស៊ីន កុំព្យូទ័រ និងជំនួស និងថែទាំឧបករណ៍ព័ត៍មាន ផងដែរ ។

ការបង្កើតបន្ទប់កុំព្យូទ័រនៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា បានបង្កើតអោយមានបរិយាកាស សិក្សាមួយដែលសិស្សអាចអភិវឌ្ឍសមត្ថភាពសិក្សាដោយឯករាជ្យបាន ។ ម៉ាស៊ីនកុំព្យូទ័រដែលបានចែកចាយដល់គ្រូបង្រៀន ៣៤០.០០០ នាក់នៅទូទាំងសាធារណរដ្ឋកូរ៉េ បានផ្តល់លទ្ធភាពដល់ពួកគេ ដើម្បីប្រើប្រាស់ឧបករណ៍ព័ត៍មាន និងអ៊ីនធឺណិតនៅក្នុងថ្នាក់ផៀន និងជំរុញទឹកចិត្តអោយពួកគេចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើព័ត៍មានូបនីយកម្មសាលាផៀន ។ គ្រឹះជារូបវន្តត្រូវបានកសាង ដើម្បីជំរុញការ ប្រើប្រាស់ ICT នៅក្នុងវិស័យអប់រំ បណ្តុះបណ្តាលធនធានមនុស្សដែលមានគុណភាពខ្ពស់ និងអភិវឌ្ឍ និងចែកចាយសម្ភារៈអប់រំ ។

ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ៖ នៅក្នុងឆ្នាំ២០០៦ ការចំណាយទៅលើការសិក្សាតាមប្រព័ន្ធអេឡិច ត្រូនិករបស់ស្ថាប័ន អប់រំក្នុងប្រព័ន្ធ រដ្ឋាភិបាល ស្ថាប័នសាធារណៈ ក្រុមហ៊ុន និងបុគ្គល មានចំនួនស្មើនឹង ១,៦១៣៣ពាន់ពាន់លាន KRW ដែល ជាកំណើន ១១,១ភាគរយខ្ពស់ជាងការចំណាយលើការសិក្សាតាម ប្រព័ន្ធអេឡិចត្រូនិកក្នុងឆ្នាំ២០០៥ (១,៤៥២៥ពាន់ពាន់ លាន KRW) ។ រហូតមកដល់ឆ្នាំ២០០៥ តម្រូវការសម្រាប់ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងសាធារណរដ្ឋកូរ៉េ ភាគច្រើនបំផុតចេញមកពី បុគ្គល ។ នៅក្នុងឆ្នាំ២០០៦ តម្រូវការសម្រាប់ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកពីអាជីវកម្ម បានកើនឡើងលើសតម្រូវការពីបុគ្គល ។ ជាងនេះទៅទៀត ការបែងចែកលម្អិតនៃកំណើនតាមវិស័យតម្រូវការ បង្ហាញអោយឃើញនូវអត្រាកំណើនខ្ពស់បំផុតនៅក្នុងស្ថាប័នរដ្ឋាភិបាល និងស្ថាប័នសាធារណៈ គឺដល់ ទៅ ៤៥,៧ភាគរយ ហើយបន្ទាប់មក គឺ ស្ថាប័នអប់រំក្នុងប្រព័ន្ធ ត្រឹម ៤២,៣ភាគរយ[34] ។

***តារាងទី ៦ ៖ តម្លៃទីផ្សារនៃការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងសាធារណរដ្ឋកូរ៉េ***

| (ឯកតា ៖ ១លាន KRW, %) | | | | |
|---|---|---|---|---|
| វិស័យតម្រូវការ | ការចំណាយទៅលើការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក | | | អត្រាកំណើនពីឆ្នាំមុន |
| | ២០០៤ | ២០០៥ | ២០០៦ | |
| ស្ថាប័នអប់រំក្នុងប្រព័ន្ធ | 13,243 | 18,424 | 26,220 | 42.3 |
| ស្ថាប័នរដ្ឋាភិបាល និង ស្ថាប័នសាធារណៈ | 83,105 | 94,418 | 137,574 | 45.7 |
| ក្រុមហ៊ុន | 527,291 | 668,169 | 752,286 | 12.6 |

[34] ទីភ្នាក់ងារសមាគមព័ត៍មានជាតិ សៀវភៅសស្តីពីព័ត៍មានូបនីយកម្ម ឆ្នាំ២០០៧ ៖ សាធារណរដ្ឋកូរ៉េ (២០០៧) ៤៤
http://www.nia.or.kr/open_content/board/fileDownload.jsp?tn=PU_0000100&id=53922&seq=1&fl=7 ។

| | | | | |
|---|---|---|---|---|
| *បុគ្គល* | 668,996 | 671,509 | 697,227 | 3.8 |
| *សរុប* | 1,292,635 | 1,452,520 | 1,613,307 | 11.1 |

*ប្រភព ៖ ទីភ្នាក់ងារសមាគមព័ត៌មានជាតិ សៀវភៅសស្តីពីព័ត៌មានូបនីយកម្ម ឆ្នាំ២០០៧ ៖ សាធារណរដ្ឋកូរ៉េ* (២០០៧) ៥៤
http://www.nia.or.kr/open_content/board/fileDownload.jsp?tn=PU_0000100&id=53922&seq=1&fl=7 ។

ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងសាធារណរដ្ឋកូរ៉េ ត្រូវបានគាំទ្រដោយទស្សនវិស័យនៃការបន្តអភិវឌ្ឍ ចំណេះដឹង និងជំនាញពេញមួយឆាកជីវិត ដែលរួមមានដូចខាងក្រោម ៖

1. កសាងប្រព័ន្ធសិក្សានៅលើអ៊ីនធឺណិតមួយ ដែលនឹងអាចប្រើប្រាស់បាននៅគ្រប់ពេលវេលា គ្រប់ទីកន្លែង និង អ្នកណាក៏អាចប្រើបានដែរ ។

   រដ្ឋាភិបាលសង្ឃឹមថា នឹងកែលម្អគុណភាពនៃការអប់រំសាធារណៈនៅក្នុងសាធារណរដ្ឋកូរ៉េ ដោយផ្តល់ថ្នាក់រៀន ក្នុងពេលដូចគ្នា ដែលតភ្ជាប់ទៅនឹងសាលារៀនផ្សេងៗនៅលើ អ៊ីនធឺណិត។ តាមរយៈវិធីនានាដូចជា អ៊ីនធឺណិត និងទូរទស្សន៍ឌីជីថល ផែនការ រដ្ឋាភិបាលដើម្បីជំរុញ"ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនៅផ្ទះ" ដែលនឹងផ្តល់លទ្ធភាពដល់ការចែករំលែកសម្ភារៈសិក្សាឌីជីថលរវាងសាលារៀន និងផ្ទះ ។

2. បង្កើតអោយមានវិធីអប់រំច្រើនសម្បូរបែប ដោយប្រើប្រាស់ឧបករណ៍ព័ត៌មានដើម្បីកែលម្អ គុណភាពនៃការ អប់រំសាធារណៈ ។

   រដ្ឋាភិបាលកូរ៉េកំណត់គោលដៅអនុបាតម៉ាស៊ីនកុំព្យូទ័រ–សិស្សត្រឹមម៉ាស៊ីនកុំព្យូទ័រ ១គ្រឿង សម្រាប់សិស្សតិចជាង៥នាក់ និងល្បឿនភ្ជាប់ទៅនឹងអ៊ីនធឺណិតជាមធ្យមមិនតិចជាង ២ Mbps នៅត្រឹមឆ្នាំ២០០៦ ។ គេរំពឹង ថា នឹងលើកទឹកចិត្តគ្រូបង្រៀនអោយប្រើប្រាស់ ឧបករណ៍ព័ត៌មានអោយបានច្រើន ដើម្បីកែលម្អគុណភាពនៃ ការបង្រៀន និងការសិក្សា ។

3. អភិវឌ្ឍមាតិកា និងសម្ភារៈឌីជីថលសម្រាប់គោលបំណងអប់រំ ដើម្បីកែលម្អបរិយាកាស សិក្សាតាមអ៊ីនធឺណិត។

   រដ្ឋាភិបាលកូរ៉េមានបំណងដើម្បីបង្កើតបរិយាកាសប្រព័ន្ធអេឡិចត្រូនិកចម្រុះតាមរយៈការ បង្កើតកម្មវិធីកុំព្យូទ័រ អប់រំ និងការធ្វើឌីជីថលភាវូបនីយកម្មសៀវភៅអាន ។ ផែនការមួយក៏ត្រូវបានរៀបចំឡើងផងដែរ ដើម្បី បង្កើតប្រព័ន្ធមួយសម្រាប់ចែករំលែកសម្ភារៈអប់រំផ្សេងៗ ដូចជាកុនឌីជីថល និងរូបភាពពីក្រុមហ៊ុនផ្សាយ សារមន្ទីរ សាកលវិទ្យាល័យ និងមជ្ឈមណ្ឌលអប់រំនានា ។

4. បង្កើនអត្រានៃការចូលរួមរបស់មនុស្សចាស់នៅក្នុងប្រព័ន្ធបន្តអភិវឌ្ឍចំណេះដឹងនិងជំនាញ ដោយពង្រីកឱកាស សម្រាប់ការសិក្សាតាមអ៊ីនធឺណិត ដើម្បីសម្រេចបានកម្រិតនៃបណ្តាប្រទេសជាសមាជិក OECD ។

   តាមរយៈវិធីផ្សេងៗដូចជា អ៊ីនធឺណិត និងទូរទស្សន៍ឌីជីថល រដ្ឋាភិបាលកូរ៉េមានបំណង ពង្រីក និងធ្វើអោយកាន់ តែមានប្រសិទ្ធភាពនូវប្រព័ន្ធសាកលវិទ្យាល័យនៅលើអ៊ីនធឺណិតដើម្បីផ្តល់ពិន្ទុដោយមិនស្ថិតក្រោមការរឹតត្បិត នៃពេលវេលា ឬទីកន្លែង ។ រដ្ឋាភិបាលនឹង ធ្វើអោយប្រព័ន្ធផ្តល់ពិន្ទុកាន់តែមានប្រសិទ្ធភាព ដោយផ្តល់ពិន្ទុ ផ្លូវការសម្រាប់ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងកម្មវិធីបណ្តុះបណ្តាលការងារ ។

5. អនុវត្តវិធីសាស្ត្រដែលជាក់ស្តែង ឬអនុវត្តផ្ទាល់ ដើម្បីពង្រីកឱកាសបន្តអភិវឌ្ឍចំណេះដឹង និងជំនាញ សម្រាប់ បុគ្គលិកនៅគ្រប់កម្រិត ។

   មន្ត្រីរដ្ឋាភិបាលនឹងត្រូវផ្តល់អោយនូវកម្មវិធីអប់រំតាមអ៊ីនធឺណិត ជាផ្នែកមួយនៃ"ប្រព័ន្ធសិក្សា រាល់ថ្ងៃ" ។ "អ្នកដែលគ្មានព័ត៌មាន" នឹងត្រូវផ្តល់ឱកាសសម្រាប់ការសិក្សាតាមរយៈ"បណ្តាញសិក្សាសង្គម" ។ បណ្តាញ សិក្សាទូទាំងប្រទេស ដែលនឹងរួមបញ្ចូលទាំង សាលាបឋមសិក្សា និងមធ្យមសិក្សា ស្ថាប័នឯកជន មជ្ឈមណ្ឌល អភិវឌ្ឍន៍ចំណេះដឹងនិងជំនាញក្នុងមូលដ្ឋាន និងប្រព័ន្ធព័ត៌មានការងារ នឹងត្រូវបង្កើតឡើងដើម្បីជំរុញ និង គាំទ្រឱកាសសិក្សាពេញមួយឆាកជីវិតសម្រាប់ពលរដ្ឋគ្រប់រូបភាពទី ។

---

**កិច្ចការដែលត្រូវអនុវត្ត**

**ចូរពណ៌នាអំពីកិច្ចប្រឹងប្រែងណាមួយដោយរដ្ឋាភិបាលរបស់អ្នក ដើម្បីធ្វើសមាហរណកម្ម** ICT ទៅក្នុង ប្រព័ន្ធអប់រំ ។ តើគោលដៅរបស់គម្រោងមានអ្វីខ្លះ? តើអ្វីខ្លះជាភាពប្រឈមនៅក្នុងការអនុវត្តគម្រោង និងតើភាពប្រឈមទាំងនេះអាច ដោះស្រាយយ៉ាងដូចម្តេច ?

---

### ៣.៤ ហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិក

នៅក្នុងផ្នែកមុននេះ កម្មវិធី ICT ដែលអាចត្រូវបានបង្កើតឡើងដោយទីភ្នាក់ងារនីមួយៗ ឬនៅកម្រិត ក្រសួង ត្រូវបានលើក យកមកពិភាក្សា ។ ជាប្រការមួយដ៏សំខាន់ដែលត្រូវកត់សម្គាល់ថា កម្មវិធីទាំងនេះចាំបាច់ត្រូវធ្វើសមាហរណកម្មដើម្បីផ្តល់ សេវារដ្ឋាភិបាលដែលបានដាក់បញ្ចូលគ្នា ។ ក្នុងទំនាក់ទំនងនេះ ផ្នែកនេះនឹងធ្វើការពិភាក្សានូវចំណុចដូចខាងក្រោម ៖

- មជ្ឈមណ្ឌលកុំព្យូទ័រ និងទិន្នន័យដែលត្រូវបានធ្វើសមាហរណកម្មក្នុងរដ្ឋាភិបាល

- បមាណីយកម្មរដ្ឋាភិបាលអេឡិចត្រូនិក
- សេវារួមរបស់រដ្ឋាភិបាលអេឡិចត្រូនិក
- មជ្ឈមណ្ឌលសហគមន៍អេឡិចត្រូនិក

**មជ្ឈមណ្ឌលរដ្ឋបាលធនធានកុំព្យូទ័រ និងព័ត៌មានជាតិ** [35]

មជ្ឈមណ្ឌលរដ្ឋបាលធនធានកុំព្យូទ័រ និងព័ត៌មានថ្នាក់ជាតិរបស់សាធារណរដ្ឋកូរ៉េ ត្រូវបានកសាងជា ប្រព័ន្ធចម្លងទុកថ្នាក់ជាតិ សម្រាប់ធនធានព័ត៌មាន ដែលរួមមានប្រព័ន្ធព័ត៌មាន និងធនធានមនុស្ស ដែលកាលពីកន្លងមកត្រូវបានដំណើរការ និងគ្រប់គ្រងដោយទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗគ្នា (មើល រូបភាពទី ១៩) ។ គម្រោងនេះ មានគោលបំណងលើកកម្ពស់ការ ប្រើប្រាស់ធនធានរួម ដើម្បីបង្កើនប្រសិទ្ធផលដែលខណៈពេលជាមួយគ្នាដើរតួនាទីជាប្រពន្ធថតចម្លងក្នុងករណីប្រព័ន្ធខូចលែងដំណើរការ។

មជ្ឈមណ្ឌលទី ១ និងទី ២ ដំណើរការប្រព័ន្ធព័ត៌មានដែលរួមបញ្ចូលគ្នាសម្រាប់ទីភ្នាក់ងាររដ្ឋាភិបាលចំនួន ៤៨ ។ មជ្ឈមណ្ឌលទី១ កសាងឡើងនៅខែតុលា ឆ្នាំ២០០៥ ក្នុងទីក្រុង Daejeon មជ្ឈមណ្ឌលនេះផ្ទុកប្រព័ន្ធព័ត៌មានរបស់ទីភ្នាក់ងាររដ្ឋាភិបាល ចំនួន ២៤ ដោយរួមមានទាំង MOGAHA ផងដែរ ។ មជ្ឈមណ្ឌលទី ២ បានបញ្ចប់នៅខែកក្កដា ឆ្នាំ២០០៧ ក្នុងខេត្ត Gwangju មជ្ឈមណ្ឌលនេះផ្ទុកប្រព័ន្ធ ព័ត៌មានរបស់ទីភ្នាក់ងារចំនួន ២៤ ផ្សេងទៀត ។

***រូបភាពទី ១៩. ដំណើរឆ្ពោះទៅកាន់ប្រព័ន្ធរដ្ឋាភិបាលសមាហរណកម្ម***

(ប្រភព ៖ Soh Bong Yu "រដ្ឋាភិបាលអេឡិចត្រូនិករបស់ប្រទេសកូរ៉េ ៖ របៀបដែលយើងកំពុងធ្វើការជាមួយរដ្ឋាភិបាលអេឡិចត្រូនិក" (បទបង្ហាញ KADO) ២៣ https://www.kado.or.kr/koil/bbs/board_view.asp?config_code=362&offset=0&board_code=3246)




**ស្ថាបត្យកម្មមជ្ឈមណ្ឌលកុំព្យូទ័រដែលបានធ្វើសមាហរណកម្ម**

[35] ផ្នែកនេះដកស្រង់ចេញពីការិយាល័យយុទ្ធសាស្ត្រព័ត៌មានីយកម្ម ។ រដ្ឋាភិបាលអេឡិចត្រូនិករបស់ប្រទេសកូរ៉េ (ទីក្រុងសេអ៊ូល ៖ MOPAS ឆ្នាំ២០០៧) ៣០ ។

ស្ថាបត្យកម្មបច្ចេកវិទ្យាព័ត៌មានបានធ្វើសមាហរណកម្ម មានបួនផ្នែកធំៗ ៖ ក) ការគ្រប់គ្រងដែលបាន ធ្វើសមាហរណកម្ម ដែលមាន ធនធានបច្ចេកវិទ្យាព័ត៌មាន ប្រតិបត្តិការសេវាកម្ម និងការគ្រប់គ្រងសន្តិសុខ ២) ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ឧបករណ៍បណ្តាញ ការរក្សាទិន្នន័យចម្លងទុក និងប្រព័ន្ធសន្តិសុខ ៣) វិស្វករបច្ចេកទេស (ធនធានមនុស្ស) សម្រាប់ផ្នែកនីមួយៗ ដែលរួមមាន កម្មវិធីកុំព្យូទ័រ មូលដ្ឋានទិន្នន័យ ផ្នែករឹង និងបណ្តាញ ព្រមទាំង ៤) ការគាំទ្រសម្រាប់ផ្នែកនីមួយៗតាមរយៈការិល័យជំនួយ និងសេវារដ្ឋបាល ។

សន្តិសុខ និងស្ថិរភាពប្រតិបត្តិការរដ្ឋាភិបាលអេឡិចត្រូនិក ត្រូវបានធានាដោយការគ្រប់គ្រងប្រព័ន្ធ លំដាប់ថ្នាក់ពិភពលោក ព្រមទាំងសេវាប្រតិបត្តិការវិជ្ជាជីវៈដែលបានធ្វើបមាណីយកម្ម ។ ជាក់ស្តែង រដ្ឋាភិបាលអេឡិចត្រូនិករបស់ប្រទេសកូរ៉េ គឺជាអង្គភាពវិស័យសាធារណៈដំបូងគេក្នុងពិភពលោកដែល ទទួលបានអាជ្ញាប័ណ្ណ ISO 2000 ។

ប្រតិបត្តិការប្រព័ន្ធត្រូវបានកែលម្អតាមរយៈការត្រួតពិនិត្យជាទៀងទាត់ដើម្បីទប់ស្កាត់ការគាំងលែងដំណើរការ ។ បុគ្គលិក វិជ្ជាជីវៈ អាចរកបានដើម្បីដោះស្រាយបញ្ហាប្រព័ន្ធភ្លាមៗ ។ ក្រៅពីនេះ សន្តិសុខត្រូវបាន រឹតបន្តឹងឡើងវិញតាមរយៈការអនុវត្ត ការលួចទិន្នន័យ (hacking) ជាប្រចាំ ការត្រួតពិនិត្យភាពងាយរង គ្រោះព្រមទាំងប្រតិបត្តិការរបស់ក្រុមគ្រប់គ្រងវិបត្តិ ។

និរន្តរភាពត្រូវបានធានាតាមរយៈការផ្ទេរប្រព័ន្ធសំខាន់ៗប្រកបដោយជោគជ័យ ដូចជាប្រព័ន្ធជម្រះបញ្ជី ពន្ធគយតាមប្រព័ន្ធ អេឡិចត្រូនិក ប្រព័ន្ធតវ៉ារបស់ប្រជាពលរដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក ព្រមទាំងប្រព័ន្ធ ចុះបញ្ជីស្នាក់នៅ ដោយគ្មានការរាំងស្ទះផ្នែក សេវាកម្ម ។

***រូបភាពទី ២០. ស្ថាបត្យកម្មមជ្ឈមណ្ឌលកុំព្យូទ័រដែលបានធ្វើសមាហរណកម្មក្នុងរដ្ឋាភិបាល***

(ប្រភព ៖ Soh Bong Yu, “រដ្ឋាភិបាលអេឡិចត្រូនិករបស់ប្រទេសកូរ៉េ ៖ របៀបដែលយើងកំពុងធ្វើការជាមួយរដ្ឋាភិបាលអេឡិចត្រូនិក” (បទបង្ហាញ KADO) ១៧
https://www.kado.or.kr/koil/bbs/board_view.asp?config_code=362&offset=0&board_code=3246)



### បមាណីយកម្មរដ្ឋាភិបាលអេឡិចត្រូនិក

ដូចមានចែងក្នុងមាត្រាទី ២ នៃច្បាប់ស្តីពីការលើកកម្ពស់ព័ត៌មានីយកម្មក្នុងសាធារណរដ្ឋកូរ៉េ បមាណីយកម្មរដ្ឋាភិបាល អេឡិចត្រូនិក រួមមានដំណើរការដែលអាចផ្តល់លទ្ធភាពក្នុងការអនុវត្តការងាររដ្ឋបាលប្រកបដោយប្រសិទ្ធផលក្នុងចំណោម ទីភ្នាក់ងាររដ្ឋាភិបាល ឬផ្តល់សេវាដែលមាន ប្រសិទ្ធផលដល់ប្រជាជនតាមរយៈការប្រើប្រាស់ ICT ។ កត្តានេះ អាចត្រូវបាន បែងចែកជាបន្តទៀតទៅជាបមាណីយកម្មប្រាប់ដំណើរការព័ត៌មានីយកម្មអាជីវកម្ម ការងាររដ្ឋបាល ប្រសិទ្ធផលអាជីវកម្មក្នុង ចំណោមបណ្តាទីភ្នាក់ងារ និងសេវាប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធផល ។ ដោយរួមគ្នាជាមួយធាតុផ្សំសម្រាប់ព័ត៌មានីយកម្ម ដូចជាការគ្រប់គ្រងដែលរួមមានយុទ្ធសាស្ត្រ វិនិយោគ/សមិទ្ធកម្ម និង ការគ្រប់គ្រងអង្គភាព ដំណើការអាជីវកម្ម ការរៀបចំផែនការ និងថវិការព័ត៌មាន និងព័ត៌មានីយកម្ម ការអនុវត្តដំណើរការវាយតម្លៃ និងសវនកម្មជាដើម ការពង្រីក វិសាលភាពបមាណីយកម្មបន្ថែមទៀត អាចត្រូវបានបង្កើតឡើង ។

អត្ថប្រយោជន៍ដែលបានរំពឹងទុកនៃបមាណីយកម្មរដ្ឋាភិបាលអេឡិចត្រូនិក ត្រូវបានបង្កើនភាពអាច ប្រតិបត្តិការទៅវិញទៅមក និងប្រសិទ្ធផល នៅពេលគម្រោងត្រូវបានធ្វើសមាហរណកម្ម ជាជាងត្រូវបានអនុវត្តភាពដោយឡែកពីគ្នាជំរុញអោយមាន ភាពអាចប្រើប្រាស់ឡើងវិញបាន ព្រមទាំងភាពអាច ប្រើប្រាស់ទូទៅរវាងប្រព័ន្ធនានាតាមរយៈគោលការណ៍ណែនាំរួម និងការសន្សំ សំចៃថ្លៃតំហែទាំគុណភាព ។ ឧទាហរណ៍ប្រទេសអាល្លឺម៉ង់ កំពុងរំពឹងថាប្រហែលមួយភាគរយ (មួយភាគបីនៃអត្រាកំណើនសេដ្ឋកិច្ច) នៃកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំនឹងទទួលបានពីបមាណីយកម្មដែលបញ្ជាក់ថាបមាណីយកម្មរដ្ឋាភិបាលអេឡិចត្រូនិកអាចសម្រេច បានលើសពីត្រឹមតែការកែច្នៃដំណើរការ ។

ក្របខ័ណ្ឌរដ្ឋាភិបាលអេឡិចត្រូនិកកូរ៉េដែលបានបង្កើតក្នុងការសិក្សាស្រាវជ្រាវឆ្នាំ ២០០៥ ធ្វើការរៀបចំ ជាលក្ខណៈប្រព័ន្ធ នូវសមាសភាពបែកខ្ញែកជាច្រើននៃដំណើរការព័ត៌មានីយកម្ម ។ ផ្នែកនានាដូចជាការរៀបចំផែនការព័ត៌មានីយកម្ម ការរចនា ការផ្តល់មូលនិធិ ប្រតិបត្តិការ ការវាយតម្លៃ និងការគ្រប់គ្រង ព្រមគ្នាជាមួយដំណើរការអាជីវកម្ម និងការគ្រប់គ្រងភ្នាក់ងារ នីមួយៗ អាចទទួលអត្ថប្រយោជន៍ពីបមាណីយកម្មទូទាំងអង្គភាពដែលក្របខ័ណ្ឌនេះអនុវត្ត ។

កិច្ចខិតខំប្រឹងប្រែងបមាណីយកម្មរបស់ MOGAHA បានអភិវឌ្ឍព្រមគ្នាជាមួយដំណើរការព័ត៌មានីយកម្មរដ្ឋបាលចាប់តាំងពី ទសវត្សឆ្នាំ ១៩៩០ ។ MOGAHA បានដាក់សញ្ញាសម្គាល់កូដរដ្ឋបាលជាលក្ខណៈប្រព័ន្ធ ដោយមានការបង្កើតគំរូឯកសារយោង ទិន្នន័យ និងបានលើកកម្ពស់បមាណីយកម្មបច្ចេកទេស ជាពិសេស សម្រាប់ប្រព័ន្ធព័ត៌មានទោលដូចជា PCs ។ កូដបទដ្ឋានរដ្ឋបាលទូទៅត្រូវបានរៀបចំបង្កើតឡើង ហើយកូដចំនួន ២១១ ប្រភេទត្រូវបានធ្វើបមាណីយកម្ម គិតមកត្រឹមខែមករា ឆ្នាំ ២០០៥ ។ ឧបករណ៍ការិយាល័យមុខងារចម្រុះក៏ត្រូវបានធ្វើបមាណីយកម្មក្នុងឆ្នាំ១៩៨៧ ផងដែរដោយមានការ អនុវត្តការកែសម្រួលក្នុងរយៈពេលពីរឆ្នាំម្តង ។ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងទាំងនេះមិនមានលក្ខណៈ គ្រប់គ្រាន់សម្រាប់គំនិតផ្តួចផ្តើមរដ្ឋាភិបាល អេឡិចត្រូនិកសំខាន់ៗចំនួន ១១ ដែលបង្កើតឡើងនៅក្នុងឆ្នាំ ២០០១ ឡើយ ។ មានការព្យាយាមមួយចំនួនក្នុងការធ្វើ បមាណីយកម្ម ប្រព័ន្ធឯកសារអេឡិចត្រូនិក ប៉ុន្តែការធ្វើបមាណីយកម្មដំណើរការព័ត៌មានីយកម្មទាំងមូលនៅទូទាំងទីភ្នាក់ងារ រដ្ឋាភិបាលមិនអាចសម្រេចជាស្ថាពរដោយសារមានកង្វះខាតចំនួនបុគ្គលិក ។

ដើម្បីពន្លឿនការធ្វើបមាណីយកម្មរដ្ឋាភិបាលអេឡិចត្រូនិកដោយអនុលោមតាមច្បាប់ស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក MOGAHA បានដកដំណើរការបមាណីយកម្មចេញពីគម្រោងគ្រប់គ្រងធនធានព័ត៌មាន ។ មានការផ្តោតជាពិសេសទៅលើកូដបទដ្ឋាន រដ្ឋបាល ឧបករណ៍ការិយាល័យមុខងារចម្រុះ និងឯកសារអេឡិចត្រូនិក ហើយបច្ចុប្បន្ននេះគោលការណ៍ណែនាំសម្រាប់ បមាណីយកម្មដ៏ទូលំទូលាយនៃមូលដ្ឋានទិន្នន័យរដ្ឋបាលកំពុងត្រូវបានបង្កើតឡើង ។

ដើម្បីសម្រេចបាននូវការធ្វើបមាណីយកម្មកូដ ព័ត៌មានអំពីលំដាប់លំដោយអាទិភាពនៃកូដរដ្ឋបាលរបស់ ទីភ្នាក់ងារនីមួយៗ កំពុងត្រូវបានប្រមូល ។ មានផែនការដើម្បីដាក់បញ្ចូលកូដជាដំណាក់កាល ៖ កូដចំនួន ១០ ភាគរយ ត្រូវបានដាក់បញ្ចូល ក្នុងឆ្នាំ២០០៦ ចំនួន ៦០ ភាគរយក្នុងឆ្នាំ២០០៧ និង ៣០ ភាគរយក្នុងឆ្នាំ២០០៨ ។

ក្រៅពីនេះ មានផែនការដើម្បីវិភាគ និងកែលម្អលើកូដរដ្ឋបាលមានបមាណីយកម្មដែលបានបង្កើត ឡើងនៅក្នុងឆ្នាំ១៩៩០ ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការសាងសង់កូដរដ្ឋបាលប្រកបដោយបទដ្ឋាន ។ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ សេចក្តីព្រាងដ៏ស្មុគស្មាញសម្រាប់មូលដ្ឋានទិន្នន័យរដ្ឋបាល ត្រូវបានរៀបចំឡើងនៅក្នុងខែមករា ឆ្នាំ២០០៦ ហើយត្រូវបាន បញ្ចប់នៅកិច្ចប្រជុំមួយរបស់អាជ្ញាធរដែលទទួលខុសត្រូវលើព័ត៌មានីយកម្មដែលមកពីទីភ្នាក់ងាររដ្ឋាភិបាលកណ្តាលចំនួន ៥៧ នៅក្នុង ខែឧសភា ឆ្នាំដដែល ។ បច្ចុប្បន្ននេះ មូលដ្ឋានទិន្នន័យព័ត៌មានរដ្ឋបាលកំពុងត្រូវបានប្រើប្រាស់ ដោយទីភ្នាក់ងាររដ្ឋាភិបាលចំនួន ១៤ ។

### សេវារួមរបស់រដ្ឋាភិបាលអេឡិចត្រូនិក [36]

សេវារួមរបស់រដ្ឋាភិបាលអេឡិចត្រូនិកគឺជាធនធានព័ត៌មានដែលអាចចែករំលែកក្នុងចំណោមទីភ្នាក់ងារ រដ្ឋាភិបាល និងប្រើប្រាស់ ស្របតាមប្រភេទ និងប្រព័ន្ធអាជីវកម្ម ។ សេវាទាំងនេះរួមមានប្រព័ន្ធអាជីវកម្ម រដ្ឋបាលទូទៅដូចជាធនធានមនុស្ស គណនេយ្យ ភ័ស្តុភារ និងហិរញ្ញវត្ថុ កម្មវិធីប្រព័ន្ធ (system software) (ប្រព័ន្ធប្រតិបត្តិការ ប្រព័ន្ធគ្រប់គ្រង មូលដ្ឋានទិន្នន័យ) និងផ្នែករឹង (hardware) (កុំព្យូទ័រមេ និងឧបករណ៍បណ្តាញ) ។ ដោយត្រូវបានកំណត់ជាទូទៅ សេវារួមទាំងនេះមានកម្មវិធីខ្នាតតូច ឬប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដែលមានភាពចាំបាច់ជាទូទៅនៅក្នុងនាយកដ្ឋានផ្សេងៗ ។

នៅក្នុងឆ្នាំ២០០៤ គណៈកម្មាធិការកែលម្អរដ្ឋាភិបាល និងវិមជ្ឈការរបស់ប្រធានាធិបតីសាធារណរដ្ឋកូរ៉េ បានស្នើអោយមាន សេវារួមទូទៅចំនួន ១៥ (សូមមើលតារាងទី ៧) ដែលមានសេវាចំនួន ៩ ត្រូវបានលើកកម្ពស់ដាច់ដោយឡែកពីគ្នាតាមរយៈគម្រោង G2C ។ សេវាទាំងនេះត្រូវបានដាក់អោយ ប្រើប្រាស់នៅក្នុងទីភ្នាក់ងាររដ្ឋាភិបាលនីមួយៗចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០០៥ ហើយបច្ចុប្បន្នសេវា ទាំងនេះ

[36] ផ្នែកនេះដកស្រង់ចេញពី NIA, ed. របាយការណ៍ប្រចាំឆ្នាំ២០០៦ សម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក (ទីក្រុងសេអ៊ូល ៖ MOGAHA ឆ្នាំ២០០៦) ទំព័រ ៣៨-៣៩ ។ http://www.nia.or.kr/open_content/common/fileList/fileList.jsp?tn=PU_0000100&id=54651.

កំពុងដំណើរការនៅក្នុងប្រព័ន្ធចំនួន ១៨ នៃទីភ្នាក់ងារផ្សេងៗគ្នាចំនួន ១១ ។ ដូចដែលបាន បង្ហាញនៅក្នុងតារាងទី ៧ សេវាដែលបានកំណត់ថាមានអាទិភាពគឺ ៖ ព័ត៌មានសេវាប្រជាពលរដ្ឋ ការចេញឯកសារ ទម្រង់បែបបទពាក្យសុំ សៀវភៅណែនាំសម្រាប់អ្នកប្រើប្រាស់ ការបញ្ជាក់សុពលភាព ដែលរួមបញ្ចូលគ្នា ការកំណត់ អត្តសញ្ញាណអ្នកប្រើប្រាស់ ការបង់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ការចុះបញ្ជីសេវាកម្មតាមវែបសាយត៍ ព្រមទាំង SMSចល័ត ។ សេវារួមមួយចំនួន ត្រូវបានរៀបចំឡើងដើម្បីបង្កភាពងាយស្រួលដល់អ្នកប្រើប្រាស់ជាជាងការសន្សំថ្លៃចំណាយ ។

*តារាងទី ៧. ការកំណត់អាទិភាពសេវារួមរដ្ឋាភិបាលអេឡិចត្រូនិកនៅសាធារណរដ្ឋកូរ៉េ*

| វិស័យ | សេវាកម្មដែលបានស្នើ | | អង្គការ |
|---|---|---|---|
| | ការកំណត់អាទិភាព | ព័តិមានសេវាប្រជាពលរដ្ឋ | |
| សេវាប្រជាពលរដ្ឋ | | ការចេញឯកសារប្រជាពលរដ្ឋ | MOGAHA |
| | | ទម្រង់បែបបទពាក្យសុំសម្រាប់ប្រជាពលរដ្ឋ | |
| | | ការបង់ប្រាក់តាមតាមប្រព័ន្ធអេឡិចត្រូនិច | |
| | | សៀវភៅណែនាំដល់អ្នកប្រើប្រាស់ (LDAP) | |
| | | ការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ (PKI) | |
| | | ការផ្តល់សុពលភាពដែលបានធ្វើសមាហរណកម្ម (SSO) | MIC |
| | | ចល័ត (SMS) | |
| សេវារួម | | ការចុះបញ្ជីសេវាកម្មតាមវែបសាយត៍ (UDDI) | |
| | សេវាអតិថិជនតាមវែបសាយត៍ | | - |
| | ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច | | - |
| | សៀវភៅណែនាំរបស់រដ្ឋាភិបាល | | - |
| ហិរញ្ញវត្ថុ/គណនេយ្យ | ជូនដំណឹង/ការបង់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច ការផ្ទេរមូលនិធិតាមប្រព័ន្ធអេឡិចត្រូ | | - |
| ដំណើរការអាជីវកម្ម | ការបញ្ចេញព័តិមាន | | - |

ប្រភព ៖ NIA, ed., *របាយការណ៍ប្រចាំឆ្នាំ២០០៦ សម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក* (សេអ៊ូល ៖ MOGAHA, ឆ្នាំ២០០៦) *ទំព័រ៣៩*
http://www.nia.or.kr/open_content/common/fileList/fileList.jsp?tn=PU_0000100&id=54651
ផែនការមេសម្រាប់ការស្វែងរកសេវាបន្ថែម និងអនុវត្តសេវារួមកំពុងត្រូវបានរៀបចំ ។

**សំណួរត្រិះរិះ**

តើសេវារួមក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាលអ្វីខ្លះដែលកើតមាននៅក្នុងប្រទេសរបស់អ្នក ? តើសេវារួមណាមួយ ដែលគួរត្រូវបានផ្តល់អាទិភាព ? ហេតុអ្វី ?

មជ្ឈមណ្ឌលសហគមន៍អេឡិចត្រូនិក

គម្រោងភូមិបណ្តាញព័ត៌មាន (INV) របស់សាធារណរដ្ឋកូរ៉េ មានគោលបំណងដើម្បីសម្រេចបាននូវ ការអភិវឌ្ឍដែលមាន តុល្យភាពទូទាំងប្រទេសតាមរយៈការកសាងបណ្តាញគមនាគមន៍អ៊ីនធឺណិតក្នុង តំបន់ដាច់ស្រយាលដូចជាភូមិប្រជាពលធ្វើស្រែ និងនេសាទ ។ គោលបំណងគឺដើម្បីតភ្ជាប់គម្លាតឌីជីថល និងស្តារសេដ្ឋកិច្ចក្នុងប្រទេសឡើងវិញតាមរយៈការចែកចាយកុំព្យូទ័រ ផ្ទាល់ខ្លួនដល់ក្រុមគ្រួសារនីមួយៗ និងការផ្តល់វគ្គបណ្តុះបណ្តាលកុំព្យូទ័រដល់បណ្តាភូមិនានា ។

តាមរយៈគម្រោង INV ការដោះដូររវាងភូមិជនបទ និងទីក្រុងត្រូវបានជំរុញ ៖ សហគមន៍ជនបទអាច ស្វែងរកទីផ្សារសម្រាប់ផលិតផលកសិកម្មទើបដាំដុះបានរបស់ខ្លួន ខណៈពេលដែលអ្នករស់នៅតាមទីក្រុង ត្រូវបានផ្តល់ឱកាសដើម្បីទទួលបានបទពិសោធន៍ ជីវិតជនបទតាមរយៈគំរូប្រាក់ចំណូលដូចជាផ្ទះសំណាក់ ការបោះជំរុំ ព្រមដំណើរទេសចរណ៍ឆ្លងកាត់ស្រុកស្រែចំការ ។

INV ចំនួន ២៥ ដំបូងត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០២ ។ គោលដៅឆ្នាំ ២០០៧ ចំនួន ៣០៦ INV សម្រាប់នៅទូទាំង ប្រទេស ។

**ធ្វើតេស្តខ្លួនឯង**

១. ដូចដែលបានពិភាក្សាក្នុងផ្នែកនេះ ជាប្រការមួយដ៏សំខាន់ដែលត្រូវធ្វើសមាហរណកម្មប្រព័ន្ធ ICT របស់រដ្ឋាភិបាល ទាំងអស់អោយទៅជាប្រព័ន្ធតែមួយ ។
តើចាំបាច់ត្រូវមានជំហានអ្វីខ្លះនៅក្នុងដំណើរការសមាហរណកម្មនេះ ?

២. តើអត្ថប្រយោជន៍នៃការបង្កើតសេវារួមរបស់រដ្ឋាភិបាលអេឡិចត្រូនិកមានអ្វីខ្លះ ?

| |
|---|
| ៣. តើប្រភេទសេវាកម្ម ឬសកម្មភាពអ្វីខ្លះដែលអាចត្រូវបានផ្តល់នៅក្នុងមជ្ឈមណ្ឌល សហគមន៍អេឡិចត្រូនិក ឬមជ្ឈមណ្ឌល សហគមន៍ឌីជីថល ? |

## ៣.៥ ប្រព័ន្ធគ្រប់គ្រងចំណេះដឹង

ការគ្រប់គ្រងចំណេះដឹងអាចត្រូវបានកំណត់ថាជាសកម្មភាពអាជីវកម្មដែលមានទិដ្ឋភាពសំខាន់ៗចំនួនពីរ ៖ ១) ការចាត់ទុក សមាសធាតុសកម្មភាពអាជីវកម្មថាជាកង្វល់ជាក់ស្តែងដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុង យុទ្ធសាស្ត្រ គោលការណ៍ និងការអនុវត្ត នៅគ្រប់កម្រិតអង្គភាព និង ២) ធ្វើការតភ្ជាប់ដោយផ្ទាល់ រវាងទ្រព្យកម្មសិទ្ធិបញ្ញារបស់អង្គភាពមួយ ទាំងលទ្ធផលអាជីវកម្ម ជាក់ស្តែង (ដែលបានកត់ត្រា) និងដោយប្រយោល (ចំណេះដឹងផ្ទាល់ខ្លួន) និងវិជ្ជមាន ។ នៅក្នុងការអនុវត្ត ការគ្រប់គ្រង ចំណេះដឹងរួមមានការកំណត់ និងការដាក់បញ្ចូលទ្រព្យកម្មសិទ្ធិបញ្ញាទៅក្នុងអង្គភាព បង្កើតចំណេះដឹងថ្មីៗ ដើម្បីគុណសម្បត្តិប្រកួតប្រជែងនៅក្នុងអង្គភាព បង្កើតលទ្ធភាពទទួលបានព័ត៌មានរួមក្នុងចំនួនដ៏ច្រើន ព្រមទាំងចែករំលែកការអនុវត្ត និងបច្ចេកវិទ្យា ប្រសើរបំផុតដែលជួយដល់ការអនុវត្តដែលបានលើកឡើង ខាងលើរួមទាំងកម្មវិធីកុំព្យូទ័ររួម និងបណ្តាញកុំព្យូទ័រក្នុងអង្គភាព ផងដែរ ។ [37]

ការគ្រប់គ្រងចំណេះដឹងពឹងផ្អែកលើគោលការណ៍ដូចខាងក្រោម ៖

- ចំណេះដឹងគឺជាទ្រព្យយុទ្ធសាស្ត្រ
- ចំណេះដឹងគឺជាធនធានដែលត្រូវចាត់ចែង ។ អាស្រ័យហេតុនេះ ចំណេះដឹងចាំបាច់ត្រូវផ្តល់អោយនៅ ក្នុងពេលវេលាដ៏ត្រឹមត្រូវ អាចរកបាននៅទីកន្លែងដែលសមស្រប ស្ថិតក្នុងទម្រង់ត្រឹមត្រូវ បំពេញតាមលក្ខខណ្ឌតម្រូវផ្នែកគុណភាព និងទទួលបានក្នុងតម្លៃទាបបំផុតតាមដែលអាចធ្វើបានសម្រាប់ ការប្រើប្រាស់ក្នុងដំណើរការអាជីវកម្ម ។
- មានតែចំណេះដឹងគឺមិនមានតម្លៃអ្វីឡើយ ចំណេះដឹងមានតម្លៃតែនៅពេលត្រូវបានប្រែក្លាយអោយ ទៅជាសកម្មភាព និងលទ្ធផលប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះ ។
- ចំណេះដឹងគឺជាព័ត៌មានដែលមាន និងធ្វើសកម្មភាពក្នុងគំនិតរបស់មនុស្ស ។ ព័ត៌មានដូចគ្នាអាចនាំ ទៅរកអត្ថន័យ និងសកម្មភាពខុសគ្នា ៖ តាមរយៈបុគ្គលផ្សេងៗគ្នានៅក្នុងបរិបទអង្គភាពខុសគ្នានៅ ក្នុងពេលវេលាខុសៗគ្នា ។

ចំណេះដឹងអាចមានលក្ខណៈដោយផ្ទាល់ ឬប្រយោល ។ ជំហានដំបូងក្នុងការគ្រប់គ្រងចំណេះដឹង គឺត្រូវដឹង W ទាំង៥ ៖

- អ្វី (what)
- នរណា (who)
- ហេតុអ្វី (why)
- ពេលណា (when)
- កន្លែងណា (where)

*តារាងទី ៨ ៖ ការប្រៀបធៀបគ្នារវាងទិន្នន័យ ព័ត៌មាន និងចំណេះដឹង*

| | **ទិន្នន័យ** | **ព័ត៌មាន** | **ចំណេះដឹង** |
|---|---|---|---|
| **មាតិកា** | ព្រឹត្តិការណ៍ | ទំនោរ | ជំនាញការ |
| **ប្រភេទ** | អន្តរកម្ម | គំរូ | ការសិក្សា |
| **ភារកិច្ច** | តំណាង | ការចាត់ចែង | ការរៀបចំជាប្រព័ន្ធ |
| **តួនាទីមនុស្ស** | ការអង្កេត | ការកាត់សេចក្តី | បទពិសោធន៍ |
| **គោលដៅ** | ស្វ័យប្រវត្តិកម្ម | ការធ្វើសេចក្តីសម្រេច | សកម្មភាព |
| **ធាតុចេញ** | ការបង្កើតប្លុក | ការកាត់បន្ថយភាពមិនច្បាស់លាស់ | ការយល់ដឹងថ្មី |

ប្រភព ៖ ម៉ូឌុលវគ្គបណ្តុះបណ្តាលការគ្រប់គ្រងចំណេះដឹង វគ្គបណ្តុះបណ្តាលការពិគ្រោះយោបល់អំពីរដ្ឋាភិបាលអេឡិចត្រូនិក (KADO ឆ្នាំ២០០៣)

កត្តាជោគជ័យក្នុងការគ្រប់គ្រងចំណេះដឹងគឺ ៖

- ភ្ជាប់ទៅនឹងលទ្ធផលសេដ្ឋកិច្ច ឬគុណតម្លៃឧស្សាហកម្ម
- ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស និងការចាត់ចែង
- រចនាសម្ព័ន្ធចំណេះដឹងដែលមានបទដ្ឋានប្រកបដោយភាពបត់បែន

[37] Joo-Haeng Choo, "ការណែនាំអំពី KMS" (បទបង្ហាញ ឆ្នាំ២០០៧) https://www.kado.or.kr/koil/bbs/board_download.asp?board_code=1567&bfile=2.

- វប្បធម៌គាំទ្រចំណេះដឹង
- គោលបំណង និងភាសាច្បាស់លាស់
- ការផ្លាស់ប្តូរក្នុងការអនុវត្តប្រកបដោយការជំរុញទឹកចិត្ត
- បណ្តាញចម្រុះសម្រាប់ការផ្ទេរចំណេះដឹង
- ការគាំទ្រថ្នាក់គ្រប់គ្រងជាន់ខ្ពស់ [38]

យុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងចំណេះដឹងរួមមានជំហានដូចខាងក្រោម ៖

១. ស្វែងយល់អំពីគោលដៅដែលចំណេះដឹងបន្ថែមគុណតម្លៃ

២. ដាក់ទុនដើម្បីបង្កើត និងប្រើប្រាស់ចំណេះដឹងអោយមានប្រសិទ្ធភាព

៣. ចងចាំនូវគុណតម្លៃនៃដើមទុនចំណេះដឹងដើម្បីទទួលបានភាពជោគជ័យ ។

៤. ធ្វើអោយចំណេះដឹងអាចទៅដល់មនុស្សគ្រប់គ្នាដែលអាចចូលរួមចំណែកក្នុងចំណេះដឹង ឬប្រើប្រាស់ ចំណេះដឹង

៥. ធានាអោយមានការប្តេជ្ញាលើការគ្រប់គ្រង និងភាពជាអ្នកដឹកនាំខ្ពស់

៦. បង្កើតបរិយាកាសដែលទ្រព្យចំណេះដឹងអាចមានការកើនឡើង

៧. ចាត់ទុកចំណេះដឹងជាទ្រព្យយុទ្ធសាស្ត្រ [39]

| |
|---|
| **ប្រព័ន្ធគ្រប់គ្រងចំណេះដឹងអេឡិចត្រូនិករបស់សាធារណរដ្ឋកូរ៉េ**<br>ប្រព័ន្ធ real-time សម្រាប់ការគ្រប់គ្រងគោលនយោបាយជាតិក្នុងរដ្ឋាភិបាលប្រទេសកូរ៉េរួមមានធាតុផ្សំ ចំនួនពីរ ៖ ប្រព័ន្ធ គ្រប់គ្រងចំណេះដឹង (KMS) និងប្រព័ន្ធគ្រប់គ្រងការងាររបស់រដ្ឋាភិបាល ។<br><br>KMS អេឡិចត្រូនិកផ្តល់លទ្ធភាពដល់គំនិតផ្សេងៗដែលបានស្នើឡើងអំឡុងដំណើរការបង្កើត គោលការណ៍ដើម្បីអោយមានការកត់ត្រា និងគ្រប់គ្រង ហើយជាបន្តបន្ទាប់ធ្វើការចែករំលែកតាមរយៈ ការគ្រប់គ្រងឯកសារអេឡិចត្រូនិកដើម្បីសម្រួលអោយមានការធ្វើសេចក្តីសម្រេចប្រកបដោយ ប្រសិទ្ធផល ។<br>KMS អេឡិចត្រូនិកត្រូវបានបង្កើតឡើងដូចខាងក្រោម ៖<br>១. ការិយាល័យប្រធានាធិបតីបានអនុម័តការប្រើប្រាស់កម្មវិធីកុំព្យូទ័ររួមលើកដំបូង<br>២. ISP ត្រូវបានអនុវត្តដើម្បីកំណត់វិធីក្នុងការសម្រេចបានការិយាល័យប្រតិបត្តិឌីជីថល ។<br>៣. សេវាកម្មគាំទ្រអេឡិចត្រូនិកត្រូវបានបង្កើតឡើង ដោយផ្តោតលើការកត់ត្រាទិន្នានុប្បវត្តិប្រចាំថ្ងៃ ជាដំណាក់កាលដំបូងសម្រាប់គម្រោងការិយាល័យគ្រប់គ្រងឌីជីថល ។<br>៤. ប្រព័ន្ធគ្រប់គ្រងឯកសារត្រូវបានបង្កើតឡើងជាដំណាក់កាលទីបីនៃគម្រោង ។<br><br>ជាមួយនឹងការបង្កើត KMS អេឡិចត្រូនិកសម្រាប់ការិយាល័យប្រធានធិបតី បមាណីយកម្មនៃការ គ្រប់គ្រងព័ត៌មាន ឯកសារ និងភារកិច្ចត្រូវបានរៀបចំឡើង ។ នីតិវិធីរដ្ឋបាលទាំងមូលនឹងត្រូវ បានដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រង នៅពេលដែលប្រព័ន្ធគ្រប់គ្រងសម្រាប់ឯកសារកាលប្បវត្តិ និងចំណេះដឹងត្រូវបានបង្កើតឡើង ។<br><br>តាមរយៈ KMS អេឡិចត្រូនិក ឯកសារកាលប្បវត្តិ និងកំណត់ត្រាអាចត្រូវបានថែរក្សាប្រកបដោយ សង្គតភាពដោយមិនមានការបាត់បង់នូវព័ត៌មានណាមួយឡើយ ហើយដំណើរការបង្កើតគោល នយោបាយអាចត្រូវបានកត់ត្រាជាមួយនឹងការអធិប្បាយអំពីគោលនយោបាយដែលអាចកំណត់បាន ។ ក្រៅពីនេះ លទ្ធភាពទទួលបានព័ត៌មានអំពីគោលនយោបាយ ស្រដៀងគ្នានឹងមានលក្ខណៈងាយស្រួល ដែលធានាអោយមានសង្គតភាពក្នុងការបង្កើតគោលនយោបាយ និងការរក្សាសុវត្ថិភាព ប្រឆាំងនឹង បរាជ័យគោលនយោបាយ ។<br><br>ប្រភព ៖<br>ដកស្រង់ពី NIA, ed *របាយការណ៍ប្រចាំឆ្នាំ២០០៦សម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក* (សេអ៊ូល:MOGAHA ឆ្នាំ២០០៦) ទំព័រទី ២០ http://www.nia.or.kr/open_content/common/fileList/fileList.jsp?tn=PU_0000100&id=54651. |

KMS អាចត្រូវបានបង្កើតឡើងសម្រាប់វិស័យជាក់លាក់ ដូចជាការគ្រប់គ្រងគ្រោះមហន្តរាយ ។

[38] Ibid.
[39] Ibid.

**ការគ្រប់គ្រងចំណេះដឹងសម្រាប់ការកាត់បន្ថយហានីភ័យក្នុងប្រទេសឥណ្ឌា**

កម្មវិធីគ្រប់គ្រងហានីភ័យគ្រោះមហន្តរាយថ្នាក់ជាតិក្រោមក្រសួងកិច្ចការប្រទេសរបស់រដ្ឋាភិបាលឥណ្ឌា មានគោលដៅ បង្កើតនូវបណ្តាញចំណេះដឹងក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាល អ្នកធ្វើសេចក្តីសម្រេច អ្នកគ្រប់គ្រង និងអ្នកជំនាញការគ្រោះ មហន្តរាយសំខាន់ៗមកពីវិស័យវិស្វកម្ម ស្ថាបត្យកម្ម រៀបចំផែនការ រញ្ជួយផែនដីវិទ្យា ជលវិទ្យា កសិកម្ម និងវិទ្យា–សាស្ត្រសង្គមដើម្បីសម្របសម្រួល ដល់ការផ្លោះប្តូរព័ត៌មាន និងកិច្ចសហការក្នុងការកាត់បន្ថយហានីភ័យគ្រោះមហន្តរាយ ។

ដើម្បីបង្កើតសហគមន៍មួយដែលមានការអនុវត្តជាក់ស្តែង វេទិកាអេឡិចត្រូនិកកំពុងត្រូវបានបង្កើត ឡើងដែលនឹងជួយសម្របសម្រួលដល់អន្តរកម្មក្នុងចំណោមដៃគូរកម្មវិធី ។ ប្រព័ន្ធនេះនឹងមាន លក្ខណៈលើកទឹកចិត្ត ហើយនិងផ្តល់ជាឧបករណ៍ ប្រព័ន្ធគាំទ្រការធ្វើសេចក្តីសម្រេច និងប្រព័ន្ធពិនិត្យ តាមដានទៅអោយភាគីពាក់ព័ន្ធ ។

នៅក្នុងដំណាក់កាលដំបូង កម្មវិធីនឹងតភ្ជាប់ស្ថាប័នចំនួន ៥០០ ។ ជាបន្តបន្ទាប់ទៀត បណ្តាញផ្សេងៗ ដូចជាបណ្តាញរដ្ឋ ដែលមាននាយកដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយរបស់រដ្ឋ ហើយបណ្តាញស្ថាប័ន បណ្តុះបណ្តាលដែលបង្កើតឡើងពីស្ថាប័ន បណ្តុះបណ្តាល រដ្ឋបាលទាំងអស់ក្នុងប្រទេសឥណ្ឌានឹងត្រូវ បានតភ្ជាប់គ្នា ។

ដៃគូកម្មវិធីរួមមាន ៖

- អ្នកជំនាញគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងនាយកដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយរបស់រដ្ឋាភិបាល រដ្ឋនៃរដ្ឋចំនួន ៣៥ ។
- កម្មវិធីថ្នាក់ជាតិសម្រាប់កសាងសមត្ថភាពវិស្វករសម្រាប់ស្ថាប័នការគ្រប់គ្រងហានីភ័យរញ្ជួយផែនដីដែលពាក់ព័ន្ធនឹងស្ថាប័នធនធានថ្នាក់ជាតិ (NRI) ចំនួន១១ ព្រមទាំងស្ថាប័នធនធានរដ្ឋចំនួន ប្រហែល ១២៥ នៅក្នុងរដ្ឋទាំង ៣៥ ។
- កម្មវិធីថ្នាក់ជាតិសម្រាប់កសាងសមត្ថភាពស្ថាបត្យករសម្រាប់ការគ្រប់គ្រងហានីភ័យរញ្ជួយផែនដីដែលពាក់ព័ន្ធនឹង NRI ចំនួន ៧ និង សាកលវិទ្យាល័យចំនួនប្រហែល ១១០ នៅក្នុងរដ្ឋទាំង ៣៥ ។
- អ្នកជំនាញផ្នែកកម្មវិធីកាត់បន្ថយភាពងាយរងគ្រោះដោយគ្រោះរញ្ជួយដីតាមទីក្រុងក្នុងទីក្រុងចំនួន ៣៨ នៃរដ្ឋចំនួន ១៧ ។
- អ្នកជំនាញផ្នែកគម្រោងកាត់បន្ថយហានីភ័យគ្រោះរញ្ជួយផែនដីថ្នាក់ជាតិក្នុងតំបន់ដែលមានរដ្ឋ រញ្ជួយដីទី IV និងទី V ។
- អ្នកជំនាញផ្នែកគម្រោងបន្ធូរបន្ថយព្យុះស៊ីក្លូនថ្នាក់ជាតិ

ច្រកបណ្តាញចំណេះដឹងនឹងសម្របសម្រួលដល់សហប្រតិបត្តិការក្នុងចំណោមសមាជិកបណ្តាញ ដោយតាមរយៈការផ្តល់ ឧបករណ៍ដើម្បីទទួលយក ឬទទួលបាន និងរៀបចំចំណេះដឹងដែលទាក់ទង នឹងការគ្រប់គ្រងគ្រោះមហន្តរាយ ។
ឧបករណ៍ទាំងនេះរួមមាន ៖

- ការទទួលបាន និងសម្របសម្រួលដែលមានការជួយសម្រួល
- ឧបករណ៍ពិនិត្យតាមដានកម្មវិធី និងចែករំលែកវិធីសាស្ត្រ
- ទីកន្លែងការងាររបស់សមាជិកសម្រាប់ការគ្រប់គ្រងខ្លឹមសារវិមជ្ឈការ
- ម៉ាស៊ីនស្រាវជ្រាវថាមពលខ្ពស់
- វេទិកាពិភាក្សាដែលមានការជួយសម្រួលសម្រាប់ដោះស្រាយបញ្ហា
- ប្រព័ន្ធគ្រប់គ្រងឯកសារ
- ក្រុមអ៊ីម៉ែលបណ្តាញខាងក្នុងដែលមានការជួយសម្រួល

បណ្តាញចំណេះដឹងត្រូវបានលើកមកពិចារណាដើម្បីទទួលបាន ៖

- ការឆ្លើយតបប្រសើរជាងមុន
- ការផ្តល់អំណាចដល់នាយកដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយរបស់រដ្ឋាភិបាល
- ការវាយតម្លៃធនធាន និងសេវាកម្មប្រសើរជាងមុន
- ការរួមបញ្ចូលទៅក្នុងការអភិវឌ្ឍទស្សនាទានបច្ចុប្បន្ន
- ការពិនិត្យតាមដានដែលមានប្រសិទ្ធភាពលើគំនិតផ្តួចផ្តើម
- ការលើកកម្ពស់ការអនុវត្តដោយយុត្តិធម៌ក្នុងសហគមន៍គ្រប់គ្រងគ្រោះមហន្តរាយ

ប្រភព ៖

នាយកដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ *ICT សម្រាប់ការកាត់បន្ថយហានីភ័យគ្រោះមហន្តរាយ ៖ បទពិសោធន៍ ប្រទេសឥណ្ឌា* (New Delhi ៖ ក្រសួងកិច្ចការជាតិឆ្នាំ២០០៦)
http://www.ndmindia.nic.in/WCDRDOCS/ICT%20for%20Disaster%20Risk%20Reduction.pdf.

នាយកដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ ការគ្រប់គ្រងចំណេះដឹងក្នុងការកាត់បន្ថយហានីភ័យគ្រោះមហន្តរាយ ៖ អភិក្រមប្រទេសឥណ្ឌា (New Delhi: ក្រសួងកិច្ចការជាតិ ឆ្នាំ២០០៦) http://www.ndmindia.nic.in/WCDRDOCS/knowledge-manageme.pdf.

**កិច្ចការដែលត្រូវអនុវត្ត**

ស្វែងរកឧទាហរណ៍លើប្រព័ន្ធគ្រប់គ្រងចំណេះដឹងក្នុងការគ្រប់គ្រងកសិកម្ម គ្រោះមហន្តរាយ និង ការគ្រប់គ្រងបរិស្ថានក្នុង ប្រទេស ឬតំបន់ ។ វិភាគឧទាហរណ៍នីមួយៗលើកត្តាជោគជ័យក្នុងការគ្រប់គ្រងចំណេះដឹង ។

## ៣.៦ កម្មវិធីសុខាភិបាល និងទូរវេជ្ជសាស្ត្រ ៖ បង្កើនការទទួលបានសេវាសុខាភិបាល[40]

សុខាភិបាលអេឡិចត្រូនិកដែលជាកម្មវិធីរបស់ ICT ក្នុងវិស័យសុខាភិបាលមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស នៅជុំវិញពិភពលោកក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ កម្មវត្ថុនៃកម្មវិធីសុខាភិបាលអេឡិចត្រូនិកគឺដើម្បីបង្កើនប្រសិទ្ធផល ការទទួលបាន ព្រមទាំងគណនេយ្យភាពនៃសេវាថែទាំសុខភាពឆ្ពោះទៅរក គុណភាពជីវិតប្រសើរជាងមុនសម្រាប់ប្រជាពលរដ្ឋ និងបរិយាកាស ការងារដែលមានផលិតភាពជាងមុន សម្រាប់គ្រូពេទ្យ និងបុគ្គលិកថែទាំសុខភាព ។

សុខាភិបាលអេឡិចត្រូនិកមានប្រើប្រាស់ក្នុងវិស័យទិន្នន័យឌីជីថលសុខាភិបាល ៖ ត្រូវបានបញ្ជូន រក្សា ទុក និងស្តារឡើងវិញ តាមប្រព័ន្ធអេឡិចត្រូនិក ពោលគឺសម្រាប់គោលបំណងព្យាបាល អប់រំ និងរដ្ឋបាល ទាំងនៅក្នុងមូលដ្ឋាន និងពីចម្ងាយ ។ សុខាភិបាលអេឡិចត្រូនិកធ្វើការប្រើប្រាស់នូវពិធីសារ និង បច្ចេកទេសបញ្ជូនទិន្នន័យផ្សេងៗ ។ សុខាភិបាលអេឡិចត្រូនិកមាន ការរួមបញ្ចូលទាំងអស់ ដោយសារវាមានការពាក់ព័ន្ធជាមួយការថែទាំសុខភាព និងអ្នកវិជ្ជាជីវៈថែទាំសុខភាពគ្រប់ប្រភេទ (ឧទាហរណ៍ វាមិនមានកំណត់ចំពោះថ្នាំ និងមិនមានកំណត់ចំពោះវេជ្ជបណ្ឌិត) ។ តារាងទី ៩ លើកឡើងនូវ ឧទាហរណ៍មួយចំនួនអំពីសុខាភិបាលអេឡិចត្រូនិក។

*តារាងទី៩. ឧទាហរណ៍នៃសុខាភិបាលអេឡិចត្រូនិក*

| **បច្ចេកវិទ្យា** | **ឧបករណ៍ និងកម្មវិធីកុំព្យូទ័រ** | **កម្មវិធីសុខាភិបាលអេឡិចត្រូនិក** |
|---|---|---|
| ការតាមដានពីចម្ងាយ | • សិនស័រ<br>• ឧបករណ៍<br>• អ៊ុលត្រាសោន | • ការថែទាំនៅផ្ទះតាមប្រព័ន្ធទូរគមនាគមន៍ |
| រោគវិនិច្ឆ័យ | • ឧបករណ៍ស្ទង់បេះដូង<br>• កំណត់ត្រាសកម្មភាពបេះដូង (EKG)<br>• កាំរស្មីអ៊ិច / CatScan និង កម្មវិធីកុំព្យូទ័រវិភាគរូបភាពវេជ្ជសាស្ត្រ<br>• ការពិគ្រោះយោបល់ | • ការថែទាំនៅផ្ទះតាមប្រព័ន្ធទូរគមនាគមន៍ |
| ការប្រាស្រ័យទាក់ទង តាមវីដេអូ | • ម៉ាស៊ីនថត (ម៉ាស៊ីនថតវីដេអូ ម៉ាស៊ីនថតភ្ជាប់អ៊ីនធឺណិត)<br>• កុំព្យូទ័រ Desktops<br>• ប្រព័ន្ធគមនាគមន៍ និងទិន្នន័យចល័ត | • ការពិគ្រោះយោបល់<br>• ទូរព្យាបាលជំងឺស្បែក<br>• ទូរសុខភាពផ្លូវចិត្ត |
| រូបភាពឌីជីថល | • ឧបករណ៍<br>• ប្រព័ន្ធផ្សព្វផ្សាយ (ឧទាហរណ៍ ខ្សែភាពយន្ត ខ្សែអាត់ម៉ាញ៉េទិច)<br>• ម៉ាស៊ីនស្កេន/ឧបករណ៍បញ្ចាំង រូបភាព<br>• ម៉ាស៊ីនថតឌីជីថល<br>• ម៉ាស៊ីនថតវីដេអូអាចពង្រីក ពង្រួមបាន | • ទូរសិក្សាជំងឺ<br>• ទូរវិទ្យុសកម្ម<br>• ទូរទន្តសាស្ត្រ<br>• ទូរព្យាបាលជំងឺស្បែក |
| បច្ចេកវិទ្យាព័ត៌មាន | • កុំព្យូទ័រមេសម្រាប់ប្រព័ន្ធរក្សា ទិន្នន័យ | • សៀវភៅកត់ត្រាវេជ្ជសាស្ត្រតាមប្រព័ន្ធអេឡិចត្រូនិក (ឧទាហរណ៍ ប្រព័ន្ធព័ត៌មានអ្នកជំងឺ |

[40] ចំណុចនេះដកស្រង់ចេញពីការសិក្សាអំពី ESCAP សុខភាពបែបអេឡិចត្រូនិកក្នុងទ្វីបអាស៊ីន និងប៉ាស៊ីហ្វិក ៖ បញ្ហាប្រឈម និងឱកាស http://www.unescap.org/esid/hds/lastestadd/eHealthReport.pdf.

| | | |
|---|---|---|
| | • កម្មវិធីកុំព្យូទ័រ/ព័ត៌មានវិទ្យា<br>• ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ<br>• ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ<br>• កម្មវិធីកុំព្យូទ័រភ្ជាប់ទំនាក់ទំនង អតិថិជនជាមួយទិន្នន័យ | ប្រព័ន្ធព័ត៌មានមន្ទីរពេទ្យ ប្រព័ន្ធព័ត៌មាន អ្នកវិជ្ជាជីវៈទូទៅ)<br>• ការស្វែងរកទិន្នន័យ ច្រកបណ្ដាញវែបសាយត៍<br>• រដ្ឋបាល DSS |
| រក្សាទុក និងបញ្ជូន | • ទិន្នន័យ/រូបភាព/បន្ទះចាប់សម្លេង/ ម៉ាស៊ីនស្កែន<br>• ម៉ាស៊ីនថត/មីក្រូហ្វូន/សម្លេង និង កម្មវិធីកុំព្យូទ័រគ្រប់គ្រងរូបភាព | • កំណត់ត្រាវេជ្ជសាស្ត្រ/សុខភាពតាមអេឡិចត្រូនិក<br>• អ្នកធ្វើរបាយការណ៍ |
| ការចម្លងតាម និងការបណ្ដុះបណ្ដាល | • ក្រាហ្វិច និងកម្មវិធីកុំព្យូទ័រប្រព័ន្ធ ផ្សព្វផ្សាយចម្រុះ<br>• សម្លេង-រូបភាព | • ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក<br>• កម្មវិធីសិក្សា<br>• សន្និសីទ |

ប្រភព: ដកស្រង់ពី David Brantley, Karen Laney-Cummings និង Richard Spivack

*នវានុវត្តន៍ តម្រូវការ និងការវិនិយោគក្នុងទូរសុខាភិបាល (ខែកុម្ភៈ ឆ្នាំ២០០៤)*

http://www.technology.gov/reports/TechPolicy/Telehealth/2004Report.pdf.

ដូចដែលតារាងទី ៩ បង្ហាញ ICT អាចត្រូវបានប្រើប្រាស់នៅក្នុងប្រព័ន្ធសុខភាពអេឡិចត្រូនិកចំនួនបួន ប្រភេទ ៖

១. ប្រព័ន្ធថែទាំសុខភាពចល័ត (ការថែទាំនៅផ្ទះតាមប្រព័ន្ធទូរគមនាគមន៍) - ការពិនិត្យ និងព្យាបាល សុខភាពអាចត្រូវ បានធ្វើឡើងតាមរយៈការប្រើទូរស័ព្ទចល័ត ខណៈដែលអ្នកជំងឺកំពុងធ្វើដំណើរ ឬស្ថិតនៅក្នុងតំបន់ដាច់ស្រយាល ។

២. ប្រព័ន្ធធ្វើរោគវិនិច្ឆ័យចល័ត (ការថែទាំតាមផ្ទះពីចម្ងាយ) - អ្នកជំងឺត្រូវបានធ្វើរោគវិនិច្ឆ័យ និង ព្យាបាលតាមរយៈប្រភេទ កូនកាត់នៃសិនស័រវាស់វែងសញ្ញាសំខាន់ៗ និងប្រព័ន្ធវិភាគសញ្ញាសំខាន់ៗ ខណៈពេលកំពុងធ្វើសកម្មភាព ។

៣. ឧបករណ៍វេជ្ជសាស្ត្រថែទាំតាមផ្ទះទំនើប (ការថែទាំតាមផ្ទះពីចម្ងាយ)-ស្ថានភាពសុខភាពអ្នកជំងឺ តាមផ្ទះ ឬនៅក្នុងមជ្ឈមណ្ឌលសហគមន៍ប្រជាពលរដ្ឋជាន់ខ្ពស់ចូលនិវត្តអាចត្រូវបានត្រួតពិនិត្យ និង ធ្វើរោគវិនិច្ឆ័យដោយឧបករណ៍ វេជ្ជសាស្ត្រទំនើប ។

៤. ប្រព័ន្ធគ្រប់គ្រងអ្នកជំងឺរួមបញ្ចូលគ្នា - ឧបករណ៍ ដូចជា PDA ទូរស័ព្ទចល័ត កុំព្យូទ័រផ្ទាល់ខ្លួន/ អ៊ីនធឺណិត និងឧបករណ៍ជំនាញអាចត្រូវបានប្រើប្រាស់ដើម្បីទទួលបានសញ្ញាសំខាន់ៗ ធ្វើការវិភាគ និងធ្វើរោគវិនិច្ឆ័យ ព្រមទាំងគ្រប់គ្រង អ្នកជំងឺនីមួយៗ ជាលក្ខណៈប្រព័ន្ធ ។

សមត្ថភាព និងជំនាញសុខាភិបាលអេឡិចត្រូនិកមានសារសំខាន់ជាពិសេសទាក់ទងនឹងផ្នែកកម្មវិធី សុខាភិបាលអេឡិចត្រូនិក សំខាន់ៗចំនួនបួន ៖

**គោលនយោបាយ និងការបង្ការសុខភាពសាធារណៈ- ផ្នែកនេះតម្រូវអោយមានការប្រមូលព័ត៌មាន ផ្នែកសុខភាព បរិស្ថាន និងសេដ្ឋកិច្ចសង្គម ដែលជួយដល់ការស្វែងរកទិន្នន័យសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថែទាំសុខភាព ។**

**សេវាព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ផ្នែកនេះមាននូវសកម្មភាពដែលផ្តល់អោយអ្នកជំងឺនូវព័ត៌មានអំពី ប្រធានបទទាក់ទងនឹងសុខភាព ដូចជា សុខភាព និងរបៀបរស់នៅល្អប្រសើរនៅពេលដែលជំនួយលក្ខណៈវិជ្ជាជីវៈមានភាពចាំបាច់ ព្រមទាំង ទីកន្លែង និងរបៀបដើម្បីទទួលបានសេវានេះ ។**

**ការគ្រប់គ្រងអ្នកជំងឺ និងកំណត់ត្រាសុខភាពអ្នកជំងឺរួមបញ្ចូលគ្នា - កម្មវិធីនេះពាក់ព័ន្ធនឹងសកម្មភាព ទាក់ទងនឹងការចែករំលែកព័ត៌មានប្រកបដោយប្រសិទ្ធផល និងសុវត្ថិភាពរវាងអ្នកវិជ្ជាជីវៈថែទាំសុខភាព និងសង្គម ព្រមទាំងការបង្កើត បរិយាកាសដើម្បីផ្តល់ការគាំទ្រសម្រាប់គ្រប់គ្រងករណីអ្នកទទួលសេវា ដែលរួមបញ្ចូលគ្នា ។**

**សេវាទូរថែទាំ និងរស់នៅដោយឯករាជ្យ កម្មវិធីនេះរួមមានការពិគ្រោះយោបល់ពីចម្ងាយ ការថែទាំតាមផ្ទះ ពីចម្ងាយការតាមដានសញ្ញាសំខាន់ៗ ព្រមទាំងសេវាកម្មផ្សេងៗទៀតដែលគាំទ្រដល់ការរស់នៅដោយឯករាជ្យសម្រាប់ប្រជាជនវ័យចំណាស់ និងជនពិការ ។**

កម្មវិធីសុខាភិបាលអេឡិចត្រូនិកត្រូវបានប្រើប្រាស់ប្រកបដោយជោគជ័យនៅក្នុងផ្នែកដូចខាងក្រោម ៖

១. មន្ទីរពេទ្យបង្អែក ជាពិសេសក្នុងការប្រើប្រាស់បច្ចេកវិទ្យា និងជំនាញវេជ្ជសាស្ត្រដែលត្រូវបាន ប្រើប្រាស់តាមរបៀប ខុសៗគ្នានៅក្នុងប្រទេសមួយចំនួន (មើលរូបភាពទី ២១) ។




***រូបភាពទី ២១. បានវិទ្យាទូរពិគ្រោះយោបល់នៅលើកោះប៉ាស៊ីហ្វិក***

(ប្រភព ៖ Isao Nakajima "បញ្ហាទាក់ទងនឹងកម្មវិធីសុខាភិបាលអេឡិចត្រូនិកនៅក្នុងប្រទេស កំពុងអភិវឌ្ឍន៍ ជាពិសេស ក្នុងតំបន់ប៉ាស៊ីហ្វិក" (បទបង្ហាញនៅឯកិច្ចប្រជុំក្រុមជំនាញ ESCAP ស្តីពី "និន្នាការតំបន់លើវិស័យពាណិជ្ជកម្មផ្នែកសេវាសុខាភិបាល និងឥទ្ធិពលនៃសេវានេះទៅលើសម្មិទ្ធកម្ម ប្រព័ន្ធសុខាភិបាលក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក" បាងកក ប្រទេសថៃ ថ្ងៃទី០៩-១១ ខែតុលា ឆ្នាំ២០០៧)

២. ការអប់រំបុគ្គលិកសុខាភិបាលដើម្បីកែលម្អការអប់រំបន្ត និងការអភិវឌ្ឍវិជ្ជាជីវៈដើម្បីកែលម្អគុណភាព និងបទដ្ឋានអនុវត្ត របស់អ្នកវិជ្ជាជីវៈសុខាភិបាល ។ ឧទាហរណ៍ ដូចជា បណ្តាញសុខាភិបាលសិក្សាបើកទូលាយតំបន់ប៉ាស៊ីហ្វិកដែលផ្តល់ឱកាសអប់រំបន្តដល់អ្នកវិជ្ជាជីវៈសុខាភិបាលតាមបណ្តា ប្រទេសលើកោះប៉ាស៊ីហ្វិក ។

***ប្រអប់ទី ៣ ៖ អង្គការសុខភាពពិភពលោកអំពីសុខភាពអេឡិចត្រូនិក***

> សុខាភិបាលអេឡិចត្រូនិកកាន់តែត្រូវបានមើលឃើញថាជាមធ្យោបាយមួយដើម្បីដោះស្រាយបញ្ហាប្រឈមធនធានមានកំណត់ ខណៈដែលបំពេញការរំពឹងទុកសម្រាប់ការកែលម្អគុណភាពសេវាថែទាំ សុខភាព ។ អង្គការសុខភាពពិភពលោក (WHO) ផ្តល់អនុសាសន៍អោយមានការប្រើប្រាស់ ទូរគមនាគមន៍នៅក្នុងការថែទាំសុខភាព ជាពិសេស ដោយសារតែ ៖
>
> - ការខ្វះខាតអ្នកវិជ្ជាជីវៈថែទាំសុខភាពក្នុងចំនួនដ៏ច្រើន
> - កង្វះខាត (ឬអវត្តមាន) ការថែទាំសុខភាពសម្រាប់ប្រជាជនជនបទ
> - អត្រាមរណៈមាតា និងទារកខ្ពស់ (រហូតដល់ ៣០ភាគរយនៅក្នុងតំបន់មួយចំនួន) ដែលផ្នែកខ្លះ បង្កឡើងដោយកង្វះខាត ផ្នែកថែទាំសុខភាពទារកក្នុងផ្ទៃ និងសេវាសុខភាពបន្តពូជ និង
> - លទ្ធភាពនៅមានកម្រិត ឬពុំមានលទ្ធភាពទទួលបានព័ត៌មានវេជ្ជសាស្ត្របន្ទាប់ពីគ្រូពេទ្យបញ្ចប់ ការសិក្សាជាពិសេសប្រជាជននៅក្នុងតំបន់ជនបទ និងដាច់ស្រយាល ។

៣. ការតាមដានជំងឺឆ្លងកាត់ព្រំដែនដែលអាចមានការរាលដាល ដូចជានៅក្នុងករណីអាការៈជំងឺផ្លូវដង្ហើម ស្រួចស្រាវធ្ងន់ធ្ងរ និងផ្តាសាយបក្សី ។ ព័ត៌មានវិទ្យាភូមិសាស្ត្រត្រូវបានមើលឃើញយ៉ាងច្បាស់ថាជាឧបករណ៍ដ៏មានឥទ្ធិពលទៅលើប្រសិទ្ធិភាពនៃការរៀបចំ និងធ្វើផែនការសម្រាប់គ្រប់គ្រងការ រាលដាលដែលរៀបចំឡើងដោយអង្គការអន្តរជាតិ និងរដ្ឋាភិបាល ។ ឧទាហរណ៍ អង្គការសុខភាពពិភពលោកបានរៀបចំបង្កើតបណ្តាញប្រកាសអាសន្ន និងឆ្លើយតបចំពោះការផ្ទុះឡើងជំងឺឆ្លង ជាសកល ដើម្បីតាមដានការផ្ទុះឡើងនូវជំងឺផ្តាសាយបក្សី ព្រមទាំងជំងឺឆ្លងផ្សេងៗទៀត ។

៤. ការកត់ត្រាព័ត៌មានវេជ្ជសាស្ត្រ និងកំណត់ត្រាវេជ្ជសាស្ត្រនៅក្នុងទីកន្លែងដែលបុគ្គលដែលមានការ បណ្តុះបណ្តាលធ្វើការចម្លង កំណត់ត្រាវេជ្ជសាស្ត្រដែលអានដោយវេជ្ជបណ្ឌិត និងអ្នកផ្តល់ការថែទាំសុខភាពដទៃទៀត ។

៥. ប្រសិទ្ធផល ជាពិសេស ការលុបបាត់ការអនុវត្តស្ទួនគ្នា ឬកំហុសបច្ចេកទេស ការសន្សំសំចៃ ពេលវេលា និងការចំណាយលើការធ្វើដំណើរ ព្រមទាំងការបែងចែកធនធានមនុស្ស និងធនធានផ្សេងៗទៀតអោយកាន់តែមានប្រសិទ្ធផល ។

ប្រសិទ្ធផលនេះបានមកពី ៖

- ការចែករំលែកចំណេះដឹង និងការគ្រប់គ្រងផែនការថែទាំសុខភាពដែលមានការកែលម្អ
- ការថែទាំអ្នកជំងឺដោយផ្ទាល់តាមរយៈទូរឱសថ និងការចែកចាយថ្នាំ និង
- ការតភ្ជាប់អ្នកជំងឺ និងវេជ្ជបណ្ឌិតតាមរយៈប្រព័ន្ធប្រជុំតាមរូបភាពវីដេអូទៅវិញទៅមកដែលសម្រួល អោយមានការថែទាំ អ្នកជំងឺដោយផ្ទាល់ ព្រមទាំងការពិនិត្យតាមដានជំងឺរ៉ាំរ៉ៃ ។

៦. ការកាត់បន្ថយចម្ងាយ/ភាពឯកោ ដោយមានការគ្របដណ្តប់លើសេវាថែទាំសុខភាពដែលត្រូវបាន ពង្រីកវិសាលភាពដល់ ភូមិដាច់ស្រយាល ឬភូមិជនបទដែលខ្វះខាតមធ្យោបាយទៅកាន់មន្ទីរពេទ្យ និងមណ្ឌលសុខភាពដោយងាយស្រួល ។ ទូរមណ្ឌលពហុគោលបំណងអាចជួយផ្តល់ព័ត៌មាន សុខភាពសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់សេវាវេជ្ជសាស្ត្រ រោគវិនិច្ឆ័យតាមរយៈ ទូរឱសថ ។

កំណត់ត្រាសុខាភិបាលអេឡិចត្រូនិកអនុញ្ញាតិអោយមានការផ្ទេរព័ត៌មានសុខភាព ទាន់ ពេលវេលា ផ្តល់លទ្ធភាពប្រជាជនដែលរស់នៅតំបន់ដាច់ស្រយាលក្នុងការពិគ្រោះយោបល់ជាមួយអ្នក ជំនាញផ្នែកសុខភាពក្នុងទីតាំងមួយផ្សេងទៀត ។

**សំណួរត្រិះរិះ**

១. តើប្រទេសរបស់អ្នកមានសេវាសុខាភិបាលអេឡិចត្រូនិកអ្វីខ្លះ ? តើសេវាមួយណាដែលអាចទៅ ដល់សហគមន៍ជនបទ ?

២. តួនាទីទូរស័ព្ទចល័តក្នុងផ្នែកសុខាភិបាលអេឡិចត្រូនិកកាន់តែមានសារសំខាន់ច្រើនជាមុន ។ តើសេវាថែទាំសុខភាពប្រភេទណាខ្លះ ដែលអាចត្រូវបានផ្តល់តាមរយៈការប្រើប្រាស់ទូរស័ព្ទចល័តនៅក្នុងប្រទេសរបស់អ្នក ?

៣. តើអ្នកដឹងអំពីកម្មវិធីសុខាភិបាលអេឡិចត្រូនិកមួយណាក្នុងប្រទេស ឬតំបន់របស់អ្នកដែល ប្រើប្រាស់មជ្ឈមណ្ឌលអេឡិចត្រូនិកសហគមន៍ឬទេ ? ចូររៀបរាប់អំពីកម្មវិធីមួយ ឬពីរនៃកម្មវិធី ទាំងនេះ ។

៣.៧ កម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយ ៖ សេវាគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិរួមបញ្ចូលគ្នា[41]

ប្រព័ន្ធគ្រប់គ្រងគ្រោះអាសន្នថ្នាក់ជាតិមានប្រសិទ្ធផលមានភាពចាំបាច់នៅក្នុងការកាត់បន្ថយផលប៉ះពាល់ដែលបង្កឡើងដោយគ្រោះមហន្តរាយធម្មជាតិ និងដោយមនុស្ស ។ នៅសាធារណរដ្ឋកូរ៉េ ទីភ្នាក់ងារគ្រប់គ្រងគ្រោះអាសន្នថ្នាក់ជាតិយកចិត្តទុកដាក់លើការគ្រប់គ្រងគ្រោះមហន្តរាយដោយផ្តោតលើការទប់ស្កាត់ជាជាងការសាងសង់ និងស្តារឡើងវិញ ។ សាធារណរដ្ឋកូរ៉េ ក៏បានបង្កើតប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ (NDMS) ដែលបានបង្កើត និងដាក់ពង្រាយប្រព័ន្ធត្រួតពិនិត្យគ្រោះមហន្តរាយដល់ ទីភ្នាក់ងាររដ្ឋាភិបាលចំនួន ១០ ដែលរួមមានក្រសួងកសិកម្ម និងរុក្ខាប្រមាញ់ ព្រមទាំងក្រសួងកិច្ចការ ដែនសមុទ្រ និងនេសាទ ។ NDMS ក៏បានបង្កើតបណ្តាញគ្រប់គ្រងគ្រោះមហន្តរាយអន្តររដ្ឋាភិបាល ជាការសាកល្បងដើម្បីពង្រឹងភាពជាដៃគូ ក្នុងចំណោមទីភ្នាក់ចំនួន ៧១ ។ ដំណើរការចែកចាយព័ត៌មានសម្រាប់គ្រោះអាសន្នត្រូវបានធ្វើអោយមានលក្ខណៈងាយស្រួល ដោយមានការបង្កើតបណ្តាញផ្ទាល់រវាង ភ្នាក់ងារកណ្តាល ព្រមទាំងរវាងរដ្ឋាភិបាលមូលដ្ឋានជាន់ខ្ពស់ និងជាន់ទាប ដែលបង្កអោយមានការឆ្លើយតបប្រកបដោយប្រសិទ្ធផលចំពោះគ្រោះមហន្តរាយ ព្រមទាំងគ្រោះអាសន្ននានា ។ នៅក្នុងការ សង្គ្រោះ គ្រោះអាសន្ន ប្រព័ន្ធនេះអាចជួយកំណត់អត្តសញ្ញាណអ្នករាយការណ៍អំពីឧបទ្ទវហេតុ និងទីតាំងរបស់អ្នកទាំងនោះ តាមរយៈប្រព័ន្ធកំណត់អត្តសញ្ញាណអ្នករាយការណ៍ ។ មធ្យោបាយនេះធ្វើអោយមាន ការថយចុះចំនួន ១,៣ ភាគរយក្នុងការរាយការណ៍ ព័ត៌មានមិនពិតទាក់ទងនឹងគ្រោះអាសន្នក្នុងឆ្នាំ២០០៥ ។ សេវាអាចត្រូវបានទទួលដោយងាយស្រួលដោយអ្នកដែលមាន ការលំបាកផ្នែកភាសា ជនបរទេស និងចាស់ជរា ។ នៅពេលដែលគម្រោងប្រទេសកូរ៉េ u-Safe ត្រូវបានបញ្ចប់នៅក្នុងរង្វង់ឆ្នាំ ២០១០ ។ មានការរំពឹងទុកថា មនុស្សដែលបានបាត់បង់ជីវិតដោយសារគ្រោះមហន្តរាយនឹងមានការថយចុះមកត្រឹម ១១,១ ភាគរយ ក្នុងចំណោមមនុស្ស ១ លាននាក់ ដែលបង្ហាញពីការថយចុះចំនួន ៣៣ ភាគរយពី ១៦,៥ ភាគរយនាពេលបច្ចុប្បន្ន ក្នុងចំណោមមនុស្ស ១ លាននាក់ ។ ការបាត់បង់ទ្រព្យសម្បត្តិជាមធ្យម ប្រចាំឆ្នាំក៏ត្រូវបានរំពឹងថានឹងមានការថយចុះមកត្រឹម ៨,២ ភាគរយ ដែលនាំអោយអាចសន្សំថវិកា បានចំនួន ៣៥ ពាន់លានដុល្លារអាមេរិកពីការខូចខាត ចាប់ពីឆ្នាំ ២០១០ រហូតដល់ ២០១៤ ។

ស៊ូណាមិដែលបានកើតឡើងក្នុងឆ្នាំ ២០០៤ នាំអោយមានការបង្កើតប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ រួមបញ្ចូលគ្នាដែលត្រូវបាន ហៅថា សាហាណា (sahana) ។

**ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយសាហាណា**

សាហាណា គឺជាកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយតាមប្រព័ន្ធកុំព្យូទ័រ សម្រាប់គ្រប់គ្រងព័ត៌មានអំឡុងពេល ប្រតិបត្តិការសង្គ្រោះ ស្រោចស្រង់ និងស្តារឡើងវិញ ដែលបង្កើតឡើងដោយក្រុមស្ម័គ្រចិត្តផ្នែក IT មកពីប្រទេសស្រីលង្កា ដែលដឹកនាំដោយ មូលនិធិ Lanka Software ។

សាហាណា គឺជាការអនុវត្តកម្មវិធីកុំព្យូទ័រប្រភពសេរី និងបើកទូលាយ មានន័យថាអ្នកប្រើប្រាស់ ទាំងអស់អាចប្រើប្រាស់ ថតចម្លង ចែកចាយ និងកែសម្រួលកម្មវិធីកុំព្យូទ័រ ក្នុងតំលៃទាបបំផុត ។ មធ្យោបាយនេះមានសារសំខាន់សម្រាប់ប្រទេស ភាគច្រើនក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ។ FOSS ក៏អាចជួយអោយមានការកែសម្រួលប្រព័ន្ធសម្រាប់កាលៈទេសៈជាក់លាក់ ឬគ្រោះមហន្តរាយច្បាស់លាស់ ដែលធ្វើអោយប្រព័ន្ធអាចប្រើប្រាស់ឡើងវិញសម្រាប់ពេលអនាគត និងមានលក្ខណៈបើកចំហរ សម្រាប់ ការអភិវឌ្ឍបន្ថែមទៀតដោយអ្នកវិជ្ជាជីវៈ IT មកពីជុំវិញពិភពលោក (មើលម៉ូឌុល ៤ ក្នុងស៊េរីម៉ូឌុលការសិក្សាអំពីសារប្រយោជន៍របស់ *ICT សម្រាប់អ្នកដឹកនាំរដ្ឋាភិបាល ដើម្បីស្វែងយល់បន្ថែមអំពី* FOSS) ។

ប្រព័ន្ធសាហាណាស្នូលត្រូវបានបែងចែកជាម៉ូឌុលឯករាជ្យដែលមានអន្តរបណ្តាញតាមរយៈមូលដ្ឋាន ទិន្នន័យរួម ៖

**ការចុះបញ្ជីអង្គភាព** — រក្សាការតាមដាន និងសម្របសម្រួលអង្គភាព និងតួនាទីរបស់អង្គភាពទាំងនោះ នៅក្នុងកិច្ចខិតខំ ប្រឹងប្រែងផ្តល់ជំនួយ ។

**ប្រព័ន្ធគ្រប់គ្រងសំណើរ – កត់ត្រា និងតាមដានរាល់សំណើរសុំការគាំទ្រទាំងអស់ពីទីតាំងផ្សេងៗ (ការបោះជំរុំ មន្ទីរពេទ្យ ។ល។) ព្រមទាំងការគាំទ្រពីសំណាក់អ្នកផ្តល់ជំនួយ ។**

**ចុះបញ្ជីជំរុំ – ចុះបញ្ជីជំរុំ មន្ទីរពេទ្យ និងទីតាំងបណ្តោះអាសន្នទាំងអស់សម្រាប់ជនរងគ្រោះ ដោយសារគ្រោះមហន្តរាយ ។**

**ប្រជាជន (មនុស្សបាត់ខ្លួន) ការចុះបញ្ជី – មូលដ្ឋានទិន្នន័យរបស់មនុស្សបាត់ខ្លួន បាត់បង់ទីជម្រក ឬស្លាប់ ព្រមទាំងមនុស្ស ដែលកំពុងស្វែងរកសាច់ញាតិ និងអ្នកដែលត្រូវបានរកឃើញ ឬកំណត់ទីតាំង (រួមមាន**

[41] ផ្នែកនេះដកស្រង់ចេញពី NIA, ed. របាយការណ៍ប្រចាំឆ្នាំ ២០០៦ សម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក (ទីក្រុងសេអ៊ូល ៖ MOGAHA ឆ្នាំ២០០៦) ទំព័រ ២៣ ។
http://www.nia.or.kr/open_content/common/fileList/fileList.jsp?tn=PU_0000100&id=54651.

**រូបភាព ស្នាមម្រាមដៃ សំណាក** DNA) ដោយប្រើសមត្ថភាពស្រាវជ្រាវទំនើប ។

**ប្រព័ន្ធគ្រប់គ្រង (អ្នកស្ម័គ្រចិត្ត) ជំនួយ – មូលដ្ឋានទិន្នន័យនៃការសន្យាផ្តល់ជំនួយ (ពីអង្គការសង្គ្រោះ ទីភ្នាក់ងាររដ្ឋាភិបាល ជំរុំ ។ល។) ព្រមទាំងការព្យាយាមផ្គូរផ្គងជំនួយទាំងនេះជាមួយសំណើរ ។**

**ការគ្រប់គ្រងសារពើភ័ណ្ឌ – ពិនិត្យទីតាំង បរិមាណ និងការបរិច្ឆេទផុតកំណត់ប្រើប្រាស់នៃសម្ភារៈ ផ្គត់ផ្គង់ក្នុងឃ្លាំង ។**

**ការយល់ដឹងអំពីស្ថានភាព – ផ្តល់ទិដ្ឋភាពទូទៅនៃប្រព័ន្ធព័ត៌មានភូមិសាស្ត្រក្នុងស្ថានភាពបច្ចុប្បន្ន ដើម្បីជួយដល់ការធ្វើសេចក្តីសម្រេច ។**

ក៏មានផងដែរនូវម៉ូឌុលជាជម្រើសយ៉ាងច្រើន ដែលអាចត្រូវបានប្រើប្រាស់ ក្នុងនោះរួមមានប្រព័ន្ធសម្រប សម្រួលស្ម័គ្រចិត្ត ព្រមទាំងការផ្ញើសារតាមទូរស័ព្ទ ។

ខុសពីការអនុវត្តនៅក្នុងព្រឹត្តការណ៍ស៊ូណាមិឆ្នាំ ២០០៤ នៅប្រទេសស្រីលង្កា សាហាណា ត្រូវបានដាក់ ពង្រាយដោយអង្គភាព ផ្សេងៗក្នុងប្រទេសចិន ឥណ្ឌូនេស៊ី ប៉ាគីស្ថាន ប៉េរូ ហ្វីលីពីន និងសហរដ្ឋអាមេរិក ក្នុងការឆ្លើយតបចំពោះគ្រោះមហន្តរាយ ដូចខាងក្រោម ៖

| | |
|---|---|
| មជ្ឈមណ្ឌលប្រតិបត្តិការជាតិ ស្រីលង្កាជាផ្នែកនៃច្រកផ័បសាយរបស់ខ្លួន | ២០០៥ |
| បន្ទាប់ពីគ្រោះរញ្ជួយផែនដីនៅកាស្មៀ/ប៉ាគីស្ថាន ដោយរដ្ឋាភិបាលនៃប្រទេសប៉ាគីស្ថាន | |
| បន្ទាប់ពីការបាក់ដីនៅ Guinsaugon ប្រទេសហ្វីលីពីន ដោយរដ្ឋាភិបាលប្រទេសហ្វីលីពីន | ២០០៦ |
| Sarvodaya អង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសស្រីលង្កា | |
| Terre des Hommes អង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសស្រីលង្កា | |
| បន្ទាប់ពីគ្រោះរញ្ជួយផែនដីនៅទីក្រុង Jogjakarta ប្រទេសឥណ្ឌូនេស៊ី | |
| បន្ទាប់ពីគ្រោះរញ្ជួយផែនដីនៅប្រទេសប៉េរូ | ២០០៧ |
| ការិយាល័យប្រចាំទីក្រុងញូវយ៉កសម្រាប់ការគ្រប់គ្រងគ្រោះអាសន្ន សហរដ្ឋអាមេរិក | |
| បន្ទាប់ពីគ្រោះរញ្ជួយផែនដីនៅខេត្ត Sichuan ប្រទេសចិន | ២០០៨ |

ការធ្វើតេស្ត និងអភិវឌ្ឍបន្តសម្រាប់សាហាណា កំពុងដំណើរការនៅក្នុងប្រទេសអេក្វាឌ័រ ឥណ្ឌូនេស៊ី លេបាណន់ និងហ្វីលីពីន ។

សម្រាប់ព័ត៌មានបន្ថែមអំពីប្រព័ន្ធ សាហាណា រួមមានឯកសារគម្រោង ។ សូមចូលទៅកាន់ http://www.sahana.lk/ .

ប្រភព ៖


Chamindra De Silva "អង្គការមនុស្សធម៌-FOSS ៖ ករណីសិក្សាអំពីការគ្រប់គ្រងគ្រោះមហន្តរាយ" (បទបង្ហាញធ្វើនៅ ISCRAM ឆ្នាំ២០០៧ ថ្ងៃទី ២៦-២៧ ខែសីហា ឆ្នាំ២០០៧ ក្នុងទីក្រុង Harbin ប្រទេសចិន)
http://chamindra.googlepages.com/សាហាណា-Overview-ISCRAM-China-AUG-200.pdf .

Isuru Samaraweera, "ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយសាហាណា និងការតាមដានស្ថានភាពជនរង គ្រោះ" (បទបង្ហាញ ធ្វើនៅឯកិច្ចប្រជុំបណ្តាញជាន់ខ្ពស់អាស៊ីប៉ាស៊ីហ្វិកលើកទី២៤ ថ្ងៃទី២៧-៣១ ខែសីហា ឆ្នាំ២០០៧ ទីក្រុង Xi'An ប្រទេសចិន) http://www.apan.net/meetings/xian2007/ presentations/dm/sahana.ppt .

Mifan Careem, Chamindra De Silva, Ravindra De Silva, Louiqa Raschid និង Sanjiva Weerawarana, "សាហាណា ៖ សេចក្តីសង្ខេបអំពីប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ" *ក្នុងដំណើរការសន្និ សីទអន្តរជាតិស្តីពីព័ត៌មាន និងស្វ័យប្រវត្តិកម្ម* (ថ្ងៃទី១៥-១៧ ខែធ្នូ ឆ្នាំ២០០៦ ទីក្រុងកូឡុមបូ ប្រទេសស្រីលង្កា)
ftp://ftp.umiacs.umd.edu/pub/louiqa/PUB06/សាហាណា6.pdf .

Soo Hoe Nah "ការគ្រប់គ្រងគ្រោះមហន្តរាយ - សាហាណា ប្រទេសស្រីលង្កា" ក្នុងការដោះស្រាយ ឧបសគ្គ ៖ សក្តានុពលនៃកម្មវិធីកុំព្យូទ័រប្រភពសេរី និងបើកទូលាយសម្រាប់ការអភិវឌ្ឍមនុស្សប្រកប ដោយនិរន្តរភាព - ការប្រមូលផ្តុំ ករណីសិក្សាពីជុំវិញពិភពលោក (បាងកក ៖ UNDP-APDIP ឆ្នាំ២០០៦) ទំព័រ ៥៦-៦៣ ។
http://www.apdip.net/ publications/ict4d/BreakingBarriers.pdf និង
http://www.iosn.net/foss/humanitarian/projects/sahana/ .

Wikibooks, "សាហាណា" មូលនិធិ Wikimedia, Inc., http://en.wikibooks.org/wiki/Sahana .

**សេចក្តីសង្ខេប**

ម៉ូឌុលនេះពិភាក្សាអំពីទស្សនាទាន និងគោលការណ៍សំខាន់ៗក្នុងការអភិវឌ្ឍប្រព័ន្ធរដ្ឋាភិបាល អេឡិចត្រូនិក ៖

១. តម្រូវការ និងការគាំទ្ររបស់សាធារណជនលើរដ្ឋាភិបាលអេឡិចត្រូនិកមានសារៈប្រយោជន៍ជា សារវ័ន្ត ។ រដ្ឋាភិបាល អេឡិចត្រូនិកនឹងទទួលបានជោគជ័យ ប្រសិនបើមានតម្រូវការ និងការគាំទ្រខ្លាំងសម្រាប់ខ្លួនពីសំណាក់ប្រជាពលរដ្ឋ និង អាជីវកម្ម ។ នៅក្នុងករណីភាគច្រើន ការទទួលបានការគាំទ្រពីសាធារណជនអាចជាការលំបាកដោយសារមូលហេតុដូច ខាងក្រោម ៖

ក. មានមនុស្សតិចណាស់យល់អំពីសារប្រយោជន៍របស់រដ្ឋាភិបាលអេឡិច ។

ខ. មានមនុស្សតិចតួចដឹងអំពីរបៀបប្រើប្រាស់សេវារដ្ឋាភិបាលអេឡិចត្រូនិកដែលបានផ្តល់អោយ ។

វិធីមួយដើម្បីដោះស្រាយបញ្ហាទាំងពីរនេះគឺត្រូវបង្កើតខ្លឹមសារដែលមានការចាប់អារម្មណ៍អោយបានពិតប្រាកដ សម្រាប់កម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិក ។ ខ្លឹមសារនេះ នឹងនាំអោយមានការកើនឡើងចំពោះអ្វីដែលត្រូវបានស្គាល់ថាជាកម្មវិធី ICT “កម្មវិធីអ្នកសម្លាប់” នៅក្នុង G2C និង G2B ។

២. រដ្ឋាភិបាលពហុបណ្តាញច្រកតែមួយកំពុងកាន់តែមានការពេញនិយម ពីព្រោះអភិក្រមពហុបណ្តាញ ផ្តល់នូវកម្រិតទទួលបានផ្សេងៗគ្នា (ឧទាហរណ៍ តាមរយៈអ៊ីនធឺណិត អ៊ីម៉ែល ទូរស័ព្ទចល័ត ទូរទស្សន៍ឌីជីថល) ដោយជំរុញអោយមាន ការចូលរួមកាន់តែច្រើនពីសំណាក់ប្រជាពលរដ្ឋ និង អាជីវកម្មនៅក្នុងរដ្ឋាភិបាលអេឡិចត្រូនិក ។ អភិក្រមនេះធ្វើអោយ សេវារដ្ឋាភិបាលអេឡិចត្រូនិកកាន់តែទទួលបានការគាំទ្រពីសំណាក់ប្រជាពលរដ្ឋ ។

៣. មានភាគីពាក់ព័ន្ធជាច្រើនក្នុងរដ្ឋាភិបាលអេឡិចត្រូនិក ។ កម្មវិធី ICT ខុសៗគ្នានៅក្នុងតំបន់រដ្ឋាភិបាល –ទៅ–ប្រជាពលរដ្ឋ (G2C) រដ្ឋាភិបាល–ទៅ–អាជីវកម្ម (G2B) ព្រមទាំងរដ្ឋាភិបាល–ទៅ–រដ្ឋាភិបាល (G2G) នឹងជួយបំពេញនូវតម្រូវការ ខុសៗគ្នាសម្រាប់ភាគីពាក់ព័ន្ធទាំងនេះ ។

៤. ការធ្វើសមាហរណកម្មធនធានកុំព្យូទ័រទូទាំងរដ្ឋាភិបាល ដូចជាហេដ្ឋារចនាសម្ព័ន្ធបណ្តាញផ្នែករឹង (hardware) ។ បុគ្គលិក និងអ្នកគ្រប់គ្រង IT នឹងទទួលបានអត្ថប្រយោជន៍ជាច្រើន ដូចជាការកាត់បន្ថយថ្លៃចំណាយ និងប្រសិទ្ធភាពនៃការ គ្រប់គ្រង ។

៥. បមាណីយកម្មរដ្ឋាភិបាលអេឡិចត្រូនិកនាំអោយមានការកើនឡើងនូវលទ្ធផលជាវិជ្ជមាន ដូចជា សមត្ថភាពប្រតិបត្តិការទៅវិញទៅមក សង្គតភាព និងភាពអាចប្រើប្រាស់ឡើងវិញ ព្រមទាំងការ រក្សាគុណភាព ។

៦. រដ្ឋាភិបាលអេឡិចត្រូនិកមិនមែនជាព្រឹត្តការណ៍ទោល ឬអភិក្រមប្រើបានតែម្តងនោះឡើយ ប៉ុន្តែជា ដំណើរការវិវត្តន៍រយៈពេលវែង ។ គំរូសម្រាប់រដ្ឋាភិបាលបានផ្លាស់ប្តូរពីការត្រួតពិនិត្យ និងការគ្រប់គ្រង ទៅជាប្រសិទ្ធផល តម្លាភាព និងការចូលរួមតាមរយៈនវានុវត្តន៍ ។

៧. រដ្ឋាភិបាលអេឡិចត្រូនិកអនាគតនឹងត្រូវបានកំណត់ថាជាប្រភេទសេវាមានលក្ខណៈរលូន និងរួម បញ្ចូលគ្នា ព្រមទាំង ការកែលម្អខ្លាំងក្លាលើភាពជឿជាក់ និងតម្លាភាពរបស់រដ្ឋាភិបាល ដោយសារតែបច្ចេកវិទ្យាព័ត៌មានទំនើបមានការវិវត្តទៅមុខ (ឧទាហរណ៍ រដ្ឋាភិបាល m និងរដ្ឋាភិបាល u)

**អំណានបន្ថែម**


កម្មវិធីអភិវឌ្ឍន៍ព័ត៌មានអាស៊ី–ប៉ាស៊ីហ្វិក ។ ករណីសិក្សារដ្ឋាភិបាលអេឡិចត្រូនិក ។ កម្មវិធីអភិវឌ្ឍន៍ សហប្រជាជាតិ ។ http://www.apdip.net/projects/e-government/capblg/casestudies.

គណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក ។ ពុំមានកាលបរិច្ឆេទ ។ *សុខាភិបាលអេឡិចត្រូនិកនៅអាស៊ី និងប៉ាស៊ីហ្វិក* : បញ្ហាប្រឈម និងឱកាស ។ បាងកក ៖ អង្គការសហប្រជាជាតិ ។
http://www.unescap. org/esid/hds/lastestadd /eHealthReport.pdf.

Holzer, Marc និង Kim, Seang-Tae. ឆ្នាំ ២០០៨ ។ រដ្ឋាភិបាលឌីជីថលក្នុងទីក្រុងទូទាំងសកលលោក (២០០៧) ៖ ការវាយតម្លៃវែបសាយត៍ក្រុងទូទាំងសកលលោក ។ New Jersey: មជ្ឈមណ្ឌលថ្នាក់ជាតិសម្រាប់សម្ថិទ្ធិកម្មសាធារណៈ ។
http://www.unpan.org/Library/MajorPublications/
DigitalGovernanceinMunicipalitiesWorldwide/tabid/804/Default.aspx.

វិទ្យាស្ថានសម្រាប់គោលនយោបាយអភិវឌ្ឍន៍ និងការគ្រប់គ្រង ។ ព័ត៌មានវិទ្យាអភិវឌ្ឍន៍ ៖ ឯកសារការងារ ។ សាកលវិទ្យាល័យ Manchester ។
http://www.sed.manchester.ac.uk/idpm/research/publications/wp/di/index.htm .

វិទ្យាស្ថានសម្រាប់គោលនយោបាយអភិវឌ្ឍន៍ និងគ្រប់គ្រង ។ រដ្ឋាភិបាល i - ប្រព័ន្ធព័ត៌មាន បច្ចេកវិទ្យា និងរដ្ឋាភិបាល ។ ឯកសារការងារ ។ សាកលវិទ្យាល័យម៉ែនឆែសស្ទើរ ។
http://www.sed.manchester.ac.uk/ idpm/research/publications/wp/igovernment/index.htm.

អង្គការសហប្រជាជាតិ ។ ឆ្នាំ២០០៨ ។ ការស្ទង់មតិរដ្ឋាភិបាលអេឡិចត្រូនិករបស់អង្គការសហប្រជាជាតិ ឆ្នាំ២០០៨ ៖ ពីរដ្ឋាភិបាលអេឡិចត្រូនិកទៅជាអភិបាលកិច្ចមានការតភ្ជាប់ ។ ញូវយ៉ក : អង្គការសហប្រជាជាតិ ។
http://unpan1.un.org/intradoc/groups/public/documents/UN/UNPAN028607.pdf.

Wattegama, Chanuka. 2007. ICT សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ ។ បាងកក ៖ UNDP និង Incheon ៖ UN-APCICT.
http://www.apdip.net/publications/iespprimers/eprimer-dm.pdf និង
http://en.wikibooks.org/wiki/ICT_for_Disaster_Management.

សទ្ទានុក្រម

| | |
|---|---|
| ការធ្វើវិស្វកម្មដំណើរការ អាជីវកម្មឡើងវិញ | ការរៀបចំលំហូរការងារនៅក្នុង ឬរវាងកម្រិតនាយកដ្ឋានឡើញវិញ ដើម្បី បង្កើនប្រសិទ្ធផលដំណើរការ (ឧទាហរណ៍ ដើម្បីលុបបំបាត់ភាព គ្មានប្រសិទ្ធផល ក្នុងដំណើរការការងារ) ។ |
| ពាណិជ្ជកម្ម C | ពាណិជ្ជកម្មសហការ គំរូអាជីវកម្មមួយដែលក្រុមហ៊ុនធ្វើសមាហរណកម្ម ប្រព័ន្ធរបស់ខ្លួនជាមួយប្រព័ន្ធរបស់អ្នកផ្គត់ផ្គង់ ព្រមទាំងដៃគូទូទាំង បណ្តាញអ៊ីនធឺណិត ។ ពាណិជ្ជកម្មប្រភេទនេះត្រូវបានគាំទ្រដោយចំនួន កម្មវិធី B2B ដែលមានការកើនឡើងដែលធ្វើស្វ័យប្រវត្តិកម្មដំណើការ អាជីវកម្មសំខាន់ៗក្នុងចង្វាក់ផ្គត់ផ្គង់ ដែលមានវិសាលភាពហួសពីព្រំដែន សហគ្រាស ពីវត្ថុធាតុដើមទៅជាផលិតសម្រេច ។ |
| ពាណិជ្ជកម្មអេឡិចត្រូនិក | ពាណិជ្ជកម្មអេឡិចត្រូនិកគឺជា ការទិញ និងលក់ទំនិញ ព្រមទាំងសេវាកម្ម តាមប្រព័ន្ធអ៊ីនធឺណិត ជាពិសេសប្រព័ន្ធវ៉េបសាយត៍ ។ |
| រដ្ឋាភិបាលអេឡិចត្រូនិក | ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការផ្លាស់ប្តូរប្រតិបត្តិការរដ្ឋាភិបាល ដើម្បីបង្កើនប្រសិទ្ធភាព ប្រសិទ្ធផល និងការចែកចាយសេវាកម្ម ។ |
| សុខាភិបាលអេឡិចត្រូនិក | សុខាភិបាលអេឡិចត្រូនិកគឺជា ការអនុវត្ត ICT ក្នុងវិស័យសុខាភិបាល ដើម្បីបង្កើនប្រសិទ្ធផល ការទទួលបាន និងគណនេយ្យភាពសេវាថែទាំ សុខភាព ឆ្ពោះទៅរកគុណភាពជីវិតប្រសើរជាងមុនសម្រាប់ប្រជាពលរដ្ឋ និងបរិយាកាសការងារប្រកបដោយផលិតភាពខ្ពស់ជាងមុនសម្រាប់គ្រូពេទ្យ និងបុគ្គលិកថែទាំសុខភាព ។ |
| ការសិក្សាតាមប្រព័ន្ធ អេឡិចត្រូនិក | ការសិក្សាតាមអេឡិចត្រូនិកជាទូទៅសំដៅលើទម្រង់នៃការសិក្សាដែល គ្រូបង្រៀន និងសិស្សនៅដាច់ដោយឡែកពីគ្នាដោយចម្ងាយ ឬពេលវេលា ហើយគម្លាតរវាងអ្នកទាំងពីរនោះត្រូវបានតភ្ជាប់តាមរយៈការប្រើប្រាស់ បច្ចេកវិទ្យាអ៊ីនធឺណិត ។ |
| កម្មវិធីអ្នកសម្រាប់ (Killer application) | ការប្រើប្រាស់ជាក់លាក់នូវបច្ចេកវិទ្យា និងសេវាកម្មដែលធ្វើអោយបច្ចេកវិទ្យា និងសេវាកម្មមានភាពពេញនិយម និងទទួលបានជោគជ័យ ។ រយៈពេល មានភាពសមស្រប ជាពិសេស នៅពេលដែលកំណែប្រែបច្ចេកវិទ្យាពីមុន មិនទាន់បានជោគជ័យនៅមុនការប្រើប្រាស់កម្មវិធី Killer ។ |

| | |
|---|---|
| ការគ្រប់គ្រងចំណេះដឹង | សកម្មភាពអាជីវកម្មដែលមានទិដ្ឋភាពសំខាន់ៗពីរ ៖ ១) ការចាត់ទុក សមាសភាគចំណេះដឹងនៃសកម្មភាពអាជីវកម្មថាជាការកង្វល់ផ្នែកអាជីវកម្មជាក់ស្តែងដែលត្រូវបានឆ្លុះបញ្ចាំងនៅ ក្នុងយុទ្ធសាស្ត្រ គោលនយោបាយ និង ការអនុវត្តនៅគ្រប់កម្រិតអង្គភាព និង ២) បង្កើតទំនាក់ទំនងផ្ទាល់រវាងទ្រព្យកម្មសិទ្ធបញ្ញារបស់អង្គភាពទាំងដោយផ្ទាល់ (មានការកត់ត្រា) និងប្រយោល (ចំណេះដឹងផ្ទាល់ខ្លួន) ព្រមទាំងលទ្ធផលអាជីវកម្មវិជ្ជមាន ។ |
| រដ្ឋាភិបាល m | ការប្រើប្រាស់ដោយរដ្ឋាភិបាលនូវបច្ចេកវិទ្យាទូរស័ព្ទចល័តដើម្បីទាក់ទង ជាមួយ ប្រជាពលរដ្ឋ ។ ឧទាហរណ៍ ការប្រកាសអាសន្នបញ្ហាសន្តិសុខអាច ត្រូវបានបញ្ជូនមកជាសារ SMS ដល់អ្នក ទាំងឡាយណាដែលធ្វើដំណើរនៅក្នុងប្រទេស ដែលគ្មានសុវត្ថិភាព ។ |
| រដ្ឋាភិបាល t | ការចែកចាយសេវាអេឡិចត្រូនិកតាមទូរទស្សន៍ឌីជីថលបញ្ជូនទៅវិញទៅមក ដោយឆ្លងកាត់បណ្តាញ/ច្រកទូរទស្សន៍របស់រដ្ឋាភិបាលដែលត្រូវបានរៀបចំ ជាពិសេសដោយមានទាំងខ្លឹមសារផ្សព្វផ្សាយ និងផ្អែកលើតម្រូវការ ។ នៅសាធារណរដ្ឋកូរ៉េ កម្មវិធី ‘T-Gov’ នឹងបង្កើតការប្រាស្រ័យទាក់ទង ពីររបៀប រវាងរដ្ឋាភិបាល និងសាធារជន តាមរយៈទូរទស្សន៍ ។ |
| រដ្ឋាភិបាល u | អក្សរ ‘U’ មកពីពាក្យ “ubiquitous” ដែលមានន័យថាជាការប្រាស្រ័យទាក់ទង រវាងឧបករណ៍ វត្ថុ មនុស្ស និងកុំព្យូទ័រនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។ ឧបករណ៍ ឬវត្ថុទាំងអស់នឹង មានបង្កប់នៅក្នុងកុំព្យូទ័រហើយបន្ទាប់មក ដំណើរការតាមរយៈបណ្តាញភ្ជាប់ប្រើខ្សែ ឬឥតខ្សែ ។ ក្រោមកម្មវិធីរដ្ឋាភិបាល u ប្រជាពលរដ្ឋនឹងមានលទ្ធភាព ប្រើប្រាស់សេវាកម្មរបស់រដ្ឋាភិបាល បាន គ្រប់ទីកន្លែង គ្រប់ពេលវេលាតាមរយៈឧបករណ៍ពហុបណ្តាញ (ផ្អែកលើបច្ចេក វិទ្យាចល័ត) ។ |

កំណត់សម្គាល់សម្រាប់គ្រូបង្គោល

ដូចដែលបានកត់សម្គាល់នៅក្នុងផ្នែកដែលមានចំណងជើងថា “អំពីស៊េរីម៉ូឌុល” ម៉ូឌុលនេះ និងម៉ូឌុលដទៃ ទៀតនៅក្នុងស៊េរីត្រូវបានរៀបចំអោយមានគុណតម្លៃសម្រាប់ប្រភេទអ្នកចូលរួមខុសៗគ្នា និងក្នុងលក្ខខណ្ឌប្រទេសផ្សេងគ្នា ព្រមទាំងការផ្លាស់ប្តូរ ។ ម៉ូឌុលនេះ ក៏ត្រូវបានរៀបចំដើម្បីបង្ហាញអោយ បានពេញលេញ ឬជាផ្នែកនៅក្នុងគំរូខុសៗគ្នាទាំងក្នុង និងក្រៅប្រព័ន្ធ ។ ម៉ូឌុលអាចត្រូវបានសិក្សា ជាបុគ្គល និងជាក្រុមនៅក្នុងស្ថាប័នបណ្តុះបណ្តាល ព្រមទាំងនៅក្នុងការិយាល័យរដ្ឋាភិបាលផងដែរ ។ សាវតាអ្នកចូលរួម ព្រមទាំងរយៈពេលនៃវគ្គបណ្តុះបណ្តាលនឹងកំណត់ជាលម្អិតនៅក្នុងបទបង្ហាញអំពីខ្លឹម នៃម៉ូឌុលនេះ ។

“កំណត់សម្គាល់” ទាំងនេះផ្តល់អោយគ្រូបង្គោលនូវគំនិត និងការស្នើឡើងមួយចំនួនសម្រាប់ការបង្រៀន ខ្លឹមសារម៉ូឌុលអោយបានកាន់តែមានប្រសិទ្ធភាព ។ ការណែនាំបន្ថែមស្តីពីអភិក្រម និងយុទ្ធសាស្ត្របណ្តុះបណ្តាលត្រូវបានផ្តល់អោយក្នុងសៀវភៅ ណែនាំអំពីការរៀបចំការបណ្តុះបណ្តាលដែលបង្កើតឡើងជា ឯកសារជំនួយសម្រាប់ស៊េរីម៉ូឌុល ការសិក្សាអំពីសារប្រយោជន៍ *ICT* *សម្រាប់អ្នកដឹកនាំរដ្ឋាភិបាល* ។ *សៀវភៅនេះអាចរកបានតាមរយៈ* http://www.unapcict.org/academy.

**ការប្រើប្រាស់ម៉ូឌុល**

ផ្នែកម៉ូឌុលនីមួយៗចាប់ផ្តើមដោយមានសេចក្តីថ្លែងអំពីគោលបំណងសិក្សា និងបញ្ចប់ដោយសំណួរ “**ធ្វើតេស្តខ្លួនឯង**” ។ អ្នកអានប្រើប្រាស់គោលបំណង និងសំណួរធ្វើជាមូលដ្ឋានសម្រាប់ការវាយតម្លៃវឌ្ឍនភាពរបស់ខ្លួននៅក្នុងម៉ូឌុលទាំងមូល ។ ផ្នែកនីមួយៗ ក៏មាននូវសំណួរពិភាក្សា និងលំហាត់អនុវត្តន៍ ដែលអាចត្រូវបានបំពេញដោយអ្នកអានម្នាក់ៗ ឬប្រើប្រាស់ដោយគ្រូបង្គោល ។ សំណួរ និងលំហាត់ទាំងនេះត្រូវបានរៀបចំឡើងដើម្បីជួយអោយអ្នកអានទទួលបានបទពិសោធន៍ផ្ទាល់របស់ខ្លួន ដើម្បីកំណត់ និយាមគំរូលើខ្លឹមសារ និងដើម្បីពិចារណាអោយបានល្អិតល្អន់អំពីបញ្ហាដែលបានលើកឡើង ។

ករណីសិក្សាបង្កើតនូវផ្នែកសំខាន់នៃខ្លឹមសារម៉ូឌុល ។ ករណីសិក្សាទាំងនេះត្រូវបានរៀបចំសម្រាប់ កិច្ចពិភាក្សា និងវិភាគ ជាពិសេស នៅក្នុងវិសាលភាពដែលទស្សនាទាន និងគោលការណ៍សំខាន់ៗដែលបានបង្ហាញក្នុងម៉ូឌុលដំណើរការនៅក្នុងគម្រោង និងកម្មវិធី ពិភពជាក់ស្តែង ។ ករណីសិក្សាមាន សារសំខាន់ចំពោះអ្នកអានដើម្បីយល់អំពីតម្រូវការក្នុងការទទួលយកនូវអភិក្រម និងគំរូដែលផ្អែកលើ និង គាំទ្រដោយ ICT ដើម្បីអោយត្រូវនឹងលក្ខខណ្ឌមូលដ្ឋាន ។ គ្រូបង្គោលអាចលើកទឹកចិត្តសិក្ខាកាម អោយលើកឡើងអំពីករណី និងឧទាហរណ៍ផ្សេងទៀតពីបទពិសោធន៍ផ្ទាល់ខ្លួនដើម្បីបង្ហាញភស្តុតាង ខ្លឹមសារម៉ូឌុល ។

**ការរៀបចំមេរៀន**

ដោយអាស្រ័យលើសិក្ខាកាម ពេលវេលាដែលមាន ព្រមទាំងការកំណត់ និងលក្ខណ្ឌក្នុងមូលដ្ឋាន ខ្លឹមសារ ម៉ូឌុលអាចត្រូវបាន បង្ហាញជាសេចក្តីសង្ខេបដែលយោងតាមពេលវេលាខុសៗគ្នា ។ អ្វីដែលអាចលើកឡើងនៅវគ្គបណ្តុះបណ្តាលដែលមានរយៈពេល ខុសៗគ្នាត្រូវបានលើកឡើងខាងក្រោម ។ គ្រូបង្គោល ត្រូវបានអញ្ជើញដើម្បីធ្វើការកែសម្រួលរចនាសម្ព័ន្ធមេរៀនដោយផ្អែក លើការយល់ដឹងផ្ទាល់ខ្លួនអំពី ប្រទេស និងសិក្ខាកាម ។

***សម្រាប់ការបណ្តុះបណ្តាលរយៈពេល ៩០នាទី***

មានគោលដៅអភិវឌ្ឍការយល់ដឹងមូលដ្ឋានអំពីរដ្ឋាភិបាលអេឡិចត្រូនិក រួមទាំងមូលហេតុនៃ អត្ថប្រយោជន៍ និងកត្តាសំខាន់ៗ សម្រាប់ជោគជ័យនៃគម្រោងរដ្ឋាភិបាលអេឡិចត្រូនិកក្នុងផ្នែកទី ១ ។

***សម្រាប់ការបណ្តុះបណ្តាលរយៈពេល ៣ ម៉ោង***

បន្ទាប់ពីការពិភាក្សាជាទូទៅអំពីសនិទានភាពសម្រាប់រដ្ឋាភិបាលអេឡិចត្រូនិក និងកត្តាជោគជ័យ សំខាន់ៗ ផ្តល់នូវទិដ្ឋភាពទូទៅ អំពីគំរូរដ្ឋាភិបាលអេឡិចត្រូនិក និងការរៀបចំផែនការយុទ្ធសាស្ត្ររដ្ឋាភិបាលអេឡិចត្រូនិកដែលនាំទៅរកការបង្កើតផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តរដ្ឋាភិបាល អេឡិច ត្រូនិក ។ ការពិភាក្សា និងលំហាត់ពាក់ព័ន្ធមាននៅក្នុងផ្នែកទី ២ ។

***សម្រាប់ការបណ្តុះបណ្តាលរយៈពេល ១ថ្ងៃ (រយៈពេលប្រាំមួយម៉ោង)***

ពេលវេលានេះនឹងអនុញ្ញាតអោយមានការស្វែងរកមួយ ឬពីរនៃកម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិកដែលបាន បង្ហាញក្នុងផ្នែកទី ៣ ជាការបន្ថែមទៅលើទិដ្ឋភាពទូទៅអំពីគោលការណ៍រដ្ឋាភិបាលអេឡិចត្រូនិក គំរូ និងការរៀបចំផែនការយុទ្ធសាស្ត្រដែល បានផ្តល់នៅក្នុងផ្នែកទី ១ និង ទី ២ ។ ផ្តោតលើកម្មវិធី រដ្ឋាភិបាលអេឡិចត្រូនិក ដែលមានការពាក់ព័ន្ធច្រើនបំផុតចំពោះ សិក្ខាកាម និងប្រើប្រាស់សំណួរ ពិភាក្សាពាក់ព័ន្ធ (“សំណួរដែលត្រូវត្រិះរិះ”) ព្រមទាំងសកម្មភាពសិក្សា (“កិច្ចការដែលត្រូវធ្វើ”) ដើម្បីធ្វើអោយមេរៀនមានអន្តរកម្ម ។

***សម្រាប់ការបណ្តុះបណ្តាលរយៈពេល ៣ថ្ងៃ***

ពេលវេលានេះគួរតែសមល្មមក្នុងជួយអោយអ្នកអាចទទួលការបណ្តុះបណ្តាលអំពីម៉ូឌុលទាំងមូលបានដោយ រួមមានការពិភាក្សា លម្អិតលើករណីសិក្សាពាក់ព័ន្ធរបស់កម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិកជាក់លាក់ ។ រួមមានករណីសិក្សាអំពី “រស់នៅ” តាមរយៈ ការធ្វើដំណើរដល់ទីកន្លែងទៅកាន់ទីតាំងគម្រោងអនុវត្ត រដ្ឋាភិបាលអេឡិចត្រូនិកក្នុងមូលដ្ឋាន ។ រៀបចំពេលវេលាសម្រាប់ការ រៀបចំផែនការយុទ្ធសាស្ត្ររដ្ឋាភិបាលអេឡិចត្រូនិកដោយសិក្ខាកាម លទ្ធផលដែលនឹងត្រូវបង្ហាញដល់ក្រុមផ្សេងទៀត ។

## អំពីអ្នកនិពន្ធ

**Nag Yeon Lee** បច្ចុប្បន្នគឺជាអ្នកផ្តល់ប្រឹក្សាផ្នែកបច្ចេកវិទ្យាពត៌មាន ផ្នែករដ្ឋាភិបាលអេឡិចត្រូនិក និងជាអ្នក ប្រឹក្សាផ្នែកបច្ចេកវិទ្យាព័ត៌មានសម្រាប់អង្គភាពជាច្រើនដែលរួមមានដូចជាបច្ចេកវិទ្យាព័ត៌មាន Hyundai ដែលរូបលោក ធ្លាប់ធ្វើជាអនុប្រធានជាន់ខ្ពស់អស់រយៈពេលជាង ១០ឆ្នាំ ។ លោកមានបទ ពិសោធន៍ជាច្រើនលើការអភិវឌ្ឍអាជីវកម្ម អន្តរជាតិជាមួយនឹងដំណោះស្រាយផ្នែកបច្ចេកវិទ្យាព័ត៌មាន ។ លោកធ្លាប់ជាអនុប្រធាននៃវេទិកា Korea Ultra Wide Band ដែលរូបលោកធ្លាប់បម្រើការងារក្នុងការ ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងគមនាគមន៍ឥតខ្សែដូចជា WiFi Wimedia WiMax និង Wibro។ លោកក៏ ធ្លាប់បម្រើការងារជាគ្រូបង្រៀនសម្រាប់កម្មវិធីសិក្សាបច្ចេកវិទ្យាប្រទេសកូរ៉េ ដោយលោក បានចូលរួមនៅក្នុងការអភិវឌ្ឍម៉ូឌុលជំនាញការបច្ចេកវិទ្យាព័ត៌មានកម្រិតខ្ពស់នៅក្រៅប្រទេសអំពី ៖ ១) រដ្ឋាភិបាល អេឡិចត្រូនិក ៖ យុទ្ធសាស្ត្រអនុវត្តកម្មវិធី (G2B G2C ប្រព័ន្ធហិរញ្ញវត្ថុថ្នាក់ជាតិ ប្រព័ន្ធពន្ធដារ ប្រព័ន្ធសន្តិសុខ សុខាភិបាល អេឡិចត្រូនិក ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក) និង ២) ISP ការធ្វើវិស្វកម្ម ឡើងវិញទៅលើដំណើការអាជីវកម្ម និង ការគ្រប់គ្រងការផ្លាស់ប្តូរ ។ លោកបានទទួលពានរង្វាន់ស្នាដៃពិសេសពីនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋកូរ៉េក្នុងឆ្នាំ ២០០២ ។

# UN-APCICT

មជ្ឍមណ្ឌលបណ្តុះបណ្តាលបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាសម្រាប់ការអភិវឌ្ឍតំបន់អាស៊ី និង ប៉ាស៊ីហ្វិករបស់អង្គការ សហប្រជាជាតិ (UN-APCICT) គឺជាអង្គភាពបុត្រសម្ព័ន្ធរបស់គណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ី និង ប៉ាស៊ីហ្វិក (ESCAP) ។ UN-APCICT មានគោលដៅពង្រឹង កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសជាសមាជិក ESCAP ដើម្បីប្រើប្រាស់ ICT ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច របស់ខ្លួនតាមរយៈការកសាងសមត្ថភាពបុគ្គលិក និងស្ថាប័ន ។ ការងារ របស់ UN-APCICT គឺផ្តោតលើ សសរស្តម្ភសំខាន់បី ៖

១. ការបណ្តុះបណ្តាល ៖ ដើម្បីកែលម្អចំណេះដឹង និងជំនាញផ្នែក ICT របស់អ្នកបង្កើតគោលនយោបាយ និងអ្នកវិជ្ជាជីវៈ ICT ព្រមទាំងពង្រឹងសមត្ថភាពរបស់គ្រូបង្គោល ICT និងស្ថាប័នបណ្តុះបណ្តាល ICT ។

២. ការស្រាវជ្រាវ ៖ ដើម្បីចាប់ផ្តើមអនុវត្តការសិក្សាវិភាគទាក់ទងនឹងការអភិវឌ្ឍន៍ធនធានមនុស្សផ្នែក ICT និង

៣. ការណែនាំ ៖ ដើម្បីផ្តល់សេវាណែនាំអំពីកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សដល់សមាជិក EKSCAP និងសមាជិកពាក់ព័ន្ធ ។

UN-APCICT មានទីតាំងនៅ Incheon សាធារណរដ្ឋកូរ៉េ ។

http://www.unapcict.org

# ESCAP

ESCAPគឺជាអង្គភាពអភិវឌ្ឍន៍ក្នុងតំបន់របស់អង្គការសហប្រជាជាតិ និងដើរតួនាទីជាមជ្ឈមណ្ឌលអភិវឌ្ឍន៍ សេដ្ឋកិច្ច និងសង្គម ចម្បងសម្រាប់អង្គការសហប្រជាជាតិក្នុងទ្វីបអាស៊ី និងប៉ាស៊ីហ្វិក ។ អាណត្តិរបស់ ESCAP គឺដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ រវាងសមាជិកចំនួន ៥៣ និងសមាជិកពាក់ព័ន្ធចំនួន ៩ របស់ខ្លួន ។ ESCAP ផ្តល់នូវការភ្ជាប់យុទ្ធសាស្ត្ររវាងកម្មវិធី និងបញ្ហា កម្រិតសកល និងកម្រិតប្រទេស ។ ESCAP គាំទ្រដល់រដ្ឋាភិបាលរបស់ប្រទេសនៅក្នុងតំបន់ក្នុងការពង្រឹងមុខងារតំបន់ និង គាំទ្រដល់វិធីសាស្ត្រក្នុងតំបន់ដើម្បីដោះស្រាយបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចសង្គមពិសេសរបស់តំបន់ក្នុងពិភព សកលភាវូបនីយកម្ម ។ ការិយាល័យ ESCAP មានទីតាំងនៅទីក្រុងបាងកក ប្រទេសថៃ ។

http://www.unescap.org

inside back page

កម្មវិធីសិក្សាជាន់ខ្ពស់ខ្ពស់នៃ អាយស៊ីធី ពិសេសសម្រាប់ថ្នាក់ដឹកនាំក្នុងជួររដ្ឋាភិបាល

http://www.unapcict.org/academy

កម្មវិធីសិក្សានេះគឺជាភាពទូលំទូលាយមួយនៃវគ្គហ្វឹកហ្វឺនលើវិស័យ ICT សម្រាប់ការអនុវត្តន៍ ដែលមាន ប្រាំបីមេរៀន និង មានគោលបំណងដើម្បីផ្តល់ឲ្យអ្នកបង្កើតច្បាប់ជាច្រើននៅចំណេះដឹងនិងជំនាញ ពិសេសចំពោះឱកាសអនុភាពដ៏ពេញលេញដែលបានបង្ហាញដោយ ICTs ដើម្បីសម្រេចបាននៅ គោលបំនងរាប់រយរបស់ជាតិ និង ជាស្ពានចម្លងក្នុង ការបែងចែកជាលក្ខណៈឌីជីថល ។

មេរៀនទី ១-ការតភ្ជាប់រវាងការអនុវត្តលើវិស័យ ICT និងការអភិវឌ្ឍន៍ដ៏សំខាន់

ធ្វើឲ្យលេចឡើងនៅចំនុចសម្រាប់ការសម្រេចចិត្តនិងបញ្ហាសំខាន់ៗនានា, ពីច្បាប់ទៅកាន់ការ អនុវត្ត ដោយការប្រើ ICTs សម្រាប់សម្រេចបាននៅគោលបំនងអភិវឌ្ឍន៍រាប់លាន ។

មេរៀនទី ២-ICT សម្រាប់ការអភិវឌ្ឍន៍ ប្រតិបត្តិការ និង ការគ្រប់គ្រង

ផ្តោតលើការបង្កើតច្បាប់ ICTD និង គ្រប់គ្រង, និងផ្តល់នៅពត៌មានយ៉ាងសំខាន់លើការរំពឹង ទុកនានានៃ ច្បាប់ជាតិ យុទ្ធសាស្រ្ត គម្រោងការណ៍នានាដើម្បីជំរុញ ICTD

មេរៀនទី ៣-ការអនុវត្តនៅប្រព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិច (e-Government)

ធ្វើការវិភាគលើ មនោភាព គោលការណ៍ និងប្រភេទនៃការអនុវត្តនានា ។ វាពិភាក្សាផង ដែលនៅរបៀបម៉េច ដែលប្រព័ន្ធ e-government គឺត្រូវបានកសាង និង កំណត់លើការបង្កើត

មេរៀនទី ៤-និន្នាការនានារបស់ ICT សម្រាប់ថ្នាក់ដឹកនាំរដ្ឋាភិបាល

ផ្តល់នៅការគិតគូចូលទៅក្នុងនិន្នាការថ្មីៗនៅក្នុងវិស័យ ICT និង ទិសដៅអនាគតរបស់វា ។ វាក្រឡេកមើល ផងដែល លើការពិចារណានានាអំពីបច្ចេកវិទ្យា និង គោលការណ៍ច្បាប់ នៅពេល ធ្វើការសម្រេចចិត្តសម្រាប់ ICTD ។

មេរៀនទី ៥-ការគ្រប់គ្រងប្រព័ន្ធ អ៊ីនធើរណិត

ពិភាក្សាទៅលើការអភិវឌ្ឍន៍នៃគោលការណ៍ច្បាប់និងវិធីសាស្រ្តនានាជាអន្តរជាតិដែលគ្រប់គ្រងការប្រើប្រាស់ និង ដំណើរការនៃប្រព័ន្ធ អ៊ិនធើរណិត ។

មេរៀនទី ៦-បណ្តាញ និង សុវត្ថិភាពពត៍មាន និង ឯកជន

បង្ហាញអំពីបញ្ហា និង និន្នាការនានានៃសុវត្ថិភាពពត៍មាន, និង ដំណើរការប្រតិបត្តិបង្កើតគំរូ យុទ្ធសាស្រ្តមួយ សម្រាប់សុវត្ថិភាពពត៍មាន

មេរៀនទី ៧- ការគ្រប់គ្រង់គម្រោង ICT នៅក្នុងទ្រឹស្តី និង អនុវត្តន៍

ណែនាំអំពីគំនិតមួយចំនួនលើការគ្រប់គ្រងគម្រោង ដែលជាប់ទាក់ទងចំពោះគម្រោង ICTD, រួមមានពីរបៀបដំណើរការប្រតិបត្តិ វិន័យមួយចំនួនលើការគ្រប់គ្រងគម្រោងដែលបានប្រើជា ទូទៅ។

មេរៀនទី ៨- ជម្រើសលើការផ្តល់មូលនិធិនៃ ICT សម្រាប់ការអភិវឌ្ឍន៍

ស្វែករកនៅជម្រើសនានាលើការផ្តល់នៅមូលនិធិសម្រាប់ ICTD និង គម្រោង e-government ។ ដៃគូឯកជនសាធារណ៍ គឺវាសំខាន់ដូចទៅនឹងជម្រើសលើការផ្តល់មូលនិធិដ៏មានប្រយោជន៍ មួយក្នុងការអភិវឌ្ឍប្រទេសមួយចំនួន ។

មេរៀនទាំងនេះគឺបាននឹងកំពុងធ្វើទៅតាមការសិក្សានៅក្នុងតំបន់ដោយដៃគូ *Academy* ថ្នាក់ជាតិដើម្បី ធានាថាមេរៀនទាំងនោះគឺត្រូវគ្នា និង ជួបនឹងការចង់បានរបស់អ្នកបង្កើតច្បាប់នៅក្នុងប្រទេសផ្សេងៗ ជាច្រើន ។ មេរៀនទាំងនេះ គឺបានត្រូវគេបកប្រែទៅជាភាសាផ្សេងៗ ។ ច្រើនជាងនេះ មេរៀនទាំងនេះ ត្រូវបានធ្វើការកែតម្រូវឲ្យទាន់សភាពការជារឿយៗ ដើម្បីធានាថាវាត្រូវគ្នានឹងសេចក្តីត្រូវការរបស់ អ្នកច្បាប់ និងមេរៀនមេរៀនថ្មីៗទៀតដែលត្រូវបានគេអភិវឌ្ឍ ដែលផ្តោតលើ ICTD សម្រាប់សតវត្សទី ២១ ។

## APCICT Virtual Academy (AVA – http://ava.unapcict.org)

. ទម្រង់សិក្សាពីចម្ងាយតាមប្រព័ន្ធ Online សម្រាប់ *Academy*

. ត្រូវបានបង្កើតឡើងដើម្បីធានាថាមេរៀនរបស់ *Academy* រួមមាន ការបង្រៀនជាក់ស្តែង ការធ្វើបទ បង្ហាញ និងមេរៀនសិក្សានីមួយៗ គឺអាចរកបាននៅលើប្រព័ន្ធ Online ។

. អាចឲ្យអ្នកសិក្សា សិក្សាលើខ្លឹមសារនានាទៅតាមសមត្ថភាពរបស់ខ្លួនពួកគេផ្ទាល់ ។

មជ្ឈមណ្ឌលសហប្រតិបត្តិការលើប្រព័ន្ធអេឡិចត្រូនិច (e-Co Hub – http://www.unapcict.org/ecohub)

. ប្រភពធនធាន និង ការចែករំលែកចំណេះដឹងបណ្តាញសម្រាប់ ICTD

. ផ្តល់នៅភាពងាយស្រួលក្នុងការដំណើរការលើប្រភពចំណេះដឹងដែលផ្តល់ដោយមេរៀន ។

. អ្នកប្រើប្រាស់អាចចូលរួមការពិភាក្សាលើប្រព័ន្ធ Online និង ក្លាយជាផ្នែកមួយនៃសហគមន៍ online របស់ e-Co Hub នៃការអនុវត្ត ដែលរក្សានៅការចែករំលែក និង ការពង្រីកនៅចំណេះដឹង

ផ្អែកលើ ICTD ។

ចុះឈ្មោះតាមប្រព័ន្ធ Online ដើម្បីទទួលបានប្រយោជន៍ពេញលេញពីសេវាកម្មនានាដែលបានផ្តល់ នៅក្នុង AVA និង e-Co Hub ជាមួយគេហទំព័រ http://www.unapcict.org/join_form